សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal university of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការដោះស្រាយវិវាទពាណិជ្ជកម្ម
# តាមយន្តការមជ្ឈត្តការនៅកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២


| | |
|---|---|
| ស្រាវជ្រាវដោយ | សាស្ត្រាចារ្យណែនាំ |
| និស្សិតឈ្មោះ **ឈន ខ្វា** | **បណ្ឌិត អ៊ុន សកក្តដា** |
| **សុខ រីណា** | |


| | |
|---|---|
| ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ** | ឆ្នាំចូលសិក្សា ២០១៨ |
| ជំនាន់ទី ២២ | ឆ្នាំសរសេរសារណា ២០២២ |

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal university of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការដោះស្រាយវិវាទពាណិជ្ជកម្ម តាមយន្តការមជ្ឈត្តការនៅកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ឈន ខ្វា**

**សុខ វីណា**

សាស្ត្រាចារ្យណែនាំ

**បណ្ឌិត អ៊ុន សកក្កដា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២២

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំព្រះករុណាអាត្មាភាពទាំងពីរព្រះអង្គឈ្មោះ **ឈន ខ្វា** និង **សុខ រីណា** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមសម្តែងនូវឧបការៈគុណយ៉ាងជ្រាលជ្រៅ និងដ៏ខ្ពង់ខ្ពស់ចំពោះ៖

- ញោមប្រុស ស្រី ដែលបានផ្តល់កំណើតដល់កូន និងបានលះបង់ទាំងកម្លាំងកាយចិត្ត ព្រមទាំងធនធានក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូន តាំងពីតូចក្រូចឆ្មារហូតដល់ធំពេញវ័យ និងបានអប់រំបង្រៀនប្រៀនប្រដៅឱ្យដើរតាមគន្លងធម៌ និងបានផ្តល់ជាកម្លាំងចិត្ត និងជំរុញឱ្យរូបកូនទទួលបានការសិក្សាអប់រំតាំងពីបឋមរហូតមកដល់ថ្នាក់បញ្ចប់នូវថ្នាក់ឧត្តមសិក្សា។ នេះជាគុណូបការៈយ៉ាងប្រសើរថ្លៃថ្លា សូមលើកហត្ថាប្រណមបួងសួងដល់វត្ថុស័ក្តិសិទ្ធ និងពួកទេវតាទាំងឡាយ សូមជួយថែរក្សាអស់លោកអ្នកមានគុណទាំងទ្វេឱ្យពើបប្រទះនូវសេចក្តីសុខ សេចក្តីចម្រើន និងមានអាយុយឺនយូរដើម្បីជាម្លប់ដ៏ត្រជាក់ត្រជុំដល់កូន។
- សូមគោរពអរគុណចំពោះអ្នកមានឧបការៈ មានដូចជាបងប្អូន មិត្តភក្តិ ដែលបានទំនុកបម្រុងដល់ចំពោះការសិក្សា និងបានលើកទឹកចិត្តយ៉ាងមុតមាំក្នុងការសិក្សារៀនសូត្រ ក៏ដូចជាផ្តល់ជាថវិកា សម្ភារៈសិក្សាដើម្បីសម្រួលដល់ការសិក្សាកន្លងមក។
- សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តមសាកលវិទ្យាធិការ **លុយ ចន្ណា** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។
- សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ សាកលវិទ្យាធិការរង លោកប្រធានការិយាល័យស្រាវជ្រាវ លោកប្រធានការិយាល័យសិក្សា លោកគ្រូសាស្ត្រាចារ្យ អ្នកគ្រូសាស្ត្រាចារ្យ និងមន្ត្រីរាជការទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំបង្ហាត់បង្ហាញ ជួយពន្យល់ណែនាំនូវមុខវិជ្ជាទាំងអស់។
- ជាពិសេស សូមគោរពអរគុណយ៉ាងក្រៃលែងចំពោះសាស្ត្រាចារ្យបណ្ឌិត **អ៊ុន សកក្កដា** ដែលបានចំណាយពេលដ៏មានតម្លៃ ក្នុងការពន្យល់ណែនាំអំពីនីតិវិធីនៃការសិក្សាស្រាវជ្រាវនៃការសរសេរសារណាប្រកបដោយការយកចិត្តទុកដាក់ដើម្បីពង្រឹង និងពង្រីកនូវពុទ្ធិដល់អាត្មាភាពទាំងពីរអង្គ។

ជាចុងក្រោយ សូមគោរពជូនពរដល់ទ្រង់ឯកឧត្តម លោក លោកស្រី សាស្ត្រាចារ្យ និងមិត្តភក្តិទាំងអស់ឱ្យជួបប្រទះពុទ្ធពរទាំងបួនប្រការ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតទៅជាបការៈដទៃឡើយ។

# អារម្ភកថា

នៅក្នុងបរិបទសង្គមរស់នៅរបស់មនុស្សជាតិ តែងតែមានការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមកទាំងផ្នែកសង្គមវប្បធម៌ និងធុរកិច្ចផ្សេងៗ។ ការធ្វើធុរកិច្ចរួមមានការទិញលក់ ការដោះដូរ ដែលអាចហៅបានថាការធ្វើនូវពាណិជ្ជកម្មរវាងមនុស្សនៅក្នុងសង្គម។ ការធ្វើពាណិជ្ជកម្មនេះ បានរុញច្រានឱ្យមនុស្សទទួលបាននូវផលប្រយោជន៍ ទន្ទឹមនឹងនោះក៏បានបង្កើតឱ្យមាននូវវិវាទ ដែលជាទិដ្ឋភាពមួយទាក់ទងនឹងពាណិជ្ជកម្ម។ ហេតុនេះបានជាបណ្តាលឱ្យរាជរដ្ឋាភិបាលត្រូវស្វែងរកដំណោះស្រាយជូនដល់ពាណិជ្ជករ ក៏ដូចជាបានបង្កើតនូវលិខិតបទដ្ឋានគតិយុត្ត និងស្ថាប័នផ្សេងៗដើម្បីជាការចូលរួមដោះស្រាយនូវជម្លោះជូនប្រជាជនឱ្យបានឆាប់រហ័ស និងប្រកបដោយប្រសិទ្ធភាពខ្ពស់។

ដោយចរន្តនៃការរីកចម្រើនលូតលាស់នៃសង្គម ដែលជាកត្តាធ្វើឱ្យមានការដោះស្រាយវិវាទផ្សេងៗអាចធ្វើឡើងតាមរយៈប្រព័ន្ធតុលាការ ហើយក៏អាចយកវិវាទទាំងនោះមកធ្វើការដោះស្រាយនូវក្រៅប្រព័ន្ធតុលាការក៏បាន ដូចជាការដោះស្រាយវិវាទតាមយន្តការមជ្ឈត្តការ គឺជាយន្តការបច្ចេកទេសមួយប្រភេទដែលរាជរដ្ឋាភិបាលបានខិតខំធ្វើកិច្ចសហប្រតិបត្តិរវាងស្ថាប័ននិងស្ថាប័ន រួមទាំងអង្គការអន្តរជាតិដើម្បីធ្វើយ៉ាងណាឱ្យសម្រួលដល់ប្រជាពលរដ្ឋក្នុងការទទួលបានយុត្តិធម៌ ក៏ដូចជាស្របតាមគោលនយោបាយស្តីពីការកំណែទម្រង់ប្រព័ន្ធយុត្តិធម៌នៅកម្ពុជា។ ដោយមានភាពចាំបាច់ ក៏ដូចជាការឆ្លើយតបទៅនឹងការចង់ទទួលបាននូវពុទ្ធិថ្មីៗ និងឈ្វេងយល់ឱ្យកាន់តែមានភាពស៊ីជម្រៅអំពីការដោះស្រាយវិវាទពាណិជ្ជកម្មតាមយន្តការមជ្ឈត្តការ ដូច្នេះក្រុមអាត្មាភាពទាំងពីរអង្គបានធ្វើការសម្រេចចិត្តចាប់យកនូវប្រធានបទនេះមកធ្វើជាសារណាបទ ដើម្បីធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងទុកជាឯកសារគោលមួយ និងជាពន្លឺសម្រាប់អ្នកសិក្សាគ្រប់ជំនាន់។

ដោយមានការតាំងចិត្តជឿជាក់យ៉ាងមុតមាំថា ការសិក្សាស្រាវជ្រាវអំពីសារណានេះ នឹងបានផ្តល់ជាប្រយោជន៍សម្រាប់អ្នកសិក្សាស្រាវជ្រាវ ជាពិសេសសម្រាប់និស្សិតចង់ដឹងអំពីនីតិវិធីក្នុងការដោះស្រាយវិវាទពាណិជ្ជកម្មតាមបែបយន្តការមជ្ឈត្តការនៅកម្ពុជា ហើយស្នាដៃនេះក៏អាចនឹងមាននូវចន្លោះខ្វះខាត ក៏ដូចជាមាននូវកំហុសខុសឆ្គងនូវពាក្យពេចន៍ អក្ខរាវិរុទ្ធ អត្ថន័យ អត្ថរស ខ្លឹមសារមិនពេញលេញ ឬប្រយោគឯណានីមួយដោយប្រការណាមួយនោះ។ អាត្មាភាពទាំងពីរព្រះអង្គសូមធ្វើការអភ័យឥតទោសអំពីសំណាក់អ្នកសិក្សាគ្រប់មជ្ឈដ្ឋាន និងរង់ចាំទទួលនូវពាក្យ ក៏ដូចជាមតិរិះគន់ក្នុងន័យស្ថាបនា និងជួយផ្តល់ជាគោលគំនិត ទស្សនាទានយោបល់ដើម្បីធ្វើយ៉ាងណាឱ្យសារណាបទនេះ មានភាពល្អប្រសើរ និងមានសុក្រឹតភាព ជាពិសេសកែលម្អនូវចំណុចខ្វះខាតដែលកើតឡើងដោយកំហុសអចេតនារបស់ក្រុមអាត្មាភាពទាំងពីរអង្គ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ...... ១

**ជំពូកទី១**

**ពាណិជ្ជកម្ម និងមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម**

**១.១. ស្ថានភាពទូទៅនៃពាណិជ្ជកម្មនៅកម្ពុជា** ...... ៦

១.១.២. វិវាទពាណិជ្ជកម្ម ...... ៦

១.១.៣. ប្រវត្តិនៃការដោះស្រាយវិវាទពាណិជ្ជកម្មនៅកម្ពុជា ...... ៨

**១.២. យន្តការដោះស្រាយវិវាទ** ...... ៨

១.២.១. សញ្ញាណនៃការដោះស្រាយវិវាទ ...... ៩

១.២.២. ការចរចា ការផ្សះផ្សា សន្ធានកម្ម និងមជ្ឈត្តការ ...... ៩

១.២.២.១. ការចរចា ...... ៩

១.២.២.២. ការផ្សះផ្សា ...... ១០

១.២.២.៣. សន្ធានកម្ម ...... ១១

១.២.២.៤. មជ្ឈត្តការ ...... ១១

**១.៣. ដំណើរការ និងការប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម** ១២

១.៣.១. ប្រវត្តិរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ...... ១២

១.៣.២. រចនាសម្ព័ន្ធ និងការគ្រប់គ្រងមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ...... ១៣

១.៣.២.១. មហាសន្និបាត ...... ១៣

១.៣.២.២. ក្រុមប្រឹក្សាប្រតិបត្តិ ...... ១៤

១.៣.២.៣. អគ្គលេខាធិការដ្ឋាន ...... ១៦

១.៣.២.៤. សមាជិកភាពនៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ...... ១៧

១.៣.២.៥. សវនកម្ម ...... ១៩

១.៣.២.៦. សាខារបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម........................................ ១៩

១.៣.៣. ប្រភពធនធាន ............................................................................................................. ១៩

## ជំពូកទី២

## នីតិវិធីនៃការដោះស្រាយវិវាទពាណិជ្ជកម្មតាមយន្តការមជ្ឈត្តការ

**២.១. សន្ធិសីទអំពីការគ្រប់គ្រងចាត់ចែងសំណុំរឿង** ........................................................... ២១

**២.២. សេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្ម** ............................................................................. ២៣

២.២.១. សេចក្ដីជូនដំណឹងអំពីការឆ្លើយតប និងបណ្ដឹងតប ...................................................... ២៦

**២.៣. កិច្ចព្រមព្រៀងមជ្ឈត្តកម្ម** ........................................................................................ ៣១

២.៣.១. គោលការការណ៍ទូទៅនៃកិច្ចព្រមព្រៀងមជ្ឈត្តកម្ម ...................................................... ៣២

២.៣.២. លក្ខខណ្ឌសុពលភាព .............................................................................................. ៣៣

២.៣.២.១. ការព្រមព្រៀង ..................................................................................................... ៣៣

២.៣.២.២. ការធ្វើឡើងជាលាយលក្ខណ៍អក្សរ ............................................................................ ៣៤

២.៣.២.៣. សមត្ថភាពគូភាគី .................................................................................................. ៣៤

២.៣.២.៤. ទំនាក់ទំនងគតិយុត្ត ................................................................................................ ៣៥

២.៣.២.៥. កម្មវត្ថុនៃវិវាទ ...................................................................................................... ៣៥

**២.៤. នីតិវិធីនៃមជ្ឈត្តការពាណិជ្ជកម្ម** ............................................................................... ៣៦

២.៤.១. ការជ្រើសរើសស្ថាប័នមជ្ឈត្តការពាណិជ្ជកម្ម.................................................................. ៣៦

២.៤.១.១. ការព្រមព្រៀងតាមកិច្ចសន្យារបស់គូភាគី ..................................................................... ៣៦

២.៤.១.២. ការព្រមព្រៀងតាមការបង្គាប់របស់ស្ថាប័នតុលាការ ....................................................... ៣៧

២.៤.១.៣. ការព្រមព្រៀងនៅពេលដែលមានវិវាទ .......................................................................... ៣៧

**២.៥. មជ្ឈត្តករបន្ទាន់** ........................................................................................................ ៣៧

**២.៦. ការចាប់ផ្ដើមមជ្ឈត្តការពាណិជ្ជកម្ម** ............................................................................. ៤២

២.៦.១. នីតិវិធីនៃការជ្រើសរើសមជ្ឈត្តករ ........................................................................ ៤២
២.៦.១.១. ការជ្រើសរើស និងចំនួនមជ្ឈត្តករ .............................................................. ៤២
២.៦.១.២. ការតែងតាំងមជ្ឈត្តករ.......................................................................................៤៣
២.៦.១.៣. ការជំទាស់នឹងការជ្រើសរើសមជ្ឈត្តករ..................................................................៤៤
២.៦.១.៤. តួនាទី និងភារកិច្ចរបស់មជ្ឈត្តករ.....................................................................៤៥
២.៦.២. ដំណើរការនៃមជ្ឈត្តការពាណិជ្ជកម្ម..................................................................៤៥
២.៦.២.១. ការជ្រើសរើសទីតាំងមជ្ឈត្តការ .........................................................................៤៥
២.៦.២.២. វិធានគតិយុត្តដែលត្រូវយកមកអនុវត្ត ................................................................ ៤៦
២.៦.២.៣. ភាសា ........................................................................................................... ៤៦
២.៦.៣. ការរៀបចំតាក់តែង និងចងក្រងសំណៅឯកសារក្នុងដំណើរការមជ្ឈត្តការ ............................. ៤៧
២.៦.៤. នីតិវិធីនៃការដោះស្រាយវិវាទពាណិជ្ជកម្ម.......................................................................... ៤៨
២.៦.៤.១. សវនាការមជ្ឈត្តការ ........................................................................................... ៤៨
២.៦.៤.២. សេចក្តីថ្លែងហេតុបើករបស់មជ្ឈត្តករ .....................................................................៤៩
២.៦.៤.៣. សេចក្តីថ្លែងហេតុបើករបស់គូភាគី ........................................................................៤៩
២.៦.៤.៤. ការប្រើប្រាស់ភស្តុតាង.........................................................................................៤៩
២.៦.៤.៥. ភាពចាំបាច់នៃសាក្សីអង្គហេតុ............................................................................. ៥០
២.៦.៤.៦. សេចក្តីថ្លែងការណ៍សក្ខីកម្មរបស់សាក្សីអង្គហេតុ ឬសាក្សីហេតុការណ៍ .......................... ៥២
២.៦.៤.៧. ការឆ្លើយ និងឆ្លើយតប ........................................................................................៥៥
២.៦.៤.៨. សេចក្តីថ្លែងការណ៍បិទ ........................................................................................៥៥
២.៦.៤.៩. ការចេញមជ្ឈត្តវិនិច្ឆ័យរបស់វេទិកាមជ្ឈត្តកម្ម............................................................ ៥៦

# ជំពូកទី៣
# បណ្តឹងឧបាស្រ័យ និងអានុភាពមជ្ឈត្តវិនិច្ឆ័យ

**៣.១. បណ្តឹងឧបាស្រ័យ** ........ ៥៧
៣.១.១. ការធ្វើបណ្តឹងជំទាស់ទៅនឹងមជ្ឈត្តវិនិច្ឆ័យ ........ ៥៧
៣.១.២. សមត្ថកិច្ចក្នុងការធ្វើបណ្តឹងជំទាស់ ........ ៥៩
៣.១.៣. លក្ខខណ្ឌនៃការធ្វើបណ្តឹងជំទាស់ ........ ៥៩
៣.១.៤. អាជ្ញាយុកាលនៃការដាក់ពាក្យសុំបដិសេធ ........ ៦០
៣.១.៥ ការកែតម្រូវ ការបំភ្លឺលម្អិត ការបកស្រាយមជ្ឈត្តវិនិច្ឆ័យ និងមជ្ឈត្តវិនិច្ឆ័យបន្ថែម ........ ៦០
**៣.២. អានុភាពនៃមជ្ឈត្តវិនិច្ឆ័យ** ........ ៦២
៣.២.១. ការទទួលស្គាល់មជ្ឈត្តវិនិច្ឆ័យ ........ ៦២
៣.២.២. ការអនុវត្តចំពោះមជ្ឈត្តវិនិច្ឆ័យ ........ ៦៣
**៣.៣. លទ្ធផលសម្រេចបានក្នុងការដោះស្រាយវិវាទពាណិជ្ជកម្មតាមយន្តការមជ្ឈត្តការ** ... ៦៥
**សេចក្តីសន្និដ្ឋាន** ........ ៦៦
**អនុសាសន៍** ........ ៦៨
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

ជាទូទៅ ការរស់នៅប្រចាំថ្ងៃរបស់មនុស្សមិនអាចកាត់ផ្តាច់ដោយរស់នៅតែម្នាក់ឯងបានទេ ពួកគេតែងតែមានការប្រាស្រ័យទាក់ទងគ្នាមិនថានៅក្នុងស្ថានភាពបែបណានោះទេ។ នៅក្នុងមិត្តភាពរមែងទទួលបានផ្លែផ្កាដែលជាប្រយោជន៍រវាងគ្នានិងគ្នា ជាពិសេសពួកគេអាចជួយទុក្ខធុរៈពេលមានបញ្ហា ផ្ទុយទៅវិញនៅក្នុងរង្វង់នៃទំនាក់ទំនងគ្នាមួយចំនួនបានបង្កជាបញ្ហាជាច្រើន ដែលកើតឡើងអំពីការកេងប្រវ័ញ្ច ការក្បត់សន្យា ឬការមិនគោរពនូវគោលការណ៍សុចរិត និងភាពស្មោះត្រង់ជាដើម ហើយវាបានបង្កើតឡើងនូវវិវាទរវាងភាគីទាំងអស់។ វិវាទខ្លះកើតឡើង ក៏បានរលត់ទៅវិញដោយសារតែគូភាគីចេះដោះស្រាយ និងយោគយល់គ្នាដើម្បីប្រយោជន៍រួម ដូច្នេះវាមិនបានបង្កឱ្យមានបញ្ហាស្មុគស្មាញកាន់តែធំឡើងពិបាកដោះស្រាយនោះទេ។ ផ្ទុយទៅវិញ ប្រសិនបើភាគីទាំងអស់មិនចេះយោគយល់ ឬអត់ឱនអធ្យាស្រ័យឱ្យគ្នានោះទេ វានឹងបង្កឱ្យមានបញ្ហាកាន់តែធំឡើង រហូតមើលមុខគ្នាលែងចំ និងជាហេតុធ្វើឱ្យពួកគេបាត់បង់នូវសាមគ្គីភាព ហើយសង្គមពោរពេញដោយជម្លោះដែលជាហេតុធ្វើឱ្យបាត់បង់នូវភាពរីកចម្រើន ព្រមទាំងបង្កឱ្យមានហានិភ័យកាន់តែខ្ពស់។ ដូច្នេះនៅពេលដែលមានជម្លោះ ឬវិវាទកើតឡើងគួរតែចេះអធ្យាស្រ័យយោគយល់ និងឈ្វេងយល់វិធីសាស្ត្រដោះស្រាយប្រកបដោយសន្តិវិធីដើម្បីជៀសវាងនូវបញ្ហានោះកាន់តែតានតឹងឡើង។

ដោយសារតែមានជម្លោះ ឬវិវាទនេះកើតឡើងដូច្នេះហើយ ក្នុងនាមជារាជរដ្ឋាភិបាល ដែលជាអ្នកដឹកនាំកាច់ចង្កូតសង្គម បានប្រឹងប្រែងស្វះស្វែងបង្កើតនូវវិធីសាស្ត្រ ឬប្រព័ន្ធនៃការដោះស្រាយវិវាទតាមក្បួនវិធីផ្សេងៗជូនដល់ប្រជាពលរដ្ឋ ពោលគឺបានបង្កើតឱ្យមាននូវការដោះស្រាយវិវាទតាមប្រព័ន្ធតុលាការ និងការដោះស្រាយវិវាទតាមក្រៅប្រព័ន្ធតុលាការ ដែលយើងអាចមើលឃើញថាមានភាពសម្បូរបែបរួមមានការដោះស្រាយតាមរយៈការប្រើគោលការណ៍នៃការផ្សះផ្សា ការដោះស្រាយតាមវិធីសាស្ត្រនៃការចរចា ការសម្រុះសម្រួល សន្ធានកម្ម និងការដោះស្រាយវិវាទតាមយន្តការមេជ្ឈត្តការ។ ទន្ទឹមនឹងនោះដែរ នៅក្នុងប្រទេសកម្ពុជាយើងឃើញថា ការដោះស្រាយវិវាទគេធ្វើឡើងតាមប្រព័ន្ធពីរបែបនេះ ដូចជាការដោះស្រាយតាមប្រព័ន្ធតុលាការ និងដោះស្រាយក្រៅប្រព័ន្ធតុលាការ។ ការដោះស្រាយវិវាទតាមប្រព័ន្ធតុលាការ គឺជាគោលការណ៍ចម្បងមួយ ដែលមានលក្ខណៈប្រព្រឹត្តទៅមានភាពស្មុគស្មាញទាក់ទងទៅនឹងនីតិវិធី ដោយវាមានលក្ខណៈចាប់បង្ខំឱ្យអនុវត្តតាមនូវសាលក្រម ឬសាលដីការបស់តុលាការ។ ចំណែកឯការដោះស្រាយតាមក្រៅប្រព័ន្ធតុលាការជាវិធីដ៏ល្អមួយ ដែលអនុញ្ញាតឱ្យគូភាគីវិវាទអាចជ្រើសរើសតាមការស្ម័គ្រចិត្តនូវបែបបទនៃការដោះស្រាយវិវាទដោយគូភាគីវិវាទអាចព្រមព្រៀងធ្វើការជ្រើសរើសយកនូវការដោះស្រាយនូវវិវាទរបស់ពួកគេតាមគោលការណ៍ក្រៅប្រព័ន្ធតុលាការ ដើម្បីជាភាពងាយស្រួលសម្រាប់ពួកគេ។

ដើម្បីជាភាពងាយស្រួល នៅពេលមានវិវាទកើតឡើង មិនថាជាប្រភេទវិវាទការងារ ឬពាណិជ្ជកម្មនោះទេ ការដោះស្រាយវិវាទតាមក្រៅប្រព័ន្ធតុលាការតាមរយៈការចរចាក្តី ការផ្សះផ្សាក្តី សន្ធានកម្មក្តី ឬមជ្ឈត្តការក្តី មានភាពងាយស្រួល និងរហ័សជាងការនាំយករឿងក្តីទៅដោះស្រាយក្នុងប្រព័ន្ធតុលាការ។ ដោយហេតុថាវាបានផ្តល់នូវការណ៍មួយដ៏ប្រសើរសម្រាប់ភាគីវិវាទក្នុងការសម្រុះសម្រួល និងអាចមើលមុខគ្នាទៅថ្ងៃក្រោយ ជាពិសេសគឺជាការប្រសើរមួយសម្រាប់ភាគីទាំងអស់ ប្រសិនបើជារាល់ជម្លោះទាំងឡាយដែលកើតមានឡើងនៅក្នុងសង្គមត្រូវបានដោះស្រាយនៅក្រៅប្រព័ន្ធតុលាការ ដូចជាយន្តការមជ្ឈត្តការប្រកបដោយសន្តិវិធីនិងសន្តិភាពរួមបញ្ចូលជាមួយគោលការណ៍ឈ្នះឈ្នះទាំងអស់គ្នា ជាជាងដែលតម្រូវឱ្យមានភាគីណាមួយជាអ្នកចាញ់ ហើយភាគីម្ខាងទៀតជាអ្នកឈ្នះ។ លើសពីនេះទៀត ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដូចជាតាមរយៈយន្តការមជ្ឈត្តការ វាគឺជាវេទិកាមួយយ៉ាងសំខាន់មួយ ដែលអាចជួយកាត់បន្ថយនូវបន្ទុករបស់គូភាគីវិវាទ ក៏ដូចជាការកាត់បន្ថយនូវភាពស្មុគស្មាញ និងបន្ទុកដល់តុលាការ។

## ២. ចំណោទបញ្ហា

នៅក្នុងសង្គមបច្ចុប្បន្ន មនុស្សទាំងឡាយមានការយល់ដឹងប្រាស្រ័យទាក់គ្នាក្នុងគោលដៅផ្សេងៗ ដូចជាការទាក់ទង ឬធ្វើជំនួញពាណិជ្ជកម្មជាដើម ដែលនៅក្នុងនោះក៏បានបង្កើតឱ្យមានជម្លោះ ឬការមិនចុះសម្រុងគ្នា ដោយសារតែការបំពានកាតព្វកិច្ច ការមិនគោរពតាមកិច្ចសន្យា និងមិនបំពេញនូវកាតព្វកិច្ចរបស់ខ្លួន ដែលជាហេតុធ្វើឱ្យមានរឿងក្តីក្តាំរវាងគ្នានិងគ្នា រហូតឈានដល់ការប្តឹងផ្តល់តាមផ្លូវតុលាការផង ហើយខ្លះទៀតក៏ធ្វើការព្រមព្រៀងគ្នារកច្រកចេញតាមក្រៅប្រព័ន្ធតុលាការផងដែរ។ ទន្ទឹមនឹងនោះ យើងឃើញថានៅក្នុងការដោះស្រាយវិវាទពាណិជ្ជកម្មតាមរយៈប្រព័ន្ធតុលាការសព្វថ្ងៃនេះមានភាពយឺតយូរ និងមានការចំណាយថវិកាច្រើន ព្រមទាំងមានភាពស្មុគស្មាញនៅក្នុងដំណើរការរឿងក្តីមាននីតិវិធីជាច្រើន ដែលធ្វើឱ្យប្រជាពលរដ្ឋមានការលំបាកក្នុងការដោះស្រាយវិវាទដើម្បីទទួលបានយុត្តិធម៌។ ចំណែកឯការដោះស្រាយវិវាទពាណិជ្ជកម្មតាមក្រៅប្រព័ន្ធតុលាការមានភាពរហ័ស និងមានភាពងាយស្រួល ដូចជាការដោះស្រាយនូវវិវាទពាណិជ្ជកម្មតាមយន្តការមជ្ឈត្តការ ដែលជាវេទិកាមួយផ្តល់ភាពងាយស្រួល និងលឿនរហ័ស ជាពិសេសវាមានភាពបត់បែន ព្រមទាំងមានអានុភាពដូចទៅនឹងតុលាការផងដែរ។

តើស្ថានភាពពាណិជ្ជកម្ម និងមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មមានលក្ខណៈប្រព្រឹត្តទៅបែបណា? តើការដោះស្រាយវិវាទពាណិជ្ជកម្មតាមយន្តការមជ្ឈត្តការនេះ មាននីតិវិធីបែបណាខ្លះ? ហើយគូភាគីវិវាទមានសិទ្ធិប្តឹងឧបាស្រ័យទៅនឹងមជ្ឈត្តវិនិច្ឆ័យដែរឬទេ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

នៅក្នុងវង្វង់នៃការសិក្សាស្រាវជ្រាវចំពោះប្រធានបទមួយនេះ គឺត្រូវបានធ្វើការសិក្សាយ៉ាងសំខាន់ទៅលើគោលការណ៍នៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដែលនឹងធ្វើការបកស្រាយទាំងស្រុងនូវការដោះស្រាយវិវាទពាណិជ្ជកម្មតាមយន្តការមជ្ឈត្តការនៅប្រទេសកម្ពុជា ព្រោះថាវាជាវេទិកាយ៉ាងសំខាន់មួយក្នុងការជំរុញឱ្យមានការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការប្រកបដោយប្រសិទ្ធភាព។ នៅក្នុងនោះផងដែរ ការស្រាវជ្រាវនេះនឹងបើកកកាយពីប្រវត្តិជាប់ទាក់ទងនឹងស្ថានភាពពាណិជ្ជកម្ម ព្រមទាំងការកកើតនៃវិវាទពាណិជ្ជកម្មរួមទាំងបញ្ចូលលំហូរនីតិវិធីនៃការដោះស្រាយតាមរយៈយន្តការមជ្ឈត្តការនៅក្នុងប្រទេសកម្ពុជា។

ជាពិសេសការសិក្សាស្រាវជ្រាវនេះ មានគោលបំណងបង្ហាញឱ្យឃើញពីស្ថានភាពមួយ នៅពេលដែលមានវិវាទពាណិជ្ជកម្មកើតឡើង ហើយគូភាគីពាំនាំបញ្ហារបស់ពួកគេមកដោះស្រាយតាមរយៈយន្តការមជ្ឈត្តការ និងបើកកកាយឱ្យឃើញពីបែបបទនីតិវិធីនៃការដោះស្រាយវិវាទតាមយន្តការមជ្ឈត្តការនៅក្នុងប្រទេសកម្ពុជាពីមួយដំណាក់កាលទៅមួយដំណាក់កាលរហូតដល់ចុងបញ្ចប់នៃរឿងក្តី។ លើសពីនេះទៀតនោះ វាក៏បានឆ្លុះបញ្ចាំងពីការកំណែទម្រង់ពីការដោះស្រាយវិវាទក្នុងប្រព័ន្ធតុលាការ បែរមកដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដែលមានភាពចាំបាច់ក្នុងការពង្រឹង នូវយន្តការនៃការដោះស្រាយវិវាទពាណិជ្ជកម្មតាមយន្តការមជ្ឈត្តការដោយមានគោលបំណងចាំបាច់មួយដ៏ប្រសើរក្នុងការដោះស្រាយដោយសន្តិវិធីតាមរយៈយន្តការមួយនេះ ដែលរួមផ្សំទាំងការសម្រុះសម្រួលវិវាទ ហើយគោលគំនិតនេះវាមានសារៈប្រយោជន៍យ៉ាងសំខាន់ដើម្បីលើកស្ទួយសិទ្ធិទទួលបានយុត្តិធម៌សម្រាប់ប្រជាជនគ្រប់រូប។

ម្យ៉ាងវិញទៀត គោលគំនិតដ៏សំខាន់ផ្សេងទៀតនោះ ក្រុមនឹងធ្វើការបើកបង្ហាញពីកត្តាយុទ្ធសាស្ត្រកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ដោយត្រូវបានផ្តល់ឱ្យនូវអំណាចយុត្តាធិការចំពោះមជ្ឈត្តករដើម្បីធ្វើការដោះស្រាយវិវាទពាណិជ្ជកម្មតាមយន្តការមជ្ឈត្តការ ដែលវាជាវេទិកាបែបក្រៅប្រព័ន្ធតុលាការប្រកបដោយប្រសិទ្ធភាព និងទទួលបានផ្លែផ្កាជាទីមនោរម្យ។ នៅក្នុងនោះ រាល់វិវាទទាំងឡាយណា ដែលមានទំនាក់ទំនងជាមួយផ្នែកពាណិជ្ជកម្ម គូភាគីវិវាទអាចបញ្ចូលរឿងទាំងនោះ យកមកដោះស្រាយនៅក្នុងវេទិកាមជ្ឈត្តកម្មបាន តាមរយៈការព្រមព្រៀងរបស់គូភាគីដែលមានការកំណត់នៅក្នុងកិច្ចសន្យា ឬក៏អាចមកដោះស្រាយតាមការបង្គាប់របស់តុលាការ និងនៅពេលដែលមានវិវាទកើតឡើង ពួកគេអាចធ្វើការព្រមព្រៀងថានឹងទៅដោះស្រាយផ្សះផ្សានៅក្នុងវេទិកាមជ្ឈត្តកម្ម ព្រមទាំងអាចសម្រុះសម្រួលតាមវិធីសាស្ត្រផ្សេងៗផងដែរ។ លើសពីនេះទៅទៀត នៅពេលដែលធ្វើមជ្ឈត្តវិនិច្ឆ័យ សេចក្តីសម្រេចនោះនឹងមានអានុភាពដែលគូភាគីវិវាទអាចយកមកអនុវត្តបាន ប៉ុន្តែប្រសិនបើភាគីណាមួយមិនពេញចិត្ត ភាគីអាចធ្វើបណ្តឹងឧបាស្រ័យដើម្បីប្តឹងជំទាស់នឹងសេចក្តីសម្រេចនោះបាន។ សរុបមកទាំងនេះគឺជាគោលបំណងដែលនឹងលើកយកមកធ្វើការសិក្សាស្រាវជ្រាវប្រកបដោយភាពស៊ីជម្រៅ និងសុក្រឹតភាព។

## ៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ដោយសារតែសង្គមចេះតែវិវត្តន៍ទៅមុខ ដែលជាហេតុធ្វើឱ្យមាននូវគោលការណ៍ថ្មីៗបានផុសឡើងដើម្បីបន្សុីគ្នាជាមួយនឹងចរន្តនៃសង្គមបែបទំនើបកម្ម។ កាលពីមុន ការដោះស្រាយជម្លោះ ឬវិវាទផ្សេងៗដូចជាវិវាទពាណិជ្ជកម្មជាភារកិច្ចរបស់អង្គការតុលាការ ប៉ុន្តែដោយសាររបត់សង្គមកែប្រែទៅជាសង្គមសាកលភាវូបនីយកម្មបានរំលេចឡើងនូវបែបបទនីតិវិធីនៃការដោះស្រាយនូវវិវាទក្រៅប្រព័ន្ធតុលាការ ជាពិសេសការដោះស្រាយវិវាទពាណិជ្ជកម្មតាមយន្តការមជ្ឈត្តការនៅកម្ពុជា ជាទម្រង់នៃការដោះស្រាយវិវាទមួយបែបទំនើប ដែលពិតជាមានសារៈសំខាន់ចំពោះកម្ពុជា ទើបបានជារាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ និងបានបង្កើតឱ្យមានមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលជាស្ថាប័នមួយឯករាជ្យនៅក្រោមការឧបត្ថម្ភរបស់ក្រសួងពាណិជ្ជកម្ម ក្នុងគោលបំណងដើម្បីជំរុញឱ្យមានការដោះស្រាយវិវាទពាណិជ្ជកម្ម។ ដោយការពិតទៅ ទម្រង់នៃការដោះស្រាយវិវាទពាណិជ្ជកម្ម អាចធ្វើបានតាមប្រព័ន្ធតុលាការ និងតាមទម្រង់ក្រៅប្រព័ន្ធតុលាការ ដូចជាការផ្សះផ្សា ឬមជ្ឈត្តការជាដើម ដែលនៅក្នុងនោះពេលណាមួយដែលគូភាគីវិវាទបានធ្វើការព្រមព្រៀងគ្នានៅក្នុងកិច្ចសន្យា នៅពេលមានវិវាទកើតឡើង មានតែវេទិកាមជ្ឈត្តកម្មនោះទេ ទើបមានសមត្ថកិច្ចក្នុងការដោះស្រាយព្រោះវាជាការព្រមព្រៀងរបស់គូភាគីវិវាទទាំងអស់។

ការពាំនាំយកនូវវិវាទពាណិជ្ជកម្មមកធ្វើការដោះស្រាយតាមបែបយន្តការមជ្ឈត្តការនៅកម្ពុជា នោះវាគឺជារឿងមួយយ៉ាងសំខាន់ ដែលមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មមានសមត្ថកិច្ចក្នុងការដោះស្រាយដោយផ្អែកតាមវិធានអាជ្ញាគតិដែលមានភាពពាក់ព័ន្ធជាមួយនឹងវិធានពាណិជ្ជកម្ម និងវិធានស្តីពីមជ្ឈត្តការ។ លើសពីនេះទៀតនោះ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មមានភារកិច្ចក្នុងការជំរុញក្នុងការដោះស្រាយវិវាទក៏ដូចជាផ្តល់នូវយុត្តិធម៌មួយដ៏សមស្របដល់គូភាគីវិវាទ ដែលមានមជ្ឈត្តករជាអ្នកធ្វើមជ្ឈត្តវិនិច្ឆ័យទៅលើរឿងក្តីទាំងនោះ។ ម្យ៉ាងទៀត ស្ថាប័ននេះមានសិទ្ធិ និងតួនាទីក្នុងការដោះស្រាយវិវាទពាណិជ្ជកម្ម ដោយមានបែបបទនីតិវិធីក្នុងការដោះស្រាយតាមច្បាប់ ព្រមទាំងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការធ្វើមជ្ឈត្តវិនិច្ឆ័យរួមទាំងមានអានុភាពសម្រាប់អនុវត្តផងដែរ។

## ៥. វិធីសាស្ត្រស្រាវជ្រាវ

ក្នុងនាមជានិស្សិត ដែលជាអ្នកសិក្សាស្រាវជ្រាវនូវឯកសារយកមកធ្វើជាគោល និងធ្វើការបកស្រាយនៅក្នុងសារណាបញ្ចប់ការសិក្សានេះ ក្រុមយើងខ្ញុំបានបានធ្វើការសិក្សា និងដកស្រង់នូវអត្ថន័យខ្លឹមសារដែលជាប់ពាក់ព័ន្ធចេញពីឯកសាផ្សេងៗ ដោយមានមូលដ្ឋានគ្រឹះប្រកបដោយសុក្រឹតភាពរួមមាន ច្បាប់ វិធាន ប្រកាស សេចក្តីសម្រេច លិខិតបទដ្ឋានគតិយុត្ត និងសៀវភៅផ្សេងៗ ដែលមានការជាប់ពាក់ព័ន្ធទៅនឹងការដោះស្រាយវិវាទពាណិជ្ជកម្មតាមយន្តការមជ្ឈត្តការនៅកម្ពុជា។ លើសពីនេះទៀត វាក៏បានស្តែងចេញឡើងនូវភាពជាដៃគូ

ក្នុងការខិតខំសហការគ្នាយ៉ាងខ្លាំងក្នុងការសរសេរ និងស្រាវជ្រាវពីមជ្ឈដ្ឋានឯកសារនានាដែលពាក់ព័ន្ធ និងឆ្លុះបញ្ចាំងអំពីភាពសាមគ្គីចំពោះការសិក្សាស្រាវជ្រាវក្នុងការសរសេរសារណាបទនេះ។

## ៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងទំហំនៃការសរសេរសារណានេះ ដើម្បីឱ្យមានភាពងាយស្រួល និងច្បាស់លាស់អំពីការដោះស្រាយវិវាទពាណិជ្ជកម្មតាមយន្តការមជ្ឈត្តការនៅកម្ពុជា ខ្ញុំព្រះករុណាអាត្មាភាពទាំងពីរអង្គនឹងធ្វើការបែងចែកជារចនាសម្ព័ន្ធដូចជា៖

ជំពូកទី១៖ ស្ដីពីពាណិជ្ជកម្ម និងដំណើរការនៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលធ្វើការពន្យល់ពីស្ថានភាពទូទៅនៃពាណិជ្ជកម្មនៅកម្ពុជាមានដូចជាប្រវត្តិពាណិជ្ជកម្ម វិវាទពាណិជ្ជកម្ម យន្តការទូទៅនៃការដោះស្រាយវិវាទ និងពន្យល់ដំណើរការនិងការប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។

ជំពូកទី២៖ ស្ដីអំពីនីតិវិធីនៃការដោះស្រាយនូវវិវាទពាណិជ្ជកម្មតាមយន្តការមជ្ឈត្តការ ដែលនឹងត្រូវធ្វើការបកស្រាយទៅលើនីតិវិធីនៃការដោះស្រាយវិវាទពាណិជ្ជកម្មតាមយន្តការមជ្ឈត្តការ មានជារួមអំពីការធ្វើសន្និសីទអំពីការគ្រប់គ្រប់សំណុំរឿង សេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្ម កិច្ចព្រមព្រៀងរបស់ភាគីវិវាទ នីតិវិធីនៃមជ្ឈត្តការពាណិជ្ជកម្ម មជ្ឈត្តករបន្ទាន់ ការចាប់ផ្ដើមវេទិកាមជ្ឈត្តកម្មពាណិជ្ជកម្ម ព្រមទាំងការចេញនូវមជ្ឈត្តវិនិច្ឆ័យ។

ជំពូកទី៣៖ ស្ដីពីបណ្ដឹងឧបាស្រ័យ និងអានុភាពមជ្ឈត្តវិនិច្ឆ័យ ដែលនឹងត្រូវធ្វើការបកស្រាយអំពីបណ្ដឹងឧបាស្រ័យទៅនឹងមជ្ឈត្តវិនិច្ឆ័យរបស់វេទិកាមជ្ឈត្តកម្ម ព្រមទាំងអានុភាពនៃការអនុវត្តចំពោះមជ្ឈត្តវិនិច្ឆ័យ និងលទ្ធផលដែលសម្រេចបានក្នុងការដោះស្រាយកន្លងមក។

# ជំពូកទី១
# ពាណិជ្ជកម្ម និងមជ្ឈមណ្ឌលជាតិ
# នៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

# ជំពូកទី១
# ពាណិជ្ជកម្ម និងមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

## ១.១. ស្ថានភាពទូទៅនៃពាណិជ្ជកម្មនៅកម្ពុជា

ប្រទេសកម្ពុជាបានក្លាយជាប្រទេសឯករាជ្យថ្មីមួយនៅឆ្នាំ១៩៥៣ ជាមួយនឹងមហិច្ឆតាសម្រាប់កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍតាមរយៈការពង្រីកឧស្សាហកម្មនិងពាណិជ្ជកម្ម។ បន្ទាប់ពីសង្គ្រាម និងការបំផ្លិចបំផ្លាញជាច្រើនទសវត្សរ៍ មហិច្ឆតាទាំងនេះបានចាប់ផ្តើមសម្រេចជាមួយនឹងអត្រាកំណើនឧស្សាហកម្ម និងពាណិជ្ជកម្ម រួមទាំងការពង្រីកសកម្មភាពអាជីវកម្ម និងសេដ្ឋកិច្ចជាបន្តបន្ទាប់។ នៅចុងទសវត្សរ៍ឆ្នាំ១៩៨០ ប្រទេសកម្ពុជាបានចាប់ផ្តើមដំណើរការសេរីភាវូបនីយកម្មទីផ្សារ។ ភាពផ្តាច់មុខរបស់រដ្ឋចំពោះពាណិជ្ជកម្មបរទេសត្រូវបានលុបចោលនៅឆ្នាំ១៩៨៧ ហើយច្បាប់វិនិយោគបរទេសត្រូវបានចូលជាធរមាននៅឆ្នាំ១៩៨៩ ដែលបានអនុញ្ញាតឱ្យក្រុមហ៊ុនឯកជនធ្វើពាណិជ្ជកម្មនៅបរទេស។ នៅដើមទសវត្សរ៍ឆ្នាំ១៩៩០ គោលនយោបាយពាណិជ្ជកម្មត្រូវបានធ្វើសេរីភាវូបនីយកម្មបន្ថែមទៀត ដោយភាគច្រើនបានដកការរឹតបន្តឹងលើក្រុមហ៊ុន និងបុគ្គលដែលចូលរួមក្នុងពាណិជ្ជកម្មអន្តរជាតិ។ ការរឹតបន្តឹងបរិមាណ និងអាជ្ញាប័ណ្ណនាំចូលភាគច្រើនត្រូវបានលុបចោល។ នៅចុងទសវត្សរ៍ឆ្នាំ១៩៩០ មានដំណាក់កាលបន្ថែមផ្សេងទៀតនៃជំហានវិជ្ជមានឆ្ពោះទៅរករបបពាណិជ្ជកម្មសេរីខ្ពស់។ កម្ពុជាបន្ទាប់ពីការបោះឆ្នោតជាសកលលើកដំបូងក្នុងឆ្នាំ១៩៩៣ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំ និងអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចទូលំទូលាយ និងកម្មវិធីកំណែទម្រង់រចនាសម្ព័ន្ធជាមួយនឹងកិច្ចខិតខំប្រឹងប្រែងដើម្បីធ្វើសមាហរណកម្មសេដ្ឋកិច្ចនៅប្រទេសកម្ពុជាទៅកាន់តំបន់ និងពិភពលោក។[1] តាមទិដ្ឋភាពជាក់ស្តែងស្ថានភាពពាណិជ្ជកម្មនៅកម្ពុជា មានការវិវឌ្ឍទៅតាមរបបនយោបាយសង្គម និងតាមកំណែទម្រង់នៃឆ្នាំនីមួយៗ ដើម្បីឱ្យមានភាពប្រសើរឡើង។ ការពិតណាស់ ដើម្បីយល់ពីស្ថានភាពទូទៅនៃពាណិជ្ជកម្មនៅកម្ពុជា ជំហានបន្តនឹងសិក្សាទៅលើ ១.១.២.វិវាទពាណិជ្ជកម្ម និង ១.១.៣.ប្រវត្តិនៃការដោះស្រាយវិវាទពាណិជ្ជកម្មនៅកម្ពុជា។

### ១.១.២. វិវាទពាណិជ្ជកម្ម

ការធ្វើអាជីវកម្ម ក្រុមអាជីវករតែងតែមានការថ្លឹងថ្លែងរវាងហានិភ័យ និងផលចំណេញ ប៉ុន្តែនៅពេលដែលបរិយាកាសអាជីវកម្មគ្មានស្ថេរភាព ឬមិនអាចព្យាករទុកមុនបាន នោះវានឹងបង្កភាពលំបាកក្នុងការថ្លឹងថ្លែងរវាងហានិភ័យ និងផលចំណេញ។ ហេតុដូច្នេះហើយ កាលណាបើមានប្រព័ន្ធច្បាប់ល្អ និងច្បាស់លាស់សម្រាប់ការធ្វើអាជីវកម្ម គឺមានសារៈសំខាន់ណាស់ក្នុងការជំរុញវិនិយោគ និងកំណើនសេដ្ឋកិច្ច។ ប្រព័ន្ធច្បាប់ល្អងាយស្រួលក្នុងការគ្រប់គ្រងប្រព័ន្ធសេដ្ឋកិច្ចក្នុងសង្គម ដែលជាកត្តាមួយនឹងធ្វើឱ្យមានភាពងាយស្រួលក្នុង

[1] លោក ឆាយ សុខធី និងអ៊ុង លុយណា, Economic history of industrialization in Cambodia, បោះពុម្ពឆ្នាំ២០១៦

ការធ្វើពាណិជ្ជកម្ម ហើយក៏ជាការល្អ និងងាយស្រួលផងដែរ កាលណាមានវិវាទពាណិជ្ជកម្មកើតឡើងនឹងមានភាពល្អប្រសើរក្នុងការដោះស្រាយវិវាទពាណិជ្ជកម្ម ដែលបានកើតនោះឱ្យប្រសើរឡើងវិញ។

វិវាទពាណិជ្ជកម្ម គឺជាវិវាទដែលកើតចេញពីការធ្វើពាណិជ្ជកិច្ច ហើយត្រូវបានកំណត់ដោយច្បាប់ជាតិ និងច្បាប់អន្តរជាតិ ព្រមទាំងទំនៀមទម្លាប់ក្នុងការធ្វើពាណិជ្ជកម្មផងដែរ។ វិវាទពាណិជ្ជកម្ម កើតឡើងជាផ្នែកនៃកិច្ចព្រមព្រៀង ឬប្រតិបត្តិការដែលបានកំណត់ជាជម្លោះពាណិជ្ជកម្ម ដែលជាដំណើរការអនុញ្ញាតឱ្យភាគីមានជម្លោះដោះស្រាយភាពខុសគ្នារបស់ពួកគេ។ ត្រូវបានចាត់ទុកផងដែរ ដោយតុលាការថាជាមធ្យោបាយមួយនៅពេលដែលការប្រាស្រ័យទាក់ទងគ្នារវាងភាគីពាក់ព័ន្ធបានបែកបាក់ នោះជម្លោះពាណិជ្ជកម្មពាក់ព័ន្ធទៅនឹងការដោះស្រាយប្រតិបត្តិការពាណិជ្ជកម្ម ឬកិច្ចព្រមព្រៀងណាមួយនៃពាណិជ្ជកម្ម។ ចំពោះវិវាទពាណិជ្ជកម្មអាចកើតមានឡើងរវាងក្រុមហ៊ុននិងក្រុមហ៊ុន បុគ្គលនិងក្រុមហ៊ុន ឬការលាយបញ្ចូលគ្នាទាំងពីរ ឬក៏រវាងគូភាគីដែលអនុវត្តពាណិជ្ជកិច្ច និងជាគូភាគីនៃវិវាទ អាចជាពាណិជ្ជករ និងពាណិជ្ជករ ឬពាណិជ្ជករ និងជនមិនមែនជាពាណិជ្ជករដោយអាស្រ័យទៅតាមប្រភេទនិងបែបផែនអាជីវកម្ម។ ខណៈដែលវិវាទពាណិជ្ជកម្មគ្របដណ្តប់ទៅលើវិស័យដ៏ធំទូលាយមួយប្រភេទនៃវិវាទជាទូទៅបំផុតរួមមាន ជម្លោះក្នុងកិច្ចសន្យា រួមទាំងការបំពាននូវកិច្ចសន្យា និងបំពានកាតព្វកិច្ច ការប្រកួតប្រជែងមិនស្មោះត្រង់ ឬវិវាទអាជីវកម្ម ជាទូទៅរវាងម្ចាស់ភាគហ៊ុន ដៃគូពាណិជ្ជកម្ម វិនិយោគិន នាយក និងបុគ្គលជាដើម។

លក្ខខណ្ឌដែលត្រូវបំពេញមុនពេលវិវាទពាណិជ្ជកម្ម អាចត្រូវបានចេញជាផ្លូវការត្រូវតែមានមូលដ្ឋានច្បាស់លាស់ជាមុនសម្រាប់ការទាមទារ។ ផ្នែកសំខាន់នៃដំណើរការវិវាទពាណិជ្ជកម្មគឺការផ្តល់ភស្តុតាងដែលបានចាត់វិធានការគ្រប់បែបយ៉ាងដើម្បីដោះស្រាយបញ្ហាដោយមិនងាកទៅរកប្រព័ន្ធតុលាការ ដោយសារនៅក្នុងតុលាការ ពិធីការសកម្មភាពមុន អាចត្រូវបានទាមទារ ដែលអ្នកត្រូវបំពេញឱ្យបានពេញលេញ។

ដំណើរការរឿងក្តីពាណិជ្ជកម្ម អនុវត្តតាមបទប្បញ្ញត្តិដូចគ្នាទៅនឹងដំណើរការក្តីរដ្ឋប្បវេណីយ៉ាងដូច្នោះដែរ លើកលែងតែសមាសភាពក្រុមប្រឹក្សាជំនុំជម្រះនៃតុលាការពាណិជ្ជកម្មតែប៉ុណ្ណោះដែលខុសគ្នា ដោយមានចៅក្រម ០៣ (បី) រូប និងទីប្រឹក្សា ០២ (ពីរ) រូបជាពាណិជ្ជករ ឬអ្នកមានចំណេះផ្នែកច្បាប់ពាណិជ្ជកម្មក្នុងរឿងក្តីពាណិជ្ជកម្មមានកម្មវត្ថុនៃបណ្តឹងតម្លៃចាប់ពី ១.០០០.០០០.០០០ (មួយពាន់លាន) រៀលឡើងទៅ។ ប្រសិនបើកម្មវត្ថុនៃបណ្តឹងមានតម្លៃចាប់ពី ១០០.០០០.០០០ (មួយរយលាន) រៀល ដល់ក្រោម ១.០០០.០០០.០០០ (មួយពាន់លាន) រៀល ក្រុមប្រឹក្សាជំនុះជម្រះមានចៅក្រមមួយរូបនិងអមដោយទីប្រឹក្សា ០២ រូប។[2]

[2] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤, មាត្រា២៣

### ១.១.៣.ប្រវត្តិនៃការដោះស្រាយវិវាទពាណិជ្ជកម្មនៅកម្ពុជា

តុលាការពាណិជ្ជកម្មអាចនឹងត្រូវបង្កើតឡើង យោងតាមច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម អនុម័តនៅឆ្នាំ១៩៩៥។ ទោះជាយ៉ាងនេះក្តី តុលាការទាំងនេះមិនទាន់ត្រូវបានបង្កើតឡើងនៅឡើយទេ។ នៅក្នុងច្បាប់នោះបានចែងផងដែរថា ក្នុងរយៈកាលដែលព្រះរាជាណាចក្រកម្ពុជានៅមិនទាន់មានតុលាការពាណិជ្ជកម្មនីតិសាមញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលជាអ្នកមានសមត្ថកិច្ចទៅលើរឿងក្តីពាណិជ្ជកម្ម សំដៅដល់តុលាការរដ្ឋប្បវេណីនៃសាលាដំបូងជំនុំជម្រះរឿងក្តីពាណិជ្ជកម្មទាំងអស់។

ចំពោះតុលាការពាណិជ្ជកម្មនៃសាលាដំបូងមានសមត្ថកិច្ចជំនុំជម្រះលើរឿងក្តីវិវាទពាណិជ្ជកម្មទាំងអស់ ព្រមទាំងរឿងក្តីក្ស័យធនក្នុងរឿងក្តីពាណិជ្ជកម្ម ដោយធ្វើការអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីពាណិជ្ជកម្ម។ សាលាដំបូងរាជធានីភ្នំពេញ ជាតុលាការមួយត្រូវបានប្រើប្រាស់ជារឿយៗ ដោយគូភាគីវិវាទផ្នែកពាណិជ្ជកម្ម។ ទោះជាយ៉ាងនេះក្តី តុលាការនេះត្រូវបានមើលឃើញដោយអ្នកអនុវត្តចំពោះការទទួលរងបន្ទុកយ៉ាងធ្ងន់ធ្ងរដោយខ្វះជំនាញ និងបទពិសោធវិជ្ជាជីវៈតុលាការនៅក្នុងការជំនុំជម្រះរឿងក្តីពាណិជ្ជកម្ម។

## ១.២. យន្តការដោះស្រាយវិវាទ

ការដោះស្រាយវិវាទពាណិជ្ជកម្មឱ្យបានឆាប់រហ័ស បត់បែន សម្ងាត់ និងប្រកបដោយប្រសិទ្ធភាពខ្ពស់ពិតជាមានសារៈសំខាន់ណាស់ ដើម្បីធ្វើឱ្យអាជីវករមានទំនុកចិត្តក្នុងការពង្រីកប្រតិបត្តិការអាជីវកម្មរបស់ខ្លួន។ ប៉ុន្តែការដោះស្រាយវិវាទពាណិជ្ជកម្មនៅកម្ពុជាមានលក្ខណៈពិបាក ហើយប្រព័ន្ធដោះស្រាយវិវាទទាំងផ្លូវការ និងមិនផ្លូវការមិនទាន់ដំណើរការបានសមស្របនៅឡើយ។[3] អាជីវករទាំងឡាយកំពុងចាត់ទុកថាការដោះស្រាយវិវាទនៅតុលាការថាជាវិធីសាស្ត្រដ៏ល្អ ដែលឆ្ពោះទៅកាន់ភាពជោគជ័យ។ ប៉ុន្តែការដោះស្រាយវិវាទមិនផ្លូវការក៏មានគុណវិបត្តិធំៗដែរ។ ដូច្នេះហើយ អាជីវកម្មភាគច្រើនសុខចិត្តរងការខាតបង់ និងចៀសវាងឱ្យឆ្ងាយពីវិវាទជាជាងប្រើសិទ្ធិស្របច្បាប់របស់ខ្លួនប្តឹងទាមទារអ្វីដែលខ្លួនគួរទទួលបានតាមផ្លូវច្បាប់។

វិធានការមួយដែលរាជរដ្ឋាភិបាលកម្ពុជាជ្រើសរើសយក ដើម្បីកែលម្អប្រព័ន្ធដោះស្រាយវិវាទពាណិជ្ជកម្មនៅកម្ពុជាគឺការបង្កើតមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។ បច្ចុប្បន្ននេះ កម្ពុជាបានបង្កើតមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការដើម្បីជាការសម្រួលដល់ការដោះស្រាយវិវាទពាណិជ្ជកម្ម នេះគឺជាជំហានវិជ្ជមានមួយសម្រាប់ប្រទេសកម្ពុជា។ បទពិសោធរបស់ប្រទេសជាច្រើន ដោយរួមបញ្ចូលទាំងប្រទេសដែលមានប្រព័ន្ធតុលាការដែលដំណើរល្អបានបង្ហាញថា ការបង្កើតយន្តការដោះស្រាយវិវាទពាណិជ្ជកម្មក្រៅប្រព័ន្ធតុលាការ អាចជួយកែលម្អនូវបរិយាកាសអាជីវកម្ម ដោយធ្វើឱ្យអាជីវករអាចដោះស្រាយវិវាទបានយ៉ាងងាយស្រួល និងមានប្រសិទ្ធភាពខ្ពស់។[4]

[3] ព្រឹត្តប័ត្រស្តីពីបញ្ហាអាជីវកម្ម (International Finance Corporation)

[4] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, លេខ នស/រកម/០៥០៦/០១០, ០៥ ឧសភា ២០០៦, មាត្រា១០

ជាការពិតណាស់ ការបង្កើតយន្តនៃការដោះស្រាយវិវាទនេះ វាជាការចាំបាច់ណាស់ដែលមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការត្រូវមានយុត្តិធម៌ និងឯករាជ្យ ដែលចំណាយអស់ប្រាក់កាសតិចដើម្បីដោះស្រាយវិវាទ និងមានប្រសិទ្ធភាព តាំងពីពេលដែលគេចាប់ផ្ដើមប្រតិបត្តិការដំបូង។ កត្តាទាំងនេះនឹងបង្កើតឱ្យមានតម្រូវការលើសេវារបស់មជ្ឈមណ្ឌល និងធ្វើឱ្យសមាគមអាជីវកម្ម មានទំនុកចិត្តមកលើមជ្ឈមណ្ឌលនេះក្នុងការដោះស្រាយវិវាទពាណិជ្ជកម្ម។[5] នៅក្នុងផ្នែកនេះយើងនឹងសិក្សាទៅ ១.២.១. សញ្ញាណនៃការដោះស្រាយវិវាទ និង១.២.២. ការចរចា ការផ្សះផ្សា សន្ធានកម្ម និងមជ្ឈត្តការ។

### ១.២.១. សញ្ញាណនៃការដោះស្រាយវិវាទ

នៅក្នុងវិស័យពាណិជ្ជកម្ម ទាមទារនូវយន្តការនៃការដោះស្រាយវិវាទមួយ ដែលមានលក្ខណៈពិសេសពីការដោះស្រាយវិវាទផ្សេងៗទៀត ដូចជាវិវាទរដ្ឋប្បវេណី វិវាទរឿងព្រហ្មទណ្ឌ ឬវិវាទរដ្ឋបាលជាដើម។ តម្រូវការនេះត្រូវបានអនុម័ត និងប្រើប្រាស់នៅតាមបណ្ដាប្រទេសជាច្រើនលើសាកលលោកតាមរយៈការបង្កើតនូវតុលាការពិសេសសម្រាប់រឿងពាណិជ្ជកម្ម។ ទន្ទឹមនឹងនេះ កម្ពុជាក៏បានបង្កើតឱ្យមានស្ថាប័នមួយសម្រាប់ការដោះស្រាយវិវាទពាណិជ្ជកម្មផងដែរ។ ការដោះស្រាយវិវាទបែបនេះ ពាណិជ្ជករនិយមប្រើប្រាស់យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដូចជាការចរចាទ្វេភាគី ការសម្របសម្រួល សន្ធានកម្ម និងមជ្ឈត្តការជាដើម ដែលជាកត្តានៃការសម្រួលដល់ប្រព័ន្ធតុលាការ ក៏ដូចជាការសម្រួលដល់ពាណិជ្ជករផងដែរ។

យើងដឹងហើយថា កាលណាបើមានវិវាទកើតឡើង ភាគីវិវាទអាចប្រើប្រាស់នូវជម្រើសជាច្រើនក្នុងការដោះស្រាយវិវាទដែលកើតឡើងនោះ។ ក្នុងនោះយើងបែងចែកយន្តការនៃការដោះស្រាយវិវាទ នេះជាពីរធំៗគឺការដោះស្រាយវិវាទតាមប្រព័ន្ធតុលាការ និងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ ក្នុងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ភាគីវិវាទអាចធ្វើការចរចា ការផ្សះផ្សា សន្ធានកម្ម និងមជ្ឈត្តការ ដើម្បីស្វែងរកដំណោះស្រាយណាមួយ ក្នុងគោលបំណងសម្រុះសម្រួល និងដោះស្រាយចំពោះវិវាទដែលកើតឡើងនោះ។

### ១.២.២. ការចរចា ការផ្សះផ្សា សន្ធានកម្ម និងមជ្ឈត្តការ

#### ១.២.២.១. ការចរចា

ការចរចា គឺជាដំណើរការនៃការឆ្លើយឆ្លងគ្នាទៅវិញទៅមក ដែលតាមរយៈនេះភាគីទាំងអស់ដាក់ជូន ឬពិចារណាលើសម្ដីផ្សេងៗ រហូតដល់សំណើណាមួយត្រូវបានធ្វើឡើង ហើយត្រូវបានគេទទួលយក។ ការចរចាគឺជាទម្រង់ដ៏សាមញ្ញបំផុតនៃដំណើរការដោះស្រាយវិវាទនៅទូទាំងពិភពលោក ដែលគេឃើញមានទាំងនៅក្នុងយុត្តាធិការនៃច្បាប់ស៊ីវិល (Civil Law) និងច្បាប់អង់គ្លេស (Common Law) ។ ការចរចា អាចដោះស្រាយវិវាទធំ និងតូច ហើយអាចជាដំណើរការដ៏ស្មុគស្មាញបំផុត ឬសាមញ្ញធម្មតាមួយ។ មនុស្សធ្វើការចរចានៅគ្រប់ពេល

[5] ព្រឹត្តប័ត្រស្ដីពីបញ្ហាអាជីវកម្ម (International Finance Corporation)

ទាំងអស់ វាគឺជាទម្រង់សំខាន់បំផុតនៃការប្រាស្រ័យទាក់ទងរវាងមនុស្ស និងមនុស្ស។ មនុស្សធ្វើការចរចា ទោះបីជានៅពេលគ្មានវិវាទក៏ដោយ។ ជាក់ស្តែង មនុស្សអាចចរចាគ្នាអំពីតម្លៃផ្លែស្វាយ ឬតម្លៃលក់ម៉ូតូជាដើម។ ពេលខ្លះខ្លួនពួកគេមិនទាំងដឹងផង ថាខ្លួនកំពុងតែចរចា។ ការចរចាអាចធ្វើឡើងដោយផ្ទាល់មាត់ និងដោយលាយលក្ខណ៍អក្សរ។ ការចរចាអាចធ្វើឡើងដោយផ្ទាល់រវាងភាគីពីរ ឬតាមរយៈតំណាងរបស់ភាគីទាំងនោះ។ ការចរចាអាចធ្វើឡើងតាមបែបធម្មតា ឬលក្ខណៈផ្លូវការ តាមរយៈសំបុត្រ ឬអ៊ីមែលផងដែរ។ ក្នុងប្រទេសកម្ពុជា ការចរចាច្រើនតែធ្វើឡើងនៅចំពោះមុខគ្នាផ្ទាល់ ប៉ុន្តែគេក៏អាចចរចាតាមទូរស័ព្ទផងដែ។ ច្បាប់របស់កម្ពុជាគាំទ្រឱ្យមានការចរចា ជាក់ស្តែងក្រមនីតិវិធីរដ្ឋប្បវេណីរបស់កម្ពុជា បានលើកទឹកចិត្តឱ្យមានការសម្រុះសម្រួលគ្នាតាមរយៈការចរចារវាងភាគីវិវាទ។[6]

យុត្តាធិការជាច្រើនផ្តល់ភាពអនុគ្រោះដល់ដំណោះស្រាយវិវាទតាមរយៈការចរចា ដោយសារតែមានហេតុផលល្អ។ ដោយហេតុថាយុត្តាធិការជាច្រើនមានបញ្ជីរឿងក្តីជាច្រើនដែលមិនទាន់វិនិច្ឆ័យ វិធីតែម្យ៉ាងគត់ក្នុងការដោះស្រាយវិវាទឱ្យទាន់ពេលវេលា គឺលើកទឹកចិត្តភាគីវិវាទឱ្យពិភាក្សាអំពីបញ្ហានោះជាមួយគ្នា ហើយព្យាយាមឈានទៅរកការព្រមព្រៀងមួយដែលសមស្របមួយ។ ចំណែកនៅប្រទេសកម្ពុជា នៅក្នុងការអង្កេតលើក្រុមហ៊ុនតូចៗមួយចំនួន ដែលធ្វើឡើងដោយធនាគារពិភពលោក ត្រូវបានរកឃើញថា ការចរចាគឺជាវិធីសាស្ត្រដែលមានការនិយមជាងគេបំផុតក្នុងការដោះស្រាយវិវាទដែលបានកើតឡើង។[7]

**១.២.២.២. ការផ្សះផ្សា**

ជាក់ស្តែង ការផ្សះផ្សា គឺជាយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដែលមានលក្ខណៈស្រដៀងទៅនឹងសន្ធានកម្ម។ អ្នកផ្សះផ្សាមានភារៈណែនាំគូភាគីដើម្បីរកដំណោះស្រាយវិវាទពាក់ព័ន្ធ។ ជាទូទៅ ភាគីធ្វើការកំណត់ជាមុនថា តើយោបល់របស់អ្នកផ្សះផ្សាមានលក្ខណៈជាកាតព្វកិច្ចឬទេក្នុងការចូលរួមក្នុងនីតិវិធីនៃការផ្សះផ្សានេះ ករណីភាគច្រើនភាគីរ៉ាប់រងការចំណាយស្មើគ្នា?

[6] មាត្រា៩៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា តាមមាត្រានេះ តុលាការអាចលើកទឹកចិត្តឱ្យភាគីវិវាទធ្វើការការចរចាឬអាចដើរតួនាទីសកម្មជាងនេះ ដោយក្នុងករណីណាមួយក៏ដោយ កិច្ចអន្តរាគមន៍របស់តុលាការគឺអាចធ្វើឡើងក្នុងរូបភាពជាសន្ធានការី។

[7] ការវាយតម្លៃបរិយាកាសអាជីវកម្មតាមខេត្តនៃប្រទេសកម្ពុជា ការវាស់ស្ទង់អភិបាលកិច្ចសេដ្ឋកិច្ច និងគោលនយោបាយបទប្បញ្ញត្តិ ធនាគារពិភពលោក និង មូលនិធិអាស៊ី ទំព័រ៤៨ បោះពុម្ព ២០០៧៖ ការអង្កេតបានរកឃើញថា ៩២% នៃ ក្រុមហ៊ុនក្នុងប្រទេសកម្ពុជាជ្រើសយកការចរចារជាជម្រើសខ្ពស់បំផុតរបស់ខ្លួនក្នុងការដោះស្រាយវិវាទ។ ផ្ទុយទៅវិញ មានក្រុមហ៊ុនតែ ១% ប៉ុណ្ណោះដែលអះអាងថាការប្តឹងទៅតុលាការ គឺជាវិធីសាស្ត្រដោះស្រាយវិវាទដ៏ទូទៅបំផុតសំរាប់ពួកគេ ។

**១.២.២.៣. សន្ធានកម្ម**

សន្ធានកម្ម គឺជាយន្តការដោះស្រាយវិវាទមួយដែលតតិយជនមិនលម្អៀង និងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ចូលរួមក្នុងការសម្របសម្រួលគូភាគីវិវាទដែលកំពុងមានវិវាទឱ្យធ្វើការផ្លាស់ប្តូរយោបល់គ្នាដោយចំពោះមុខក្តី ឬមិនចំពោះមុខក្តី។ បេសកកម្មរបស់សន្ធានកម្ម គឺជួយស្តារទំនាក់ទំនង និងជំរុញឱ្យគូភាគីអាចស្វែងរកការព្រមព្រៀងមួយដែលអាចទទួលយកបានទាំងសងខាង។

ជាទូទៅ សន្ធានកម្មត្រូវមានភាគីវិវាទពីរ ឬច្រើន ដែលព្យាយាមចរចាលើដំណោះស្រាយមួយ ដោយមានជំនួយពីភាគីទីបី គឺសន្ធានការីដែលមានអព្យាក្រឹតភាពចំពោះគូភាគីនៃវិវាទទាំងនោះ ក៏ដូចជាលទ្ធផលនៃដំណោះស្រាយដោយផ្ទាល់។ សន្ធានការីមិនមានសិទ្ធិអំណាចក្នុងការចាប់បង្ខំឱ្យយកដំណោះស្រាយណាមួយឡើយ។ ផ្ទុយទៅវិញ ភាគីវិវាទនៅតែមានសិទ្ធិអំណាចក្នុងការសម្រេចថា តើខ្លួនចង់ ឬមិនចង់ដោះស្រាយ? ប្រសិនបើភាគីវិវាទមិនចង់ដោះស្រាយ ឬមិនមានការព្រមព្រៀងគ្នា នោះនឹងគ្មានដំណោះស្រាយឡើយ ទោះជាមានការខិតខំប្រឹងប្រែងរបស់សន្ធានការីយ៉ាងណាក៏ដោយ។ មិនដូចក្នុងមជ្ឈត្តការ ឬបណ្តឹងទៅតុលាការឡើយ សន្ធានការីគ្រាន់តែអាចស្នើឡើងនូវដំណោះស្រាយចំពោះភាគីវិវាទតែប៉ុណ្ណោះ។[8]

នៅក្នុងដំណើរការសន្ធានកម្ម ជាធម្មតាសន្ធានការីមានតួនាទី ដូចជាស្តាប់ភាគីវិវាទនីមួយៗ លើកទឹកចិត្តភាគីនីមួយៗឱ្យស្តាប់ និងពិចារណាអំពីការស្រុះស្រួលគ្នា និងជួយស្វែងរកដំណោះស្រាយ ដែលប្រកបដោយគំនិតច្នៃប្រតិដ្ឋ ព្រមទាំងជួយឱ្យភាគីស្វែងយល់អំពីអង្គហេតុ អង្គច្បាប់ ដូចដែលអ្នកអព្យាក្រឹតម្នាក់មើលឃើញ និងបង្កើតចំណុចជាក់លាក់នៅក្នុងកិច្ចព្រមព្រៀងស្រុះស្រួល។

**១.២.២.៤. មជ្ឈត្តការ**

មជ្ឈត្តការ គឺជាវិធីសាស្ត្រដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការចម្បងមួយ។ នៅក្នុងមជ្ឈត្តការ គូភាគីដាក់វិវាទរបស់ខ្លួនជូនទៅភាគីទីបីដែលអព្យាក្រឹតមួយ ដែលជាទូទៅហៅថា "មជ្ឈត្តករ" ឬ ប្រសិនបើច្រើនជាងម្នាក់ហៅថា "ក្រុមមជ្ឈត្តករ" ឬ "វេទិកាមជ្ឈត្តកម្ម" ។ ភាគីទីបីនេះពិចារណាអំពីភស្តុតាងដែលភាគីវិវាទបានដាក់ជូន និងចេញសេចក្តីសម្រេចមួយហៅថា "មជ្ឈត្តវិនិច្ឆ័យ"។ ដូចដែលនឹងលើកយកមកពិភាក្សានៅក្នុងអត្ថបទខាងក្រោមនេះ មជ្ឈត្តវិនិច្ឆ័យជាទូទៅភ្ជាប់កាតព្វកិច្ចចំពោះគូភាគីទាំងអស់ យ៉ាងណាមិញក្នុងករណីខ្លះមជ្ឈត្តវិនិច្ឆ័យក៏អាចមិនភ្ជាប់កាតព្វកិច្ចចំពោះគូភាគីដែរ។

[8] Patterson, et al. កំណត់សម្គាល់ខាងលើលេខ៩ ទំព័រ៥៣ ។ សន្ធានកម្មក៏ត្រូវបានកំណត់និយមន័យផងដែរ ថាជា "ដំណើរការដែលនៅក្នុងនោះ អ្នកធ្វើអន្តរាគមន៍មិនលម្អៀងម្នាក់ជួយភាគីចរចាពីរ ឬច្រើន ឱ្យកំណត់ពីបញ្ហាកង្វល់ ហើយបន្ទាប់មកបង្កើតនូវវិធីនានា ដែលអាចទទួលយកបានទៅវិញទៅមក ដើម្បីដោះស្រាយកង្វល់ទាំងនោះ" ។

ជាទូទៅ មជ្ឈត្តការត្រូវបានចាត់ទុកថាជាវិធីសាស្ត្រដោះស្រាយវិវាទមួយដែលចងភ្ជាប់កាតព្វកិច្ច។ ភាគីវិវាទ ត្រូវបង្ហាញភស្តុតាងរបស់ខ្លួន ហើយមជ្ឈត្តករជាអ្នកចេញសេចក្តីសម្រេចមួយដែលចងភ្ជាប់កាតព្វកិច្ចលើគូភាគីវិវាទ។ ភាគីវិវាទត្រូវគោរពតាមសេចក្តីសម្រេច ហើយពួកគេមានសិទ្ធិក្នុងការប្តឹងឧបាស្រ័យក្នុងករណីមិនសុខចិត្ត។ សេចក្តីសម្រេចនេះអាចដាក់ឱ្យអនុវត្តដោយប្រព័ន្ធតុលាការសាធារណៈ។ នេះគឺជាទម្រង់នៃមជ្ឈត្តការទូទៅបំផុត ត្រូវបានហៅឈ្មោះតាមពាក្យបច្ចេកទេសថា "មជ្ឈត្តការភ្ជាប់កាតព្វកិច្ច" ប៉ុន្តែថ្មីៗនេះ មជ្ឈត្តការមិនភ្ជាប់កាតព្វកិច្ចក៏កំពុងក្លាយជាជម្រើសដ៏ពេញនិយមមួយផងដែរ។ មជ្ឈត្តការមិនភ្ជាប់កាតព្វកិច្ច គឺស្រដៀងគ្នានឹងមជ្ឈត្តការចងភ្ជាប់កាតព្វកិច្ចដែរ ដោយខុសគ្នាត្រង់ថាភាគីនីមួយៗអាចបដិសេធនូវសេចក្តីសម្រេចរបស់មជ្ឈត្តករក្នុងរយៈពេលដ៏ខ្លីមួយ ក្រោយពេលចេញសេចក្តីសម្រេចរួច។ មជ្ឈត្តការមិនភ្ជាប់កាតព្វកិច្ច ពេលខ្លះត្រូវបានប្រើប្រាស់ដើម្បីជួយរក្សាទំនាក់ទំនងរបស់ភាគីវិវាទ។ មជ្ឈត្តករអាចចេញសេចក្តីសម្រេចដែលមានលក្ខណៈជាជម្រើសជាជាងការអនុវត្តសេចក្តីសម្រេចដោយបង្ខំលើគូភាគីនោះ។ ភាគីវិវាទប្រើប្រាស់សេចក្តីសម្រេចនេះជាមធ្យោបាយចរចានៅក្នុងការដោះស្រាយវិវាទរបស់ខ្លួន។ ភាគីវិវាទក៏អាចទទួលយកសេចក្តីសម្រេចនេះបានដែរ ក្នុងករណីដែលសេចក្តីសម្រេចនោះឆ្លើយតបនឹងផលប្រយោជន៍របស់ខ្លួន។

មជ្ឈត្តការមិនភ្ជាប់កាតព្វកិច្ចស្រដៀងគ្នានឹងសន្ទានកម្មផងដែរ ព្រោះថាគឺជាដំណើរការបណ្តឹងតុលាការដោយសារតែវាមានផ្នែកមួយដែលជាការចរចាគ្នា ហើយតាមរយៈនោះ គូភាគីគឺជាអ្នកគ្រប់គ្រងលើដំណើរការនិងលទ្ធផលនៃការចរចានោះទាំងស្រុងផងដែរ។ ផ្ទុយមកវិញ មជ្ឈត្តការភ្ជាប់កាតព្វកិច្ចមាននិន្នាការដូចគ្នាទៅនឹងដំណើរការបណ្តឹងទៅតុលាការជាង សន្ទានកម្ម ដោយសារតែនីតិវិធីនេះមានការពាក់ព័ន្ធនឹងសេចក្តីសម្រេចចុងក្រោយ ដែលត្រូវធ្វើឡើងដោយភាគីអព្យាក្រឹត។

## ១.៣. ដំណើរការ និងការប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

### ១.៣.១. ប្រវត្តិរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

ដោយអនុលោមទៅតាមច្បាប់ស្តីពីមជ្ឈត្តការពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ត្រង់ជំពូកទី៣ បានកំណត់អំពីការបង្កើតឡើងនូវមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលជាស្ថាប័នមួយឯករាជ្យ នៅក្រោមការឧបត្ថម្ភរបស់ក្រសួងពាណិជ្ជកម្ម ក្នុងគោលបំណងដើម្បីជំរុញឱ្យមានការដោះស្រាយវិវាទពាណិជ្ជកម្មតាមរយៈការផ្សះផ្សា និងបង្កើតនូវរចនាសម្ព័ន្ធព្រមទាំងវិធានការចាំបាច់សម្រាប់ធ្វើការគ្រប់គ្រងរឿងមជ្ឈត្តការក្នុងព្រះរាជាណាចក្រកម្ពុជា នៅពេលដែលមានការព្រមព្រៀងគ្នាយ៉ាងជាក់ច្បាស់ណាមួយនៃភាគីវិវាទដាក់វិវាទទៅមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ។[9]

[9] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, លេខ នស/រកម/០៥០៦/០១០, ០៥ ឧសភា ២០០៦, មាត្រា១០

ម្យ៉ាងវិញទៀត បើយោងតាមអនុក្រឹត្យលេខ១២៤ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ដែលបានកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដោយសរសេរអក្សរកាត់ថា **ម.ជ.ម.** ដែលអង្គភាពនេះមិនស្វែងរកប្រាក់ចំណេញ និងមានទីស្នាក់ការនៅរាជធានីភ្នំពេញ។[10] យោងតាមអនុក្រឹត្យនេះ បានកំណត់អំពីតួនាទី និងភារកិច្ចរបស់មជ្ឈមណ្ឌល ដែលជាស្ថាប័នជាតិក្នុងការដោះស្រាយវិវាទណាមួយទាក់ទងនឹងវិស័យពាណិជ្ជកម្មនៅក្រៅប្រព័ន្ធតុលាការតាមបែបយន្តការមជ្ឈត្តការ និងជាទីកន្លែងសម្រាប់ធ្វើការបណ្ដុះបណ្ដាល និងហ្វឹកហ្វឺនបុគ្គលដែលកំពុងអនុវត្តនិងបុគ្គលដែលមានបំណងអនុវត្តវិជ្ជាជីវៈជាមជ្ឈត្តករ ដើម្បីធានាឱ្យមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាមានគុណភាព។ លើសពីនេះទៀតនោះ វាក៏ជាមជ្ឈមណ្ឌលផ្ដល់សេវាដោះស្រាយវិវាទផ្នែកពាណិជ្ជកម្មនៅក្រៅប្រព័ន្ធតុលាការ និងរៀបចំសិក្ខាសាលា វគ្គសិក្សា ធ្វើសន្និសីទថ្នាក់ជាតិ និងអន្តរជាតិ ក្នុងគោលដៅមួយជំរុញវិស័យមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ព្រមទាំងប្រមូលបោះពុម្ព ផ្សព្វផ្សាយព័ត៌មាន អត្ថបទនិពន្ធ សៀវភៅ និងឯកសារដែលទាក់ទងទៅនឹងមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។[11]

ការគោរពបាននូវភារកិច្ច និងតួនាទីតាមការកំណត់របស់មជ្ឈមណ្ឌលជាតិផ្នែកពាណិជ្ជកម្មវានាំឱ្យមានការជំរុញ និងជាការធានាបាននូវគុណភាពរបស់មជ្ឈត្តការពាណិជ្ជកម្ម ដែលជាហេតុបណ្ដាលឱ្យមានជំនឿជាក់ពីសំណាក់ភាគីវិវាទក៏ដូចជាពាណិជ្ជករ ដែលមានវិវាទផ្នែកពាណិជ្ជកម្មកាន់តែមានភាពជឿជាក់ និងផ្ដល់ឱ្យនូវសេចក្ដីទុកចិត្តទៅលើយន្តការមជ្ឈត្តការ ដោយសារតែយន្តការនេះមានប្រសិទ្ធភាព គុណភាព យុត្តិធម៌ត្រឹមត្រូវ ឯករាជ្យ និងប្រកបដោយភាពរហ័សក្នុងការដោះស្រាយ។

### ១.៣.២. រចនាសម្ព័ន្ធ និងការគ្រប់គ្រងមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

នៅក្នុងរចនាសម្ព័ន្ធនៃការគ្រប់គ្រងរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការពាណិជ្ជកម្មត្រូវបានបែងចែកចេញជា ០៦ ផ្នែកសំខាន់ៗ រួមមាន មហាសន្និបាត ក្រុមប្រឹក្សាប្រតិបត្តិ អគ្គលេខាធិការដ្ឋាន សមាជិក សវនកម្ម និងសាខារបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។

#### ១.៣.២.១. មហាសន្និបាត

មហាសន្និបាត គឺជាផ្នែកមួយដែលមានសិទ្ធិអំណាចកំពូលរបស់ ម.ជ.ម. ហើយមហាសន្និបាតប្រចាំឆ្នាំធ្វើឡើងតាមកាលបរិច្ឆេទកំណត់ដោយក្រុមប្រឹក្សាប្រតិបត្តិ និងអាចស្នើសុំបើកមហាសន្និបាតវិសាមញ្ញបានដោយភ្ជាប់មកនូវរបៀបវារៈក្នុងរយៈពេលយ៉ាងតិច ១៥ (ដប់ប្រាំ) ថ្ងៃ មុនថ្ងៃប្រជុំ ព្រោះមហាសន្និបាតវិសាមញ្ញនេះត្រូវពិចារណាតែលើបញ្ហាណាដែលមិនបានលើកឡើង ឬដោះស្រាយក្នុងមហាសន្និបាតប្រចាំឆ្នាំដែលបានធ្វើ

[10] អនុក្រឹត្យស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ម.ជ.ម., លេខ ១២៤ អនក្រ.បក, ១២ សីហា ២០០៩, មាត្រា១

[11] អនុក្រឹត្យស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ម.ជ.ម., លេខ ១២៤ អនក្រ.បក, ១២ សីហា ២០០៩, មាត្រា២

ឡើងរួចហើយតែប៉ុណ្ណោះ។ មហាសន្និបាតប្រចាំឆ្នាំត្រូវមានការជូនដំណឹងយ៉ាងតិច ៣០ (សាមសិប) ថ្ងៃ មុនថ្ងៃប្រជុំដោយរួមទាំងមានការបញ្ជាក់ពីរបៀបវារៈ កាលបរិច្ឆេទ និងទីកន្លែងផងដែរ។[12]

មហាសន្និបាតនេះ អាចធ្វើឡើងទៅបានលុះត្រាតែមានវត្តមានសមាជិក ២/៣ (ពីរភាគបី) នៃសមាជិកទាំងអស់ ហើយបញ្ហាផ្សេងៗដែលត្រូវបានលើកយកមកពិភាក្សាត្រូវសម្រេចដោយសំឡេងភាគច្រើនដាច់ខាត។ ក្នុងករណីមិនមានកូរ៉ុមដើម្បីដំណើរការមហាសន្និបាត កិច្ចប្រជុំនេះត្រូវពន្យារយៈពេលចំនួន ១៤ (ដប់បួន) ថ្ងៃ ហើយកូរ៉ុមសម្រាប់កិច្ចប្រជុំលើកទីពីរនេះគឺ ១/២ (មួយភាគពីរ) នៃសមាជិកទាំងអស់គិតទាំងសមាជិកផ្ទេរសិទ្ធិ។ ក្នុងករណីដែលកិច្ចប្រជុំលើកទីពីរពុំមានកូរ៉ុម មហាសន្និបាតត្រូវពន្យារយៈពេលចំនួន ១៤ (ដប់បួន) ថ្ងៃទៀត ហើយប្រសិនបើនៅតែគ្មានកូរ៉ុមនៅក្នុងកិច្ចប្រជុំនេះទៀត ចំនួនអ្នកចូលរួមក្នុងកិច្ចប្រជុំដែលត្រូវពន្យារពេលជាលើកទីពីរនោះ ត្រូវចាត់ទុកថាជាកូរ៉ុមដើម្បីចាប់ផ្តើមមហាសន្និបាត។[13] នៅក្នុងនោះផងដែរ មហាសន្និបាតប្រចាំឆ្នាំត្រូវបានលើកយកបញ្ហាមួយចំនួនមកពិនិត្យ និងអនុម័តមានជារួមដូចជា៖

- របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ និងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាប្រតិបត្តិ
- គម្រោងថវិកាប្រចាំឆ្នាំរបស់ ម.ជ.ម.
- ការបោះឆ្នោតជ្រើសតាំង និងដកហូតសមាជិកក្រុមប្រឹក្សាប្រតិបត្តិ
- បទបញ្ជាផ្ទៃក្នុងនិងវិធាន ដែលទាក់ទងនឹងការដោះស្រាយវិវាទផ្នែកពាណិជ្ជកម្ម
- ការកែប្រែនូវបទប្បញ្ញត្តិនានា ដែលទាក់ទងនឹងដំណើរការរបស់ ម.ជ.ម.
- បែបបទហិរញ្ញវត្ថុ និងរដ្ឋបាលសម្រាប់ការគ្រប់គ្រងដំណើរការរបស់ ម.ជ.ម.
- នីតិវិធីសម្រាប់ការចុះបញ្ជីមជ្ឈត្តករ
- លក្ខណៈសម្បត្តិបន្ថែមសម្រាប់ឱ្យធ្វើជាមជ្ឈត្តករនៅ ម.ជ.ម.
- ក្រមសីលធម៌សម្រាប់មជ្ឈត្តករ។[14]

#### ១.៣.២.២. ក្រុមប្រឹក្សាប្រតិបត្តិ

មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មត្រូវបានគ្រប់គ្រងដោយក្រុមប្រឹក្សាប្រតិបត្តិ ដែលត្រូវមានសមាជិកជាចំនួនសេសមិនលើសពី ៧ (ប្រាំពីរ) រូប និងមិនតិចជាង៥ (ប្រាំ) រូបបានឡើយ ហើយមុនពេលបញ្ចប់អាណត្តិនីមួយៗ មានរយៈពេល៣ (បី) ឆ្នាំ មហាសន្និបាតអាចសម្រេចកំណត់ចំនួនសមាជិកក្រុមប្រឹក្សាប្រតិបត្តិសម្រាប់អាណត្តិបន្ទាប់។ នៅក្នុងសមាជិករបស់ក្រុមប្រឹក្សាប្រតិបត្តិ មានដូចជា៖

[12] អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ ម.ជ.ម., លេខ ១២៤ អនក្រ.បក, ១២ សីហា ២០០៩, មាត្រា៤

[13] អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ ម.ជ.ម., លេខ ១២៤ អនក្រ.បក, ១២ សីហា ២០០៩, មាត្រា៦

[14] អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ ម.ជ.ម., លេខ ១២៤ អនក្រ.បក, ១២ សីហា ២០០៩, មាត្រា៥

- ប្រធានក្រុមប្រឹក្សាប្រតិបត្តិ និងជាប្រធាន ម.ជ.ម.
- អនុប្រធានក្រុមប្រឹក្សាប្រតិបត្តិ និងជាអនុប្រធាន ម.ជ.ម.
- ហេរញ្ញិក
- សមាជិកមួយចំនួន
- ជាសមាជិក និងជាតំណាងសមាគមសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា។[15]

ម្យ៉ាងវិញទៀត បើយើងក្រឡេកទៅមើលពីតួនាទីរបស់ក្រុមប្រឹក្សាប្រតិបត្តិវិញនោះ ឃើញថាមានតួនាទីជាអ្នកគ្រប់គ្រង និងសម្រេចការងារប្រចាំថ្ងៃព្រមទាំងបង្កើត និងអនុម័តគោលនយោបាយរបស់ ម.ជ.ម. ផងដែរ។ លើសពីនេះទៀតនោះ ក្រុមប្រឹក្សាប្រតិបត្តិបំពេញតួនាទីជាអ្នករៀបចំតាក់តែង ពិនិត្យ និងកែប្រែវិធាន នីតិវិធីនានារបស់ ម.ជ.ម. ឱ្យកាន់តែមានប្រសិទ្ធភាព ហើយក៏ជាអ្នកចូលរួមរៀបចំ និងត្រួតពិនិត្យសកម្មភាពបណ្តុះបណ្តាលអភិវឌ្ឍវិជ្ជាជីវៈសម្រាប់មជ្ឈត្តករបស់ ម.ជ.ម.។

លើសពីនេះទៀតនោះ ក្រុមប្រឹក្សាប្រតិបត្តិក៏ជាអ្នកបង្កើត អនុម័ត កែប្រែ វិសោធនកម្មនូវវិធាន និងនីតិវិធីនានាសម្រាប់ពិនិត្យពិច័យលើទម្រង់នៃមជ្ឈត្តវិនិច្ឆ័យនៃសំណុំរឿងដែលគ្រប់គ្រងដោយ ម.ជ.ម. ជាពិសេសពិនិត្យ និងតាមដានស្ថានភាពហិរញ្ញវត្ថុរបស់ ម.ជ.ម. ដោយផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ ដែលត្រូវរៀបចំដោយអគ្គលេខាធិការស្របតាមវិធានជាធរមានអនុវត្តចំពោះដំណើររដ្ឋបាលនិងហិរញ្ញវត្ថុ ដើម្បីជួយដល់ការបំពេញតួនាទីនិងភារកិច្ច ក្រុមប្រឹក្សាប្រតិបត្តិត្រូវបង្កើតគណៈកម្មាធិការចំណុះមួយចំនួនរួមមានដូចជា គណៈកម្មាធិការតែងតាំងនិងនីតិវិធី គណៈកម្មាធិការវិន័យនិងគណៈកម្មាធិការអប់រំនិងបណ្តុះបណ្តាល គណៈកម្មាធិការសមាជិកភាពដែលមានតួនាទី និងសមាសភាពដូចមានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុង។[16]

ចំពោះការតែងតាំង និងការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាប្រតិបត្តិ កើតឡើងពីមហាសន្និបាតប្រចាំឆ្នាំ ដែលត្រូវបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាប្រតិបត្តិចេញពីសមាជិករបស់ ម.ជ.ម. ដែលមានសិទ្ធិបោះឆ្នោតសម្រាប់អាណត្តិរយៈពេល ៣ (បី) ឆ្នាំ ហើយសមាជិកក្រុមប្រឹក្សាប្រតិបត្តិមិនអាចបំពេញមុខងារក្នុងក្រុមប្រឹក្សាប្រតិបត្តិលើសពី ២ (ពីរ) អាណត្តិបានឡើយ លើកលែងតែមុខតំណែងជាហិរញ្ញិក ដែលអាចត្រូវបានជ្រើសរើសសម្រាប់រយៈពេល ២ (ពីរ) អាណត្តិជាប់ៗគ្នា។ សមាជិកជាមជ្ឈត្តករ ឬសមាជិកជានីតិបុគ្គលអាចឈរឈ្មោះសម្រាប់ការបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សាប្រតិបត្តិ ហើយគណៈកម្មការរៀបចំការបោះឆ្នោតត្រូវរាយនាមបេក្ខជនតាមលំដាប់ព្យញ្ជនៈនៃភាសាឡាតាំងតម្រៀបទន្ទឹមនឹងឈ្មោះជាភាសាខ្មែរ។ បេក្ខជនដែលទទួលបានសំឡេងឆ្នោតច្រើនបំផុត និងដែលមានចំនួនស្មើនឹងចំនួនតំណែងក្នុងក្រុមប្រឹក្សាប្រតិបត្តិត្រូវបានចាត់

[15] សេចក្តីប្រកាសព័ត៌មានរបស់ ម.ជ.ម. ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២

[16] បទបញ្ជាផ្ទៃក្នុងរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១, ប្រការ២៥

ទុកថាបានជាប់ឆ្នោត ប៉ុន្តែប្រសិនបើបញ្ជីបេក្ខជនដែលជាប់ឆ្នោតមិនអាចកំណត់បាន ដោយសារតែមានបេក្ខជន ២ (ពីរ) ឬច្រើនរូបបានទទួលសំឡេងឆ្នោតស្មើគ្នា កិច្ចប្រជុំមហាសន្និបាតប្រចាំឆ្នាំដដែលនោះ ត្រូវរៀបចំបោះឆ្នោតជាលើកទីពីរសម្រាប់បេក្ខជនដែលទទួលបានសំឡេងបោះឆ្នោតស្មើៗគ្នានោះ។ ក្នុងករណី បេក្ខជននៅតែទទួលបានសំឡេងឆ្នោតស្មើគ្នាក្នុងការបោះឆ្នោតជាលើកទីពីរ បេក្ខជនដែលមានអាយុច្រើនជាងគេនឹងត្រូវបានជ្រើសរើស ចំពោះបេក្ខជនជានីតិបុគ្គលអាយុរបស់អ្នកតំណាងគឺជាកត្តាកំណត់។ គណៈកម្មការត្រូវតែប្រកាសលទ្ធផលនៃការបោះឆ្នោតភ្លាមៗក្នុងកិច្ចប្រជុំមហាសន្និបាត និងបន្ទាប់មកត្រូវជូនដំណឹងទៅសមាជិកទាំងអស់របស់ ម.ជ.ម. ក៏ដូចជាសាធារណជនអំពីលទ្ធផលនេះ។ ដោយអនុលោមតាមវិធានស្តីពីការបោះឆ្នោតដែលបានអនុម័តដោយក្រុមប្រឹក្សាប្រតិបត្តិ សមាជិកក្រុមប្រឹក្សាប្រតិបត្តិដែលទើបត្រូវបានបោះឆ្នោតថ្មីត្រូវចូលកាន់តំណែងក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីបានការបញ្ជាក់ពីការបោះឆ្នោត។[17]

ចំណែកការបញ្ចប់សមាជិកភាពជារូបវន្តបុគ្គលនៃសមាជិកក្រុមប្រឹក្សាប្រតិបត្តិ ក្នុងករណីមួយចំនួនដែលមានដូចជាសមាជិកទាំងឡាយណាបានក្លាយជាអសមត្ថជនផ្នែកខាងរូបរាងកាយ ឬសតិស្មារតីដោយមិនអាចបំពេញនូវតួនាទីរបស់ខ្លួនបាន ហើយក្នុងករណីផ្សេងទៀតដូចជា សមាជិកទាំងនោះត្រូវបានផ្តន្ទាទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋ។ មិនត្រឹមតែប៉ុណ្ណោះ ក្នុងករណីអវត្តមានពីកិច្ចប្រជុំ ៣ (បី) ដងជាប់ៗ គ្នាដោយគ្មានមូលហេតុសមរម្យ ឬត្រូវបានតុលាការប្រកាសថាត្រូវបានក្ស័យធន ឬបានសុំលាឈប់ជាលាយលក្ខណ៍អក្សរពីក្រុមប្រឹក្សាប្រតិបត្តិ ឬលែងជាសមាជិករបស់ ម.ជ.ម. ឬបានទទួលមរណភាព។ ដូច្នេះសមាជិកទាំងនោះ ដែលជាសមាជិកជាមជ្ឈត្តករត្រូវចេញពីតំណែងរបស់ខ្លួន។ រីឯសមាជិកនៃក្រុមប្រឹក្សាប្រតិបត្តិ ជាសមាជិកនីតិបុគ្គលត្រូវចេញពីតំណែងរបស់ខ្លួននៅក្នុងករណីមួយចំនួនដូចជា ត្រូវបានផ្តន្ទាទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋ អវត្តមានពីកិច្ចប្រជុំ ៣ ដងជាប់ៗគ្នាដោយគ្មានមូលហេតុសមរម្យ ឬត្រូវប្រកាសក្ស័យធនដោយតុលាការ ឬត្រូវដាក់ឱ្យស្ថិតនៅក្រោមដំណើរការនៃការជម្រះបញ្ជី ឬសុំលាឈប់ដោយជាលាយក្ខណ៍អក្សរពីក្រុមប្រឹក្សាប្រតិបត្តិ ឬលែងជាអ្នកតំណាងរបស់សមាជិកជានីតិបុគ្គល ឬលែងជាសមាជិករបស់ ម.ជ.ម.។[18]

**១.៣.២.៣. អគ្គលេខាធិការដ្ឋាន**

អគ្គលេខាធិការដ្ឋាននៃ ម.ជ.ម. គឺជាសេនាធិការមួយរបស់ក្រុមប្រឹក្សាប្រតិបត្តិ ដែលត្រូវបានដឹកនាំដោយអគ្គលេខាធិការមួយរូប អមដោយអគ្គលេខាធិការរងមួយចំនួនជាជំនួយការ ដែលត្រូវជ្រើសរើសដោយក្រុមប្រឹក្សាប្រតិបត្តិ។ អគ្គលេខាធិការដ្ឋានអនុវត្តតួនាទីដែលមានចែងក្នុងបទបញ្ជាផ្ទៃក្នុង រួមមានការគ្រប់គ្រងសំណុំរឿងមជ្ឈត្តការ កិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ ទំនាក់ទំនងសាធារណៈ និងការផ្តល់ការបណ្តុះបណ្តាល។

[17] បទបញ្ជាផ្ទៃក្នុងរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១, ប្រការ២៦

[18] បទបញ្ជាផ្ទៃក្នុងរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១, ប្រការ៣០

ក្រុមការងារអគ្គលេខាធិការដ្ឋានរបស់ ម.ជ.ម. ប្រមូលផ្តុំដោយបុគ្គលដែលមានឆន្ទៈខ្ពស់ក្នុងការបំពេញការងារ ប្រកបដោយចំណេះដឹង និងជំនាញច្បាស់លាស់ ព្រមទាំងសមត្ថភាពក្នុងការប្រើប្រាស់ភាសាបរទេសជាច្រើនផងដែរ។ នៅក្នុងអគ្គលេខាធិការដ្ឋានបច្ចុប្បន្ន ត្រូវបានដឹកនាំដោយ៖ អគ្គលេខាធិការ មន្រ្តីផ្នែកច្បាប់ និងជំនួយការផ្នែកច្បាប់ផងដែរ។[19]

លើសពីនេះទៅទៀត អគ្គលេខាធិការក៏មានតួនាទី និងភារកិច្ចគ្រប់គ្រងលើការងារនិងសកម្មភាពប្រចាំថ្ងៃរបស់ ម.ជ.ម. ព្រមទាំងអនុវត្តគោលនយោបាយដែលក្រុមប្រឹក្សាប្រតិបត្តិបានដាក់ចេញ រួមទាំងជាអ្នករៀបចំកិច្ចប្រជុំរបស់ក្រុមប្រឹក្សាប្រតិបត្តិ មហាសន្និបាត និងកិច្ចការផ្សេងៗទៀតដូចជាការរក្សាឯកសារ ប្រមូលព័ត៌មានដែលពាក់ព័ន្ធនឹងសកម្មភាពមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។ ជាពិសេស អគ្គលេខាធិការក៏ជាអ្នកផ្តួចផ្តើមគំនិតលើកិច្ចការថ្មីៗ រៀបចំសកម្មភាព ឬគម្រោងនានាដែលជួយទ្រទ្រង់តួនាទីរបស់ ម.ជ.ម. ហើយផ្តល់សេវាផ្នែកលេខាធិការដល់សមាជិក ដោយយកកម្រៃសេវាតាមលក្ខខណ្ឌដែលអនុម័តដោយក្រុមប្រឹក្សាប្រតិបត្តិព្រមទាំងជាអ្នកកាន់កាប់គេហទំព័ររបស់ ម.ជ.ម. និងរៀបចំបណ្តុះបណ្តាលផងដែរ។[20]

**១.៣.២.៤. សមាជិកភាពនៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម**

នៅក្នុងករណីបុគ្គលទាំងឡាយណា ដែលចង់ក្លាយខ្លួនជាសមាជិកភាពនៃ ម.ជ.ម. បុគ្គលទាំងឡាយនោះត្រូវមានការចុះបញ្ជីជាមជ្ឈត្តករនៅ ម.ជ.ម. ហើយរាល់ពាក្យសុំចុះឈ្មោះទាំងអស់ត្រូវដាក់ជូនទៅកាន់ក្រុមប្រឹក្សាប្រតិបត្តិ ព្រមទាំងភ្ជាប់មកជាមួយនូវឯកសារផ្សេងៗ តាមតម្រូវការរបស់ក្រុមប្រឹក្សាប្រតិបត្តិ និងបង់ភាគទានតាមការកំណត់របស់ ម.ជ.ម. ។[21]

ដើម្បីចុះបញ្ជីជាសមាជិកមជ្ឈត្តករបាន រូបវន្តបុគ្គលដែលមានសញ្ជាតិខ្មែរ ឬបរទេស អាចដាក់ពាក្យសុំធ្វើជាមជ្ឈត្តករជាមួយ ម.ជ.ម. បើសិនជារូបវន្តបុគ្គលនោះ មានលក្ខណសម្បត្តិដូចខាងក្រោម៖

- មានអាយុយ៉ាងតិច ៣០ (សាមសិប) ឆ្នាំ។
- មានសញ្ញាបត្របរិញ្ញាបត្រណាមួយ ក្រោយពីបានបញ្ចប់ការសិក្សានៅតាមសកលវិទ្យាល័យណាមួយក្នុងព្រះរាជាណាចក្រកម្ពុជា ឬនៅបរទេស។
- បានឆ្លងកាត់វគ្គបណ្តុះបណ្តាលផ្នែកមជ្ឈត្តការផ្នែកពាណិជ្ជកម្មជាមួយ ម.ជ.ម. ឬវគ្គបណ្តុះបណ្តាលដែលរៀបចំដោយស្ថាប័នវិជ្ជាជីវៈមជ្ឈត្តការផ្នែកពាណិជ្ជកម្មណាមួយ ទទួលស្គាល់ដោយ ម.ជ.ម. ។

---

[19] ដកស្រង់ចេញពីគេហទំព័រ https://ncac.org.kh/general-secretariat/, ចូលមើលថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២២

[20] អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ ម.ជ.ម., លេខ ១២៤ អនក្រ.បក, ១២ សីហា ២០០៩, មាត្រា២៦

[21] អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ ម.ជ.ម., លេខ ១២៤ អនក្រ.បក, ១២ សីហា ២០០៩, មាត្រា២៥

- បានប្រឡងជាប់ការប្រឡងដែលរៀបចំឡើងដោយ ម.ជ.ម. ឬស្ថាប័នវិជ្ជាជីវៈមជ្ឈត្តការផ្នែកពាណិជ្ជកម្មណាមួយ ដែលទទួលស្គាល់ដោយ ម.ជ.ម.។

ប្រសិនបើពុំមានលក្ខណៈសម្បត្តិទាំងអស់ដូចករណីខាងលើទេនោះ រូបវន្តបុគ្គលអាចត្រូវបានចុះបញ្ជីជាសមាជិកជាមជ្ឈត្តករ ក្នុងករណីណារូបវន្តបុគ្គលនោះមានលក្ខណៈសម្បត្តិធ្លាប់ធ្វើជាសមាជិក ដែលបានចុះបញ្ជីត្រឹមត្រូវជាមជ្ឈត្តករយ៉ាងតិច ២ (ពីរ) ឆ្នាំ នៅស្ថាប័នវិជ្ជាជីវៈមជ្ឈត្តការផ្នែកពាណិជ្ជកម្មណាមួយ ដែលទទួលស្គាល់ដោយ ម.ជ.ម. ឬធ្លាប់ជាមជ្ឈត្តករ ឬអ្នកតំណាងក្នុងរឿងដំណើរការមជ្ឈត្តការផ្នែកពាណិជ្ជកម្មចាប់ពី ៣ (បី) សំណុំរឿងវិវាទឡើងទៅ ឬបានសរសេរមជ្ឈត្តវិនិច្ឆ័យផ្នែកពាណិជ្ជកម្មចំនួនយ៉ាងតិច ៣ (បី) ក្នុងពេលដែលបុគ្គលនោះធ្វើជាមជ្ឈត្តករ។ ចំពោះរូបវន្តបុគ្គល ដែលមានលក្ខណៈសម្បត្តិបែបនេះត្រូវប្រឡងជាប់ការប្រឡងដែលរៀបចំឡើងដោយ ម.ជ.ម. ឬដោយស្ថាប័នវិជ្ជាជីវៈផ្នែកមជ្ឈត្តការផ្នែកពាណិជ្ជកម្មណាមួយទទួលស្គាល់ដោយ ម.ជ.ម. ឬក៏មានវិញ្ញាបនបត្រចុះបញ្ជីជាមជ្ឈត្តករនៅ ម.ជ.ម. និងបានរក្សាសមាជិកភាពជាមជ្ឈត្តករនៅ ម.ជ.ម. យ៉ាងតិចណាស់ ២ (ពីរ) ឆ្នាំ ជាប់គ្នាគិតពីថ្ងៃចុះបញ្ជី។ ផ្ទុយទៅវិញ សមាជិកភាពមិនត្រូវជា មន្ត្រីរាជការ ឬស្ថិតនៅក្នុងឋានានុក្រមជាមន្ត្រីនៃស្ថាប័ននីតិប្រតិបត្តិ ឬស្ថាប័ននីតិបញ្ញត្តិ ឬតុលាការនោះឡើយ។

លើសពីនេះទៀតនោះ នៅពេលដែលរូបវន្តបុគ្គលបានក្លាយជាខ្លួនជាសមាជិកជាមជ្ឈត្តករហើយនោះមានសិទ្ធិទទួលបានឈ្មោះជាមជ្ឈត្តករដែលបានចុះបញ្ជីនៅ ម.ជ.ម. អាចចូលរួមកិច្ចប្រជុំមហាសន្និបាត និងបោះឆ្នោតលើបញ្ហានានា ដែលត្រូវបានលើកមកពិភាក្សាក្នុងកិច្ចប្រជុំនោះ។ ម្យ៉ាងទៀតនោះ ក្លាយជាសមាជិកនៃគណៈកម្មាធិការណាមួយ និងអាចបម្រើការក្នុងក្រុមប្រឹក្សាប្រតិបត្តិ ឬក្នុងផ្នែកណាមួយនៃ ម.ជ.ម. ព្រមទាំងអាចធ្វើសកម្មភាពនានាដែលបានចែងក្នុងច្បាប់ស្ដីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។[22]

សមាជិក ម.ជ.ម. ត្រូវបាត់បង់សមាជិកភាពរបស់ខ្លួន ក្នុងករណីណាមួយដូចខាងក្រោមនេះ៖

- មិនបានបន្តចុះបញ្ជីជាមជ្ឈត្តករជាមួយ ម.ជ.ម. តាមការកំណត់
- ក្លាយជាអសមត្ថជនផ្នែករូបរាងកាយនិងសតិស្មារតី ដែលពុំអាចបំពេញមុខងាររបស់ខ្លួនបាន
- ត្រូវបានវិនិច្ឆ័យថា ក្ស័យធន ឬត្រូវដាក់ឱ្យជម្រះបញ្ជី
- សុំលាលែងជាលាយលក្ខណ៍អក្សរទៅកាន់ ម.ជ.ម.
- ត្រូវបានផ្ដន្ទាទោសពីបទមជ្ឈិម ឬឧក្រិដ្ឋ
- បានរំលោភបំពានលើក្រមសីលធម៌របស់មជ្ឈត្តករនិងបទបញ្ជាផ្ទៃក្នុង
- ទទួលមរណភាព និងខកខានមិនបានបង់ភាគទានតាមការកំណត់

[22] បទបញ្ជាផ្ទៃក្នុងរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១, ប្រការ១២

ការបាត់បង់សមាជិកភាពនេះត្រូវសម្រេចដោយក្រុមប្រឹក្សាប្រតិបត្តិ។[23] ក្នុងករណីក្រុមប្រឹក្សាប្រតិបត្តិសម្រេចដកហូតសមាជិកភាពពី ម.ជ.ម. ក្រុមប្រឹក្សាត្រូវផ្តល់ហេតុផលណាមួយជាលាយលក្ខណ៍អក្សរ ប្រសិនបើសាមីខ្លួនមិនសុខចិត្តនឹងសេចក្តីសម្រេចនេះ សមាជិកនោះមានសិទ្ធិប្តឹងទៅសាលាឧទ្ធរណ៍។[24]

**១.៣.២.៥. សវនកម្ម**

ក្រុមហ៊ុនសវនកម្មដែលទទួលបានការអនុម័តយល់ព្រមពីមហាសន្និបាត ត្រូវបានជ្រើសតាំងជាសវនកររបស់ ម.ជ.ម. សម្រាប់រយៈពេល ០១ ឆ្នាំ ហើយអាចត្រូវបានជ្រើសតាំងសារជាថ្មីទៀតបាន។ ចំណែកឯ សវនករមានតួនាទី និងភារកិច្ចក្នុងការធ្វើសវនកម្មប្រចាំឆ្នាំ និងបង្ហាញនូវរបាយការណ៍សវនកម្មរបស់ខ្លួននៅក្នុងមហាសន្និបាតប្រចាំឆ្នាំ និងអាចធ្វើសវនកម្មតាមការស្នើសុំរបស់ប្រធាន ម.ជ.ម. សម្រាប់រយៈពេលណាមួយ និងគ្រប់ពេលវេលានៅអំឡុងពេលនៃកិច្ចសន្យា ហើយត្រូវធ្វើរបាយការណ៍ជូនក្រុមប្រឹក្សាប្រតិបត្តិ។ រីឯសមាជិកនិងបុគ្គលិកគ្រប់រូបមានកាតព្វកិច្ចផ្តល់ព័ត៌មាន និងសេចក្តីពន្យល់នានា ដែលតម្រូវដោយសវនករ។[25] លើសពីនេះទៀត អាជ្ញាធរសវនកម្មជាតិក៏មានសិទ្ធិអំណាចពេញលេញក្នុងការធ្វើសវនកម្មបានផងដែរ ទៅលើមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ព្រោះថា ម.ជ.ម. គឺជាគ្រឹះស្ថានសាធារណៈ ស្ថិតក្រោមការឧបត្ថម្ភគាំទ្រពីក្រសួងពាណិជ្ជកម្ម ដែលជាសេនាធិការមួយរបស់រាជរដ្ឋាភិបាល។ ដោយយោងតាមមូលហេតុនេះហើយ អាជ្ញាធរសវនកម្មជាតិអាចធ្វើសវនកម្មលើមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មបាន។

**១.៣.២.៦. សាខារបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម**

បើយើងនិយាយអំពីសាខារបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម យើងឃើញថាមិនទាន់មានភាពទូលំទូលាយនោះទេ ប៉ុន្តែនៅក្នុងបទប្បញ្ញត្តិ ម.ជ.ម. អាចបង្កើតសាខារបស់ខ្លួនបាននៅតាមបណ្តាខេត្តនានានៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបង្កើតការរៀបចំនិងការប្រព្រឹត្តទៅរបស់សាខានីមួយៗ ត្រូវបានកំណត់ដោយសេចក្តីសម្រេចរបស់ ម.ជ.ម.។[26] គោលបំណងនៅក្នុងការបង្កើតសាខារបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនេះ ដើម្បីផ្តល់នូវភាពងាយស្រួល និងភាពរហ័សទាន់ចិត្តក្នុងការដោះស្រាយវិវាទដែលទាក់ទងជាមួយផ្នែកពាណិជ្ជកម្មនៅតាមបណ្តាមូលដ្ឋាននានាក្នុងព្រះរាជាណាចក្រកម្ពុជា។

**១.៣.៣. ប្រភពធនធាន**

ប្រភពធនធានរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មមានចំនួន ៣ (បី) សំខាន់ៗ មានដូចជាការភាគទានរបស់សមាជិក អំណោយនិងវិភាគទានពីប្រភពផ្សេងៗ និងកម្រៃសេវាផ្នែករដ្ឋបាលរបស់ខ្លួន។

---

[23] អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ ម.ជ.ម., លេខ ១២៤ អនក្រ.បក, ១២ សីហា ២០០៩, មាត្រា៣៥

[24] អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ ម.ជ.ម., លេខ ១២៤ អនក្រ.បក, ១២ សីហា ២០០៩, មាត្រា៣៦

[25] អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ ម.ជ.ម., លេខ ១២៤ អនក្រ.បក, ១២ សីហា ២០០៩, មាត្រា៤០

[26] អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ ម.ជ.ម., លេខ ១២៤ អនក្រ.បក, ១២ សីហា ២០០៩, មាត្រា៤១

ប្រភពដែលបានមកពីការបង់ភាគទានរបស់សមាជិក ត្រូវបានធ្វើឡើងជារៀងរាល់ឆ្នាំតាមការកំណត់របស់មហាសន្និបាតដែលបានស្នើដោយក្រុមប្រឹក្សាប្រតិបត្តិ ភាគទានត្រូវបង់ជាមុនក្នុងអំឡុងខែទីមួយរៀងរាល់ឆ្នាំ។ ប្រសិនក្នុងករណីដែលសមាជិកណាមួយមានភាពយឺតយ៉ាវក្នុងការបង់ភាគទានប្រចាំឆ្នាំ ឬវិភាគទានដទៃទៀតនោះ ហេរញ្ញិកត្រូវក្រើនរំឭកជាបន្ទាន់ដល់សមាជិកនោះ។ ប្រសិនណាបើសមាជិកណាម្នាក់មានការយឺតយ៉ាវក្នុងការបង់ភាគទានប្រចាំឆ្នាំ លើសពី ៣ (បី) ខែ ចាប់ពីខែទីពីរ សមាជិកនោះត្រូវបានបាត់បង់សមាជិកភាពរបស់ខ្លួនដោយស្វ័យប្រវត្តិ។ លើសពីនេះទៅទៀត ម.ជ.ម. អាចបង្កើតមូលនិធិបន្ថែមនានាសម្រាប់គោលបំណងពិសេសណាមួយ ដែលអាចប្រមូលពីសមាជិកបាន។ ក្នុងករណីនេះ អាចធ្វើទៅបាន លុះត្រាណាតែមានសំឡេងយល់ព្រមពីមហាសន្និបាតរបស់សមាជិកលើសពី៥០ (ហាសិប) ភាគរយនៃសមាជិកដែលមានវត្តមាននៅក្នុងមហាសន្និបាត។[27]

បន្ថែមពីលើនេះទៀតនោះ ភាគទានប្រចាំឆ្នាំត្រូវបានចែកជាបួនយ៉ាងមានដូចជាភាគទានប្រចាំឆ្នាំរបស់សមាជិកជាមជ្ឈត្តករ សមាជិកជានីតិបុគ្គល សមាជិកគាំទ្រជារូបវន្តបុគ្គល និងសមាជិកគាំទ្រជានីតិបុគ្គល ដែលត្រូវបានកំណត់ និងកែប្រែដោយមហាសន្និបាត។ វាគឺជារឿងមួយ ធ្វើយ៉ាងណាស្របទៅតាមតម្រូវការ និងស្ថេរភាពផ្នែកហិរញ្ញវត្ថុ។ ចំពោះភាគទានប្រចាំឆ្នាំរបស់ ម.ជ.ម. សម្រាប់សមាជិកជានីតិបុគ្គលត្រូវមានតម្លៃពីរដងនៃភាគទានប្រចាំឆ្នាំរបស់សមាជិកជាមជ្ឈត្តករ និងភាគទានប្រចាំឆ្នាំរបស់ ម.ជ.ម. ក្នុងន័យនេះសមាជិកគាំទ្រជានីតិបុគ្គល ត្រូវមានតម្លៃពីរដងនៃភាគទានប្រចាំឆ្នាំរបស់សមាជិកគាំទ្រជារូបវន្តបុគ្គល។[28]

មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មក៏អាចទទួលអំណោយ ឬជំនួយផ្សេងៗពីមជ្ឈដ្ឋាននានាដូចជាស្ថាប័ន អង្គការ ឬអង្គភាពផ្សេងៗ ដើម្បីឧបត្ថម្ភគាំទ្រដល់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ធ្វើយ៉ាងណាដើម្បីផ្តល់នូវភាពងាយស្រួលរលូនទៅមុខប្រកបដោយប្រសិទ្ធភាព និងរហ័សទាន់ចិត្តក្នុងការដោះស្រាយវិវាទដែលទាក់ទងជាមួយផ្នែកពាណិជ្ជកម្មនៅកម្ពុជា។ មួយវិញទៀត ប្រភពធនធានរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មក៏ទទួលបានអំពីកម្រៃសេវានានា ដែលទាក់ទងជាមួយកម្រៃសេវាមជ្ឈត្តកម្ម កម្រៃសេវាចុះបញ្ជីសំណុំរឿង កម្រៃសេវាពាក្យសុំនានា កម្រៃសេវារដ្ឋបាល កម្រៃសេវាតែងតាំងមជ្ឈត្តករ និងកម្រៃសេវានានាសម្រាប់នីតិវិធីមជ្ឈត្តករបន្ទាន់។

[27] អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ ម.ជ.ម., លេខ ១២៤ អនក្រ.បក, ១២ សីហា ២០០៩, មាត្រា៤៣

[28] បទបញ្ជាផ្ទៃក្នុងរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១, ប្រការ១៧

# ជំពូកទី២
# នីតិវិធីនៃការដោះស្រាយវិវាទ
# ពាណិជ្ជកម្មតាមយន្តការមជ្ឈត្តការ

# ជំពូកទី២

# នីតិវិធីនៃការដោះស្រាយវិវាទពាណិជ្ជកម្មតាមយន្តការមជ្ឈត្តការ

## ២.១. សន្និសីទអំពីការគ្រប់គ្រងចាត់ចែងសំណុំរឿង

សន្និសីទអំពីការគ្រប់គ្រងចាត់ចែងសំណុំរឿងបានផ្ដល់ឱ្យនូវយន្តការសម្រាប់កំណត់នូវលក្ខណៈ និងរបៀបនៃដំណើរការនីតិវិធីមជ្ឈត្តការនឹងត្រូវប្រព្រឹត្តឡើង។ ប្រសិនបើមិនអាចកំណត់នូវនីតិវិធីទាំងមូលបានតាមរយៈសន្និសីទនៃការគ្រប់គ្រងចាត់ចែងសំណាង់រឿងដំបូងបានទេ គេអាចរៀបចំសន្និសីទបន្តបន្ទាប់ក្រោយៗមកទៀតដើម្បីសម្រេចបានលើបញ្ហាដែលនៅសេសសល់។ ចំពោះសេចក្ដីសម្រេចដែលបានធ្វើឡើងនៅក្នុងអំឡុងសន្និសីទអំពីការគ្រប់គ្រងចាត់ចែងក្នុងសំណុំរឿងអាចត្រូវបានកែប្រែក្នុងអំឡុងពេលដំណើរការមជ្ឈត្តការ ដោយមានការព្រមព្រៀងពីគូភាគីវិវាទ ហើយក្នុងករណីគូភាគីវិវាទខកខានក្នុងការព្រមព្រៀងនោះ វេទិកាមជ្ឈត្តកម្ម គឺជាអ្នកធ្វើនូវសេចក្ដីសម្រេច។[29]

ប្រការ៣៥.២ នៃវិធានស្ដីពីមជ្ឈត្តការរបស់ ម.ជ.ម. តម្រូវឱ្យវេទិកាមជ្ឈត្តកម្មកោះប្រជុំជាមួយគូភាគីវិវាទដោយផ្ទាល់ ឬដោយមធ្យោបាយសមស្របផ្សេងៗទៀតដើម្បីរៀបចំ និងកំណត់កាលវិភាគនៃដំណើរការមជ្ឈត្តការការបន្ទាន់ដើម្បីធ្វើការពិភាក្សាអំពីនីតិវិធីនានាដែលមានភាពសមស្រប និងចំណាយអស់តិចបំផុតសម្រាប់ការចាត់ចែងដំណើរការមជ្ឈត្តការនៃសំណុំរឿង។[30] បន្ថែមលើការប្រជុំត្រៀមវេទិកាមជ្ឈត្តកម្មអាចនឹងរៀបចំឱ្យមានការប្រជុំបន្ថែមក្រោយៗមកទៀត។ ឧទាហរណ៍៖ ការប្រជុំដើម្បីពិនិត្យមើលទីតាំង វត្ថុ ឬឯកសារនានា ដូចមានចែងក្នុងប្រការ ៤០.២ នៃវិធានស្ដីពីមជ្ឈត្តការរបស់ម.ជ.ម. ឬការប្រជុំពិនិត្យមើលភាពរីកចម្រើននៃដំណើរការមជ្ឈត្តការ។

ភាពឆាប់រហ័សក្នុងការរៀបចំសន្និសីទអំពីការគ្រប់គ្រងចាត់ចែងសំណុំរឿងបានកាន់តែលឿន គឺអាចធ្វើឱ្យវេទិកាមជ្ឈត្តកម្មអាចចាប់ផ្ដើមពិគ្រោះយោបល់ជាមួយគូភាគីវិវាទ ស្ដីពីការរៀបចំដំណើរការនៃនីតិវិធីមជ្ឈត្តកម្មបានលឿនផងដែរ។ ដោយអនុលោមតាមប្រការ ៣៥.១ នៃវិធានស្ដីពីមជ្ឈត្តការរបស់ ម.ជ.ម. វេទិកាមជ្ឈត្តកម្មអាចអនុម័តវិធានការនៃនីតិវិធី (សេចក្ដីបង្គាប់នីតិវិធី) សម្រាប់ដំណើរការប្រព្រឹត្តទៅរបស់មជ្ឈត្តការដោយវិធាននៃនីតិវិធីនោះ និងមិនត្រូវផ្ទុយគ្នាទៅនឹងការព្រមព្រៀងណាមួយរបស់ភាគីវិវាទឡើយ។ នៅក្នុងប្រការ ៣៥.១ ក៏បានចែងផងដែរថា វេទិកាមជ្ឈត្តកម្មត្រូវអនុវត្តដំណើរការមជ្ឈត្តការភ្លាមក្នុងលក្ខណៈដែលខ្លួនយល់ថាសមស្រប និងដោយធានាភាពយុត្តិធម៌ ឆាប់រហ័សចំណាយអស់តិច និងផ្ដល់ដំណោះស្រាយចុងក្រោយនៃវិវាទ ទោះបីជា

---

[29] លោក ហួន សុខនីម, កម្រងវិធីសាស្ត្រគន្លឹះនីតិវិធីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, បោះពុម្ពឆ្នាំ២០២១, ទំព័រ១៦

[30] វិធានស្ដីពីមជ្ឈត្តការ, ២៨ មីនា ២០២១, ប្រការ៣៥.២

លក្ខណៈនៃវិវាទមានភាពសាំញ៉ាំយ៉ាងណាក៏ដោយ និងមានទំហំតម្លៃនៃវិវាទប៉ុនណាក៏ដោយ។ ការធ្វើបែបនេះបាន ជានិច្ចជាកាលផទិកាមជ្ឈត្តកម្មចាំបាច់ត្រូវធ្វើការពិភាក្សាជាមួយគូភាគីវិវាទជាមុនសិន។

បញ្ហានានាដែលត្រូវកាសម្រេចនៅក្នុងដំណាក់កាលនៃសន្និសីទអំពីការគ្រប់គ្រងចាត់ចែងសំណុំរឿងទាំងនេះរួមមាន៖ ការកំណត់អំពីចំនួនជុំ ឬវគ្គនៃការដាក់សេចក្ដីថ្លែងសង្ខេប វិសាលភាពនៃការផលិតរៀងចំចងក្រងឯកសារ និងលិខិតស្នាមផ្សេងៗ (ប្រសិនបើមាន) ការកំណត់អំពីចំណុចវិវាទជាបឋម ការកំណត់ពីអត្តសញ្ញាណចំនួនសាក្សីអង្គហេតុ សាក្សីជំនាញ និងការកំណត់អំពីរបៀបដំណើរការរៀបចំសវនាការ។

នៅក្នុងនោះ កិច្ចដំណើរការនីតិវិធីមជ្ឈត្តការ ដែលត្រូវប្រកបដោយលក្ខណៈឆាប់រហ័ស ចំណាយអស់តិច ប្រសិទ្ធភាពខ្ពស់ និងការចំណាយទាបមិនអាចចេះតែទទួលបានយ៉ាងងាយៗដោយខ្លួនឯងឡើយ។ កម្រិតនៃភាពស្មុគស្មាញនិងទំហំកម្រៃនៃវិវាទត្រូវយកមកពិចារណាឱ្យបានដិតដល់ផងដែរ។ ដំណើរការមជ្ឈត្តការដែលចំណាយអស់តិច និងឆាប់រហ័សគឺអាស្រ័យលើពេលវេលាដែលគ្រប់តួរអង្គនៃភាគីពាក់ព័ន្ធត្រូវធ្វើការលះបង់ និងថ្លៃសោហ៊ុយចំណាយនានាដែលត្រូវរ៉ាប់រងក្នុងការដោះស្រាយវិវាទ ដោយសមស្របទៅតាមអ្វីដែលពាក់ព័ន្ធក្នុងសំណុំរឿង។ នៅក្នុងសំណុំរឿងនីមួយៗគេចាំបាច់ត្រូវធ្វើការវិភាគអំពីការប្រៀបធៀបរវាងតម្លៃ នៃការចំណាយ និងអត្ថប្រយោជន៍ដែលត្រូវទទួលបានមកវិញដើម្បីឱ្យដឹងថា តើវិធាននៃនីតិវិធីមជ្ឈត្តការជាក់លាក់មួយណាដែលសាកសមទៅនឹងការចំណាយទាំងនោះ?

គោលបំណងនានារបស់គូភាគីវិវាទនឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការធ្វើការសម្រេចចិត្តថា នឹងត្រូវយកជាជម្រើសណាមួយដែលខ្លួនយល់ថាសមស្របបំផុត។ ឧទាហរណ៍ខ្លះៗខាងក្រោមនេះនឹងបង្ហាញអំពីគោលដៅរបស់គូភាគីវិវាទដែលជារបៀបវារៈ ឬកត្តាសម្រាប់កំណត់យុទ្ធសាស្ត្រក្នុងការគ្រប់គ្រងចាត់ចែងសំណុំរឿង៖

- នៅពេលដែលមានភាពសំខាន់នៃគោលការណ៍ ដែលជាប់ពាក់ព័ន្ធកើតឡើងចំពោះមុខចាំបាច់ត្រូវបង់ពេលវេលា នឹងចំណាយថវិកាដើម្បីធ្វើការពិនិត្យយ៉ាងហ្មត់ចត់ទៅលើអង្គហេតុនានា និងស្វះស្វែងរកការបញ្ជាក់ឱ្យបានច្បាស់លាស់ពីទឡ្ហីករណ៍ស្របតាមផ្លូវច្បាប់ទាំងអស់។ ភាគីវិវាទដែលមានគោលបំណងបែបនេះ គឺគេមានឆន្ទៈក្នុងការចំណាយថវិកាលើការផលិតរៀបចំឯកសារ និងលិខិតស្នាមផ្សេងៗឱ្យបានគ្រប់សព្វ ត្រៀមលក្ខណៈរួចជាស្រេចក្នុងការដាក់ចេញសេចក្ដីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរ និងលិខិតស្នាមផ្សេងៗជាច្រើនដង ឬច្រើនជុំចំណាយលើការរៀបចំសាក្សីអង្គហេតុ និងសាក្សីជំនាញ និងចំណាយលើការរៀបចំផ្សេងៗទៀតដែលមានលក្ខណៈប្រហាក់ប្រហែលគ្នានេះ។[31]

---

[31] លោក ហួន សុខនីម, កម្រងវិធីសាស្ត្រគន្លឹះនីតិវិធីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, បោះពុម្ពឆ្នាំ២០២១, ទំព័រ១៩

- នៅពេលដែលមិនមានភាពសំខាន់នៃគោលការណ៍ ដែលជាប់ពាក់ព័ន្ធកើតឡើងចំពោះមុខ ឬទំហំតម្លៃនៃវិវាទតូចតាច គូភាគីវិវាទប្រាកដជាចង់បានដំណើរការមជ្ឈត្តការប្រព្រឹត្តទៅលឿន ឆាប់រហ័ស និងចំណាយអស់កាន់តែតិចតាមដែលអាចធ្វើទៅបាន។ ក្នុងករណីនេះផ្ទុយទៅវិញពីភាគីវិវាទអាចស្វែងរកការកម្រិតផលិតផល និងរៀបចំចងក្រងឯកសារមួយចំនួនកំណត់និងចំនួនសាក្សីត្រូវកំណត់ឱ្យកាន់តែតិច និងកាត់បន្ថយរយៈពេលសវនាការ ឬកាត់បន្ថយចំនួនជុំនៃការដាក់សេចក្តីថ្លែងការណ៍ដែលធ្វើជាលាយលក្ខណ៍អក្សរ និងលិខិតស្នាមផ្សេងៗឱ្យកាន់តិចជាអប្បបរមា។[32]
- នៅពេលគូភាគីវិវាទមានបំណងចង់ដោះស្រាយវាដោយស្ម័គ្រចិត្ត ដើម្បីរក្សាទំនាក់ទំនងរបស់ពួកគេ ឬកាត់បន្ថយហានិភ័យនៃការខាតបង់ ពួកគេអាចប្រើសន្និសីទអំពីការគ្រប់គ្រងចាត់ចែងសំណុំរឿង ដើម្បីស្វែងរកការបំបែកដំណើរការមជ្ឈត្តការដាច់ពីគ្នាៗសម្រាប់ដំណើរការនីតិវិធីមជ្ឈត្តការ ឬការកំណត់ជាបឋមដើម្បីត្រួតពិនិត្យលើចំណុចវិវាទ ដែលមធ្យោបាយនេះដោះស្រាយបែបនេះអាចនាំមកនូវលទ្ធផលជាវិជ្ជមានតាមរយៈការដោះស្រាយវិវាទស្ម័គ្រចិត្តដល់គូភាគីវិវាទ។ ដោយគូភាគីវិវាទអាចព្រមព្រៀងគ្នាដើម្បីជ្រើសរើសយកការអនុវត្តនីតិវិធីនានាក្នុងការដោះស្រាយវិវាទដោយស្ម័គ្រចិត្តទាំងមុនពេល ឬក្នុងដំណាក់កាលណាមួយក្នុងអំឡុងពេលនៃដំណើរការមជ្ឈត្តការ។

## ២.២. សេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្ម

នៅក្នុងដំណើរការនីតិវិធីមជ្ឈត្តការ ត្រូវបានចាត់ទុកថាចាប់ផ្តើមកាលបរិច្ឆេទនៃការដាក់សំណុំឯកសារក្តីជូនដំណឹងអំពីមជ្ឈត្តកម្មពេញលេញដោយភាគីបណ្តឹងទាមទារ បញ្ជូនទៅអគ្គលេខាធិការដ្ឋាននៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។ នៅគ្រប់ករណីទាំងអស់ ភាគីវិវាទត្រូវជូនដំណឹងអំពីមជ្ឈត្តកម្មពេញលេញត្រូវតែមានព័ត៌មានច្បាស់លាស់។[33]

គោលការណ៍ខាងលើនេះ គឺមានគោលបំណងទាញយកនូវព័ត៌មានដែលគ្រប់គ្រាន់ពេញលក្ខណៈដើម្បីអាចឱ្យភាគីឆ្លើយតប ធ្វើការឆ្លើយតបទៅនឹងការទាមទាររបស់ភាគីបណ្តឹងទាមទារទៅតាមគ្រប់ចំណុចដែលជាការតម្រូវដែលគេចង់បាន ដោយយោងតាមប្រការ ៨.១ សេចក្តីជូនដំណឹងអំពីការឆ្លើយតប នៃវិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នឹងបំពេញមុខងារនឹងតួនាទីរបស់ខ្លួនស្របតាមវិធាននានា ក្នុងការធានានូវការគោរពតាមអនុលោមភាពនៅក្នុងការបង្កើតឡើងវេទិកាមជ្ឈត្តកម្ម និងការកំណត់សកម្មភាពចាំបាច់ទាំងឡាយសម្រាប់ដំណើរការមជ្ឈត្តការលើសំណុំរឿងនោះ។[34]

---

[32] លោក ហួន សុខនីម, កម្រងវិធីសាស្ត្រគន្លឹះនីតិវិធីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, បោះពុម្ពឆ្នាំ២០២១, ទំព័រ២០

[33] វិធានស្តីពីមជ្ឈត្តការ, ២៨ មីនា ២០២១, ប្រការ៧.១

[34] លោក ហួន សុខនីម, កម្រងវិធីសាស្ត្រគន្លឹះនីតិវិធីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, បោះពុម្ពឆ្នាំ២០២១, ទំព័រ១៩

ជាមួយនឹងសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្មនោះ គួរតែមានវិសាលភាពខ្លឹមសាររៀបរាប់ត្រឹមការតម្រូវជាអប្បរមារបស់វិធានស្តីពីមជ្ឈត្តការ ឬត្រូវភ្ជាប់មកបន្ថែមនូវសេចក្តីថ្លែងលម្អិតផ្សេងទៀតអំពីសំណុំរឿងដែរឬទេ?

ការដាក់សេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្ម ជាទម្រង់សង្ខេបដែលមានខ្លឹមសាររៀបរាប់ត្រឹមការតម្រូវអប្បបរមារបស់វិធានស្តីពីមជ្ឈត្តការដោយមិនចាំបាច់ផ្តល់នូវខ្លឹមសារ ឬភ្ជាប់ភស្តុតាងច្រើនលើសពីអ្វីដែលវិធានបានតម្រូវជាក់លាក់នោះទេ។ ម្យ៉ាងទៀតការដាក់បញ្ជូនសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្ម ជាទម្រង់ពិស្តារលម្អិតដែលមានខ្លឹមសារគ្រប់ជ្រុងជ្រោយដោយមានភ្ជាប់ទាំងភស្តុតាង ឬវត្ថុតាងពាក់ព័ន្ធ ដែលធ្វើជាសេចក្តីថ្លែងការណ៍ពេញលេញអំពីសំណុំរឿង។

ទោះបីយ៉ាងណាក៏ដោយ ក៏នៅតែមានជម្រើសវិធីសាស្ត្រក្នុងការដាក់សេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្មដែលខ្លឹមសារ និងភស្តុតាងមានកម្រិតពិស្តារ គឺអាស្រ័យទៅតាមស្ថានភាព និងកាលៈទេសៈតម្រូវជាក់ស្តែង។ ការរៀបចំតាក់តែងសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្មដែលមានខ្លឹមសារបែបសង្ខេបខ្លី គឺគេអាចធ្វើបានលឿនឆាប់រហ័ស ព្រមទាំងអស់តម្លៃសោហ៊ុយចំណាយតិចជាងការរៀបចំតាក់តែងសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្មតាមទម្រង់វែងពិស្តារនិងលម្អិត ដែលមានភ្ជាប់ទាំងសំណៅឯកសារ និងលិខិតស្នាមផ្សេងៗ បន្ថែមទៀតផងដែរ។[35]

ផ្ទុយទៅវិញ ចំពោះការរៀបចំតាក់តែងសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្មតាមទម្រង់វែងដែលមានលក្ខណៈខ្លឹមសារលម្អិតពិស្តារ អាចជាករណីមួយចាំបាច់សម្រាប់ការកាត់បន្ថយចំនួនជុំនៃការដាក់ជូនសំណុំឯកសារ និងលិខិតស្នាមពាក់ព័ន្ធដែលនឹងត្រូវដាក់បន្ថែមនាពេលក្រោយៗមកទៀត។ នៅក្នុងករណីនេះ វាគឺជាកត្តាជំរុញឱ្យដំណើរការនៃនីតិវិធីមជ្ឈត្តការអាចពន្លឿនទៅមុខបានកាន់តែឆាប់រហ័ស។ លើសពីនេះទៅទៀតចំពោះការផ្តល់ព័ត៌មានបន្ថែមក៏អាចបង្កើតនូវផលប៉ះពាល់ទៅលើសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្មចំពោះភាគីឆ្លើយតបផងដែរ។

ព័ត៌មានពិស្តារលម្អិតបន្ថែមអាចនឹងធ្វើឱ្យគូភាគីវិវាទ និងវេទិកាមជ្ឈត្តកម្មមានឱកាសក្នុងការផ្តោតការយកចិត្តទុកដាក់លើចំណុចវិវាទសំខាន់ៗ ក្នុងសំណុំរឿងបានកាន់តែឆាប់រហ័សតាមដែលអាចធ្វើទៅបានជាហេតុនាំឱ្យគេអាចសម្រួលបានកាន់តែឆាប់រហ័សក្នុងការរៀបចំសេចក្តីថ្លែងអំពីលក្ខខណ្ឌយោង និងក៏មានភាពឆាប់រហ័សក្នុងការចាប់ផ្តើមរៀបចំការប្រជុំសន្និសីទអំពីការគ្រប់គ្រងចាត់ចែងសំណុំរឿងផងដែរ។[36]

នៅគ្រប់កាលៈទេសៈទាំងអស់ភាគីអាចប្តឹងទាមទារគួរពិចារណាឱ្យបានហ្មត់ចត់ដើម្បីធ្វើការតម្លៃជាបឋមលើលក្ខណៈនៃសំណុំរឿង ចំណុចខ្លាំង និងចំណុចខ្សោយរបស់សំណុំរឿងមុននឹងសម្រេចចិត្តដាក់បញ្ជូនសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្មទៅអគ្គលេខាធិការដ្ឋានមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មរបស់ ម.ជ.ម.។[37]

[35] វិធានស្តីពីមជ្ឈត្តការ, ២៨ មីនា ២០២១, ប្រការ២

[36] លោក ហួន សុខនីម, កម្រងវិធីសាស្ត្រគន្លឹះនីតិវិធីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, បោះពុម្ពឆ្នាំ២០២១, ទំព័រ២០

[37] វិធានស្តីពីមជ្ឈត្តការ, ២៨ មីនា ២០២១, ប្រការ១

ការវាយតម្លៃជាបឋមតាមរបៀបនេះ គឺអាចឱ្យភាគីប្តឹងទាមទារធ្វើការកំណត់ជាមុន ថាតើការប្តឹងទាមទារក្នុងសំណុំរឿងរបស់ខ្លួនមានភាពរឹងមាំគ្រប់គ្រាន់ដែរឬទេ មុននឹងសម្រេចចិត្តដាក់បញ្ជូនសំណុំរឿងនោះទៅក្នុងដំណើរការមជ្ឈត្តការ? ឬថាតើវាជាការល្អប្រសើរជាងដែរឬទេ ដែលគួរតែស្វែងរកការដោះស្រាយវិវាទដោយស្ម័គ្រចិត្តជាមុនសិន ប្រសិនបើគេសម្រេចចិត្តដាក់បញ្ជូនសំណុំរឿងនោះទៅក្នុងដំណើរការមជ្ឈត្តការការវាយតម្លៃជាបឋមលើសំណុំរឿងនឹងជួយឱ្យធានាបានថាសេចក្តីជូនដំណឹងអំពីមជ្ឈត្តការពុំមានវិការៈ ឬខ្វះចន្លោះនៅចំណុចត្រង់ណាមួយ ហើយរាល់ការទាមទាររបស់ភាគីប្តឹងទាមទារត្រូវបានរៀបចំតាក់តែងពិពណ៌នាយ៉ាងត្រឹមត្រូវ និងកំណត់បានគ្រប់ចំណុចប្រកបដោយប្រសិទ្ធភាពបំផុត? ខណៈពេលការវាយតម្លៃជាបឋមទាមទារពេលវេលា និងឱ្យមានតម្លៃសោហ៊ុយចំណាយខ្លះក៏ពិតមែន តែជាធម្មតាក៏អាចជួយសន្សំសំចៃពេលវេលា និងថ្លៃសោហ៊ុយចំណាយតិចនៅពេលដំណើរការមជ្ឈត្តការទាំងមូលកំពុងប្រព្រឹត្តទៅ។

ប្រសិនបើគូភាគីប្តឹងទាមទារសម្រេចចិត្តពិតជាត្រូវដែលចាប់ផ្តើមដំណើរការមជ្ឈត្តការ គេត្រូវកំណត់ថាតើគេត្រូវដាក់បញ្ជូនសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្មជាទម្រង់សង្ខេប ឬសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្មតាមទម្រង់វែងដែលមានខ្លឹមសារលម្អិតនិងពិស្តារ? ការសម្រេចចិត្តថា តើសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្ម គួរតែមានខ្លឹមសារលម្អិតពិស្តារគឺមានឥទ្ធិពលយ៉ាងខ្លាំងទៅលើកាលៈទេសៈនៃសំណុំរឿង និងពិចារណាជាយុទ្ធសាស្ត្រឬ? គេអាចសន្សំសំចៃពេលវេលា និងថ្លៃសោហ៊ុយចំណាយបានមួយចំនួនក្នុងករណី ដែលគេសម្រេចចិត្តថានឹងដាក់បញ្ជូលនូវសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្មជាទម្រង់សង្ខេប។ បើទោះបីជាការសន្សំសំចៃជាបណ្តោះអាសន្នក៏ដោយ ប្រសិនបើភាគីប្តឹងទាមទារត្រូវបានតម្រូវឱ្យបំពេញបន្ថែមចំពោះសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្មនោះជាមួយនឹងព័ត៌មានលម្អិតបន្ថែមនៅពេលក្រោយៗទៀត។ នៅពេលសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្ម និងសេចក្តីជូនដំណឹងអំពីការឆ្លើយតបរួមគ្នា បង្កើតបានជាសេចក្តីថ្លែងពេញលេញនៃសំណុំរឿងនឹងសេចក្តីថ្លែងពេញលេញអំពីការដោះសារ គេអាចសន្សំសំចៃពេលវេលា និងថ្លៃសោហ៊ុយចំណាយបានមួយចំនួនដោយសារតែភាគីវិវាទពុំចាំបាច់ដាក់សេចក្តីជូនដំណឹង និងសំណៅឯកសារណាមួយ ឬច្រើនជុំបន្ថែមទៀតនៅពេលក្រោយៗ។ ទោះបីជាយ៉ាងណាក៏ដោយ ចំពោះសំណុំរឿងដែលមានលក្ខណៈស្មុគស្មាញវិធីសាស្ត្រខាងលើនេះមិនអាចអនុវត្តបានឡើយ ហើយសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្ម និងសេចក្តីជូនដំណឹងអំពីការឆ្លើយតបអាចនឹងត្រូវបានបន្ថែមដោយសារការបញ្ជូននូវសេចក្តីថ្លែងជាលាយលក្ខណ៍អក្សរជាបន្តទៀត។[38] ប្រសិនបើគោលបំណងចម្បងនៃការដាក់បញ្ជូនសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្ម ដើម្បីជំរុញឱ្យមានការពិភាក្សាចរចារកដំណោះស្រាយដោយស្ម័គ្រចិត្ត ចំណុចដែលគេគួរគប្បីពិចារណាថាតើគេត្រូវជ្រើសរើសវិធីសាស្ត្រមួយណាទើបប្រសើរវាងសេចក្តី

[38] លោក ហួន សុខនីម, កម្រងវិធីសាស្ត្រគន្លឹះនីតិវិធីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, បោះពុម្ពឆ្នាំ២០២១, ទំព័រ២១

ជូនដំណឹងអំពីមជ្ឈត្តកម្មជាទម្រង់សង្ខេប និងសេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្មតាមទម្រង់វែងដែលមានខ្លឹមសារលម្អិត និងពិស្តារ។[39]

- សេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្មជាទម្រង់សង្ខេប គឺជាជម្រើសល្អប្រសើរជាង ប្រសិនបើភាគីឆ្លើយតបទំនងជាមិនមានចេតនាក្នុងការពិភាក្សាចរចារកដំណោះស្រាយដោយស្ម័គ្រនោះទេ លុះត្រាណាតែសេចក្ដីជូនដំណឹងការមជ្ឈត្តកម្មបានចាប់ផ្ដើម ហើយទិដ្ឋភាពអង្គសេចក្ដីសំខាន់ៗនៃការទាមទារអាចនឹងត្រូវបានឆ្លើយតបល្អបំផុតតាមរយៈការពិភាក្សាចរចារកដំណោះស្រាយដោយស្ម័គ្រចិត្ត។
- សេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្មតាមទម្រង់វែងដែលមានខ្លឹមសារ លម្អិតពិស្តារ គឺជាជម្រើសល្អប្រសើរជាងប្រសិនបើគោលបំណងចម្បងនៃការដាក់បញ្ជូនសេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្ម ដើម្បីជាការបង្ហាញដល់ភាគីឆ្លើយតបជាលាយលក្ខណ៍អក្សរអំពីចំណុចខ្លាំង និងភាពមាំទាំនៃសំណុំរឿងរបស់ភាគីប្ដឹងទាមទារមុនពេលចាប់ផ្ដើមឱ្យមានការពិភាក្សារកដំណោះស្រាយដោយស្ម័គ្រចិត្ត។

### ២.២.១. សេចក្ដីជូនដំណឹងអំពីការឆ្លើយតប និងបណ្ដឹងតប

បន្ទាប់ពីបានទទួលសេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្មរួចមក ភាគីឆ្លើយតបត្រូវដាក់បញ្ជូនសេចក្ដីជូនដំណឹងអំពីការឆ្លើយតបទៅអគ្គលេខាធិការដ្ឋានរបស់ ម.ជ.ម.។[40] ក្នុងគ្រប់ករណីទាំងអស់ សេចក្ដីជូនដំណឹងអំពីការឆ្លើយតបត្រូវតែមានព័ត៌មានច្បាស់លាស់ ហើយរាល់សេចក្ដីជូនដំណឹងអំពីការឆ្លើយតបទាំងអស់អាចមានភ្ជាប់ជាមួយនឹងសេចក្ដីថ្លែងដោះសារ ដែលអាចរួមមានទាំងបណ្ដឹងតប ឬការដោះសារនិងឯកសារយោងនានា។[41] ម្យ៉ាងទៀត បើភាគីប្ដឹងទាមទារមិនទាន់បានដាក់សំណើសុំដំណើរការនីតិវិធីពន្លឿនទេ ភាគីឆ្លើយតបអាចដាក់សំណើសុំដំណើរការនីតិវិធីពន្លឿនបាន ដោយភ្ជាប់សំណើនោះមកជាមួយសេចក្ដីជូនដំណឹងអំពីការឆ្លើយតប។ ប៉ុន្តែប្រសិនបើភាគីប្ដឹងទាមទារ បានដាក់សំណើសុំដំណើរការនីតិវិធីពន្លឿនរួចហើយភាគីឆ្លើយតបគ្រាន់តែធ្វើការផ្ដល់យោបល់លើសំណើ នៅពេលដាក់បញ្ជូនសេចក្ដីជូនដំណឹងអំពីការឆ្លើយតបរបស់ខ្លួនគឺជាការស្រេច។[42]

ក្នុងចំណុចនេះក៏មានបញ្ហាមួយចំនួន ដែលត្រូវលើមកពីនិត្យផងដែរពីទម្រង់នៃសេចក្ដីជូនដំណឹងអំពីការឆ្លើយតប និងបណ្ដឹងតប ថាតើគួរសរសេរដោយមានលក្ខណៈជាទម្រង់ពិស្តារលម្អិត ដែលអាចត្រូវអធិប្បាយរៀបរាប់ឱ្យលើសពីអ្វីដែលវិធានស្ដីពីមជ្ឈត្តការរបស់ ម.ជ.ម. តម្រូវដែរឬទេ? ជម្រើសសម្រាប់ពិចារណាក្នុងការដាក់បណ្ដឹងតបមានដូចជា៖

[39] លោក ហួន សុខនីម, កម្រងវិធីសាស្ត្រគន្លឹះនីតិវិធីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, បោះពុម្ពឆ្នាំ២០២១, ទំព័រ២២

[40] វិធានស្ដីពីមជ្ឈត្តការ, ២៨ មីនា ២០២១, ប្រការ៨.១

[41] វិធានស្ដីពីមជ្ឈត្តការ, ២៨ មីនា ២០២១, ប្រការ៣៧.៣

[42] លោក ហួន សុខនីម, កម្រងវិធីសាស្ត្រគន្លឹះនីតិវិធីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, បោះពុម្ពឆ្នាំ២០២១, ទំព័រ២១

- ការដាក់បញ្ជូននូវសេចក្តីជូនដំណឹងអំពីការឆ្លើយតបដែលសរសេររៀបរាប់តាមទម្រង់សង្ខេបខ្លីមួយដោយត្រឹមតែបំពេញទៅតាមការតម្រូវរបស់វិធានស្តីពីមជ្ឈត្តការ និងពុំចាំបាច់ផ្តល់នូវខ្លឹមសារ ឬភស្តុតាងច្រើនលើសជាងអ្វីដែលវិធានស្តីពីមជ្ឈត្តការតម្រូវនោះទេ។
- ការដាក់បញ្ជូនសេចក្តីជូនដំណឹងអំពីការឆ្លើយតបដែលសរសេររៀបរាប់តាមទម្រង់ពិស្តារលម្អិត គ្រប់ជ្រុងជ្រោយដោយរួមបញ្ចូលទាំងសេចក្តីថ្លែងដោះសារមានភ្ជាប់ទាំងវត្ថុតាង និងភស្តុតាងជាមួយផង។ ជម្រើសវិធីសាស្ត្រទាំងពីរខាងលើនេះ គឺជាចំណុចនៃសេចក្តីបញ្ចប់នៅក្នុងការតាក់តែងសេចក្តីជូនដំណឹងអំពីការឆ្លើយតប។ ទោះបីជាយ៉ាងណាក៏ដោយ ក៏នៅតែមានជម្រើសក្នុងការដាក់សេចក្តីជូនដំណឹងអំពីការឆ្លើយតបដែលមានខ្លឹមសារ និងភស្តុតាងមានកម្រិតពិស្តារអាស្រ័យទៅតាមស្ថានភាព និងកាលៈទេសៈតម្រូវជាក់ស្តែង។ ដើម្បីសម្រេចចិត្តថាតើសេចក្តីដំណឹងអំពីការឆ្លើយតបដែលសរសេររៀបរាប់គួរមានខ្លឹមសារពិស្តារលម្អិតកម្រិតប៉ុនណា ភាគីឆ្លើយតបគួរតែពិចារណាថាតើភាគីប្តឹងទាមទារបានជ្រើសរើសយកកម្រិតពិស្តារលម្អិតវែងប៉ុនណាដែរនៅក្នុងសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្ម និងសេចក្តីថ្លែងទាមទារ។ ជាពិសេស ភាគីឆ្លើយតបអាចជ្រើសរើសយកជម្រើសណាមួយរវាងជម្រើសដូចជា ការដាក់បញ្ជូនសេចក្តីជូនដំណឹងអំពីការឆ្លើយតបដោយស្របទៅនឹងវិធីសាស្ត្រ ដែលភាគីប្តឹងទាមទារបានជ្រើសរើស ឬទម្រង់នៃសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្មដែលភាគីប្តឹងទាមទារបានជ្រើសរើស។
- ការដាក់បញ្ចូលបណ្តឹងតបជាមួយដោយមិនគិតពីទំហំ និងខ្លឹមសារនៃសេចក្តីជូនដំណឹងពីការឆ្លើយតប។ ការសម្រេចចិត្តឱ្យមានការលើកឡើងនូវបណ្តឹងតប ក៏ជាកម្មវត្ថុនៃការពិចារណាស្រដៀងគ្នាទៅនឹងអ្វីដែលពិពណ៌នាក្នុងសេចក្តីអធិប្បាយពាក់ព័ន្ធនឹងសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្មខាងលើផងដែរ។[43]

មានខ្លឹមសារពិស្តារលម្អិត ឬសេចក្តីជូនដំណឹងអំពីការឆ្លើយតបដែលសរសេររៀបរាប់មានខ្លឹមសារបែបសង្ខេបខ្លី អាចប្រែប្រួលបានអាស្រ័យលើទម្រង់បែបបទនៃសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្មដែលបានដាក់ដោយភាគីប្តឹងទាមទារ។ ប្រសិនបើភាគីប្តឹងទាមទារដាក់បញ្ជូនសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្មមានខ្លឹមសារតាមទម្រង់បែបសង្ខេបខ្លី នោះភាគីឆ្លើយតបត្រូវឆ្លើយតបដោយដាក់បញ្ជូនសេចក្តីជូនដំណឹងអំពីការឆ្លើយតបដែលសរសេររៀបរាប់មានខ្លឹមសារបែបសង្ខេបខ្លីដូចគ្នាដែរ ហើយបន្ទាប់មកវេទិកាមជ្ឈត្តកម្មគួរតែអាចចាប់ផ្តើមដំណើរការនីតិវិធីមជ្ឈត្តការបានភ្លាមដែរដើម្បីឈានដល់ការកំណត់សេចក្តីថ្លែងអំពីលក្ខខណ្ឌយោង និងមានភាពឆាប់រហ័ស ក្នុងការរៀបចំឱ្យមានការប្រជុំសន្និសីទអំពីការគ្រប់គ្រងចាត់ចែងសំណុំរឿង លើកលែងតែក្នុងករណីដែលថាភាគីឆ្លើយតបចាំបាច់ត្រូវទាមទារស្នើសុំពេលវេលាសម្រាប់ដាក់ជូនដំណឹងអំពីការឆ្លើយតបដោយមានខ្លឹមសារ។[44]

[43] លោក ហួន សុខនីម, កម្រងវិធីសាស្ត្រគន្លឹះនីតិវិធីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, បោះពុម្ពឆ្នាំ២០២១, ទំព័រ២២
[44] វិធានស្តីពីមជ្ឈត្តការ, ២៨ មីនា ២០២១, ប្រការ៨.៥

ម្យ៉ាងវិញទៀត ប្រសិនបើភាគីប្តឹងទាមទារដាក់សេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្មមានខ្លឹមសារតាមទម្រង់វែង និងមានខ្លឹមសារពិស្តារលម្អិត ភាគីឆ្លើយតបអាចស្នើសុំការពន្យារពេលបន្ថែមក្នុងការដាក់បញ្ជូនសេចក្តីជូនដំណឹងអំពីការឆ្លើយតបជាមួយនឹងចម្លើយលម្អិតទៅតាមទម្រង់វែង និងមានខ្លឹមសារពិស្តារដូចគ្នាដែរ។

ចំពោះការដាក់បញ្ជូនសេចក្តីជូនដំណឹងអំពីការឆ្លើយតប ដែលសរសេររៀបរាប់មានខ្លឹមសារបែបសង្ខេបខ្លី គឺគេអាចរៀបចំបានយ៉ាងលឿននិងរហ័សជាង ហើយអស់ថ្លៃសោហ៊ុយចំណាយតិចជាងការរៀបចំសេចក្តីជូនដំណឹងអំពីការឆ្លើយតបដែលសរសេររៀបរាប់មានខ្លឹមសារពិស្តារលម្អិត ។

ប្រសិនបើភាគីណាមួយប្តឹងទាមទារដាក់បញ្ជូនសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្មមានខ្លឹមសារពិស្តារលម្អិតតាមទម្រង់វែង ហើយភាគីឆ្លើយតបបានសម្រេចចិត្តដាក់បញ្ជូនសេចក្តីជូនដំណឹងអំពីការឆ្លើយតបដែលបានសរសេររៀបរាប់មានខ្លឹមសារពិស្តារលម្អិត គេអាចកាត់បន្ថយចំនួនជុំនៃការដាក់សេចក្តីថ្លែង និងសំណុំឯកសារពាក់ព័ន្ធដែលត្រូវដាក់បន្ថែមក្រោយៗមកទៀត ដែលជាហេតុធ្វើឱ្យដំណើរការនៃនីតិវិធីមជ្ឈត្តការអាចពន្លឿនទៅមុខបានកាន់តែឆាប់រហ័ស។

លើសពីនេះការផ្តល់ព័ត៌មានកាន់តែពិស្តារបន្ថែម អាចបង្កើនផលប៉ះពាល់ចំពោះសេចក្តីជូនដំណឹងអំពីការឆ្លើយតប។ ការផ្តល់ព័ត៌មានកាន់តែពិស្តារបន្ថែម ក៏អាចបង្កើនសមត្ថភាពរបស់គូភាគីវិវាទនិងវេទិកាមជ្ឈត្តកម្មឱ្យមានការផ្តោតការយកចិត្តទុកដាក់ទៅលើចំណុចវិវាទសំខាន់ៗ នៅក្នុងសំណុំរឿងឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន ដែលជាហេតុធ្វើឱ្យការតាក់តែងបង្កើតសេចក្តីថ្លែងអំពីលក្ខខណ្ឌយោងបានឆាប់រហ័សផងដែរ និងការរៀបចំឱ្យមានការប្រជុំសន្និសីទអំពីការគ្រប់គ្រងចាត់ចែងសំណុំរឿងភ្លាមៗដែរ ដើម្បីឈានដល់ការកំណត់សេចក្តីបង្គាប់នីតិវិធី។

ដោយផ្អែកទៅលើវិសាលភាពនៃពេលវេលាមានច្រើន ឬតិចភាគីឆ្លើយតបគួរតែធ្វើការវាយតម្លៃជាបឋមទៅលើលក្ខណៈនៃសំណុំរឿង ចំណុចខ្លាំង និងចំណុចខ្សោយរបស់សំណុំរឿងជាមុននឹងសម្រេចចិត្តដាក់បញ្ជូនសេចក្តីជូនដំណឹងអំពីការឆ្លើយតប។ ការធ្វើរបៀបនេះនឹងអនុញ្ញាតឱ្យគេអាចកំណត់យ៉ាងច្បាស់តាំងពីដំបូងថា តើគេគួរគប្បីធ្វើការតបតឆ្លើយដោះសារចំពោះសំណុំរឿងនេះដែរទេ ឬគួរស្វែងរកការដោះស្រាយវិវាទដោយស្ម័គ្រចិត្ត? ប្រសិនបើភាគីឆ្លើយតបសម្រេចចិត្តធ្វើការតបតឆ្លើយដោះសារចំពោះសំណុំរឿងមជ្ឈត្តការ និងអាចដាក់បញ្ចូលជាមួយនូវបណ្តឹងតបផងនោះ ការវាយតម្លៃជាបឋមលើលក្ខណៈនៃសំណុំរឿងនឹងជួយឱ្យគេធានា បានថាសេចក្តីជូនដំណឹងអំពីការឆ្លើយតបត្រូវបានរៀបចំតាក់តែងបានត្រឹមត្រូវ និងពុំមានខ្លឹមសារខុសឆ្គងហើយនិងធានាបានថាសេចក្តីថ្លែងដោះសារ និងបណ្តឹងតបរបស់ភាគីឆ្លើយតបត្រូវបានរៀបចំតាក់តែង និងអធិប្បាយពិពណ៌នាមានខ្លឹមសារពេញលេញគ្រប់ជ្រុងជ្រោយ និងមានលក្ខណៈសុក្រឹតបំផុត។ នៅពេលដែលគេត្រូវការប្រើប្រាស់ពេលវេលាច្រើន និងទាមទារឱ្យមានការចំណាយខ្លះដើម្បីអនុវត្តការវាយតម្លៃជាបឋមលើលក្ខណៈនៃសំណុំរឿង

នោះ ជាធម្មតាជាការតបស្នងវិញ ការវាយតម្លៃជាបឋមនេះក៏ជួយសន្សំសំចៃពេលវេលានិងកាត់បន្ថយការចំណាយថវិកាលើដំណើរមជ្ឈត្តការទាំងមូលផងដែរ។[45]

ចំណុចពិចារណាមួយបន្ថែមទៀតសម្រាប់ភាគីឆ្លើយតប គឺរយៈពេលកំណត់ដែលមានចែងដោយវិធានស្ដីពីមជ្ឈត្តការក្នុងការធ្វើការវាយតម្លៃជាបឋមលើលក្ខណៈនៃសំណុំរឿង និងការដាក់បញ្ជូនសេចក្ដីជូនដំណឹងអំពីការឆ្លើយតប ប្រសិនបើភាគីឆ្លើយតបត្រូវបានដឹងឮជាមុនអំពីវិវាទនោះ គេគួរតែអាចធ្វើការវាយតម្លៃជាបឋមលើលក្ខណៈនៃសំណុំរឿងមុននឹងទទួលយកសេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្ម។ ម៉្យាងទៀត ប្រសិនបើការទទួលយកសេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្ម គឺពិតជាឱកាសដំបូងបំផុតរបស់ភាគីឆ្លើយតបដើម្បីធ្វើការវាយតម្លៃអំពីការទាមទាររបស់ភាគីប្ដឹងទាមទារនោះ ភាគីឆ្លើយតបគួរគប្បីយកចិត្តទុកដាក់ក្នុងការប្រើប្រាស់ពេលរបស់ខ្លួនឱ្យបានត្រឹមត្រូវ ព្រោះពេលវេលាដែលបញ្ញត្តិដោយវិធានស្ដីពីមជ្ឈត្តការរបស់ ម.ជ.ម. គឺមានកាលកំណត់ដាក់លាក់។ សេចក្ដីជូនដំណឹងអំពីការឆ្លើយតបក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីបានទទួលសេចក្ដីជូនដំណឹង ភាគីឆ្លើយតបត្រូវបញ្ជូនទៅអគ្គលេខាធិការដ្ឋាន ម.ជ.ម. នូវសេចក្ដីជូនដំណឹងអំពីការឆ្លើយតប។[46]

អាស្រ័យលើកាលៈទេសៈចាំបាច់នានាដែលបានរៀបរាប់ខាងលើ ភាគីឆ្លើយតបត្រូវធ្វើការសម្រេចចិត្តថាតើខ្លួនត្រូវដាក់បញ្ជូនសេចក្ដីជូនដំណឹងអំពីការឆ្លើយតប ដែលសរសេររៀបរាប់មានខ្លឹមសារពិស្ដារលម្អិតតាមទម្រង់វែង ឬក៏ដាក់បញ្ជូនសេចក្ដីជូនដំណឹងអំពីការឆ្លើយតបដែលសរសេររៀបរាប់មានខ្លឹមសារសង្ខេបតាមទម្រង់ខ្លី? ការសម្រេចចិត្តថាតើសេចក្ដីជូនដំណឹងអំពីការឆ្លើយតបដែលសរសេររៀបរាប់តាមទម្រង់វែងគួរមានខ្លឹមសារពិស្ដារលម្អិតសព្វគ្រប់ប៉ុណ្ណានោះ គឺវាអាស្រ័យទាំងស្រុងទៅលើកាលៈទេសៈជាក់ស្ដែងរបស់សំណុំរឿង ការគិតគូរពិចារណាជាយុទ្ធសាស្ត្រនិងពេលវេលាដែលកំណត់ដោយវិធានស្ដីពីមជ្ឈត្តការក្នុងការដាក់បញ្ជូនសេចក្ដីជូនដំណឹងអំពីការឆ្លើយតប។ គេអាចសន្សំសំចៃពេលវេលា និងថ្លៃសោហ៊ុយចំណាយបានមួយចំនួនដោយគ្រាន់តែរៀបចំតាក់តែងនូវសេចក្ដីជូនដំណឹងអំពីការឆ្លើយតប ដែលបានសរសេររៀបរាប់មានខ្លឹមសារសង្ខេបតាមទម្រង់ខ្លីទោះបីជាការសន្សំសំចៃពេលវេលា និងថ្លៃសោហ៊ុយចំណាយដែលមានលក្ខណៈជាបណ្ដោះអាសន្នក៏ដោយ ព្រោះថានៅទីបំផុតភាគីឆ្លើយតបត្រូវបំពេញបន្ថែមសេចក្ដីជូនដំណឹងអំពីការឆ្លើយតបជាមួយនឹងព័ត៌មានពិស្ដារលម្អិតក្រោយៗមកទៀត។

ប្រសិនបើភាគីវិវាទប្ដឹងទាមទារបានដាក់បញ្ជូនសេចក្ដីថ្លែងទាមទារពេញលេញ អំពីសំណុំរឿងជាមួយនឹងសេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្មរបស់ខ្លួន ហើយប្រសិនបើមានពេលវេលាគ្រប់គ្រាន់ដែលអាចឱ្យភាគីឆ្លើយតបដាក់បញ្ជូនសេចក្ដីថ្លែងដោះសារពេញលេញភ្ជាប់ជាមួយនឹងសេចក្ដីជូនដំណឹងអំពីការឆ្លើយតបនោះ គឺគេអាច

[45] លោក ហួន សុខនីម, កម្រងវិធីសាស្ត្រគន្លឹះនីតិវិធីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, បោះពុម្ពឆ្នាំ២០២១, ទំព័រ២៦
[46] វិធានស្ដីពីមជ្ឈត្តការ, ២៨ មីនា ២០២១, ប្រការ៧.៧

សន្សំសំចៃពេលវេលា និងកាត់បន្ថយថ្លៃសោហ៊ុយចំណាយជាច្រើនដោយគេពុំចាំបាច់មានចំនួនជុំ ឬវគ្គនៃការដាក់បញ្ជូនសំណុំឯកសារផ្សេងៗក្រោយមកទៀតឡើយ។ ទោះបីជាយ៉ាងណាក៏ដោយករណីបែបនេះគឺពុំអាចអនុវត្តទៅរួចបានឡើយ ប្រសិនបើសំណុំរឿងមានលក្ខណៈស្មុគស្មាញ។

ការពិចារណាក្នុងការដាក់បញ្ជូននូវសេចក្តីជូនដំណឹងអំពីការឆ្លើយតប ដែលសរសេររៀបរាប់មានខ្លឹមសារពិស្តារលម្អិតតាមទម្រង់បែបវែង ឬក៏ដាក់បញ្ជូនសេចក្តីជូនដំណឹងការឆ្លើយតបដែលសរសេររៀបរាប់មានខ្លឹមសារសង្ខេបតាមទម្រង់បែបខ្លី វាបានជួយជំរុញដល់គូភាគីវិវាទខិតខំស្វះស្វែងរកការពិភាក្សាអំពីការដោះស្រាយវិវាទដោយស្ម័គ្រចិត្ត។ ការសម្រេចជ្រើសរើសយកការដាក់បញ្ជូននូវសេចក្តីជូនដំណឹងអំពីការឆ្លើយតបដែលសរសេររៀបរាប់មានខ្លឹមសារពិស្តារលម្អិតតាមទម្រង់វែង គួរធ្វើនៅពេលដែលភាគីឆ្លើយតបមានគោលបំណងចង់បង្ហាញទៅភាគីប្តឹងទាមទារជាលាយលក្ខណ៍អក្សរអំពីចំណុចខ្លាំងនៃសេចក្តីថ្លែងដោះសារ និងបណ្តឹងតបនានាដែលខ្លួនមាន ដើម្បីជាប្រយោជន៍ឱ្យមានលទ្ធភាពក្នុងការពិភាក្សា ដោះស្រាយវិវាទដោយស្ម័គ្រចិត្ត។ នៅក្នុងនោះ សំណួរដែលជាចំណោទបញ្ហាដូចជា៖

- តើពិតជាមានការសន្សំសំចៃថ្លៃសោហ៊ុយចំណាយ និងទទួលបាននូវអត្ថប្រយោជន៍ដែរឬទេពីការដាក់បញ្ជូនសេចក្តីជូនដំណឹងអំពីការឆ្លើយតបដែលសរសេររៀបរាប់មានខ្លឹមសារសង្ខេបតាមទម្រង់ខ្លី? តើការដាក់បញ្ជូនសេចក្តីជូនដំណឹងអំពីការឆ្លើយតប ដែលសរសេររៀបរាប់មានខ្លឹមសារសង្ខេបតាមទម្រង់ខ្លីពិតជាផ្តល់អត្ថប្រយោជន៍ច្រើនជាងការដាក់បញ្ជូនសេចក្តីជូនដំណឹងអំពីការឆ្លើយតបដែលសរសេររៀបរាប់មានខ្លឹមសារពិស្តារលម្អិតពេញលេញតាមទម្រង់វែងដែរឬទេ បើយោងទៅលើមូលហេតុនានាដែលបានរៀបរាប់ខាងលើ?
- តើគេមានពេលវេលាគ្រប់គ្រាន់ដែរឬទេ ដើម្បីធ្វើការវាយតម្លៃបឋមទៅលើការដោះសា និងដាក់បញ្ជូនសេចក្តីជូនដំណឹងអំពីការឆ្លើយតបក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃប្រតិទិន ដែលកំណត់ដោយវិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម ឬតើពិតជាមានការចាំបាច់ដែរឬទេដែលគេត្រូវស្នើសុំពន្យាពេលវេលាក្នុងការដាក់បញ្ជូនសេចក្តីជូនដំណឹងអំពីការឆ្លើយតបស្របទៅតាមប្រការ៨១?
- តើពិតជាមានបណ្តឹងតបមែនដែរឬទេ ដែលត្រូវដាក់បញ្ជូនទៅក្នុងដំណើរការមជ្ឈត្តការ? តើបណ្តឹងតបទាំងនោះគួរត្រូវបានរៀបចំឡើងដោយគ្រាន់តែឆ្លើយតបទៅនឹងលក្ខខណ្ឌតម្រូវអប្បបរមាដែលកំណត់ ឬក៏ត្រូវរៀបចំលម្អិត និងភ្ជាប់ជាមួយឯកសារភស្តុតាងទាំងអស់ដែលមាន?

ដោយអនុលោមតាមប្រការ៣៥.២ នៃវិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. គឺថាបន្ទាប់ពីសេចក្តីថ្លែងនៃលក្ខខណ្ឌយោងត្រូវបានរៀបចំរួច គេនឹងមិនអនុញ្ញាតឱ្យមានការទាមទារជាថ្មីណាមួយឡើយដោយគ្មានការ

អនុញ្ញាតពីវេទិកាមជ្ឈត្តកម្ម។[47] ប្រសិនបើភាគីឆ្លើយតបមានបំណងចង់បញ្ចូលភាគីវិវាទណាមួយបន្ថែម ដោយអនុលោមទៅតាមប្រការ៣៥.៥ និងប្រការ៣៦ វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. ភាគីឆ្លើយតបត្រូវតែមានការយកចិត្តទុកដាក់ដោយហ្មត់ចត់ក្នុងការធ្វើបែបនោះ ក្នុងរយៈពេលកំណត់ ដែលវិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម.បានចែង។[48] ប្រសិនបើមានបណ្តឹងជំទាស់ទៅនឹងយុត្តាធិការរបស់វេទិកាមជ្ឈត្តកម្ម ភាគីឆ្លើយតបត្រូវពិចារណាជ្រើសរើសយកការដាក់បញ្ជូនសេចក្តីជូនដំណឹងអំពីការឆ្លើយតប ដែលសរសេររៀបរាប់មានខ្លឹមសារសង្ខេបតាមទម្រង់ខ្លីដោយផ្តោតទៅលើតែអង្គសេចក្តីនៃវិវាទបានហើយ។ ចំណុចខ្លះដែលគួរពិចារណា មុនពេលចាប់ផ្តើមមជ្ឈត្តការសម្រាប់ភាគីឆ្លើយតបៈ

- ភាគីឆ្លើយតប ត្រូវយកចិត្តទុកដាក់អំពីការកំហិតពេលវេលានៃការដាក់បញ្ជូនសេចក្តីជូនដំណឹងអំពីការឆ្លើយតប។ ក្នុងករណីមិនមានពេលគ្រប់គ្រាន់ គឺអាចស្នើសុំទៅ ម.ជ.ម. នូវរយៈពេលសមស្របបន្ថែមសម្រាប់ការឆ្លើយតប ក្នុងករណីដែលត្រូវគោរពតាមការកំហិតពេលវេលាភាគីឆ្លើយតបអាចត្រូវដាក់បញ្ជូនសេចក្តីជូនដំណឹងអំពីការឆ្លើយតប មិនពេញលេញទៅមុនហើយព័ត៌មានផ្សេងទៀតអាចត្រូវបញ្ជូនទៅតាមក្រោយតាមការស្នើសុំរបស់ ម.ជ.ម.។
- ភាគីឆ្លើយតបត្រូវយកចិត្តទុកដាក់លើការបដិសេធអំពីយុត្តាធិការនៃវេទិកាមជ្ឈត្តកម្ម ខ្លួនអាចនឹងមាន។
- ភាគីឆ្លើយតបអាចអញ្ជើញទៅកាន់ ម.ជ.ម. ផ្ទាល់ដើម្បីសាកសួរព័ត៌មានជាមុន ដើម្បីធានាការដាក់បញ្ជូនសេចក្តីជូនដំណឹងអំពីការឆ្លើយតបមានភាពរលូន។[49]

## ២.៣. កិច្ចព្រមព្រៀងមជ្ឈត្តកម្ម

កិច្ចព្រមព្រៀងមជ្ឈត្តកម្ម គឺជាចំណុចចាប់ផ្តើមដំបូងមុនឈានដល់ការបើកវេទិកាមជ្ឈត្តកម្មជាការព្រមព្រៀងមជ្ឈត្តកម្ម ដែលស្តែងចេញឡើងភាគច្រើនក្រោមទម្រង់ជាខចែងក្នុងកិច្ចសន្យាពាណិជ្ជកម្ម។[50]

កិច្ចព្រមព្រៀងមជ្ឈត្តកម្ម គឺជាការព្រមព្រៀងរវាងភាគីនៃកិច្ចសន្យាពាណិជ្ជកម្មថានឹងព្រមព្រៀងដោះស្រាយវិវាទ ដែលកើតចេញពីកិច្ចសន្យានោះតាមរយៈមជ្ឈត្តការផ្នែកពាណិជ្ជកម្ម នៅទីតាំងនៃមជ្ឈមណ្ឌលមជ្ឈត្តការផ្នែកពាណិជ្ជកម្មណាមួយ។

វិវាទពាណិជ្ជកម្មត្រូវដោះស្រាយតាមតរយៈយន្តការមជ្ឈត្តការ ក្នុងករណីដែលមានខចែងស្តីពីមជ្ឈត្តការត្រូវបានសរសេរជាលាយលក្ខណ៍អក្សរនៅក្នុងកិច្ចសន្យារបស់គូភាគី ឬប្រសិនបើពួកគេព្រមព្រៀងទទួលយក

[47] វិធានស្តីពីមជ្ឈត្តការ, ២៨ មីនា ២០២១, ប្រការ៣៥.២
[48] វិធានស្តីពីមជ្ឈត្តការ, ២៨ មីនា ២០២១, ប្រការ៣៥.៥
[49] លោក ហួន សុខនីម, កម្រងវិធីសាស្ត្រគន្លឹះនីតិវិធីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, បោះពុម្ពឆ្នាំ២០២១, ទំព័រ៣០
[50] វិធានស្តីពីមជ្ឈត្តការ, ២៨ មីនា ២០២១, ប្រការ៣៤.៣

ការដោះស្រាយតាមមជ្ឈត្តការនៅក្នុងកិច្ចព្រមព្រៀងស្ដីពីមជ្ឈត្តការត្រូវជាលាយលក្ខណ៍អក្សរដោយឡែកមួយ។ កិច្ចព្រមព្រៀងទទួលយកមជ្ឈត្តការត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ប៉ុន្តែលក្ខខណ្ឌតម្រូវនេះអាចបំពេញបានដោយការសរសេរលិខិតឆ្លើយឆ្លងគ្នា ដែលបង្ហាញឱ្យឃើញពីការព្រមព្រៀងទទួលយកការធ្វើមជ្ឈត្តកានោះ។ ការសរសេរលិខិតឆ្លើយឆ្លងបែបនេះ អាចមានភាពគ្រប់គ្រាន់ក្នុងការធ្វើជាកិច្ចព្រមព្រៀងទទួលយកដំណោះស្រាយដោយមជ្ឈត្តការបាន។[51]

ដើម្បីដោះស្រាយវិវាទរបស់ខ្លួនដោយមជ្ឈត្តការ គូភាគីត្រូវមានខចែងស្ដីពីមជ្ឈត្តការដែលមានសុពលភាព និង អាចអនុវត្តបាននៅក្នុងកិច្ចសន្យារបស់ខ្លួន។ ដើម្បីឱ្យខចែងនោះមានសុពលភាព ខចែងនោះត្រូវសរសេរជាលាយលក្ខណ៍អក្សរ ហើយមានភាពច្បាស់លាស់។ ប្រការនេះមានន័យថា ខចែងស្ដីពីមជ្ឈត្តការត្រូវបញ្ជាក់ច្បាស់ថា គូភាគីចង់ដោះស្រាយដោយមជ្ឈត្តការក្នុងករណីមានវិវាទកើតឡើង។ ប៉ុន្តែក្រៅពីលក្ខខណ្ឌតម្រូវសាមញ្ញទាំងនេះ ខចែងនេះក៏ត្រូវស្ថិតលើគូភាគី ឬមេធាវីរបស់ពួកគេ ដែលជាអ្នកបន្ថែមចំណុចលម្អិតសំខាន់ៗ។ ក្នុងស្ថានភាពមួយចំនួន ខចែងស្ដីពីមជ្ឈត្តការជាមូលដ្ឋាន ដែលបានរៀបរាប់ដូចខាងលើ គឺមានភាពគ្រប់គ្រាន់។ ប៉ុន្តែក្នុងស្ថានភាពផ្សេងទៀត ចំណុចលម្អិតបន្ថែមទៀតអាចត្រូវការជាចាំបាច់។ ក្នុងករណីទាំងពីរនេះ ខចែងស្ដីពីមជ្ឈត្តការ គឺមានសារៈសំខាន់យ៉ាងខ្លាំង ក្នុងដំណោះស្រាយដោយមជ្ឈត្តការដ៏ជោគជ័យ។[52]

នៅពេលកំណត់អំពីចំណុចលម្អិត ដែលត្រូវបន្ថែមក្នុងខចែងស្ដីពីមជ្ឈត្តការជាមូលដ្ឋាននោះគូភាគីត្រូវធ្វើការពិចារណាអំពីបញ្ហាគន្លឹះមួយចំនួន។ បញ្ហាទាំងនេះនឹងកើតឡើងនៅក្នុងដំណើរការមជ្ឈត្តការ។ មេធាវីដ៏ល្អម្នាក់ត្រូវគិតទុកជាមុនអំពីបញ្ហាទាំងនេះ ហើយនៅក្នុងដំណើរការចុះកិច្ចសន្យាដំបូងត្រូវយកចិត្តទុកដាក់ជាពិសេសចំពោះបញ្ហាទាំងនេះ ដើម្បីជួយកូនក្ដីរបស់ខ្លួនឱ្យមានប្រៀបប្រសិនបើមានតម្រូវការធ្វើមជ្ឈត្តការ។[53]

### ២.៣.១. គោលការណ៍ទូទៅនៃកិច្ចព្រមព្រៀងមជ្ឈត្តកម្ម

ជាអានុភាពគតិយុត្តនៅពេលដែលបុគ្គលនៃកិច្ចព្រមព្រៀងមជ្ឈត្តការ បានព្រមព្រៀងគ្នាដើម្បីដោះស្រាយវិវាទរបស់ខ្លួនតាមយន្តការអ្វីមួយ បែបនោះបានន័យថាភាគីនៃវិវាទទាំងអស់ព្រមទទួលយកការព្រមព្រៀងគ្នាជ្រើសរើសយកមជ្ឈត្តការជាយន្តការដើម្បីដោះស្រាយវិវាទរបស់ខ្លួន។ ក្នុងន័យនេះភាគីនៃវិវាទនឹងបោះបង់ចោលការដោះស្រាយវិវាទតាមប្រព័ន្ធតុលាការ។ ជាគោលការណ៍នៃកិច្ចព្រមព្រៀងមជ្ឈត្តកម្មក៏មានការព្រមព្រៀងផងដែរ ទៅលើដំណើរការនៃនីតិវិធីមជ្ឈត្តកម្មដូចជាព្រមព្រៀងលើខចែងស្ដីពីមជ្ឈត្តការជាមូលដ្ឋានក្នុងកិច្ចសន្យា ឬជាការតាក់តែងខចែងស្ដីអំពីមជ្ឈត្តការក្នុងការតាក់តែងខចែងនេះ បានធ្វើឱ្យគូភាគីនៃកច្ចព្រមព្រៀងអាចតាក់

[51] ច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, លេខ នស/រកម/០៥០៦/០១០, ០៥ ឧសភា ២០០៦, មាត្រា៧

[52] មេធាវី ស្ទីវិន អ៊ែន អស្ទើរមីឡឺរ៍, ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅកម្ពុជា, បោះពុម្ពឆ្នាំ២០១០, ទំព័រ១៥៣

[53] មេធាវី ស្ទីវិន អ៊ែន អស្ទើរមីឡឺរ៍, ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅកម្ពុជា, បោះពុម្ពឆ្នាំ២០១០, ទំព័រ១៥៤

តែងនូវខចែងមួយចំនួនក្នុងកិច្ចព្រមព្រៀងនោះដូចជាការកំណត់មជ្ឈត្តការគួរភ្ជាប់កាតព្វកិច្ចដែរឬយ៉ាងណា? មជ្ឈត្តការនោះគួរតែជាមជ្ឈត្តការមានការគ្រប់គ្រង ឬមជ្ឈត្តការពិសេសកំណត់ក្នុងខចែងអាចកំណត់ពីទីកន្លែង ការជ្រើសរើសចំនួននៃមជ្ឈត្តករ ការកំណត់វេទិកាមជ្ឈត្តកម្ម និងកំណត់អំពីវិធានដើម្បីគ្រប់គ្រងវេទិកាមជ្ឈត្តកម្ម ភាគីព្រមព្រៀងកំណត់អំពីភាសាដែលត្រូវប្រើប្រាស់ក្នុងវេទិការមជ្ឈត្តកម្ម និងវិធានច្បាប់ក្នុងការដោះស្រាយវិវាទ ផងដែរ ដែលអ្វីទាំងអស់នេះនឹងជួយសម្រួលដល់ភាគីនៃកិច្ចព្រមព្រៀងមជ្ឈត្តកម្មឱ្យមានភាពងាយស្រួលក្នុងការ ដោះស្រាយវិវាទរបស់ខ្លួន។

### ២.៣.២. លក្ខខណ្ឌសុពលភាព

សុពលភាពនៃកិច្ចព្រមព្រៀងមជ្ឈត្តការ គឺសំដៅដល់អានុភាពគតិយុត្តនៃកិច្ចព្រមព្រៀង ដែលចែងអំពីការ ដោះស្រាយវិវាទរវាងគូភាគីវិវាទនៃកិច្ចសន្យាពាណិជ្ជកម្មតាមរយៈយន្តការមជ្ឈត្តការ ក្នុងនោះទាមទារឱ្យមាន ភាពសមស្របទៅតាមលក្ខខណ្ឌ តម្រូវតាមបទបញ្ញត្តិនៃច្បាប់ជាធរមានពាក់ព័ន្ធនឹងមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។ លក្ខខណ្ឌដំបូងបំផុតនោះ គឺទាមទារឱ្យកិច្ចព្រមព្រៀងត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរ ព្រោះកាលដែលមិន បានចែងច្បាស់នូវការព្រមព្រៀងនេះ អាចបង្កជាបញ្ហាក្នុងការរារាំងដល់ដំណើរការនៃមជ្ឈត្តការ ជាពិសេសគឺមិន មាននូវទឡ្ហីករណ៍ក្នុងការបញ្ជាក់អំពីភាពច្បាស់លាស់ និងឆន្ទៈពិតប្រាកដរបស់គូភាគីក្នុងការដោះស្រាយវិវាទ តាមមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។ ក្នុងបរិបទនៃ ម.ជ.ម. ជាដំណោះស្រាយដល់បញ្ហាដែលបានជម្រាបជូនខាង លើនេះ ម.ជ.ម. បានតាក់តែងឡើងនូវខចែងគំរូ ឬគំរូនៃកិច្ចព្រមព្រៀងមជ្ឈត្តកម្ម ដែលភាគីវិវាទត្រូវអនុវត្តតាម។ បន្ថែមពីលើនេះ ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មបានបញ្ជាក់ផងដែរថាកិច្ចព្រមព្រៀងជាលាយលក្ខណ៍ អក្សរក្នុងបរិបទនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម គឺសំដៅដល់ការព្រមព្រៀងក្នុងឯកសារតាមរយៈការចុះហត្ថលេខា ដោយភាគីវិវាទ ឬមធ្យោបាយទូរគមនាគមន៍តាមប្រព័ន្ធអេឡិចត្រូនិច ដែលអាចផ្តល់នូវកំណត់ត្រាអំពីការព្រម ព្រៀងគ្នាបាន។[54]

#### ២.៣.២.១. ការព្រមព្រៀង

ជាគោលការណ៍នៃកិច្ចព្រមព្រៀង គឺជាការបង្ហាញឆន្ទៈរបស់គូភាគី ថានឹងព្រមធ្វើអ្វីមួយដែលស្រប នឹងឆន្ទៈរបស់គូរភាគីរបស់ខ្លួន។ ជាក់ស្តែងនៅក្នុងបញ្ញត្តិនៃច្បាប់ភាគីនៃកិច្ចសន្យា ឬកិច្ចព្រមព្រៀងត្រូវបានផ្តល់ ឱ្យនូវសេរីភាពនៃឆន្ទៈ និងការព្រមព្រៀងគ្នាក្នុងការធ្វើកិច្ចព្រមព្រៀង។ ដោយឡែកនៅក្នុងច្បាប់ស្តីពីមជ្ឈត្តការ ផ្នែកពាណិជ្ជកម្មវិញនោះ តម្រូវឱ្យមានការព្រមព្រៀងផងដែររវាងគូភាគីនៃវិវាទចំពោះការព្រមព្រៀងមានន័យ ថាកិច្ចព្រមព្រៀងមជ្ឈត្តការបានបង្កើតឡើងដោយគ្មានការបង្ខិតបង្ខំ ការភ័ន្តច្រឡំ ការគំរាមកំហែង និងការកេង ចំណេញហួសហេតុពីភាគីណាមួយ ពោលគឺកិច្ចព្រមព្រៀងនេះបង្កើតឡើងដោយគ្មានវិការៈ។

[54] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, លេខ នស/រកម/០៥០៦/០១០, ០៥ ឧសភា ២០០៦, មាត្រា៧

ជាមួយគ្នានេះផងដែរ ច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម មាត្រា២ ចំណុច ឃ ក៏បានបញ្ជាក់បង្ហាញផងដែរថា កិច្ចព្រមព្រៀងផ្សះផ្សា គឺជាកិច្ចព្រមព្រៀងរវាងភាគីវិវាទក្នុងការធ្វើមជ្ឈត្តការវិវាទទាំងអស់ ឬវិវាទបែបណាមួយដែលកើតឡើងរវាងភាគីវិវាទនានា ដោយគោរពតាមទំនាក់ទំនងកំណត់ដោយច្បាប់នោះ ទោះបីជាមានកិច្ចសន្យា ឬគ្មានក៏ដោយ។[55] ដូចអ្វីដែលបានរៀបរាប់ខាងលើ ជាមួយនឹងការព្រមព្រៀងភាគីនៃកិច្ចព្រមព្រៀងអាចកំណត់ខ្លឹមសារក្នុងកិច្ចព្រមព្រៀមដើម្បីដោះស្រាយវិវាទតាមប្រព័ន្ធណាមួយនោះ ដូចជាមជ្ឈត្តការជាដើម ដែលក្នុងនេះភាគីវិវាទ អាចព្រមព្រៀងលើមជ្ឈត្តករ និងចំនួនរបស់មជ្ឈត្តករព្រមព្រៀងលើវិធានច្បាប់ដើម្បីអនុវត្ត ព្រមព្រៀងលើទីកន្លែងសម្រាប់វេទិកាមជ្ឈត្តកម្ម ព្រមព្រៀងលើពេលវេលាសម្រាប់ធ្វើសវនាការ និងការព្រមព្រៀងលើភាសាក្នុងនីតិវិធីមជ្ឈត្តការផងដែរ។[56]

ជារួមមក ការព្រមព្រៀង គឺជាការយល់ស្របលើកិច្ចសន្យារបស់គូភាគីវិវាទដើម្បីឈានយកវិធានការក្នុងការដោះស្រាយវិវាទរបស់ខ្លួនមុនពេលមានវិវាទកើតឡើង ឬក្នុងពេលមានវិវាទដើម្បីឱ្យការដោះស្រាយវិវាទនោះមានប្រសិទ្ធភាព ចំគោលដៅ និងយុត្តិធម៌សម្រាប់ភាគីវិវាទនីមួយៗ។

**២.៣.២.២. ការធ្វើឡើងជាលាយលក្ខណ៍អក្សរ**

នៅកម្ពុជាកិច្ចព្រមព្រៀងមជ្ឈត្តកម្ម គឺតម្រូវឱ្យធ្វើជាលាយលក្ខណអក្សរ។ ការធ្វើជាលាយលក្ខណ៍អក្សរនេះសំដៅទៅលើកិច្ចព្រមព្រៀងដែលស្ថិតនៅក្នុងឯកសារចុះហត្ថលេខាដោយភាគីវិវាទ ឬដែលស្ថិតនៅក្នុងការផ្ទេរលិខិតស្នាម ឬដែលស្ថិតនៅក្នុងការប្ដូរគ្នាទៅវិញទៅមកនូវពាក្យទាមទារ ឬពាក្យដោះសារ ដែលក្នុងនោះភាគីវិវាទមួយបានទាមទារហើយមិនត្រូវបានបដិសេធដោយភាគីវិវាទម្ខាងទៀត ជារួមឯកសារដែលគូភាគីទាំងពីរបានព្រមព្រៀងគ្នា និងបានចុះហត្ថលេខាលើលិខិតនោះ។[57] ម៉្យាងទៀតដើម្បីធ្វើឱ្យកាន់តែមានភាពច្បាស់លាស់ និងមានសុពលភាពពេញលេញនោះ ភាគីវិវាទគួរតែកំណត់ឱ្យបានច្បាស់អំពីសិទ្ធិ និងការរៀបចំនូវដំណើរការនៃមជ្ឈត្តការដូចជាកំណត់អំពីទីកន្លែង ភាសា ចំនួនមជ្ឈត្តករ ច្បាប់ដែលត្រូវយកមកអនុវត្ត និងនីតិវិធីជាដើម។

**២.៣.២.៣. សមត្ថភាពគូភាគី**

បុគ្គលដែលអាចចុះកិច្ចសន្យាបាន ហើយកិច្ចសន្យានោះមានសុពលភាព លុះត្រាតែបុគ្គលនោះមានសមត្ថភាពគតិយុត្តតាមច្បាប់បានកំណត់។ បុគ្គលទាំងឡាយណាដែលក្រមរដ្ឋប្បវេណីបានកម្រិតនូវសមត្ថភាពរបស់បុគ្គលនោះដូចជាអនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ និងជននៅក្រោមហិតូបត្ថម្ភ គឺជាបុគ្គលដែលគ្មានសមត្ថភាពគ្រប់គ្រាន់ក្នុងការចុះកិច្ចសន្យា។ ដូច្នេះក្រៅពីបុគ្គល ដែលក្រមរដ្ឋប្បវេណីបានកំណត់ដូច

---

[55] ច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, លេខ នស/រកម/០៥០៦/០១០, ០៥ ឧសភា ២០០៦, មាត្រា២

[56] វិធានស្ដីពីមជ្ឈត្តការ, ២៨ មីនា ២០២១, ប្រការ៣៣.១

[57] ច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, លេខ នស/រកម/០៥០៦/០១០, ០៥ ឧសភា ២០០៦, មាត្រា៧

មានរៀបរាប់ ត្រូវបានចាត់ទុកថាជាបុគ្គលដែលមានសមត្ថភាពគ្រប់គ្រាន់ដែលអាចចុះនូវកិច្ចសន្យា ឬកិច្ចព្រមព្រៀងបាន។ សមត្ថភាពគូភាគី សំដៅលើអនុភាពគតិយុត្តដែលបុគ្គលអាចធ្វើសកម្មភាពរបស់ខ្លួនតាមការកំណត់របស់ច្បាប់ ក្នុងការកំណត់សមត្ថភាពដូចជា សមត្ថភាពខាងឆន្ទៈ និងសមត្ថភាពក្នុងការធ្វើសកម្មភាព។

សមត្ថភាពខាងឆន្ទៈ គឺជាសមត្ថភាពដែលអាចយល់ដឹង និងវិនិច្ឆ័យបានអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន។[58] បុគ្គលគ្រប់រូបមានសមត្ថភាពទទួលសិទ្ធិ ប៉ុន្តែបុគ្គលគ្រប់រូបមិនមែនសុទ្ធតែអាចធ្វើកិច្ចការជំនួញដែលមានសុពលភាពដោយឯកឯងគ្រប់ពេលនោះទេ។ ឧទាហរណ៍៖ ទោះបីជាក្មេងអាយុ១០ឆ្នាំ និងបុគ្គលដែលកំពុងតែស្រវឹងស្រាខ្លាំងបានសន្យាទិញទំនិញ ដែលមានតម្លៃថ្លៃក៏ដោយ ក៏មិនចាំបាច់ត្រូវទទួលស្គាល់នូវអានុភាពនៃកិច្ចសន្យាបែបនេះនោះទេ។ ដូច្នេះក្រមរដ្ឋប្បវេណីបានបញ្ញត្តិនូវប្រព័ន្ធសមត្ថភាពខាងឆន្ទៈនេះឡើងដើម្បីអាចលុបចោលនូវសកម្មភាពរបស់បុគ្គលដែលខ្វះសមត្ថភាពខាងឆន្ទៈ។

សមត្ថភាពខាងឆន្ទៈ មានន័យថាសកម្មភាពក្នុងស្ថានភាពដែលអាចយល់ និងវិនិច្ឆ័យបាននូវលទ្ធផលតាមផ្លូវច្បាប់នូវសកម្មភាពរបស់ខ្លួន។ ផ្ទុយទៅវិញនៅពេលធ្វើសកម្មភាពអ្វីមួយ មានករណីជាច្រើនដែលមិនអាចធ្វើការវិនិច្ឆ័យថាអ្នកធ្វើសកម្មភាពនោះមាន ឬមិនមានសមត្ថភាពខាងឆន្ទៈ ហើយការបញ្ជាក់ក៏មិនមានភាពងាយស្រួលនោះទេ។ ឧទាហរណ៍៖ ក្មេងដែលមានអាយុស្មើគ្នាក៏ដោយ ក៏សមត្ថភាពមានគម្លាតខុសគ្នាដែរ ហើយករណីមានជំងឺ ផ្នែកបញ្ញាស្មារតី និងការស្រវឹងស្រា ក៏មានការណ៍ជាច្រើនមិនអាចបញ្ជាក់អំពីស្ថានភាពនៃកម្រិតកង្វះសមត្ថភាពខាងឆន្ទៈបាននោះទេ។ ប្រសិនបើមិនអាចបញ្ជាក់អំពីភាពអាច ឬមិនអាចក្នុងការលុបចោលកិច្ចសន្យា ឬសកម្មភាពឯកតោភាគីបានទេ វាធ្វើឱ្យប៉ះពាល់ដល់សុវត្ថិភាពពាណិជ្ជកម្មរបស់ភាគីម្ខាងទៀត ព្រមទាំងមិនអាចការពារជនដែលខ្វះសមត្ថភាពខាងឆន្ទៈបានគ្រប់គ្រាន់ទៀតផង។

**២.៣.២.៤. ទំនាក់ទំនងគតិយុត្ត**

ទោះបីជាយ៉ាងណាក៏ដោយ ដើម្បីឱ្យកិច្ចព្រមព្រៀងមជ្ឈត្តការនេះមានសុពលភាពគឺទាមទារឱ្យមាននូវទំនាក់ទំនងគតិយុត្តិដែលពុំអាចខ្វះបានឡើយនៅក្នុងវិស័យពាណិជ្ជកម្មអន្តរជាតិ។[59] នៅក្នុងន័យនេះទំនាក់ទំនងគតិយុត្ត សំដៅដល់ទំនាក់ទំនងតាមផ្លូវច្បាប់រវាងភាគីទាំងពីរក្នុងការបង្កើតនូវកិច្ចសន្យា។

**២.៣.២.៥. កម្មវត្ថុនៃវិវាទ**

ថ្វីត្បិតតែភាគីមានសេរីភាពក្នុងការជ្រើសរើសយកយន្តការមជ្ឈត្តការ មកធ្វើការដោះស្រាយវិវាទរបស់ខ្លួនក៏ពិតមែន ប៉ុន្តែដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម គឺបានកម្រិតត្រឹមការ

---

[58] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/០៥១១/០០៧, ០៨ ធ្នូ ២០០៧, មាត្រា១៤

[59] មាត្រា២ នៃអនុសញ្ញាទីក្រុងញូវយ៉ក់ស្តីពី ការទទួលស្គាល់ និងការប្រតិបត្តិសេចក្តីសម្រេចមជ្ឈត្តករបរទេស និងមាត្រា ៧ (ជម្រើសទី ២) នៃUNICITRAL Model Law

ដោះស្រាយវិវាទផ្នែកពាណិជ្ជកម្មតែប៉ុណ្ណោះ។ បាននន័យថាកម្មវត្ថុដែលអាចធ្វើឱ្យកិច្ចព្រមព្រៀងមានសុពលភាពចំពោះមជ្ឈត្តការ លុះត្រាតែកម្មវត្ថុនៃវិវាទនោះជារឿងដែលទាក់ទងទៅនឹងពាណិជ្ជកម្ម ដែលមិនធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងជាកម្មវត្ថុស្របច្បាប់។ នៅក្នុងកិច្ចព្រមព្រៀងមជ្ឈត្តកម្ម ភាគីបានកំណត់ថារាល់វិវាទកើតឡើងរវាងនិយោជក និងនិយោជិតត្រូវធ្វើការដោះស្រាយតាមរយៈមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។ ក្នុងករណីនេះកម្មវត្ថុនៃវិវាទមិនមែនជាកម្មវត្ថុនៃពាណិជ្ជកម្មទេ គឺពាក់ព័ន្ធទៅនឹងវិវាទការងារ។ ដូច្នេះកិច្ចព្រមព្រៀងនេះមិនមានសុពលភាពចំពោះមជ្ឈត្តការផ្នែកពាណិជ្ជកម្មទេ។

## ២.៤. នីតិវិធីនៃមជ្ឈត្តការពាណិជ្ជកម្ម

ជាការពិតណាស់ ដើម្បីឱ្យមជ្ឈត្តការពាណិជ្ជកម្មអាចដំណើរការទៅបាន គឺអាស្រ័យលើគូភាគីវិវាទត្រូវបានទទួលការយកចិត្តទុកដាក់ស្មើៗគ្នា និងត្រូវបានផ្តល់ឱកាសពេញលេញ ដើម្បីបង្ហាញពីរឿងរ៉ាវរបស់ខ្លួនរួមទាំងសិទ្ធិតែងតាំងជនណាម្នាក់ឱ្យធ្វើជាអ្នកតំណាងរបស់ខ្លួនបាន។[60] ភាគីវិវាទអាចព្រមព្រៀង ឬមិនព្រមព្រៀងលើនីតិវិធីដែលវេទិកាមជ្ឈត្តកម្មត្រូវអនុវត្តដើម្បីចាត់ចែងដំណើរការមជ្ឈត្តការ។ ក្នុងករណីមិនមានការព្រមព្រៀងលើនីតិវិធីនោះទេ វេទិកាមជ្ឈត្តកម្មអាចចាត់ចែងនូវការធ្វើមជ្ឈត្តការ ទៅតាមបែបបទណាដែលវេទិកាយល់ឃើញថាសមស្របដោយអនុលោមតាមនៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។ អំណាចដែលត្រូវបានប្រគល់ឱ្យទៅវេទិកាមជ្ឈត្តកម្មទាំងអំណាចក្នុងការកំណត់ពីភាពយកជាការបាននៃភស្តុតាងណាមួយ។[61] វេទិកាមជ្ឈត្តកម្មអាចប្រជុំនៅទីកន្លែងណាមួយ ដែលសមស្របក្នុងព្រះរាជាណាចក្រកម្ពុជាលើកលែងតែភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះក្នុងការពិគ្រោះយោបល់ក្នុងចំណោមសមាជិករបស់វេទិកា ស្តាប់សាក្សី ស្តាប់អ្នកជំនាញការ ស្តាប់ភាគីវិវាទ ឬធ្វើអធិការកិច្ចលើសម្ភារៈ កម្មសិទ្ធិ ឬឯកសារដទៃទៀត។

### ២.៤.១. ការជ្រើសរើសស្ថាប័នមជ្ឈត្តការពាណិជ្ជកម្ម

ការជ្រើសយន្តការមជ្ឈត្តការ មកធ្វើជាជ្រើសសម្រាប់ការដោះស្រាយវិវាទពាណិជ្ជកម្មអាចធ្វើឡើងបានតាមរយៈពីររបៀប គឺការព្រមព្រៀងគ្នាទៅតាមស្ថាប័នមជ្ឈត្តការតាមកិច្ចព្រមព្រៀងមជ្ឈត្តការនិងការព្រមព្រៀងគ្នាទៅតាមស្ថាប័នមជ្ឈត្តការក្រោយពេលមានវិវាទកើតឡើង។

#### ២.៤.១.១. ការព្រមព្រៀងតាមកិច្ចសន្យារបស់គូភាគី

នៅពេលដែលភាគីទាំងពីរបានព្រមព្រៀងគ្នានៅក្នុងកិច្ចព្រមព្រៀងមជ្ឈត្តកម្ម នៅពេលដែលមានវិវាទកើតឡើង វិវាទនោះគឺត្រូវតែដោះស្រាយតាមរយៈមជ្ឈត្តការ លើកលែងតែភាគីទាំងពីរធ្វើការព្រមព្រៀងគ្នាផ្សេងពីនេះ

[60] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, លេខ នស/រកម/០៥០៦/០១០, ០៥ ឧសភា ២០០៦, មាត្រា២៦

[61] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, លេខ នស/រកម/០៥០៦/០១០, ០៥ ឧសភា ២០០៦, មាត្រា២៧

មានន័យថា នៅពេលមានវិវាទភាគីណាមួយនៃកិច្ចព្រមព្រៀងមជ្ឈត្តកម្មអាចធ្វើការប្ដឹងទៅមជ្ឈត្តការបានដោយសំអាងលើកិច្ចព្រមព្រៀងមជ្ឈត្តកម្មនោះ។[62]

**២.៤.១.២. ការព្រមព្រៀងតាមការបង្គាប់របស់ស្ថាប័នតុលាការ**

ដូចអ្វីដែលបានរៀបរាប់ខាងលើក្ដី ក៏ភាគីវិវាទនូវតែមានសិទ្ធិប្ដឹងទៅតុលាការបាន។ ប៉ុន្តែនៅពេលវិវាទដែលបានដាក់ទៅតុលាការជាកម្មវត្ថុនៃកិច្ចព្រមព្រៀងមជ្ឈត្តកម្ម តុលាការត្រូវតែបញ្ជូនវិវាទនោះទៅមជ្ឈត្តការវិញនៅពេលដែលមានការស្នើសុំពីភាគីវិវាទម្ខាងទៀត លើកលែងតែតុលាការរកឃើញថាកិច្ចព្រមព្រៀងមជ្ឈត្តការនោះត្រូវទុកជាមោឃៈ ដោយមិនបានបំពេញនូវលក្ខខណ្ឌសុពលភាព ឬមិនអាចអនុវត្តបាន។

ជាទូទៅកិច្ចព្រមព្រៀងមជ្ឈត្តការត្រូវបានចែងនៅក្នុងកិច្ចសន្យារវាងភាគីទាំងពីរ។ ក្នុងករណីនេះទោះបីជាកិច្ចសន្យារវាងភាគីទាំងពីរត្រូវបានទុកជាមោឃៈក៏ដោយ ក៏វាមិននាំឱ្យបាត់បង់នូវសុពលភាពនៃខចែងពីកិច្ចព្រមព្រៀងមជ្ឈត្តកម្មដែរ។

**២.៤.១.៣. ការព្រមព្រៀងនៅពេលដែលមានវិវាទ**

នៅពេលដែលភាគីវិវាទមិនបានធ្វើការព្រមព្រៀងគ្នាជាមុន ឬបានធ្វើការព្រមព្រៀងគ្នាក្នុងការដោះស្រាយវិវាទតាមរយៈមជ្ឈត្តការក៏ដោយ តែការព្រមព្រៀងនោះមិនបានកំណត់ចំពោះបញ្ហាវិវាទដែលកើតឡើង ក៏ភាគីវិវាទអាចធ្វើការព្រមព្រៀងគ្នានៅពេលក្រោយបានដែរ។ ការព្រមព្រៀងគ្នាក្រោយពេលមានវិវាទកើតឡើងនេះ ភាគីវិវាទអាចព្រមព្រៀងគ្នាទៅមជ្ឈត្តការតែម្ដង ឬធ្វើឡើងនូវកិច្ចព្រមព្រៀងមជ្ឈត្តកម្មថ្មីមួយក្រោយពេលវិវាទដែលកំណត់ពីនីតិវិធី និងបញ្ហាវិវាទដែលមាននៅក្នុងកិច្ចព្រមព្រៀងនោះ។[63]

ឧទាហរណ៍ ភាគីមានកិច្ចព្រមព្រៀងមជ្ឈត្តកម្មដែលចែងថា រាល់វិវាទដែលមិនអាចធ្វើការដោះស្រាយបានទាក់ទងនឹងការដឹកជញ្ជូនត្រូវយកទៅដោះស្រាយតាមរយៈមជ្ឈត្តការ ប៉ុន្តែនៅពេលដែលមានវិវាទកើតឡើង បញ្ហាវិវាទគឺទាក់ទងនឹងការប្រគល់ប្រាក់។ ដូច្នេះប្រសិនបើគូភាគីវិវាទចង់ដោះស្រាយវិវាទនេះតាមរយៈយន្តការមជ្ឈត្តការ គូភាគីវិវាទទាំងពីរអាចបង្កើតនូវកិច្ចព្រមព្រៀងមជ្ឈត្តកម្មថ្មីមួយទៀត ដែលកំណត់លើការដោះស្រាយវិវាទទាក់ទងនឹងការប្រគល់ប្រាក់នោះ។

## ២.៥. មជ្ឈត្តករបន្ទាន់

មជ្ឈត្តករបន្ទាន់ គឺជាយន្តការបែបទំនើបមួយដែលអាចឱ្យគូភាគីស្នើសុំវិធានការបណ្ដោះអាសន្ននៅមុនពេលវេទិកាមជ្ឈត្តកម្មត្រូវបានបង្កើតឡើង។[64] គោលបំណងជាប្រយោជន៍ដល់បុគ្គលចាំបាច់ដែលពាក់ព័ន្ធនឹង

[62] វិធានស្ដីពីមជ្ឈត្តការ, ២៨ មីនា ២០២១, ប្រការ៦៩

[63] ច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, លេខ នស/រកម/០៥០៦/០១០, ០៥ ឧសភា ២០០៦, មាត្រា២

[64] សិក្ខាសាលាស្ដីពីមជ្ឈត្តករបន្ទាន់ Emergency Arbitrator Webinar. | ការិយាល័យមេធាវី អូវីធី ឡាយអិន "អូវីធី ច្បាប់" OVT LION LAW OFFICE "OVT LAW"

យន្តការមជ្ឈត្តការនេះដើម្បីបំពេញបំណងនិងសេចក្តីត្រូវការរបស់ភាគី និងធ្វើឱ្យដំណើរការដោះស្រាយវិវាទមានភាពបត់បែន រហ័ស និងងាយស្រួលព្រមទាំងធ្វើឱ្យកាន់តែប្រសើរឡើង ពីព្រោះវាអាចផ្តល់ផលប្រយោជន៍ដល់គ្រប់បុគ្គលដែលពាក់ព័ន្ធនឹងដំណើរការមជ្ឈត្តការដែលរួមមាន ភាគីវិវាទ ម.ជ.ម. និងមជ្ឈត្តករ។ លើសពីនេះទៀតនោះ នៅក្នុងវិធានស្តីពីវិធានមជ្ឈត្តការបានធ្វើការកំណត់ឱ្យ ម.ជ.ម. អាចដំណើរការដោះស្រាយវិវាទពាណិជ្ជកម្មដោយតាមរយៈយន្តការមជ្ឈត្តករបន្ទាន់ តាមសំណើរសុំពីភាគីវិវាទចង់ឱ្យមានដំណោះស្រាយបន្ទាន់និងជាបណ្តោះអាសន្ននោះ បើប្រៀបទៅនឹងនីតិវិធីតុលាការ នេះត្រូវបានគេហៅថា នីតិវិធីចាត់ចែងរក្សាការពារ។ មជ្ឈត្តករបន្ទាន់ (Emergency Arbitrator) គឺជាមជ្ឈត្តករដែលបានចុះបញ្ជីជាមួយនឹង ម.ជ.ម. និងកំពុងប្រកបវិជ្ជាជីវៈនេះ ឬមានសុពលភាពពោលគឺជាសមាជិករបស់មជ្ឈមណ្ឌលនេះ ហើយត្រូវបានតែងតាំងឡើងដោយគណៈកម្មាធិការតែងតាំងនិងនីតិវិធី បន្ទាប់ពីមានការស្នើសុំអំពីនីតិវិធីនេះពីគូភាគីវិវាទដល់អគ្គលេខាធិការដ្ឋានរបស់ ម.ជ.ម.។ ជាទូទៅ មជ្ឈត្តករបន្ទាន់មានតែម្នាក់ប៉ុណ្ណោះ លើកលែងតែភាគីវិវាទតម្រូវឱ្យមានផ្សេងក្រៅពីនេះ ហើយក្នុងរយៈពេល ១៥ ថ្ងៃបន្ទាប់ពីមានការយល់ព្រមក្នុងការតែងតាំងនូវមជ្ឈត្តករបន្ទាន់ត្រូវចេញសេចក្តីបង្គាប់ ឬមជ្ឈត្តវិនិច្ឆ័យរបស់ខ្លួន ដែលជាវិធានការបណ្តោះអាសន្ន (Interim Measure) ចំពោះវិវាទរបស់ភាគីវិវាទនោះមុនពេលបង្កើតវេទិកាមជ្ឈត្តកម្ម។ ពេលដំណើរការវេទិកាមជ្ឈត្តកម្ម ជាបន្ទាប់មកមជ្ឈត្តករដែលត្រូវបានតែងតាំងជាមជ្ឈត្តករបន្ទាន់ មិនអាចចូលរួម ឬមានវត្តមានជាមួយនោះទេ។ ក៏ដូចគ្នាផងដែរ វេទិកាមជ្ឈត្តកម្មនឹងចេញនូវមជ្ឈត្តវិនិច្ឆ័យស្ថាពរមិនអាស្រ័យ ឬពឹងផ្អែកនឹងសេចក្តីបង្គាប់របស់មជ្ឈត្តករបន្ទាន់នោះដែរ។ ហេតុនេះ ចាប់តាំងពីការស្នើសុំរបស់ភាគីនៃវិវាទចំពោះការតែងតាំង ការដំណើរការ និងប្រតិបត្តិការទាំងមូលនៃការដោះស្រាយវិវាទពាណិជ្ជកម្មរបស់មជ្ឈត្តករបន្ទាន់។[65] ម្យ៉ាងទៀតនោះ ខណៈពេលដែរភាគីត្រូវបញ្ជូនសំណៅចម្លងនៃសំណើនោះមួយច្បាប់ទៅភាគីមួយទៀតទាំងអស់ ក្នុងពេលដំណាលគ្នាដែលដាក់សំណើរសុំវិធានការបណ្តោះអាសន្នចេញដោយមជ្ឈត្តករបន្ទាន់ ដែលសំណើទាំងនោះមានព័ត៌មានទាក់ទងនឹងលក្ខណៈនៃវិធានការដែលបានស្នើសុំ រួមផ្សំទាំងមូលហេតុដែលភាគីវិវាទបានស្នើសុំមានសិទ្ធិទទួលបានវិធានការនោះ និងសេចក្តីថ្លែងការដែលបានបញ្ជាក់ថា ភាគីវិវាទផ្សេងទៀតទាំងអស់បានទទួលសំណៅចម្លងនៃសំណើសុំវិធានការបណ្តោះអាសន្នបានចេញដោយមជ្ឈត្តករបន្ទាន់ ឬបើគ្មានទេ សេចក្តីថ្លែងការពិពណ៌នាអំពីចំណាត់ការដែលបានធ្វើរួចដោយសុចរិតនិងស្មោះត្រង់ដើម្បីប្រគល់សំណៅចម្លងសំណើ ឬសេចក្តីជូនដំណឹងទៅភាគីវិវាទផ្សេងទៀតទាំងអស់។[66]

លើសពីនេះផងដែរ សម្រាប់កម្រៃសេវានៃការស្នើសុំវិធានបណ្តោះអាសន្នចេញដោយមជ្ឈត្តករបន្ទាន់ទាំងអស់ត្រូវភ្ជាប់មកជាមួយនូវការបង់កម្រៃសេវានៃការស្នើសុំរួមមាន កម្រៃសេវាស្នើសុំ និងកម្រៃសេវាមជ្ឈត្តករបន្ទាន់

[65] ដកស្រង់ចេញពីគេហទំព័រ https://ovtlaw.com/2022/02/07, ចូលមើលថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២២

[66] វិធានស្តីពីមជ្ឈត្តការ, ២៨ មីនា ២០២១, ប្រការ១០

ព្រមទាំងការចំណាយផ្សេងៗ សម្រាប់ដំណើរការនីតិវិធីដោយយោងតាមតារាងសេវារបស់ ម.ជ.ម.។ ប្រសិនបើនៅក្នុងកាលៈទេសៈពិសេស អគ្គលេខាធិការដ្ឋានអាចបង្កើនកម្រៃសេវានៃការស្នើសុំវិធានការបណ្តោះអាសន្នចេញដោយមជ្ឈត្តករបន្ទាន់ពីភាគីដែលធ្វើការដាក់សំណើរ ប៉ុន្តែប្រសិនបើភាគីមិនព្រមបង់បន្ថែមតាមការបង្កើននោះទេ នោះចាត់ទុកថាសំណើត្រូវបានដក។[67] ជាមួយគ្នានោះដែរ ប្រសិនបើគណៈកម្មាធិការតែងតាំងនិងនីតិវិធីទទួលយកសំណើវិធានការបណ្តោះអាសន្នចេញដោយមជ្ឈត្តករបន្ទាន់ គណៈកម្មាធិការតែងតាំងនិងនីតិវិធីត្រូវតែងតាំងមជ្ឈត្តករបន្ទាន់ម្នាក់ ក្នុងអំឡុងពេល ៣ (បី) ថ្ងៃប្រតិទិន បន្ទាប់ពីអគ្គលេខាធិការដ្ឋានទទួលសំណើនោះ និងការទូទាត់កម្រៃសេវាវិធានការបណ្តោះអាសន្នចេញដោយមជ្ឈត្តករបន្ទាន់[68]។

បន្ទាប់ពីការដាក់សំណើក្នុងការស្នើសុំវិធានការបណ្តោះអាសន្នត្រូវបានទទួលហើយនោះ គូភាគីអាចធ្វើការជ្រើសរើសកន្លែងទីតាំងសម្រាប់ធ្វើមជ្ឈត្តការ ប្រសិនបើគូភាគីនៃវិវាទបានព្រមព្រៀងលើទីកន្លែងធ្វើមជ្ឈត្តការ ទីកន្លែងធ្វើមជ្ឈត្តការនោះ ត្រូវតែជាទីកន្លែងធ្វើមជ្ឈត្តការសម្រាប់ដំណើរការនីតិវិធីមជ្ឈត្តការលើវិធានការបណ្តោះអាសន្នចេញដោយមជ្ឈត្តករបន្ទាន់។ ផ្ទុយទៅវិញ ក្នុងករណីណាមិនមានការព្រមព្រៀងរវាងគូភាគីវិវាទ ទីកន្លែងធ្វើមជ្ឈត្តការសម្រាប់ដំណើរការមជ្ឈត្តការវិធានការបណ្តោះអាសន្នចេញដោយមជ្ឈត្តករបន្ទាន់ គឺរាជធានីភ្នំពេញស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនប៉ះពាល់ដល់ការធ្វើសេចក្តីសម្រេចរបស់វេទិកាមជ្ឈត្តកម្ម អំពីទីកន្លែងធ្វើមជ្ឈត្តការនោះទេ។[69] មិនតែប៉ុណ្ណោះ មុនពេលទទួលយកការតែងតាំង មជ្ឈត្តករបន្ទាន់ដែលអាចតែងតាំងត្រូវធ្វើការបង្ហាញទៅអគ្គលេខាធិការដ្ឋានអំពីកាលៈទេសៈទាំងឡាយណាដែលអាចបង្កឱ្យមានការសង្ស័យសមហេតុសមផលណាមួយពាក់ព័ន្ធនិងឯករាជភាព និងអព្យាក្រឹតភាពរបស់ខ្លួន។ នេះមានន័យថា ប្រសិនបើមានគំនិតសង្ស័យចំពោះសមាសភាពមជ្ឈត្តករបន្ទាន់ចំពោះឯករាជ្យភាព និងភាពអព្យាក្រឹត នោះភាគីអាចមានសិទ្ធិជំទាស់ទៅនឹងបញ្ហានោះបាន ដែលវាមានភាពស្រដៀងនឹងបណ្តឹងជិតចិត្តចៅក្រមស្ថិតនៅក្នុងរឿងរដ្ឋប្បវេណីដែរ។[70] រាល់ការជំទាស់ទៅនឹងការតែងតាំងមជ្ឈត្តករបន្ទាន់ត្រូវធ្វើឡើងក្នុងអំឡុងពេល ២ (ពីរ) ថ្ងៃប្រតិទិន បន្ទាប់ពីអគ្គលេខាធិការដ្ឋានជូនដំណឹងអំពីការតែងតាំងមជ្ឈត្តករបន្ទាន់ និងកាលៈទេសៈដែលបានបង្ហាញទៅគូភាគីវិវាទ[71]។

បន្ទាប់មកទៀត កាលវិភាគសម្រាប់វិធានការបណ្តោះអាសន្នចេញដោយមជ្ឈត្តករបន្ទាន់អាចចេញភ្លាមៗតាមដែលធ្វើទៅបាន ដោយមិនលើសពីអំឡុងពេល ២ (ពីរ) ថ្ងៃប្រតិទិន បន្ទាប់ពីការតែងតាំង។ មជ្ឈត្តករបន្ទាន់

[67] វិធានស្តីពីមជ្ឈត្តការ, ២៨ មីនា ២០២១, ប្រការ១១

[68] វិធានស្តីពីមជ្ឈត្តការ, ២៨ មីនា ២០២១, ប្រការ១២

[69] វិធានស្តីពីមជ្ឈត្តការ, ២៨ មីនា ២០២១, ប្រការ១៣

[70] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៨

[71] វិធានស្តីពីមជ្ឈត្តការ, ២៨ មីនា ២០២១, ប្រការ១៤

ត្រូវបង្កើតនូវកាលវិភាគ ដើម្បីពិចារណាលើសំណើសុំវិធានការបណ្តោះអាសន្នចេញដោយមជ្ឈត្តករបន្ទាន់។ កាលវិភាគនោះត្រូវផ្តល់ឱកាសសមរម្យឱ្យភាគីវិវាទក្នុងការបង្ហាញរឿងរ៉ាវរបស់ខ្លួន។ មជ្ឈត្តករបន្ទាន់អាចអនុវត្ត ដំណើរការនីតិវិធីបានតាមរយៈសន្និសីទវីដេអូ ទូរស័ព្ទ ឬមធ្យោបាយទាក់ទងអេឡិចត្រូនិចផ្សេងទៀតជាមួយអ្នកចូលរួម ដែលស្ថិតនៅទីកន្លែងមួយ ឬច្រើន ឬក្នុងទម្រង់រួមបញ្ចូលគ្នា ឬដោយផ្អែកលើឯកសារ និងលិខិតស្នាមផ្សេងៗ សម្រាប់ជាមធ្យោបាយជំនួសការចូលរួមសវនាការដោយផ្ទាល់។ មជ្ឈត្តករបន្ទាន់មានអំណាចដូចជាវេទិកាមជ្ឈត្តកម្មដូចមានចែងក្នុងវិធាននេះ រួមបញ្ចូលទាំងកំណត់ និងមិនកំណត់ចំពោះសមត្ថកិច្ចក្នុងការសម្រេចអំពីយុត្តាធិការរបស់ខ្លួន ដោយមិនប៉ះពាល់ដល់ការសម្រេចរបស់វេទិកាមជ្ឈត្តកម្ម។[72] ចំណែកឯអំណាចរបស់មជ្ឈត្តករបន្ទាន់នោះ មជ្ឈត្តករបន្ទាន់មានអំណាចក្នុងការចេញសេចក្តីបង្គាប់ ឬមជ្ឈត្តវិនិច្ឆ័យលើវិធានការជាបណ្តោះអាសន្ន ដែលខ្លួនយល់ថាចាំបាច់រួមបញ្ចូលទាំងការចេញនូវសេចក្តីបង្គាប់បឋមក្នុងអំឡុងពេលរង់ចាំសវនាការ ឬដំណើរការនីតិវិធីតាមរយៈសន្និសីទវីដេអូ ឬឯកសារ និងលិខិតស្នាមផ្សេងៗទៀតដោយភាគីវិវាទ។ មជ្ឈត្តករបន្ទាន់ត្រូវផ្តល់សំអាងហេតុក្នុងសេចក្តីសម្រេចជាទម្រង់សង្ខេប ដែលធ្វើឡើងជាលាយលក្ខណ៍អក្សរ។ មជ្ឈត្តករបន្ទាន់អាចកែប្រែ ឬបញ្ចប់សេចក្តីបង្គាប់បឋម សេចក្តីបង្គាប់ ឬមជ្ឈត្តវិនិច្ឆ័យវិធានការបណ្តោះអាសន្នបន្ទាប់ពីទទួលបានមូលហេតុត្រឹមត្រូវណាមួយ។[73] ជាពិសេសនោះ ការចេញសេចក្តីបង្គាប់ ឬមជ្ឈត្តវិនិច្ឆ័យ ធ្វើឡើងដោយមជ្ឈត្តករបន្ទាន់នោះ មជ្ឈត្តករបន្ទាន់ត្រូវចេញសេចក្តីបង្គាប់ ឬមជ្ឈត្តវិនិច្ឆ័យលើវិធានការបណ្តោះអាសន្នរបស់ខ្លួនក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃចាប់ពីថ្ងៃដែលត្រូវបានតែងតាំង លើកលែងតែក្នុងកាលៈទេសៈពិសេសណាមួយ ដែលជាហេតុធ្វើឱ្យអគ្គលេខាធិការដ្ឋានអាចពន្យារពេល នេះជាហេតុធ្វើឱ្យមជ្ឈត្តករបន្ទាន់ មិនត្រូវចេញសេចក្តីបង្គាប់ ឬមជ្ឈត្តវិនិច្ឆ័យលើវិធានការបណ្តោះអាសន្នឡើយ។ ក្នុងករណីដូចជាទម្រង់របស់សេចក្តីបង្គាប់ ឬមជ្ឈត្តវិនិច្ឆ័យលើវិធានការបណ្តោះអាសន្ននោះមិនទាន់ត្រូវបានពិនិត្យពិច័យ និងមានការឯកភាពដោយអគ្គលេខាធិការដ្ឋាន។[74]

ចំណែកឯអំណាចរបស់វេទិកាមជ្ឈត្តកម្ម ក្នុងការពិនិត្យដើម្បីកែប្រែ ឬផ្អាក ឬធ្វើការបញ្ឈប់សេចក្តីបង្គាប់ ឬមជ្ឈត្តវិនិច្ឆ័យចេញដោយមជ្ឈត្តករបន្ទាន់ នោះមជ្ឈត្តករបន្ទាន់មិនមានសិទ្ធិអំណាចទៀតនោះឡើយ បន្ទាប់ពីវេទិកាមជ្ឈត្តកម្មត្រូវបានបង្កើត។ វេទិកាមជ្ឈត្តកម្មអាចពិនិត្យ កែប្រែ ផ្អាក ឬបញ្ឈប់សេចក្តីបង្គាប់ ឬមជ្ឈត្តវិនិច្ឆ័យលើវិធានការបណ្តោះអាសន្ន ដែលបានចេញដោយមជ្ឈត្តករបន្ទាន់ រួមបញ្ចូលទាំងការសម្រេចអំពីយុត្តាធិការរបស់ខ្លួន។ វេទិកាមជ្ឈត្តកម្មមិនជាប់កាតព្វកិច្ចទៅនឹងមូលហេតុផ្តល់ដោយមជ្ឈត្តករបន្ទាន់ឡើយ។ ដោយរាល់

[72] វិធានស្តីពីមជ្ឈត្តការ, ២៨ មីនា ២០២១, ប្រការ១៦
[73] វិធានស្តីពីមជ្ឈត្តការ, ២៨ មីនា ២០២១, ប្រការ១៧
[74] វិធានស្តីពីមជ្ឈត្តការ, ២៨ មីនា ២០២១, ប្រការ១៨

ការចេញសេចក្ដីបង្គាប់ ឬមជ្ឈត្តវិនិច្ឆ័យដោយមជ្ឈត្តករបន្ទាន់ ទោះក្នុងកាលៈទេសៈណាក៏ដោយ ត្រូវចាត់ទុកថាឈប់មានអានុភាពអនុវត្ត ប្រសិនបើវេទិកាមជ្ឈត្តកម្មមិនត្រូវបានបង្កើតឡើងក្នុងអំឡុងពេល ៩០ (កៅសិប) ថ្ងៃប្រតិទិន បន្ទាប់ពីការចេញសេចក្ដីបង្គាប់ ឬមជ្ឈត្តវិនិច្ឆ័យ ឬពេលវេទិកាមជ្ឈត្តកម្មចេញមជ្ឈត្តវិនិច្ឆ័យស្ថាពរ ឬប្រសិនបើការទាមទារត្រូវបានដក។ លក្ខខណ្ឌនៃការចេញសេចក្ដីបង្គាប់ ឬមជ្ឈត្តវិនិច្ឆ័យដោយមជ្ឈត្តករបន្ទាន់អាចត្រូវចេញក្រោមលក្ខខណ្ឌ ដែលមានការផ្ដល់នូវការធានាសមស្របដោយគូភាគីវិវាទ ដែលបានស្នើសុំវិធានការបណ្ដោះអាសន្នចេញដោយមជ្ឈត្តករបន្ទាន់នោះ។[75] នៅពេលដែលអនុវត្តសេចក្ដីបង្គាប់ ឬមជ្ឈត្តវិនិច្ឆ័យចេញដោយមជ្ឈត្តករបន្ទាន់ គូភាគីវិវាទយល់ព្រមថាសេចក្ដីបង្គាប់ ឬមជ្ឈត្តវិនិច្ឆ័យចេញដោយមជ្ឈត្តករបន្ទាន់នេះត្រូវមានអានុភាពអនុវត្តចំពោះគូភាគីវិវាទចាប់ពីថ្ងៃដែលបានចេញ ហើយគូភាគីវិវាទត្រូវគោរពតាមសេចក្ដីបង្គាប់ ឬមជ្ឈត្តវិនិច្ឆ័យដោយមិនបង្អង់។ គូភាគីវិវាទមានសិទ្ធិក្នុងការតវ៉ាការស្នើសុំការពិនិត្យឡើងវិញ ឬការប្ដឹងទាស់ក្នុងទម្រង់ណាមួយទៅតុលាការដែលមានសមត្ថកិច្ច ឬសមត្ថកិច្ចតុលាការផ្សេងទៀតពាក់ព័ន្ធនឹងសេចក្ដីបង្គាប់ ឬក៏មជ្ឈត្តវិនិច្ឆ័យនោះធ្វើឡើងដោយមានសុពលភាព ឬគូភាគីវិវាទមានសិទ្ធិបោះបង់សិទ្ធិនេះបានផងដែរ។[76]

ជារួមមក យើងឃើញថាមជ្ឈត្តករបន្ទាន់ជាយន្តការថ្មីស្រឡាងមួយ ដែលទើបតែបានបង្កើតឡើងដោយមានការធ្វើវិសោធនកម្មចំពោះវិធានស្ដីពីមជ្ឈត្តការ ដូច្នេះរាល់ការដោះស្រាយវិវាទមិនទាន់មានភាពទូលំទូលាយប៉ុន្មាននោះទេ ប៉ុន្តែថ្មីៗនេះការដោះស្រាយតាមយន្តការមជ្ឈត្តករបន្ទាន់ទទួលបានជោគជ័យជាលើកដំបូង។ ជាក់ស្ដែង នៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២ ម.ជ.ម. បានជូនដំណឹងអំពីមជ្ឈត្តករបន្ទាន់បានចេញមជ្ឈត្តវិនិច្ឆ័យលើវិធានបណ្ដោះអាសន្ន ជាលើកដំបូងបន្ទាប់ពីវិធាននេះចូលជាធរមាន។ នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០២២ ម.ជ.ម. បានទទួលសេចក្ដីជូនដំណឹងស្ដីពីមជ្ឈត្តកម្ម ភ្ជាប់ជាមួយនឹងសំណើសុំវិធានបណ្ដោះអាសន្នចេញដោយមជ្ឈត្តករបន្ទាន់ក្រោមវិធាន ម.ជ.ម.។[77] សំណុំរឿងនៃសំណើនេះពាក់ព័ន្ធនឹងវិវាទក្នុងវិស័យអចលនវត្ថុរវាងភាគីជាជនជាតិបរទេស និងជនជាតិខ្មែរ ដែលមជ្ឈត្តវិនិច្ឆ័យលើវិធានការបណ្ដោះអាសន្ននេះត្រូវបានចេញដោយមជ្ឈត្តករបន្ទាន់ក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃប្រតិទិន។ ដំណើរការនៃនីតិវិធីមជ្ឈត្តករបន្ទាន់តម្រូវឱ្យចេញសេចក្ដីសម្រេចរយៈពេល១៥ ថ្ងៃ បន្ទាប់ពីការតែងតាំងមជ្ឈត្តករបន្ទាន់។ ភាពជោគជ័យនៃដំណើរការសំណុំរឿងមជ្ឈត្តករបន្ទាន់លើកដំបូងនេះឆ្លុះបញ្ចាំងឱ្យឃើញថា ម.ជ.ម. មានសមត្ថភាពគ្រប់គ្រាន់ក្នុងការដោះស្រាយសំណុំរឿងមជ្ឈត្តករបន្ទាន់ឆ្លើយតបទៅនឹងត្រូវការរបស់អ្នកប្រើប្រាស់។[78]

---

[75] វិធានស្ដីពីមជ្ឈត្តការ, ២៨ មីនា ២០២១, ប្រការ២០

[76] វិធានស្ដីពីមជ្ឈត្តការ, ២៨ មីនា ២០២១, ប្រការ២១

[77] សេចក្ដីប្រកាសព័ត៌មានស្ដីពី សំណុំរឿងមជ្ឈត្តករបន្ទាន់ដំបូងត្រូវបានប្រព្រឹត្តទៅដោយជោគជ័យ, ថ្ងៃទី០១ កុម្ភៈ ២០២២

[78] ប្រសាសន៍លោកមជ្ឈត្តករ ប៊ុន យូឌី អតីតប្រធាន ម.ជ.ម.

## ២.៦. ការចាប់ផ្តើមមជ្ឈត្តការពាណិជ្ជកម្ម

បន្ទាប់ពីមានវិវាទពាណិជ្ជកម្មបានកើតឡើង គូភាគីត្រូវបានធ្វើការព្រមព្រៀងក្នុងការដោះស្រាយតាមរយៈយន្តការមជ្ឈត្តការ នោះត្រូវតែធ្វើសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្មទៅកាន់អគ្គលេខាធិការដ្ឋានរបស់ ម.ជ.ម.។ នៅក្នុងសេចក្តីជូនដំណឹងនោះ ត្រូវធ្វើការរៀបរាប់អំពីព័ត៌មានមួយចំនួនដែលបានចែងក្នុងវិធានស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មមានដូចជា ឈ្មោះគូភាគី អាសយដ្ឋាន លេខទូរសព្ទ សញ្ជាតិរបស់ភាគីវិវាទ កិច្ចសន្យា កិច្ចព្រមព្រៀងមជ្ឈត្តកម្ម សេចក្តីថ្លែងបញ្ជាក់ថាភាគីវិវាទដាក់ឱ្យដោះស្រាយតាមរយៈមជ្ឈត្តការ សេចក្តីថ្លែងសង្ខេប ចំនួនមជ្ឈត្តករ និងការស្នើសុំផ្សេងៗ។ ទន្ទឹមនឹងនោះ សេចក្តីជូនដំណឹងនោះ អគ្គលេខាធិការដ្ឋានត្រូវពិនិត្យលើភាពពេញលេញនៃសេចក្តីជូនដំណឹង និងកម្រៃបង់សេវាដែលតម្រូវដោយ ម.ជ.ម. ដើម្បីឱ្យសេចក្តីជូនដំណឹងនោះមានភាពពេញលេញ។ បន្ទាប់ពីអគ្គលេខាធិការដ្ឋានពិនិត្យចប់សព្វគ្រប់ហើយឃើញថាវាមានភាពពេញលេញហើយនោះ អគ្គលេខាធិការដ្ឋាននឹងជូនដំណឹងទៅកាន់ភាគីវិវាទវិញ។[79]

ជាកិច្ចបន្ទាប់ អគ្គលេខាធិការដ្ឋានត្រូវធ្វើសេចក្តីជូនដំណឹងទៅភាគីវិវាទ ហើយភាគីវិវាទនោះមានរយៈ១៥ (ដប់ប្រាំ) ថ្ងៃក្នុងការធ្វើសេចក្តីជូនដំណឹងតបទៅអគ្គលេខាធិការដ្ឋានវិញ ដោយបំពេញនូវព័ត៌មានដូចគ្នាទៅនឹងការធ្វើសេចក្តីជូនដំណឹងអំពីមជ្ឈត្តការ។[80]

### ២.៦.១. នីតិវិធីនៃការជ្រើសរើសមជ្ឈត្តករ

នៅក្នុងកិច្ចនីតិវិធីនៃការជ្រើសរើសមជ្ឈត្តករ គឺជាសិទ្ធិសេរីភាពរបស់ភាគី ដែលជាការកើតឡើងតាមរយៈការព្រមព្រៀងគ្នាដែលមានចែងក្នុងកិច្ចព្រមព្រៀង ឬក្នុងកិច្ចសន្យា។

#### ២.៦.១.១. ការជ្រើសរើស និងចំនួនមជ្ឈត្តករ

វាជាសិទ្ធិសេរីភាពរបស់ភាគីនៅក្នុងការជ្រើសរើសមជ្ឈត្តករ និងចំនួនមជ្ឈត្តករដើម្បីធ្វើការដោះស្រាយវិវាទពាណិជ្ជកម្ម ប៉ុន្តែទោះបីជាយ៉ាងនេះក្តី សិទ្ធិសេរីភាពក្នុងការជ្រើសរើស និងចំនួនមជ្ឈត្តករត្រូវបានកម្រិតក្នុងវិធានឱ្យត្រឹមតែចំនួនសេសប៉ុណ្ណោះ ព្រោះដើម្បីធានាឱ្យបាននូវដំណោះស្រាយចុងក្រោយនៃវិវាទ។ ប្រសិនបើគូភាគីវិវាទមិនបានកំណត់ចំនួននៃមជ្ឈត្តករទេ នោះមជ្ឈត្តករត្រូវបានកំណត់ថាមានចំនួន ០៣ នាក់ លើកលែងតែគូភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ។[81]

[79] វិធានស្តីពីមជ្ឈត្តការ, ២៨ មីនា ២០២១, ប្រការ៧

[80] វិធានស្តីពីមជ្ឈត្តការ, ២៨ មីនា ២០២១, ប្រការ៨

[81] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, លេខ នស/រកម/០៥០៦/០១០, ០៥ ឧសភា ២០០៦, មាត្រា១៩

**២.៦.១.២. ការតែងតាំងមជ្ឈត្តករ**

ចំពោះជ្រើសរើសចំនួនមជ្ឈត្តករ និងការតែងតាំងមជ្ឈត្តករក៏មិនខុសគ្នាដែរ ព្រោះថាវាជាសិទ្ធិសេរីភាពរបស់ភាគីវិវាទក្នុងការតែងតាំងមជ្ឈត្តករ។ ចំពោះវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករ ០១ រូប ប្រសិនបើមជ្ឈត្តករមិនទាន់ត្រូវបានតែងតាំងតាមរយៈសេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្មនោះទេ ឬសេចក្ដីជូនដំណឹងអំពីការឆ្លើយតបទេនោះ គូភាគីវិវាទត្រូវរួមគ្នាតែងតាំងមជ្ឈត្តករមួយរូបក្នុងអំឡុងពេល១៥ ថ្ងៃ បន្ទាប់ពីបានទទួលការជូនដំណឹងអំពីការឆ្លើយតបពេញលេញ។ ប្រសិនបើគូភាគីនៃវិវាទទាំងពីខកខានក្នុងការរួមគ្នាតែងតាំងមជ្ឈត្តករក្នុងអំឡុងពេលដែលបានបញ្ជាក់នៅក្នុងវិធានស្ដីពីមជ្ឈត្តការ ដូច្នេះគណៈកម្មាធិការតែងតាំងនិងនីតិវិធីត្រូវបានតែងតាំងមជ្ឈត្តករមួយរូបដើម្បីវេទិកាមជ្ឈត្តកម្ម។[82]

ចំណែកចំពោះវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករ ០៣ រូប ឬវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករច្រើនរូប ប្រសិនបើការតែងតាំងមិនត្រូវបានធ្វើឡើងតាមរយៈសេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្ម ឬសេចក្ដីជូនដំណឹងអំពីការឆ្លើយតបទេនោះ ភាគីវិវាទនីមួយៗត្រូវតែងតាំងមជ្ឈត្តករម្នាក់មួយរូប ឬច្រើនរូបស្មើៗគ្នា។ ក្នុងអំឡុងពេល១៥ ថ្ងៃបន្ទាប់ពីមានការតែងតាំងមជ្ឈត្តកររូបចុងក្រោយ មជ្ឈត្តករដែលត្រូវបានតែងតាំងទាំងអស់ត្រូវរួមគ្នាតែងតាំងមជ្ឈត្តករមួយរូបផ្សេងទៀតជាប្រធានវេទិកាមជ្ឈត្តកម្ម។ នៅក្នុងករណីណាមួយ ភាគីវិវាទណាមួយបានខកខានក្នុងការតែងតាំងមជ្ឈត្តករតាមការតម្រូវ ឬមជ្ឈត្តករត្រូវបានតែងតាំងនោះខកខានតែងតាំងប្រធានវេទិកាមជ្ឈត្តកម្មក្នុងអំឡុងពេលនោះ គណៈកម្មាធិការតែងតាំងនិងនីតិវិធីត្រូវតែងតាំងមជ្ឈត្តករ ឬប្រធានវេទិកាមជ្ឈត្តកម្ម។[83]

រីឯចំពោះការតែងតាំងមជ្ឈត្តករដោយពហុភាគីវិវាទ ប្រសិនបើភាគីវិវាទលើសពី២ភាគីក្នុងមជ្ឈត្តកម្ម និងវេទិកាមជ្ឈត្តកម្ម ជាវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករ៣រូប ឬច្រើនរូប ដែលនឹងត្រូវបានតែងតាំង ភាគីប្ដឹងទាមទារទាំងអស់ត្រូវរួមគ្នាតែងតាំងមជ្ឈត្តករ ០១ រូប ឬច្រើនរូប និងភាគីឆ្លើយតបទាំងអស់ត្រូវរួមគ្នាតែងតាំងមជ្ឈត្តករ ០១ រូប ឬច្រើនរូប។ ក្នុងករណីប្រសិនបើ ភាគីវិវាទណាមួយខកខានក្នុងការចូលរួមគ្នាក្នុងការតែងតាំងក្នុងអំឡុងពេលតែងតាំងនោះ គណៈកម្មាធិការតែងតាំងនិងនីតិវិធីក្នុងនាមរបស់ភាគីវិវាទដែលខកខានមិនបានតែងតាំង ត្រូវតែងតាំងស្របតាមការតែងតាំងមជ្ឈត្តករដោយ ម.ជ.ម.។ ក្នុងអំឡុងពេល១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីមានការតែងតាំងមជ្ឈត្តករចុងក្រោយ មជ្ឈត្តករដែលត្រូវបានតែងតាំងទាំងអស់ត្រូវរួមគ្នាតែងតាំងមជ្ឈត្តករម្នាក់ទៀតដែលត្រូវបំពេញតួនាទីជាប្រធានវេទិកាមជ្ឈត្តកម្ម។ ប្រសិនបើមជ្ឈត្តករ ដែលត្រូវបានតែងតាំងទាំងអស់ខកខានក្នុងការចូលរួមក្នុងការតែងតាំងប្រធានវេទិកាមជ្ឈត្តកម្មតាមការកំណត់ នោះគណៈកម្មាធិការតែងតាំងនិងនីតិវិធី

[82] វិធានស្ដីពីមជ្ឈត្តការ, ២៨ មីនា ២០២១, ប្រការ២៥.៣

[83] វិធានស្ដីពីមជ្ឈត្តការ, ២៨ មីនា ២០២១, ប្រការ២៥.២

ត្រូវតែងតាំងមជ្ឈត្តករជាប្រធានវេទិកាមជ្ឈត្តកម្ម។[84] អនុលោមតាមការតែងតាំងមជ្ឈត្តករនេះ រាល់ការតែងតាំងទាំងអស់ត្រូវធ្វើឡើងតាមរយៈការជូនដំណឹងទៅអគ្គលេខាធិការដ្ឋាន។ បន្ទាប់ពីមជ្ឈត្តករត្រូវបានតែងតាំង អគ្គលេខាធិការដ្ឋានត្រូវជូនដំណឹងទៅភាគីវិវាទថាវេទិកាមជ្ឈត្តកម្មត្រូវបានបង្កើត និងជូនដំណឹងដល់គូភាគីពីព័ត៌មានលម្អិតទាក់ទងនឹងមជ្ឈត្តករ បន្ទាប់មកអគ្គលេខាធិការដ្ឋានត្រូវផ្ញើសំណុំរឿងនោះទៅវេទិកាមជ្ឈត្តកម្ម។[85]

**២.៦.១.៣. ការជំទាស់នឹងការជ្រើសរើសមជ្ឈត្តករ**

ចំពោះបញ្ហានៃការប្ដឹងទាស់ទៅនឹងមជ្ឈត្តករនេះ ភាគីវិវាទណាមួយអាចធ្វើការបដិសេធចំពោះមជ្ឈត្តករបាន ដោយការប្ដឹងជំទាស់ទៅនឹងមជ្ឈត្តករនោះ។ ការប្ដឹងជំទាស់ទៅនឹងមជ្ឈត្តករអាចធ្វើទៅបាន លុះត្រាតែមានការសង្ស័យអំពីភាពមិនលម្អៀង ឬអំពីភាពឯករាជ្យរបស់មជ្ឈត្តករនោះ ឬនៅពេលដែលមជ្ឈត្តករមិនមាននូវលក្ខណៈសម្បត្តិដូចដែលភាគីបានព្រមព្រៀងតាំងពីពេលជ្រើសតាំងរហូតដល់បញ្ចប់ដំណើរការ។ ចំពោះការប្ដឹងជំទាស់នេះផងដែរ គឺអាចធ្វើទៅបានតែក្នុងករណីដែលមូលហេតុនៃការជំទាស់ត្រូវបានដឹងក្រោយពេលជ្រើសតាំងរួចប៉ុណ្ណោះ ប្រសិនបើមជ្ឈត្តករនោះមិនទាន់ជ្រើសតាំងជាមជ្ឈត្តករសម្រាប់វេទិកាមជ្ឈត្តកម្មទេ ភាពលម្អៀង និងភាពឯករាជ្យរបស់មជ្ឈត្តករនោះមិនប៉ះពាល់វេទិកាមជ្ឈត្តកម្មឡើយ។ ម្យ៉ាងទៀតមជ្ឈត្តករត្រូវតែគោរពនូវគោលការណ៍មិនលម្អៀង និងឯករាជ្យនៅក្នុងដំណើរការវេទិកាមជ្ឈត្តកម្ម។ ដូច្នេះមានតែមជ្ឈត្តករដែលត្រូវបានជ្រើសតាំងរួចទើបអាចបញ្ជាក់បានថាមជ្ឈត្តករនោះមានភាពមិនលម្អៀង និងឯករាជ្យភាពនៅក្នុងវេទិកាមជ្ឈត្តកម្ម និងអាចធ្វើការប្ដឹងជំទាស់បាន។[86]

ដើម្បីធ្វើការប្ដឹងជំទាស់ទៅនឹងមជ្ឈត្តករ ភាគីវិវាទត្រូវធ្វើការប្ដឹងជាលាយលក្ខអក្សរទៅវេទិកាមជ្ឈត្តកម្មក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ឬក្រោយពីបានដឹងពីភាពលម្អៀង ឬមិនឯករាជ្យរបស់មជ្ឈត្តករនោះ សម្រាប់ករណីដែលភាគីមិនមានការព្រមព្រៀងគ្នាជាមុនក្នុងការប្ដឹងជំទាស់ ប៉ុន្តែប្រសិនបើភាគីវិវាទបានព្រមព្រៀងគ្នារួចលើនីតិវិធីក្នុងការប្ដឹងទាស់ នោះត្រូវធ្វើតាមការព្រមព្រៀងនោះ។ នៅពេលទទួលបានពាក្យបណ្ដឹងទាស់ វេទិកាមជ្ឈត្តកម្មត្រូវធ្វើការពិនិត្យ និងសម្រេចលើបណ្ដឹងនោះ ប៉ុន្តែប្រសិនបើមជ្ឈត្តករបានលាលែងពីមុខដំណែងជាមជ្ឈត្តករសម្រាប់វេទិកាដោយខ្លួនឯង ឬភាគីម្ខាងទៀតយល់ព្រមក្នុងការប្ដឹងជំទាស់នេះ វេទិការមជ្ឈត្តកម្មមិនចាំបាច់ធ្វើការពិនិត្យឡើយ គឺវេទិកាមជ្ឈត្តកម្មត្រូវសម្រេចដកមជ្ឈត្តករនោះចេញនឹងជំនួសដោយមជ្ឈត្តករថ្មីតែម្ដង។ ការជំនួសដោយមជ្ឈត្តករថ្មី ត្រូវធ្វើការតែងតាំងតាមនីតិវិធីជ្រើសរើសមជ្ឈត្តករមុនដដែល។ ក្នុងករណីការប្ដឹងជំទាស់ត្រូវបានបដិសេធ ភាគីជំទាស់អាចធ្វើការស្នើទៅតុលាការ ឬមជ្ឈត្តការផ្នែកពាណិជ្ជកម្មដើម្បីចេញសេចក្ដីសម្រេច

[84] វិធានស្ដីពីមជ្ឈត្តការ, ២៨ មីនា ២០២១, ប្រការ២៥.៤

[85] វិធានស្ដីពីមជ្ឈត្តការ, ២៨ មីនា ២០២១, ប្រការ២៥.៧

[86] ច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, លេខ នស/រកម/០៥០៦/០១០, ០៥ ឧសភា ២០០៦, មាត្រា២០

ចុងក្រោយក្នុងរយៈពេល ៣០ថ្ងៃ។ ទន្ទឹមនឹងការប្តឹងជំទាស់នេះ ដំណើរការមជ្ឈត្តការនៅតែបន្តដដែល ដើម្បីធានាដល់ភាពឆាប់រហ័សនៃដំណើរការមជ្ឈត្តការ។[87]

### ២.៦.១.៤. តួនាទី និងភារកិច្ចរបស់មជ្ឈត្តករ

ក្នុងនាមជាមជ្ឈត្តករនៅក្នុងដំណើរការមជ្ឈត្តការ មជ្ឈត្តករមានតួនាទីនិងភារកិច្ចមួយចំនួនដូចជា៖

- ធានានូវភាពមិនលម្អៀង និងអព្យាក្រឹតភាព
- ធានាថាមជ្ឈត្តវិនិច្ឆ័យមានអានុភាពអនុវត្ត និងចាប់បង្ខំ
- រក្សាភាពសម្ងាត់ជូនភាគី
- បំពេញនូវកាតព្វកិច្ចរហូតដល់បញ្ចប់កិច្ចនីតិវិធី
- ពន្លឿននីតិវិធី
- មិនអាចធ្វើការផ្ទេរអំណាចឱ្យទៅភាគីណាមួយ
- អនុលោមតាមនីតិវិធីដែលមានក្នុងការព្រមព្រៀង ឬការកំណត់របស់ ម.ជ.ម.
- មិនរំលោភអំណាចខ្លួន
- ធ្វើសេចក្តីសម្រេចតាមបញ្ញត្តិច្បាប់
- មានសាមគ្គីនិងសហការគ្នាក្នុងដំណើរការមជ្ឈត្តការ។[88]

## ២.៦.២. ដំណើរការនៃមជ្ឈត្តការពាណិជ្ជកម្ម

នៅក្នុងដំណើរការនៃមជ្ឈត្តការពាណិជ្ជកម្មនេះ ជាដំណាក់កាលមួយដែលអនុញ្ញាតឱ្យភាគីទាំងអស់ធ្វើការព្រមព្រៀងគ្នាក្នុងការជ្រើសរើសយកនូវទីតាំងណាមួយមកធ្វើជាកន្លែងដោះស្រាយវិវាទ ព្រមទាំងចាប់យកវិធានគតិយុត្តមកធ្វើជាសំអាងក្នុងការដោះស្រាយ និងភាសាផងដែរ ដែលជាសិទ្ធិជ្រើសរើសសម្រាប់ភាគីក្នុងនោះដែរ ភាគីវិវាទក៏អាចជ្រើសរើសក្នុងការបោះបង់សិទ្ធិ ឬបន្តនៅក្នុងដំណើរការមជ្ឈត្តការនេះ។

### ២.៦.២.១. ការជ្រើសរើសទីតាំងមជ្ឈត្តការ

សិទ្ធិនៅក្នុងការជ្រើសរើសទីតាំងត្រូវបានផ្តល់ឱ្យគូភាគី ដោយផ្អែកតាមការព្រមព្រៀងគ្នាក្នុងការជ្រើសរើសទីកន្លែងដើម្បីនឹងធ្វើនូវមជ្ឈត្តការ អនុលោមតាមភាគីព្រមព្រៀងគ្នាគិតថាទីកន្លែងណាមួយដែលមានលក្ខណៈគ្រប់គ្រាន់និងសមរម្យដើម្បីអាចធ្វើមជ្ឈត្តការបាន។ ម្យ៉ាងវិញទៀត ក្នុងករណីមិនបានព្រមព្រៀងគ្នា ប៉ុន្តែទីតាំងផ្សេងវាផ្តល់ភាពសមស្របតាមកាលៈទេសៈនៃសំណុំរឿងតម្រូវ ដែលអាចផ្តល់ភាពងាយស្រួលនិងរហ័ស ដូច្នេះ

[87] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, លេខ នស/រកម/០៥០៦/០១០, ០៥ ឧសភា ២០០៦, មាត្រា២១

[88] ដកស្រង់ចេញពីគេហទំព័រ http://www.preservearticles.com/201104065087/arbitrator-his-appointment-powers-and-duties.html, ចូលមើលថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២២

ទីកន្លែងនោះអាចធ្វើនូវមជ្ឈត្តការបាន។ ឧទាហរណ៍៖ ភាគីវិវាទមិនបានធ្វើការព្រមព្រៀងនោះទេ ប៉ុន្តែភាគីវិវាទស្ថិតនៅខេត្តណាមួយដូចគ្នា ហើយកម្មវត្ថុនៃវិវាទក៏ស្ថិតនៅក្នុងខេត្តនោះដែរ ដូច្នេះយើងឃើញថាទាំងភាគីវិវាទទាំងកម្មវត្ថុនៃវិវាទស្ថិតនៅក្នុងទីតាំងតែមួយ ហេតុនេះភាគីអាចជ្រើសរើសទីតាំងនេះសម្រាប់ធ្វើមជ្ឈត្តការបាន។ ផ្ទុយទៅវិញ ប្រសិនបើភាគីវិវាទមិនបានធ្វើការព្រមព្រៀងគ្នានោះទេ ឬក៏ផ្អែកតាមកាលៈទេសៈណាមួយដែលមិនសមស្របនោះ ទីកន្លែងសម្រាប់ធ្វើមជ្ឈត្តការគឺត្រូវស្ថិតនៅក្នុងរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា។[89]

**២.៦.២.២. វិធានគតិយុត្តដែលត្រូវយកមកអនុវត្ត**

គូភាគីមានសិទ្ធិក្នុងការជ្រើសរើសច្បាប់ណាមួយ ឬបទប្បញ្ញត្តិគតិយុត្តណាមួយ ដែលវេទិកាមជ្ឈត្តកម្មត្រូវយកមកអនុវត្តចំពោះខ្លឹមសារនៃវិវាទ។ ផ្ទុយទៅវិញ ក្នុងករណីដែលគូភាគីមិនបានធ្វើការព្រមព្រៀងគ្នានោះទេ វេទិកាមជ្ឈត្តកម្មអាចត្រូវកំណត់យកច្បាប់ ឬបទប្បញ្ញត្តិគតិយុត្តណាមួយ ដែលវេទិកាមជ្ឈត្តកម្មយល់ថាមានភាពសមស្របដើម្បីយកមកអនុវត្ត។ នៅគ្រប់ករណីទាំងអស់ វេទិកាមជ្ឈត្តកម្មត្រូវយកមកពិចារណានូវបញ្ញត្តិនានាដែលមានចែងក្នុងកិច្ចសន្យា ប្រសិនបើមាន និងរួមទាំងទំនៀមទម្លាប់ពាណិជ្ជកម្មនានាដែលពាក់ព័ន្ធ។[90]

**២.៦.២.៣. ភាសា**

ក្នុងករណីនេះ គូភាគីវិវាទមានសិទ្ធិសេរីភាពក្នុងការជ្រើសរើសយកភាសាណាមួយ ឬច្រើនមកប្រើក្នុងដំណើរការមជ្ឈត្តការ។ ផ្ទុយទៅវិញ ក្នុងករណីដែលគូភាគីមិនបានធ្វើការព្រមព្រៀងគ្នានោះទេ វេទិកាមជ្ឈត្តកម្មអាចសម្រេចយកភាសាណាមួយជាភាសាសម្រាប់ដំណើរការមជ្ឈត្តការដោយគិតពិចារណាទៅលើកាលៈទេសៈនានាដែលពាក់ព័ន្ធទាំងអស់ ព្រមទាំងរួមបញ្ចូលទាំងភាសានៃកិច្ចសន្យាផងដែរ។ លើសពីនេះ វេទិកាមជ្ឈត្តកម្មអាចមានសិទ្ធិនៅក្នុងការបង្គាប់ឱ្យគូភាគីវិវាទធ្វើការបកប្រែ ដែលជាការទាក់ទងជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់ណាមួយទៅជាភាសាណាមួយ និងទម្រង់ណាមួយដែលវេទិកាមជ្ឈត្តកម្មយល់ថាសមស្រប។

ម្យ៉ាងវិញទៀត ប្រសិនបើភាសានៃដំណើរការមជ្ឈត្តការ ទោះតាមរយៈការជ្រើសរើសរបស់គូភាគីវិវាទ ឬតាមការកំណត់របស់វេទិកាមជ្ឈត្តកម្ម ដែលមានភាសាផ្សេងក្រៅពីភាសាខ្មែរ ឬភាសាអង់គ្លេសក៏ដោយ ក៏ភាសានៃមជ្ឈត្តវិនិច្ឆ័យ ឬសេចក្តីបង្គាប់ដែលចេញដោយវេទិកាមជ្ឈត្តកម្មត្រូវតែជាភាសាខ្មែរ ឬភាសាអង់គ្លេស បន្ទាប់ពីបានពិភាក្សាជាមួយភាគីវិវាទរួចហើយ។[91]

---

[89] វិធានស្តីពីមជ្ឈត្តការ, ២៨ មីនា ២០២១, ប្រការ៣១

[90] វិធានស្តីពីមជ្ឈត្តការ, ២៨ មីនា ២០២១, ប្រការ៣២

[91] វិធានស្តីពីមជ្ឈត្តការ, ២៨ មីនា ២០២១, ប្រការ១៨

### ២.៦.៣. ការរៀបចំតាក់តែង និងចងក្រងសំណៅឯកសារក្នុងដំណើរការមជ្ឈត្តការ

យ៉ាងណាមិញ របៀបរៀបចំនៃការតាក់តែងនិងចងក្រងសំណៅឯកសារ គឺមានការពាក់ព័ន្ធជាមួយនឹងការប្រើប្រាស់ពេលវេលា និងថ្លៃសោហ៊ុយចំណាយផ្សេងៗ ដែលជាក់ស្តែងភាគីវិវាទម្ខាងៗអាចដាក់សំណៅឯកសារជាលក្ខណៈឯកតោភាគីដើម្បីជាការគាំទ្រដល់សំណុំរឿងរបស់ពួកគេ។ របៀបនៃការរៀបចំតាក់តែង និងចងក្រងសំណៅឯកសារនោះ វាបានកំណត់អំពីវិសាលភាពនៃការទាមទារក្នុងការរៀបចំឯកសារតាមរបៀបតែមួយ។ ម្យ៉ាងវិញទៀត យោងតាមវិធានស្តីពីមជ្ឈត្តការ អាចអនុញ្ញាតឱ្យវេទិកាមជ្ឈត្តកម្មអាចបង្គាប់ភាគីណាមួយអាចឱ្យផ្តល់ការបង្ហាញផ្សេងៗ រួមទាំងការរៀបចំឯកសារនៅពេលណាមួយក្នុងអំឡុងពេលនៃដំណើរការមជ្ឈត្តការ។[92]

ដូច្នេះជារួមមក នៅក្នុងវិធានស្តីពីមជ្ឈត្តការនេះបានផ្តល់នៅចន្លោះសម្រាប់ភាគីវិវាទ និងវេទិកាមជ្ឈត្តកម្មជាអ្នកសម្រេចអំពីកម្រិតនៃវិសាលភាពដែលគូភាគីវិវាទគួរតែគប្បីកំណត់ដើម្បីធ្វើការរៀបចំតាក់តែង និងចងក្រងនូវសំណៅសំណៅឯកសារនៅក្នុងដំណើរការមជ្ឈត្តការនៃសំណុំរឿងរបស់ខ្លួន ដើម្បីជាការទទួលបាននូវភាពយុត្តិធម៌ស្មើៗគ្នា និងមានអព្យាក្រឹតភាព ព្រមទាំងភាគីវិវាទនីមួយៗទទួលបាននូវឱកាសសមហេតុផលក្នុងការបង្ហាញនូវអំណះអំណាងហេតុផលទាក់ទងនឹងរឿងរ៉ាវនៃសំណុំរឿងរបស់ពួកគេដោយទទួលបានការយកចិត្តទុកដាក់ស្មើៗគ្នាពីវេទិកាមជ្ឈត្តកម្ម។

នៅក្នុងការរៀបចំតាក់តែង និងចងក្រងសំណៅឯកសារត្រូវបានកំណត់ត្រឹមតែចំពោះសំណៅឯកសារដែលមានភាពជាក់លាក់ ឬជំពូកឯកសារដែលមានភាពចាំបាច់ទាក់ទងនឹងសំណុំរឿង និងមានភាពសំខាន់ដែលទាក់ទងជាមួយការសម្រេចលើចំណុចវិវាទនៅក្នុងដំណើរការមជ្ឈត្តការ។ នៅក្នុងនោះផងដែរ ចំណុចដែលត្រូវពិចារណាក្នុងការរៀបចំតាក់តែង និងចងក្រងសំណៅឯកសារមានដូចជា វិធានរបស់គណៈមេធាវីអន្តរជាតិដែលស្តីពីការទទួលយកភស្តុតាងក្នុងមជ្ឈត្តការអន្តរជាតិ មកធ្វើជាបទដ្ឋានសម្រាប់ការប្រើប្រាស់ក្នុងដំណើរការមជ្ឈត្តការ។ មិនតែប៉ុណ្ណោះ ក៏គួរពិចារណាទៅលើអនុសាសន៍នានាក្នុងរបាយការណ៍របស់គណៈកម្មការរបស់សភាពាណិជ្ជកម្មអន្តរជាតិអំពីមជ្ឈត្តការអន្តរជាតិ និងការដោះស្រាយក្រៅប្រព័ន្ធតុលាការ ព្រមជាមួយនឹងរបាយការណ៍របស់គណៈកម្មការសភាពាណិជ្ជកម្មអន្តរជាតិជាដើម។ នៅពេលដែលមានការតម្រូវឱ្យមានការរៀបចំតាក់តែង និងរៀបចំសំណៅឯកសារគូភាគីវិវាទអាចព្រមព្រៀងគ្នាលើវិធានមូលដ្ឋានមួយចំនួនសម្រាប់ធ្វើការស្នើសុំឯកសារ និងការរៀបចំតាក់តែង និងរៀបចំសំណៅឯកសារដោយចម្លងនិងបញ្ជូនឱ្យគ្នាទៅវិញទៅមក។ ផ្ទុយទៅវិញ ប្រសិនបើភាគីវិវាទមិនអាចឈានដល់ការឯកភាពគ្នាបាននោះទេ វេទិកាមជ្ឈត្តកម្មនឹងក្លាយជាអ្នកធ្វើសេចក្តីសម្រេចលើបញ្ហានេះ។

[92] វិធានស្តីពីមជ្ឈត្តការ, ២៨ មីនា ២០២១, ប្រការ៤០.២

ជាងនេះទៀតនោះ ដោយអាចធ្វើការពិចារណាផងដែរ ទៅលើថាការជ្រើសរើសយកនូវវិធានទាំងឡាយណាដែលជាមូលដ្ឋាននោះដែលគូភាគីវិវាទត្រូវព្រមព្រៀងគ្នាសម្រាប់យកការរៀបចំតាក់តែង និងរៀបចំសំណៅឯកសារសម្រាប់ដំណើរការមជ្ឈត្តការ បូករួមទាំងកាលវិភាគ និងការកំណត់រយៈពេលឆាប់បំផុតដែលសមស្របសម្រាប់ការផលិតឯកសារ ការរៀបចំតាក់តែង និងរៀបចំសំណៅឯកសារសម្រាប់ដំណើរការមជ្ឈត្តការនោះ។ មិនតែប៉ុណ្ណោះ ចំណុចដែលគួរពិចារណានិងត្រូវយកចិត្តទុកដាក់ជាពិសេសគឺថាគូភាគីវិវាទព្រមព្រៀងគ្នាឱ្យមាន ឬក៏វេទិកាមជ្ឈត្តកម្មបង្គាប់ឱ្យមានការផលិតឯកសារ ការរៀបចំតាក់តែង និងរៀបចំសំណៅឯកសារតាមទម្រង់ជាអេឡិកត្រូនិកសម្រាប់ដំណើរការមជ្ឈត្តការជាដើម។[93]

### ២.៦.៤. នីតិវិធីនៃការដោះស្រាយវិវាទពាណិជ្ជកម្ម

ជាកិច្ចបន្ទាប់ក្រោយពីបានជ្រើសរើសទីកន្លែងដើម្បីដោះស្រាយវិវាទ មួយអន្លើដោយការដាក់ពាក្យបណ្ដឹង ព្រមទាំងបានព្រមព្រៀងគ្នាក្នុងការជ្រើសរើសភាសា នីតិវិធីការតែងតាំងមជ្ឈត្តករ ការរៀបចំតាក់តែង និងរៀបចំសំណៅឯកសារសម្រាប់ដំណើរការមជ្ឈត្តការរួចមក ភាគីវិវាទអាចធ្វើការព្រមព្រៀងគ្នានៅក្នុងការជ្រើសរើសនូវនីតិវិធីដើម្បីដោះស្រាយវិវាទ។ ក្នុងករណីដែលគូភាគីវិវាទមិនអាចធ្វើការព្រមព្រៀងគ្នាបានទេ វេទិកាមជ្ឈត្តកម្មត្រូវកំណត់យកនីតិវិធីណាមួយដែលវេទិកាមជ្ឈត្តកម្មគិតថាសមស្របសម្រាប់ការដោះស្រាយវិវាទពាណិជ្ជកម្ម។[94]

#### ២.៦.៤.១. សវនាការមជ្ឈត្តការ

នៅក្នុងទីនេះ គូភាគីវិវាទអាចធ្វើការព្រមព្រៀងគ្នានៅក្នុងការជ្រើសរើសនូវនីតិវិធីដើម្បីដោះស្រាយវិវាទ ប៉ុន្តែករណីដែលគូភាគីវិវាទមិនបានធ្វើការព្រមព្រៀងគ្នាបានទេ វេទិកាមជ្ឈត្តកម្មត្រូវកំណត់យកនីតិវិធីណាមួយដែលវេទិកាមជ្ឈត្តកម្មគិតថាសមស្របសម្រាប់ការដោះស្រាយ ដែលមានដូចជាការធ្វើសវនាការដោយផ្ទាល់មាត់ ឬដោយផ្អែកលើឯកសារ និងលិខិតស្នាមផ្សេងៗ។ នៅពេលកំណត់ពីរបៀបនៃការដោះស្រាយវិវាទពាណិជ្ជកម្មរួចមក វេទិកាមជ្ឈត្តកម្មត្រូវកំណត់អំពីកាលបរិច្ឆេទ ពេលវេលា ទីកន្លែង និងរបៀបនៃការធ្វើសវនាការ បន្ទាប់មកជូនដំណឹងទៅភាគីវិវាទអំពីបញ្ហានេះ យ៉ាងហោចណាស់១៥ ថ្ងៃ មុនកាលបរិច្ឆេទធ្វើសវនាការ។[95]

ជាទូទៅ ដំណើរការមជ្ឈត្តការតម្រូវឱ្យមានសវនាការមួយ ដែលមានភាពស្រដៀងគ្នាទៅនឹងដំណើរការនៃការជំនុំជម្រះនៅក្នុងតុលាការដែរ គឺត្រូវបានចែកជាច្រើនជំហានដូចជា សេចក្តីថ្លែងហេតុបើករបស់មជ្ឈត្តករ សេចក្តីថ្លែងហេតុបើករបស់ភាគី ការប្រើប្រាស់ភស្តុតាង ភាពចាំបាច់នៃសាក្សីអង្គហេតុ សេចក្តីថ្លែងការណ៍

[93] លោក ហួន សុខនីម, កម្រងវិធីសាស្ត្រគន្លឹះនីតិវិធីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, បោះពុម្ពឆ្នាំ២០២១, ទំព័រ៤៣-៤៩

[94] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, លេខ នស/រកម/០៥០៦/០១០, ០៥ ឧសភា ២០០៦, មាត្រា២៧

[95] វិធានស្តីពីមជ្ឈត្តការ, ២៨ មីនា ២០២១, ប្រការ២៤

សក្ខីកម្មរបស់សាក្សីអង្គហេតុ ឬសាក្សីហេតុការណ៍ ការឆ្លើយនិងឆ្លើយតប និងសេចក្តីថ្លែងការបិទ និងការចេញសេចក្តីសម្រេចរបស់មជ្ឈត្តវិនិច្ឆ័យ។[96]

**២.៦.៤.២. សេចក្តីថ្លែងហេតុបើករបស់មជ្ឈត្តករ**

នៅក្នុងដំណាក់កាលនេះ មជ្ឈត្តករជាមនុស្សដ៏សំខាន់ក្នុងការបើកសវនាការ និងត្រូវណែនាំពីខ្លួនទៅកាន់ភាគីវិវាទ ព្រមទាំងមានការបញ្ជាក់ឡើងវិញនូវនីតិវិធីនៃការដោះស្រាយដែលភាគីវិវាទបានព្រមព្រៀងគ្នា ឬត្រូវបានកំណត់ដោយវេទិកាមជ្ឈត្តកម្ម ដើម្បីឱ្យភាគីវិវាទបានយល់ច្បាស់ពីនីតិវិធីតាមលំដាប់បែបបទ និងបញ្ហាវិវាទដែលត្រូវលើកយកមកធ្វើការដោះស្រាយក្នុងមជ្ឈត្តការសវនាការ។

**២.៦.៤.៣. សេចក្តីថ្លែងហេតុបើករបស់គូភាគី**

បន្ទាប់ពីការធ្វើនូវសេចក្តីថ្លែងហេតុបើករបស់មជ្ឈត្តកររួចមក ភាគីវិវាទត្រូវធ្វើសេចក្តីថ្លែងហេតុបើករបស់ខ្លួនទៅនៅក្នុងសវនាការ ដែលបញ្ជាក់ពីអង្គហេតុដែលគាំទ្រការទាមទារ មូលដ្ឋានច្បាប់ ឬទឡ្ហីករណ៍តាមផ្លូវច្បាប់ដែលគាំទ្រការទាមទារនោះ និងសំណងនៃការខូចខាត ឬការសង្គ្រោះដែលទាមទារ ព្រមជាមួយទឹកប្រាក់នៃការទាមទារដែលបានកំណត់។[97] មិនតែប៉ុណ្ណោះ វាក៏ជាការបញ្ជាក់បន្ថែមដើម្បីធ្វើឱ្យយល់កាន់តែច្បាស់អំពីអង្គហេតុ និងមានភាពងាយស្រួលវាយតម្លៃលើភស្តុតាង និងឯកសារនានាដែលបានដាក់ជូនក្នុងសវនាការ។

**២.៦.៤.៤. ការប្រើប្រាស់ភស្តុតាង**

នៅក្នុងវិវាទដែលមានភាពស្មុគស្មាញ ភស្តុតាងជាឯកសារ គឺមានសារៈសំខាន់ណាស់ក្នុងការដោះស្រាយវិវាទ។ ជាទូទៅភាគីដែលចាប់ផ្តើមដំណើរការមជ្ឈត្តការ គឺតែងតែមាននូវភស្តុតាង និងឯកសារនានា ក្នុងការអះអាងសម្រាប់ការទាមទាររបស់ខ្លួន។ ភាគីនីមួយៗត្រូវមានបន្ទុកបង្ហាញអង្គហេតុ វិធានដែលត្រូវអនុវត្ត និងទម្លាប់ពាណិជ្ជកម្មនានាដែលជាមូលដ្ឋាននៃការទាមទារ ឬបណ្តឹងតប ឬដោះសាររបស់ភាគី។ នៅពេលណាមួយនៃអំឡុងពេលនៃដំណើរការមជ្ឈត្តការ វេទិកាមជ្ឈត្តកម្មអាច រៀបចំឱ្យមានការសាកសួរ ឬបង្គាប់ភាគីវិវាទណាមួយផ្តល់ការបង្ហាញផ្សេងៗ ដែលវេទិកាមជ្ឈត្តកម្មយល់ថាចាំបាច់ ឬសមស្របដូចជា៖

- ផ្តល់ឯកសារ វត្ថុតាង ឬភស្តុតាងផ្សេងទៀត
- ផ្តល់តារាងរៀបតាមអក្សរ ឬសេចក្តីសង្ខេបរបស់ឯកសារ ឬភស្តុតាងផ្សេងទៀតដែលភាគីវិវាទនោះបានបង្ហាញ ឬមានបំណងបង្ហាញ
- ផ្តល់ទីកន្លែង វត្ថុ ឬឯកសារនានាដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន សម្រាប់វេទិកាមជ្ឈត្តកម្ម ភាគីវិវាទម្ខាងទៀត ឬអ្នកជំនាញដែលត្រូវបានតែងតាំងដោយវេទិកាមជ្ឈត្តកម្មធ្វើការត្រួតពិនិត្យ និង

[96] មេធាវី ស៊ីវិន អ៊ែន អស្ទើរមីឡឺរ៍, ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅកម្ពុជា, បោះពុម្ពឆ្នាំ២០១០, ទំព័រ១៧៥

[97] វិធានស្តីពីមជ្ឈត្តការ, ២៨ មីនា ២០២១, ប្រការ៣៧

- រៀបចំការយកគំរូដែលត្រូវយកពីទីកន្លែង វត្ថុ ឬឯកសារ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ភាគីវិវាទ ឬរៀបចំឱ្យមានការអង្កេតលើ ឬពិសោធលើគំរូនោះ ដែលនឹងត្រូវយកទៅពិនិត្យ។[98]

ភាគីវិវាទមានសិទ្ធិក្នុងការត្រួតពិនិត្យភស្តុតាងដែលបង្ហាញដោយភាគីវិវាទម្ខាងទៀត។ វេទិកាមជ្ឈត្តកម្មត្រូវកំណត់អំពីភាពអាចទទួលយកបាន ទំនាក់ទំនង សារៈសំខាន់ និងទម្ងន់នៃភស្តុតាងទាំងអស់។

**២.៦.៤.៥. ភាពចាំបាច់នៃសាក្សីអង្គហេតុ**

ស្មារតីនៃប្រការ៤១ នៃវិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មរបស់ ម.ជ.ម. តម្រូវឱ្យវេទិកាមជ្ឈត្តកម្មត្រូវប្រមូលយកអង្គហេតុនៃសំណុំរឿងតាមគ្រប់មធ្យោបាយសមស្រប។ ការប្រមូលយកអង្គហេតុនេះអាចរួមបញ្ចូលទាំងការស្តាប់ចម្លើយសាក្សីអង្គហេតុក្នុងសវនាការផងដែរ។ ប្រការ៤១.៤ នៃវិធានស្តីពីមជ្ឈត្តការនេះដែលបានអនុញ្ញាតឱ្យវេទិកាមជ្ឈត្តកម្មសម្រេចឱ្យមានសវនការស្តាប់សក្ខីកម្មរបស់សាក្សីជាពិសេស។[99] ទោះបីជាយ៉ាងណាក៏ដោយប្រការ៣៩.១ នៃវិធានស្តីមជ្ឈត្តការផ្នែកពាណិជ្ជកម្មបានអនុញ្ញាតឱ្យវេទិកាមជ្ឈត្តកម្មសម្រេចវិនិច្ឆ័យសេចក្តីលើសំណុំរឿងដោយផ្អែកលើលើឯកសារ និងលិខិតស្នាមផ្សេងៗតែប៉ុណ្ណោះ ឬផ្អែកតាមការព្រមព្រៀងធ្វើសវនាការដោយផ្ទាល់មាត់។ ក្នុងករណីនេះ មានន័យថាវេទិកាមជ្ឈត្តកម្មអាចដំណើរការនីតិវិធីដោយពុំចាំបាច់មានសវនាការផ្ទាល់មាត់ និងគ្មានសាក្សីអង្គហេតុសម្រាប់សួរដេញដោល និងផ្ទៀងផ្ទាត់។ ផ្ទុយទៅវិញប្រសិនបើមានការស្នើសុំដោយគូភាគីវិវាទណាមួយ វេទិកាមជ្ឈត្តកម្មត្រូវធ្វើសវនាការដោយផ្ទាល់មាត់នៅដំណាក់កាលសមរម្យណាមួយនៃដំណើរការមជ្ឈត្តការ។[100]

ក្នុងករណីដែលសវនាការដោយផ្ទាល់មាត់នឹងត្រូវធ្វើឡើង វេទិកាមជ្ឈត្តកម្មអាចសម្រេចថាសវនាការនោះត្រូវធ្វើឡើងដោយមានការចូលរួមដោយផ្ទាល់ ឬពីចម្ងាយតាមរយៈសន្និសីទវីដេអូ ទូរស័ព្ទ ឬមធ្យោបាយទាក់ទងអេឡិចត្រូនិចផ្សេងទៀតជាមួយអ្នកចូលរួមដែលស្ថិតនៅទីកន្លែងមួយ ឬច្រើន បន្ទាប់ពីបានពិភាក្សាជាមួយគូភាគីវិវាទ និងដោយផ្អែកលើអង្គហេតុពាក់ព័ន្ធ និងកាលៈទេសៈរបស់សំណុំរឿង។[101]

សាក្សីអង្គហេតុអាចចាំបាច់ក្នុងការអះអាងបង្ហាញជាភស្តុតាងលើសំណុំរឿង។ ទោះបីជាយ៉ាងណាក៏ដោយភាពចាំបាច់តម្រូវឱ្យមានសាក្សីអង្គហេតុនេះនឹងធ្វើឱ្យដំណើរការមជ្ឈត្តការមានរយៈពេលយូរបន្ថែម និងបង្កើនថ្លៃសោហ៊ុយចំណាយកាន់តែខ្ពស់ជាចាំបាច់ ព្រោះជាធម្មតាវានឹងតម្រូវឱ្យមានសេចក្តីថ្លែងសក្ខីកម្មរបស់សាក្សីជាលាយលក្ខណ៍អក្សរមួយ ឬច្រើនសម្រាប់សាក្សីម្នាក់ៗ ហើយវានឹងតម្រូវឱ្យមានសវនាការសម្រាប់ស្តាប់សក្ខីកម្មផ្ទាល់មាត់របស់សាក្សីម្នាក់ៗដែរ។

---

98 វិធានស្តីពីមជ្ឈត្តការ, ២៨ មីនា ២០២១, ប្រការ៤១

99 វិធានស្តីពីមជ្ឈត្តការ, ២៨ មីនា ២០២១, ប្រការ៤១.៤

100 លោក ហួន សុខនីម, កម្រងវិធីសាស្ត្រគន្លឹះនីតិវិធីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, បោះពុម្ពឆ្នាំ២០២១, ទំព័រ៥០

101 លោក ហួន សុខនីម, កម្រងវិធីសាស្ត្រគន្លឹះនីតិវិធីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, បោះពុម្ពឆ្នាំ២០២១, ទំព័រ៥១

សាក្សីអង្គហេតុអាចជាការតម្រូវចាំបាច់ក្នុងការបង្ហាញភស្តុតាងនៃចំណុចវិវាទលើអង្គហេតុ ឬបង្ហាញឱ្យឃើញកាន់តែទូលំទូលាយគ្រប់ជ្រុងជ្រោយអំពីកាលៈទេសៈ ដែលពាក់ព័ន្ធជុំវិញចំណុចវិវាទដែលបានកើតឡើងនៅក្នុងសំណុំរឿងនោះ។ ដើម្បីកំណត់ថា តើចាំបាច់ត្រូវការមានសាក្សីអង្គហេតុដែរឬទេ? បញ្ហាមួយចំនួនខាងក្រោមនេះគួរគប្បីត្រូវបានយកមកពិចារណាៈ

- តើពិតជាមានចំណុចវិវាទលើអង្គហេតុដែរឬទេ? ចំណុចវិវាទលើអង្គហេតុអាចលេចចេញពីក្នុងដំណាក់កាលសាកសួរដេញដោលទាញហេតុផលផ្ទាល់មាត់ ប៉ុន្តែបន្ទាប់ក្រោយពីមានការពិភាក្សារវាងគូភាគីវិវាទរួចមក គឺពុំមានចំណុចវិវាទលើអង្គហេតុនេះតទៅទៀតទេ។ លើសពីនេះភាគីវិវាទម្ខាងអាចយល់ព្រមដោយមិនជំទាស់ជាមួយនឹងភាគីវិវាទម្ខាងទៀតអំពីចំណុចវិវាទលើអង្គហេតុខ្លះ ចំពោះការងាររបស់ខ្លួនដើម្បីសន្សំសំចៃពេលវេលា និងថ្លៃសោហ៊ុយចំណាយនៅពេលដែលចំណុចវិវាទលើអង្គហេតុទាំងនោះមិនមានសារៈសំខាន់គ្រប់គ្រាន់ចាំបាច់នៅក្នុងសំណុំរឿង។
- ប្រសិនបើមានចំណុចវិវាទលើអង្គហេតុ យើងត្រូវពិចារណាថាតើវាពាក់ព័ន្ធជាសម្ភារៈសម្រាប់ធ្វើការសម្រេចសេចក្ដីលើចំណុចវិវាទណាមួយនៃសំណុំរឿងដែរឬទេ? ប្រសិនបើដូច្នោះមែននោះ វានឹងពុំចាំបាច់ឱ្យមានការចំណាយពេលវេលាបន្ថែម និងបង្កើនថ្លៃសោហ៊ុយចំណាយពាក់ព័ន្ធនឹងសាក្សីអង្គហេតុដែលត្រូវផ្ដល់សក្ខីកម្មចំពោះចំណុចវិវាទលើអង្គហេតុនោះ ព្រោះថាវាមិនប៉ះពាល់ដល់ការសម្រេចសេចក្ដីលើចំណុចវិវាទណាមួយនៃសំណុំរឿង។
- ប្រសិនបើមានចំណុចវិវាទលើអង្គហេតុ ដែលមានភាពចម្រូងចម្រាស់ដែលពាក់ព័ន្ធជាសម្ភារៈគេត្រូវពិចារណាថា តើគេអាចគ្រាន់តែត្រូវអះអាងបង្ហាញដោយផ្អែកលើភាពត្រឹមតែទៅលើឯកសារប៉ុណ្ណោះ ឬពិតជាត្រូវការជាចាំបាច់ឱ្យមានការអះអាងបញ្ជាក់ជាភស្តុតាងដោយសក្ខីកម្មរបស់សាក្សីអង្គហេតុ?
- តើមានប្រយោជន៍ទេនៅក្នុងការឱ្យមានការកោះហៅសាក្សីអង្គហេតុមកធ្វើការបង្ហាញស្ថានភាពទូទៅអំពីកាលៈទេសៈនៃវិវាទ?

នៅពេលភាគីវិវាទណាមួយបានសម្រេចចិត្តឱ្យមានសាក្សីអង្គហេតុនៅក្នុងដំណើរការមជ្ឈត្តការ គេអាចកាត់បន្ថយពេលវេលា និងថ្លៃសោហ៊ុយចំណាយបានតាមរយៈការចៀសវាងកុំឱ្យមានសាក្សីច្រើននាក់ផ្ដល់សក្ខីកម្មចំពោះអង្គហេតុដដែលដូចៗគ្នា និងដោយផ្ដោតការយកចិត្តទុកដាក់លើការកំណត់វិសាលភាពនៃសក្ខីកម្មរបស់សាក្សីនីមួយៗផងដែរ។[102]

[102] លោក ហួន សុខនីម, កម្រងវិធីសាស្ត្រគន្លឹះនីតិវិធីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, បោះពុម្ពឆ្នាំ២០២១, ទំព័រ៥២

**២.៦.៤.៦. សេចក្តីថ្លែងការណ៍សក្ខីកម្មរបស់សាក្សីអង្គហេតុ ឬសាក្សីហេតុការណ៍**

ចំណោទបញ្ហាដែលកើតឡើងនៅក្នុងផ្នែកនេះ នៅពេលដែលគូភាគីវិវាទណាមួយសម្រេចចិត្តក្នុងការបង្ហាញភស្តុតាងជាសាក្សីអង្គហេតុថា តើភាគីវិវាទគួរតែដាក់បញ្ជូនសេចក្តីថ្លែងសក្ខីកម្មរបស់សាក្សីដែរឬទេ? តើកម្រិតវិសាលភាពនៃសេចក្តីថ្លែងសក្ខីកម្មទាំងនោះគួរមានខ្លឹមសារពិស្តារប៉ុនណា? តើពេលណាសេចក្តីថ្លែងសក្ខីកម្ម ទាំងនោះត្រូវបានដាក់បញ្ជូនទៅក្នុងដំណើរការមជ្ឈត្តការ?

អនុលោមតាមប្រការ៤១ (សាក្សី) នៃវិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. ការរៀបចំចាត់ចែងឱ្យមានវត្តមានរបស់សាក្សីនៅក្នុងដំណើរការមជ្ឈត្តការដោយបានកំណត់អំពីរបៀបនៃការរៀបចំសេចក្តីថ្លែងសក្ខីកម្មភាពចាំបាច់ដែលតម្រូវដោយវេទិកាមជ្ឈត្តកម្មឱ្យភាគីវិវាទនីមួយៗ ត្រូវផ្តល់សេចក្តីជូនដំណឹងជាមុនអំពីអត្តសញ្ញាណរបស់សាក្សី និងបង្ហាញពីអំណាចរបស់វេទិកាមជ្ឈត្តកម្មដែលមានឆន្ទានុសិទ្ធិអនុញ្ញាតក្នុងការកម្រិត ឬបដិសេធការបង្ហាញរបស់សាក្សី ហើយសាក្សីណាម្នាក់ដែលផ្តល់សក្ខីកម្មដោយផ្ទាល់មាត់ ដែលត្រូវបានសាកសួរដោយវេទិកាមជ្ឈត្តកម្ម និងដោយភាគីវិវាទនីមួយៗក្នុងទម្រង់ណាមួយដែលវេទិកាមជ្ឈត្តកម្មបានកំណត់។ សាក្សីណាម្នាក់អាចត្រូវបានវេទិកាមជ្ឈត្តកម្មតម្រូវឱ្យធ្វើសក្ខីកម្មក្រោមសម្បថ ឬការអះអាង។[103] ទម្រង់សេចក្តីថ្លែងសក្ខីកម្មរបស់សាក្សី៖

- ពុំចាំបាច់មានការដាក់បញ្ជូនសេចក្តីថ្លែងសក្ខីកម្មរបស់សាក្សី
- សេចក្តីថ្លែងសង្ខេបអំពីវិសាលភាពនៃភស្តុតាងជាសាក្សី
- សេចក្តីថ្លែងសក្ខីកម្មពេញលេញរបស់សាក្សី

ម្យ៉ាងវិញទៀតការកម្រិតវិសាលភាពសេចក្តីថ្លែងពេញលេញសក្ខីកម្មរបស់សាក្សីមានដូចជា៖

- សេចក្តីថ្លែងតាមទម្រង់វែង និងមានខ្លឹមសារពិស្តារទូលំទូលាយគ្រប់ជ្រុងជ្រោយ
- សេចក្តីថ្លែងបែបសង្ខេបដែលកំណត់យកខ្លឹមសារសំខាន់ៗចំពោះចំណុចវិវាទជាក់លាក់នៅក្នុងសំណុំរឿង

ចំណែកចំនួនជុំ និងការកំណត់ពេលវេលានៃការដាក់បញ្ជូនសេចក្តីថ្លែងសក្ខីកម្មរបស់សាក្សីដូចជា៖

- ការដាក់បញ្ជូនសេចក្តីថ្លែងសក្ខីកម្មរបស់សាក្សី គួរតែត្រូវធ្វើឡើងក្នុងមួយជុំ ឬច្រើនជុំ
- សេចក្តីថ្លែងសក្ខីកម្មរបស់សាក្សីត្រូវបានដាក់បញ្ជូនស្របពេលដំណាលគ្នានឹងសំណុំឯកសារជាលាយលក្ខណ៍អក្សរនៅក្នុងពេលតែមួយ
- សេចក្តីថ្លែងសក្ខីកម្មរបស់សាក្សីដែលត្រូវបានដាក់បញ្ជូនបន្ទាប់ពីការផ្លាស់ប្តូរសំណុំឯកសារជាលាយលក្ខណ៍អក្សររវាងគូភាគីវិវាទ

[103] លោក ហួន សុខនីម, កម្រងវិធីសាស្ត្រគន្លឹះនីតិវិធីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, បោះពុម្ពឆ្នាំ២០២១, ទំព័រ៥៤

- សេចក្តីថ្លែងសក្ខីកម្មរបស់សាក្សីដែលត្រូវបានដាក់បញ្ជូនក្នុងពេលដំណាលគ្នា ឬឆ្លាស់គ្នាតាមលំដាប់លំដោយពេលបន្តបន្ទាប់ក្រោយៗទៀត។[104]

ការរៀបចំសេចក្តីថ្លែងសក្ខីកម្មរបស់សាក្សីជាអក្សរទាមទារឱ្យមានការចំណាយពេលវេលាយូរ និងមានការចំណាយកម្រៃសោហ៊ុយផ្សេងៗច្រើនផងដែរនៅក្នុងដំណាក់កាលមុនពេលសវនាការ ប៉ុន្តែគេអាចកាត់បន្ថយពេលវេលា និងថ្លៃសោហ៊ុយចំណាយលើសវនាការបានតាមរយៈការត្រួតពិនិត្យផ្ទៀងផ្ទាត់ដោយផ្ទាល់ក្នុងការសួរដេញដោល និងអនុញ្ញាតឱ្យមានការផ្តោតការយកចិត្តទុកដាក់ក្នុងការពិនិត្យផ្ទៀងផ្ទាត់ដោយ ការសួរដេញដោលលើសាក្សីបានកាន់តែច្រើន និងហ្មត់ចត់។ ប្រភេទនៃសេចក្តីថ្លែងសក្ខីកម្មរបស់សាក្សីក្នុងដំណើរការមជ្ឈត្តការ ឬការដាក់បញ្ជូនសេចក្តីថ្លែងសក្ខីកម្មសាក្សីទម្រង់ខ្លី នឹងកាត់បន្ថយថ្លៃសោហ៊ុយចំណាយនានាមុនពេលសវនាការ ប៉ុន្តែអាចបង្កើនរយៈពេលវែង និងត្រូវមានការចំណាយច្រើនលើដំណើរការសវនាការ។ ចំណែកឯសេចក្តីថ្លែងសក្ខីកម្មរបស់សាក្សីទម្រង់ពិស្តារគ្រប់ជ្រុងជ្រោយ អាចជាផ្នែកមួយដ៏មានសារៈសំខាន់ក្នុងការបង្ហាញភស្តុតាងទៅលើសំណុំរឿង ដែលវាបានអនុញ្ញាតឱ្យសាក្សីប្រាប់រឿងរ៉ាវនៃវិវាទនោះឱ្យបានក្បោះក្បាយ និងដាក់ភស្តុតាងជាឯកសារត្រូវតាមបរិបទរបស់សំណុំរឿង។ តែទោះជាយ៉ាងណាក៏ដោយ សេចក្តីថ្លែងសក្ខីកម្មរបស់សាក្សីទម្រង់ពិស្តារនឹងបង្កឱ្យមានការចំណាយពេលវេលាយូរ និងថ្លៃចំណាយខ្ពស់ ហើយកម្រិតវិសាលភាពក្នុងការពិនិត្យផ្ទៀងផ្ទាត់ក៏កាន់តែធំទូលាយដែរ។

ចំពោះចំនួនជុំ និងការកំណត់ពេលវេលានៃការដាក់បញ្ជូនសេចក្តីថ្លែងសក្ខីកម្មរបស់សាក្សី មានច្រើនជាងមួយជុំ ដែលនឹងផ្តល់ឱកាសឱ្យសាក្សីក្នុងការបដិសេធភស្តុតាងរបស់សាក្សីម្ខាងទៀត ប៉ុន្តែនឹងបង្កើនពេលវេលាឱ្យកាន់តែយូរ និងមានថ្លៃសោហ៊ុយចំណាយខ្ពស់មុនពេលសវនាការ។

ការដាក់បញ្ជូនសេចក្តីថ្លែងសក្ខីកម្មរបស់សាក្សីរួមជាមួយការបញ្ជូនសេចក្តីថ្លែង និងសំណៅឯកសារដែលដាក់ដោយភាគីវិវាទក្នុងពេលដំណាលគ្នា គឺវាអាចបញ្ជាក់ដោយផ្ទាល់ជាភស្តុតាងអំពីអង្គហេតុ ដែលមានការយល់ឃើញផ្ទុយគ្នាដោយគូភាគីវិវាទ ការអនុវត្តរបៀបនេះក៏អនុញ្ញាតឱ្យគូភាគីនៃវិវាទអាចធ្វើការកំណត់នូវអត្តសញ្ញាណលក្ខណៈវិវាទ និងបង្រួមចំណុចវិវាទលើអង្គហេតុឱ្យរួមតូច កាន់តែជាក់លាក់ជាបន្តបន្ទាប់និងធ្វើឱ្យគេអាចផ្តោតលើការយកចិត្តទុកដាក់បានគ្រប់គ្រាន់ និងចំគោលដៅក្នុងការដាក់សំណៅឯកសារពេលក្រោយៗមកទៀត។ ចំពោះការបញ្ជូននូវសេចក្តីថ្លែងសក្ខីកម្មរបស់សាក្សី បន្ទាប់ពីការផ្លាស់ប្តូរនៃការដាក់បញ្ជូនសំណៅឯកសារជាលាយលក្ខណ៍អក្សរអាចអនុញ្ញាតឱ្យគូភាគីបង្រួមការដោះស្រាយវិវាទនៅមុនពេលមានការរៀបចំ និង

[104] លោក ហួន សុខនីម, កម្រងវិធីសាស្ត្រគន្លឹះនីតិវិធីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, បោះពុម្ពឆ្នាំ២០២១, ទំព័រ៥៥

ការដាក់បញ្ជូនសេចក្តីថ្លែងសក្ខីកម្មរបស់សាក្សី ដែលបន្ទាប់មកគេអាចមានពេលវេលាសម្រាប់យកចិត្តទុកដាក់ផ្តោតតែទៅលើចំណុចវិវាទផ្សេងទៀតបានកាន់តែច្រើនជាងមុន។

ខណៈពេល សេចក្តីថ្លែងសក្ខីកម្មរបស់សាក្សីអាចផ្តល់ជាភស្តុតាងដ៏មានតម្លៃគ្រប់គ្រាន់ ដើម្បីធ្វើការគាំទ្រដល់អំណះអំណាងអំពីជំហររបស់ភាគីវិវាទម្ខាងៗ គេក៏ចាំបាច់ត្រូវតែយកចិត្តទុកដាក់បន្ថែមជាសំខាន់ចំពោះការប្រើប្រាស់ពេលវេលា និងការចំណាយពាក់ព័ន្ធនានាផងដែរ។ គេត្រូវតែថ្លឹងថ្លែងកម្រិតនៃសារៈសំខាន់ និងទម្ងន់នៃភស្តុតាងដែលត្រូវបង្ហាញធៀបទៅនឹងការប្រើប្រាស់ពេលវេលា និងការចំណាយពាក់ព័ន្ធនានាដែលត្រូវការជាចាំបាច់សម្រាប់ការរៀបចំសេចក្តីថ្លែងសក្ខីកម្មរបស់សាក្សី។ ឧទាហរណ៍ ប្រសិនបើមានជម្រើសនៃភស្តុតាងផ្សេងទៀតដែលអាចជំនួសបាន គេប្រហែលជាមិនមានហេតុផលណាមួយដែលត្រូវធ្វើការចំណាយទៅលើការរៀបចំឱ្យមានសេចក្តីថ្លែងសក្ខីកម្មរបស់សាក្សីអំពីអង្គហេតុនោះទេ។ ប្រសិនបើមានសាក្សីណាម្នាក់បានដាក់បញ្ជូនសេចក្តីថ្លែងសក្ខីកម្មរបស់ខ្លួនទៅលើអង្គហេតុណាមួយដែលបានផ្តល់ឱ្យរួចហើយ នោះសេចក្តីថ្លែងសក្ខីកម្មរបស់សាក្សីដទៃផ្សេងទៀត ដែលបង្ហាញអំពីអង្គហេតុដូចគ្នាពុំចាំបាច់ត្រូវយកមកដាក់បញ្ជូនថែមទៀតទេព្រោះវានឹងបង្កឱ្យមានថ្លៃសោហ៊ុយចំណាយបន្ថែមដោយគ្មានហេតុផល ប្រសិនបើជាកម្រិតមួយដែលសារៈសំខាន់នៃអង្គហេតុនោះមានតម្លៃតិចតួចនៅក្នុងសំណុំរឿង ។

វាជាការពិតប្រាកដណាស់ ការរៀបចំឱ្យមានសេចក្តីថ្លែងសក្ខីកម្មរបស់សាក្សីតាមទម្រង់ពិស្តារ គ្រប់ជ្រុងជ្រោយ គឺទាមទារឱ្យមានការប្រើប្រាស់ពេលវេលាយូរ និងអស់ថ្លៃសោហ៊ុយចំណាយច្រើនជាងការរៀបចំ សេចក្តីថ្លែងសក្ខីកម្មរបស់សាក្សីតាមទម្រង់សង្ខេបខ្លី ប៉ុន្តែការរៀបចំឱ្យមានសេចក្តីថ្លែងសក្ខីកម្មរបស់សាក្សីតាមទម្រង់ពិស្តារគ្រប់ជ្រុងជ្រោយជួយឱ្យគេសន្សំសំចៃពេលវេលា និងថ្លៃសោហ៊ុយចំណាយបានមួយចំនួនព្រោះថាគេនឹងពុំចាំបាច់ប្រើប្រាស់ពេលវេលាច្រើនក្នុងការសាកសួរដេញដោលសាក្សីនៅក្នុងសវនាការ។[105]

ចំពោះការសាកសួរសាក្សីក៏មានសារៈសំខាន់ដែរ ក្នុងការស្រាយបំភ្លឺបន្ថែមនូវបញ្ហាវិវាទ។ នៅក្នុងនីតិវិធីសាកសួរសាក្សីក្នុងដំណើរការមជ្ឈត្តការ គឺដូចគ្នាទៅនឹងដំណើរការនៃការសាកសួរសាក្សីនៅក្នុងតុលាការដែរ។ ភាគីដែលចង់ដាក់បញ្ចូលនូវសាក្សីចូលសវនាការត្រូវមានការយល់ព្រមពីមជ្ឈត្តករជាមុនសិន ហើយសាក្សីត្រូវធ្វើការស្បថស្បែរមុននឹងផ្តល់ចម្លើយ ឬធ្វើការអះអាង។ សាក្សីជំនាញជាទូទៅអាចជួយក្នុងការបញ្ជាក់ពីករណីវិវាទរបស់នរណាម្នាក់នៅក្នុងដំណើរការមជ្ឈត្តការ។ នៅក្នុងនីតិវិធីសាកសួរសាក្សីនេះ ភាគីអាចធ្វើការសាកសួរដេញដោលជាមួយសាក្សីបាន ហើយបើសិនជាមជ្ឈត្តករមានសំណួរបន្ថែម មជ្ឈត្តករក៏អាចធ្វើការសាកសួរទៅលើសាក្សីនោះបានផងដែរ។

[105] លោក ហួន សុខនីម, កម្រងវិធីសាស្ត្រគន្លឹះនីតិវិធីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, បោះពុម្ពឆ្នាំ២០២១, ទំព័រ៥៧

**២.៦.៤.៧. ការឆ្លើយ និងឆ្លើយតប**

នៅអំឡុងពេលដំណើរការការសវនាការមជ្ឈត្តការនេះ អនុញ្ញាតឱ្យគូភាគីវិវាទមានការឆ្លើយ និងឆ្លើយតប ដែលភាគីម្ខាងឆ្លើយ ជាបន្ទាប់មកភាគីម្ខាងជាអ្នកឆ្លើយតបវិញ ដោយសំអាងទៅលើភស្តុងតាងដែលមាន និង អាចបញ្ជាក់បន្ថែមនៅក្នុងការឆ្លើយ និងឆ្លើយតបនោះ វេទិកាមជ្ឈត្តកម្មអាចសុំឱ្យភាគីពន្យល់បន្ថែមលើភស្តុតាង ដែលខ្លួនបានដាក់ជូនសវនាការឱ្យបានល្អិតល្អន់ និងច្បាស់លាស់។

**២.៦.៤.៨. សេចក្តីថ្លែងការណ៍បិទ**

គូភាគីវិវាទនៅក្នុងដំណើរមជ្ឈត្តការមានឱកាសបង្ហាញនូវអំណះអំណាងផ្នែកច្បាប់របស់ខ្លួន និងអង្គហេតុ ដែលពាក់ព័ន្ធក្នុងសំណៅឯកសារដែលត្រូវដាក់បញ្ជូនមុនពេលសវនាការ និងដាក់ក្នុងអំឡុងពេលសវនាការផ្ទាល់។

សេចក្តីថ្លែងសង្ខេបក្រោយសវនាការអាចត្រូវបានប្រើប្រាស់ ដើម្បីទាក់ទាញការយកចិត្តទុកដាក់របស់ វេទិកាមជ្ឈត្តកម្មចំពោះអង្គហេតុពាក់ព័ន្ធនានាដែលបានលេចឡើងនៅក្នុងសវនាការ ហើយសេចក្តីថ្លែងសង្ខេប ក្រោយសវនាការនោះត្រូវតាក់តែងក្នុងខ្លឹមសារស្របតាមបរិបទនៃការទាមទារ និងការដោះសារ (ការឆ្លើយតប) របស់គូភាគីវិវាទ។ សេចក្តីថ្លែងសង្ខេបក្រោយសវនាការត្រូវបានតាក់តែងក្នុងលក្ខណៈជួយដល់វេទិកាមជ្ឈត្តកម្ម ក្នុងការធ្វើសេចក្តីព្រាងសេចក្តីសម្រេចនៃមជ្ឈត្តវិនិច្ឆ័យ។ ក្នុងករណីខ្លះ វេទិកាមជ្ឈត្តកម្មអាចកំណត់ពីចំណុច វិវាទសំខាន់ៗ គូភាគីវិវាទត្រូវបានលើកយកមករៀបរាប់នៅក្នុងសេចក្តីថ្លែងសង្ខេបក្រោយសវនាការរបស់ខ្លួន។ ប្រសិនបើសេចក្តីថ្លែងបិទត្រូវបានតម្រូវឱ្យធ្វើឡើងនៅពេលបិទបញ្ចប់នៃសវនាការនោះ គេពុំចាំបាច់ធ្វើសេចក្តី ថ្លែងសង្ខេបក្រោយសវនាការឡើយ។ ផ្ទុយមកវិញប្រសិនបើមានសេចក្តីថ្លែងសង្ខេបក្រោយសវនាការ ត្រូវបាន តម្រូវឱ្យធ្វើឡើងនៅបិទបញ្ចប់នៃសវនាការនោះគេពុំចាំបាច់ធ្វើសេចក្តីថ្លែងបិទឡើយ។ អ្វីដែលត្រូវគិតនោះគឺៈ

- ការចាត់ឱ្យមានដំណើរការនីតិវិធីតាក់តែងធ្វើនូវមជ្ឈត្តវិនិច្ឆ័យភ្លាមៗ បន្ទាប់ពីសវនាការរួចដោយពុំចាំបាច់ មានការធ្វើសេចក្តីថ្លែងបិទ ឬសេចក្តីថ្លែងសង្ខេបក្រោយសវនាការទេ។
- អនុញ្ញាតឱ្យមានការដាក់សេចក្តីថ្លែងបិទភ្លាមៗបន្ទាប់ពីសវនាការ ឬនៅពេលវេលាកំណត់ណាមួយដែល បានព្រមព្រៀងគ្នាបន្ទាប់ពីសវនាការ ប៉ុន្តែពុំចាំបាច់មានសេចក្តីថ្លែងសង្ខេបក្រោយសវនាការទេ។
- អនុញ្ញាតឱ្យមានការដាក់ទាំងសេចក្តីថ្លែងបិទ និងសេចក្តីថ្លែងសង្ខេបក្រោយសវនាការ។

លំដាប់ ហើយការដាក់បញ្ជូនសេចក្តីថ្លែងសង្ខេបក្រោយសវនាការ នោះអាចមានច្រើនជាងមួយជុំ។

ការដាក់បញ្ជូនសេចក្តីថ្លែងសង្ខេបក្រោយសវនាការអាចបម្រើគោលបំណងមានប្រយោជន៍ មួយចំនួនដូច ដែលបានរៀបរាប់ខាងលើ។ នៅក្នុងសវនាការដែលប្រើពេលវេលាវែង និងមានលក្ខណៈស្មុគស្មាញ សេចក្តីថ្លែង សង្ខេបក្រោយសវនាការអាចមានប្រយោជន៍សម្រាប់ភាគីវិវាទនីមួយៗ ដើម្បីធ្វើការបូកសរុបនូវអ្វីដែលពួកគេចាត់ ទុកថាចាំបាច់ត្រូវបង្ហាញនៅក្នុងសវនាការ។ សេចក្តីថ្លែងសង្ខេបក្រោយសវនាការអាចរួមបញ្ចូលរាប់ទាំងឯកសារ

យោងមានតម្លៃផ្សេងៗទៀតរហូតដល់ប្រតិចារឹកនៃសវនាការ និងបង្ហាញចំណុចសំយោគចុងក្រោយខ្លីៗទាក់ទងនឹងភស្តុតាងនានា និងអង្គហេតុទាំងអស់នៃសំណុំរឿងដែលអាចមានគុណតម្លៃខ្ពស់ចំពោះវេទិកាមជ្ឈត្តកម្មនៅពេលរៀបចំតាក់តែងធ្វើសេចក្តីព្រាងមជ្ឈត្តវិនិច្ឆ័យ។ ការរៀបចំសេចក្តីថ្លែងសង្ខេបក្រោយសវនាការជាការបន្ថែមចំណាយលើដំណើរការមជ្ឈត្តការ ហើយអាចធ្វើឱ្យមានការពន្យារពេលវេលាក្នុងការចេញមជ្ឈត្តវិនិច្ឆ័យ។ សេចក្តីថ្លែងសង្ខេបក្រោយសវនាការអាចមានប្រយោជន៍តិចតួច ប្រសិនបើសេចក្តីថ្លែងសង្ខេបក្រោយសវនាការនោះ គ្រាន់តែនិយាយឡើងវិញនូវអង្គហេតុ និងអំណះអំណាងដែលវេទិកាមជ្ឈត្តកម្មបានយល់ច្បាស់រួចហើយ។

**២.៦.៤.៩. ការចេញមជ្ឈត្តវិនិច្ឆ័យរបស់វេទិកាមជ្ឈត្តកម្ម**

បន្ទាប់ពីកម្មវត្ថុវិវាទត្រូវបានដោះស្រាយចប់ហើយ ជាចុងក្រោយនោះគឺការចេញនូវមជ្ឈត្តវិនិច្ឆ័យ។ ការចេញនូវសេចក្តីសម្រេចនេះ ជាសមត្ថកិច្ចរបស់វេទិកាមជ្ឈត្តកម្មដែលពិចារណាទៅលើចំណុចមួយចំនួនដូចជាអង្គហេតុ មូលដ្ឋានច្បាប់ វិធាន លក្ខខណ្ឌផ្សេងៗក្នុងកិច្ចសន្យា និងទម្លាប់ផ្នែកពាណិជ្ជកម្មដោយស្របតាមគោលការណ៍សមធម៌។[106] ប៉ុន្តែមុននឹងចេញនូវសេចក្តីសម្រេចមជ្ឈត្តវិនិច្ឆ័យជាផ្លូវការនោះ វេទិកាមជ្ឈត្តកម្មត្រូវធ្វើសេចក្តីព្រាងមួយ ហើយបញ្ជូនសេចក្តីព្រាងសេចក្តីសម្រេចមជ្ឈត្តវិនិច្ឆ័យនោះ ទៅកាន់អគ្គលេខាធិការដ្ឋានក្នុងគោលបំណងធ្វើការត្រួតពិនិត្យលើទម្រង់ផ្សេងៗចំពោះសេចក្តីសម្រេចនោះមុនធ្វើការចេញសេចក្តីសម្រេចមជ្ឈត្តវិនិច្ឆ័យ។ នៅក្នុងការចេញនូវមជ្ឈត្តវិនិច្ឆ័យនោះដែរ ត្រូវធ្វើឡើងជាទម្រង់លាយលក្ខណ៍អក្សរដែលបានព្រមព្រៀង បញ្ជាក់មូលមូលហេតុ កាលបរិច្ឆេទ ទីកន្លែង និងចុះហត្ថលេខាដោយមជ្ឈត្តករទាំងអស់។

ចំពោះវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករច្រើនរូប ហត្ថលេខារបស់សមាជិកភាគច្រើននៃវេទិការមជ្ឈត្តកម្មត្រូវចាត់ទុកថាគ្រប់គ្រាន់ ល្គឹកណាមានការបញ្ជាក់ពីមូលហេតុដែលមជ្ឈត្តករដទៃផ្សេងមិនបានចុះហត្ថលេខា។[107]ម្យ៉ាងវិញទៀតនោះ ប្រសិនបើក្នុងដំណើរការមជ្ឈត្តការដែលមានមជ្ឈត្តករលើសពីម្នាក់ មជ្ឈត្តវិនិច្ឆ័យរបស់វេទិកាមជ្ឈត្តកម្ម ត្រូវធ្វើឡើងដោយមតិភាគច្រើនដោយប្រៀបនៃមជ្ឈត្តករជាសមាជិកនៃវេទិកាមជ្ឈត្តកម្ម។ នៅពេលដែលវេទិកាមជ្ឈត្តកម្មបានចេញនូវមជ្ឈត្តវិនិច្ឆ័យរួចហើយ អគ្គលេខាធិការដ្ឋានត្រូវតែបោះត្រា ម.ជ.ម. ទៅលើមជ្ឈត្តវិនិច្ឆ័យនោះដោយមិនមានការបង្អង់ និងបញ្ជូនមជ្ឈត្តវិនិច្ឆ័យនោះទៅគ្រប់ភាគីវិវាទទាំងអស់ ប្រសិនបើកម្រៃសេវាទាំងអស់លើមជ្ឈត្តការត្រូវបានបង់គ្រប់ចំនួនទៅ ម.ជ.ម. សម្រាប់ក្នុងករណីមជ្ឈត្តវិនិច្ឆ័យស្ថាពរ ហើយមជ្ឈត្តវិនិច្ឆ័យនឹងក្លាយជាមជ្ឈត្តវិនិច្ឆ័យស្ថាពរ ប្រកបដោយអានុភាពអនុវត្តចំពោះគូភាគីចាប់ពីពេលដែលមជ្ឈត្តវិនិច្ឆ័យនោះត្រូវបានចេញ និងបោះត្រា។[108]

---

[106] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, លេខ នស/រកម/០៥០៦/០១០, ០៥ ឧសភា ២០០៦, មាត្រា៣៦

[107] វិធានស្តីពីមជ្ឈត្តការ, ២៨ មីនា ២០២១, ប្រការ៤៩

[108] វិធានស្តីពីមជ្ឈត្តការ, ២៨ មីនា ២០២១, ប្រការ៥២

# ជំពូកទី៣
# បណ្តឹងឧបាស្រ័យ
# និងអានុភាពមជ្ឈត្តវិនិច្ឆ័យ

# ជំពូកទី៣
# បណ្តឹងឧបាស្រ័យ និងអានុភាពមជ្ឈត្តវិនិច្ឆ័យ

## ៣.១. បណ្តឹងឧបាស្រ័យ

អនុលោមតាមច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងច្បាប់ស្តីពីមជ្ឈត្តការពាណិជ្ជកម្មអន្តរជាតិភាគច្រើន មជ្ឈត្តវិនិច្ឆ័យមិនងាយប្តឹងជំទាស់បានឡើយ លើកលែងតែនៅក្នុងកាលៈទេសៈដែលរឹតត្បិតបំផុត។ ការអនុញ្ញាតឱ្យភាគីម្ខាងធ្វើការប្តឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យដោយងាយស្រួលនឹងធ្វើឱ្យបាត់អត្ថប្រយោជន៍របស់មជ្ឈត្តការដ៏សំខាន់បំផុតមួយ ពោលលទ្ធភាពក្នុងការផ្តល់នូវដំណោះស្រាយយ៉ាងឆាប់រហ័ស មានប្រសិទ្ធភាព និងប្រកបដោយលក្ខណៈវិជ្ជាជីវៈ។ គេអាចនិយាយម្យ៉ាងទៀតថា ភាគីវិវាទនឹងមិនរកបាននូវការលើកទឹកចិត្តពិតប្រាកដក្នុងការចាប់ផ្តើមមជ្ឈត្តការឡើយ ប្រសិនបើសេចក្តីសម្រេចរបស់មជ្ឈត្តការ អាចត្រូវបានប្តឹងជំទាស់យ៉ាងងាយស្រួលទៅតុលាការនោះ។[109]

ដោយហេតុនេះ ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មចែងតែអំពីមូលហេតុតិចតួចបំផុតប៉ុណ្ណោះក្នុងការលុបចោលនូវមជ្ឈត្តវិនិច្ឆ័យណាមួយ។ មិនមានមូលហេតុណាមួយតម្រូវឱ្យមានការពិនិត្យមើលឡើងវិញអំពីលក្ខណៈសម្បត្តិនៃភស្តុតាង និងសេចក្តីសម្រេចឡើយ។ ទោះជាយ៉ាងណាក៏ដោយ តុលាការកម្ពុជាអាចលុបចោលនូវមជ្ឈត្តវិនិច្ឆ័យណាមួយបាន ប្រសិនបើមាន។ ដើម្បីឱ្យកាន់តែច្បាស់អំពីផ្នែកនេះនឹងមានការរៀបរាប់បន្ថែមទៀតទៅលើ ៣.១.១. ការធ្វើបណ្តឹងទាស់ទៅនឹងមជ្ឈត្តវិនិច្ឆ័យ, ៣.១.២. សមត្ថកិច្ចក្នុងការធ្វើបណ្តឹងទាស់, ៣.១.៣. លក្ខខណ្ឌនៃការធ្វើបណ្តឹងទាស់, ៣.១.៤. អាជ្ញាយុកាលនៃការដាក់ពាក្យសុំបដិសេធ និងចុងក្រោយ ៣.១.៥. ការកែតម្រូវ ការបំភ្លឺលម្អិត ការបកស្រាយមជ្ឈត្តវិនិច្ឆ័យ និងមជ្ឈត្តវិនិច្ឆ័យបន្ថែម។

### ៣.១.១. ការធ្វើបណ្តឹងជំទាស់ទៅនឹងមជ្ឈត្តវិនិច្ឆ័យ

ត្បិតថាការប្តឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យជាការមួយដែលពិបាក តែមិនមែនមានន័យមិនអាចធ្វើទៅបាននោះទេ ជាការពិតណាស់ ភាគីវិវាទអាចប្តឹងជំទាស់ទៅនឹងមជ្ឈត្តវិនិច្ឆ័យតាមទ្រង់ទ្រាយជាបណ្តឹងបដិសេធ។

ជាការពិតណាស់បណ្តឹងជំទាស់ អាចនិយាយបានថាជាបណ្តឹងឧបាស្រ័យមួយប្រភេទ ធ្វើទៅកាន់តុលាការជាន់ខ្ពស់ដើម្បីទាមទារឱ្យលុបចោល ឬផ្លាស់ប្តូរដីកាសម្រេចជាដើម។[110] ស្របជាមួយគ្នានេះផងដែរ ការប្តឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យមិនអាចធ្វើឡើងចំពោះការមិនពេញចិត្តនឹងសេចក្តីសម្រេចនោះបានទេ ភាគីវិវាទអាចប្តឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យបានតែក្នុងករណីណា ដែលដំណើរការមជ្ឈត្តការធ្វើខុសនូវនីតិវិធីត្រង់ណាមួយ ឬភាគីមិនសុខចិត្តនឹងសេចក្តីសម្រេចចុងក្រោយនៅក្នុងមជ្ឈត្តវិនិច្ឆ័យនោះតែប៉ុណ្ណោះ វាអាចជាមូលហេតុ

[109] មេធាវី ស៊ីវីន អ៊ែន អស្ទើរមីឡើរ, ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅកម្ពុជា, បោះពុម្ពឆ្នាំ២០១០, ទំព័រ១៩០

[110] វចនានុក្រមច្បាប់តាមបទដ្ឋានគតិយុត្តិខ្មែរ ដោយសមាគមស្រាវជ្រាវ និងផ្សព្វផ្សាយច្បាប់ខ្មែរ ឆ្នាំ២០១៨ ទំព័រ២១៨

ធ្វើឱ្យគូរភាគីណាម្ខាងមិនអាចទទួលស្គាល់ និងយកមកអនុវត្តបាននូវមជ្ឈត្តវិនិច្ឆ័យនោះត្រង់ផ្នែកខ្លះ ឬចំណុចណាមួយ ហើយគូភាគីនៃវិវាទត្រូវយល់ដឹងអំពីស្ថាប័នមានសមត្ថកិច្ចក្នុងការទទួលនូវការប្តឹងជំទាស់របស់ខ្លួន លក្ខខណ្ឌនៃបណ្តឹងជំទាស់ និងអាជ្ញយុកាលនៃការដាក់ពាក្យសុំបដិសេធ ដើម្បីកុំឱ្យមានការខ្វះខាត ឬខុសត្រង់ចំណុចណាមួយ ដែលនាំឱ្យមានភាពយឺតយ៉ាវក្នុងការដាក់ពាក្យប្តឹងជំទាស់ទៅស្ថាប័នដែលមានសមត្ថកិច្ច។

ជាទូទៅភាគីវិវាទប្រសិនបើបានបញ្ចប់នីតិវិធីត្រឹមវេទិកាមជ្ឈត្តកម្មនោះ គឺពុំអាចធ្វើការប្តឹងបានទេ នៅក្នុងកម្រិតមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដោយសារតែមជ្ឈត្តវិនិច្ឆ័យ គឺជាសេចក្តីសម្រេចចុងក្រោយដែលបិទផ្លូវតវ៉ា។ ក៏ប៉ុន្តែដោយសារយន្តនេះត្រូវបានជាធរមាន នៅក្នុងព្រះរាជាណាចក្រកម្ពុជាផ្តល់សិទ្ធិដល់គូភាគីវិវាទក្នុងការធ្វើបណ្តឹងជំទាស់ដើម្បីបដិសេធមជ្ឈត្តវិនិច្ឆ័យទៅកាន់ស្ថាប័នតុលាការ ទើបសេចក្តីសម្រេចរបស់វេទិកាមជ្ឈត្តកម្មអាចត្រូវបានយកមកពិនិត្យ និងវិនិច្ឆ័យឡើងវិញដោយតុលាការមានសមត្ថកិច្ច។ ជាការបញ្ជាក់ផងដែរថាការធ្វើបណ្តឹងជំទាស់នេះ គឺមិនមែនជាការធ្វើបណ្តឹងមួយដោយស្រេចតែបំណងរបស់ភាគីវិវាទ ដោយគ្មានមូលហេតុ ឬភស្តុតាងត្រឹមត្រូវ ឬដើម្បីពន្យាពេលនៃការអនុវត្តមជ្ឈត្តវិនិច្ឆ័យនោះទេ។ ការពិនិត្យមើលទៅលើបណ្តឹងជំទាស់នេះ ភាគីត្រូវមានភស្តុតាងដាក់បន្ទុកដូចមានចែងក្នុងមាត្រា៤៤ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។ លើសពីនេះទៅទៀត ការពិនិត្យមើលមជ្ឈត្តវិនិច្ឆ័យនេះផងដែរ តុលាការពុំមានសិទ្ធិធ្វើការពិនិត្យទៅលើសេចក្តីសម្រេចរបស់វេទិកាមជ្ឈត្តការបានទាំស្រុងទេ គឺពិនិត្យមើលបានត្រឹមក្របខណ្ឌ ឬត្រឹមមូលដ្ឋានដែលបានផ្តល់ជូនដល់ភាគីវិវាទក្នុងការធ្វើបណ្តឹងជំទាស់តែប៉ុណ្ណោះ។ មូលហេតុដែលតុលាការពុំអាចពិនិត្យមើលមជ្ឈត្តវិនិច្ឆ័យទាំងស្រុងបាន នេះដោយសារតែវេទិកាមជ្ឈត្តកម្ម គឺជាវេទិកានៃការដោះស្រាយវិវាទដែលមានចរិកលក្ខណៈឯកជនការពារការសម្ងាត់ទាំងឡាយរបស់គូភាគីវិវាទ ពោលគឺគូភាគីវិវាទបើពុំមានការព្រមព្រៀងជាលាយលក្ខណ៍អក្សរនោះទេ គឺមានកាតព្វកិច្ចរក្សាការសម្ងាត់ និងមិនត្រូវបង្ហាញនៅអង្គហេតុដែលពាក់ព័ន្ធទៅតតិយជន ឬបុគ្គលដទៃដោយគ្មានការអនុញ្ញាត ឬការព្រមព្រៀងពីភាគីម្ខាតទៀតបានឡើយ។[111] ប៉ុន្តែមានអញ្ញត្រកម្មចំពោះវិធាន ម.ជ.ម. ថ្មីបានអនុញ្ញាតឱ្យភាគីនៃវិវាទបង្ហាញអង្គហេតុ ឬព័ត៌មានដែលដែលពាក់ព័ន្ធទៅកាន់អង្គតុលាការដែលមានសមត្ថកិច្ចបាន ក្នុងករណីដែលភាគីបានដាក់ពាក្យបណ្តឹងទៅតុលាការមានសមត្ថកិច្ច ដើម្បីធ្វើបណ្តឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យ។[112] លើសពីនេះទៅទៀតក្នុងករណីដែលមានដីកាបង្គាប់ ឬដីកាកោះរបស់តុលាការមានសមត្ថកិច្ច ភាគីវិវាទចាំបាច់ជាដាច់ខាតក្នុងការបង្ហាញនូវអង្គហេតុ ឬព័ត៌មានទាំងឡាយណាដែលពាក់ព័ន្ធតបតាមដីការបស់តុលាការមានសមត្ថកិច្ច។[113]

[111] វិធានស្តីពីមជ្ឈត្តការ, ២៨ មីនា ២០២១, ប្រការ៦៦

[112] វិធានស្តីពីមជ្ឈត្តការ, ២៨ មីនា ២០២១, ប្រការ៦៦.៣ (ក)

[113] វិធានស្តីពីមជ្ឈត្តការ, ២៨ មីនា ២០២១, ប្រការ៦៦.៣ (ខ)

### ៣.១.២. សមត្ថកិច្ចក្នុងការធ្វើបណ្តឹងជំទាស់

ដែនសមត្ថកិច្ចក្នុងការធ្វើបណ្តឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យ គឺសំដៅដល់មូលដ្ឋាននៃដែនយុត្តាធិការតុលាការសម្រាប់ការពារ និងផ្តល់ជាមូលដ្ឋានឱ្យគូភាគីវិវាទ ដែលអាចមានសមត្ថភាពតាមផ្លូវច្បាប់ដើម្បីប្តឹងជំទាស់ទៅនឹងមជ្ឈត្តវិនិច្ឆ័យ ដែលត្រូវបានសម្រេចដោយវេទិកាមជ្ឈត្តកម្មរួចមក។ ជាការពិតណាស់ក្នុងនៅន័យនេះ គឺចង់សំដៅទៅដល់មូលហេតុនានា ដែលច្បាប់បានកំណត់ថាមានភាពមិនសមស្របដល់ដំណើរការមជ្ឈត្តការ ឬអាចជាចំណុចនៃកិច្ចព្រមព្រៀងរបស់គូភាគីនៃវិវាទ ហេតុដូច្នេះបានជាទិដ្ឋភាពផ្លូវច្បាប់បានផ្តល់ឱកាសដល់ភាគីវិវាទអាចធ្វើការប្តឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យនោះបាន។ ជាការពិតណាស់ ផ្នែកនេះបានផ្តល់សញ្ញាណអំពីដែនសមត្ថកិច្ចនៃការធ្វើបណ្តឹងទាស់នឹងមជ្ឈត្តវិនិច្ឆ័យរបស់វេទិកាមជ្ឈត្តកម្មផងដែរ។

ដូច្នេះហើយចំពោះភាគីដែលស្វែងរកការលុបចោល ឬស្នើសុំការកែប្រែ មជ្ឈត្តវិនិច្ឆ័យ អាចសំអាងលើច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលបានកំណត់ថា សាលាឧទ្ធរណ៍នៃព្រះរាជាណាចក្រកម្ពុជា មានសមត្ថកិច្ចក្នុងការចេញសេចក្តីសម្រេចលើការប្តឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យ ដោយមានវត្តមានផងដែរចំពោះតុលាការកំពូលជាសាលាជំនុំជម្រះក្តីចុងក្រោយ ចំពោះករណីដែលភាគីវិវាទមានបំណងក្នុងការធ្វើបណ្តឹងឧបាស្រ័យជំទាស់ជាមួយនឹងសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍។[114]

### ៣.១.៣. លក្ខខណ្ឌនៃការធ្វើបណ្តឹងជំទាស់

ជាការពិត គូភាគីវិវាទនៃបណ្តឹងជំទាស់ជាមួយនឹងមជ្ឈត្តវិនិច្ឆ័យ ដោយខ្លួនអាចធ្វើឡើងបានតាមទ្រង់ទ្រាយជាបណ្តឹងបដិសេធ។[115] គូភាគីអាចប្តឹងតាមលក្ខខណ្ឌមួយចំនួនដូចខាងក្រោយគឺៈ

- បណ្តឹងបដិសេធទៅនឹងមជ្ឈត្តវិនិច្ឆ័យតាមផ្លូវតុលាការ អាចធ្វើទៅបានលុះត្រាតែស្របតាមលក្ខខណ្ឌ ដូចមានចែងក្នុងវាក្យខ័ណ្ឌទី២ និងវាក្យខ័ណ្ឌទី៣ នៃមាត្រា៤៤។
- សាលាឧទ្ធរណ៍ និងតុលាការកំពូលអាចបដិសេធមជ្ឈត្តវិនិច្ឆ័យរបស់មជ្ឈត្តករបានក្នុងករណី ភាគីដែលដាក់ពាក្យសុំបដិសេធផ្តល់ភស្តុតាងគ្រប់គ្រាន់ថា ភាគីមួយនៃកិច្ចព្រមព្រៀងផ្សះផ្សាដូចមានយោងក្នុងមាត្រា៧ នៃច្បាប់នេះ បានបាត់បង់សិទ្ធិមួយចំនួនខាងផ្លូវច្បាប់ ឬកិច្ចព្រមព្រៀងផ្សះផ្សានោះ ពុំអាចយកជាការបាន បើយោងតាមច្បាប់ដែលភាគីវិវាទបានសំអាងនោះ ឬកិច្ចព្រមព្រៀងផ្សះផ្សាពុំបានគោរពតាមបញ្ញត្តិណាមួយនៃច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា។ មិនតែប៉ុណ្ណោះ ភាគីដាក់ពាក្យសុំបដិសេធនោះមិនបានទទួលដំណឹងត្រឹមត្រូវពីការតែងតាំងមជ្ឈត្តករ ឬដំណើរមជ្ឈត្តការ ឬភាគីនោះពុំអាចបង្ហាញពីអង្គហេតុរបស់ខ្លួនបានដោយប្រសិទ្ធភាព។ ម្យ៉ាងទៀតនោះ មជ្ឈត្តវិនិច្ឆ័យដែលទាក់ទិននឹងវិវាទនោះពុំ

---

[114] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, លេខ នស/រកម/០៥០៦/០១០, ០៥ ឧសភា ២០០៦, មាត្រា១ត្រា៤២

[115] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, លេខ នស/រកម/០៥០៦/០១០, ០៥ ឧសភា ២០០៦, មាត្រា៤៤

ឆ្លើយតប ឬពុំគោរពលក្ខខណ្ឌនៃកិច្ចព្រមព្រៀងផ្សះផ្សា។ ការបង្កើតវេទិកាមជ្ឈត្តកម្មពុំស្របនឹងកិច្ចព្រមព្រៀងរបស់ភាគីវិវាទ ក្នុងករណីដែលកិច្ចព្រមព្រៀងនោះ ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។ ក្នុងករណីដែលគ្មានកិច្ចព្រមព្រៀងផ្សះផ្សាទេ វេតិកាមជ្ឈត្តកម្ម ឬដំណើរការមជ្ឈត្តការខាងលើមិនស្របតាមច្បាប់នេះ។ សាលាឧទ្ធរណ៍ និងតុលាការកំពូលរកឃើញថា កម្មវត្ថុនៃវិវាទនោះ ពុំអាចដោះស្រាយតាមរយៈការធ្វើមជ្ឈត្តការឡើយ បើយោងទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ មជ្ឈត្តវិនិច្ឆ័យនោះផ្ទុយនឹងនយោបាយសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា។[116]

### ៣.១.៤. អាជ្ញាយុកាលនៃការដាក់ពាក្យសុំបដិសេធ

អាជ្ញាយុកាលនៃការដាក់ពាក្យសុំបដិសេធ គឺជាគម្លាតនៃអំឡុងពេលមួយដែលច្បាប់បានកំណត់ ដែលជាអំឡុងពេលមួយដែលច្បាប់ទុកពេលឱ្យភាគីវិវាទត្រៀមខ្លួនចំពោះការប្តឹងជំទាស់ ឬប្តឹងបដិសេធបាន។ ក្នុងរយៈនៃអំឡុងពេលនេះគូភាគីវិវាទត្រូវត្រៀមលក្ខណៈមួយចំនួនដូចជា ឯកសារ ភស្តុតាង កិច្ចព្រមព្រៀងគូភាគី និងកិច្ចព្រមព្រៀងផ្សះផ្សានៃគូភាគី ឱ្យបានល្អដើម្បីមានភាពងាយស្រួលនៅក្នុងដំណើរការនៃនីតិវិធីមិនយឺតយ៉ាវ។

ចំពោះការបដិសេធទៅកាន់សាលាឧទ្ធរណ៍ គឺមានរយៈពេល៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីភាគីដែលបានទទួលមជ្ឈត្តវិនិច្ឆ័យ ឬមួយក៏ ៣០ ថ្ងៃបន្ទាប់ពីភាគីវិវាទបានដាក់ពាក្យស្នើឱ្យសុំមានការកែប្រែមជ្ឈត្តវិច្ឆ័យ ឬស្នើសុំបំពេញបន្ថែមនូវចំណុចណាមួយនៃមជ្ឈត្តវិនិច្ឆ័យនោះ ដែលបានទទួលនូវមជ្ឈត្តវិនិច្ឆ័យដែលបានកែតម្រូវ ឬមជ្ឈត្តវិនិច្ឆ័យបន្ថែមរួចហើយ។

សម្រាប់បណ្តឹងសាទុក្ខពីសាលាឧទ្ធរណ៍ទៅតុលាការកំពូលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវតែធ្វើឡើងក្នុងរយៈពេល១៥ថ្ងៃ ក្រោយពេលសាលាឧទ្ធរណ៍ចេញសាលដីការួច។ នៅក្នុងកាលៈទេសៈសមស្របណាមួយ តុលាការកម្ពុជាអាចផ្អាកដំណើរការកាត់ក្តីនៅក្នុងតុលាការសិន ដើម្បីអនុញ្ញាតឱ្យវេទិកាមជ្ឈត្តកម្មបន្តដំណើរការកាត់ក្តី ឬចាត់វិធានការលុបបំបាត់មូលហេតុនៃការលុបចោលមជ្ឈត្តវិនិច្ឆ័យនោះ ដើម្បីឱ្យវេទិកាមជ្ឈត្តកម្មអាចបញ្ចប់ដំណើរការមជ្ឈត្តការនោះស្របតាមច្បាប់។[117]

### ៣.១.៥ ការកែតម្រូវ ការបំភ្លឺលម្អិត ការបកស្រាយមជ្ឈត្តវិនិច្ឆ័យ និងមជ្ឈត្តវិនិច្ឆ័យបន្ថែម

បន្ទាប់ពីវេទិកាមជ្ឈត្តកម្មចេញនូវមជ្ឈត្តវិនិច្ឆ័យរួចមក ច្បាប់ក៏ផ្តល់ឱ្យមានការកែតម្រូវចំពោះមជ្ឈត្តវិនិច្ឆ័យផងដែរ បន្ទាប់ពីមជ្ឈត្តវិនិច្ឆ័យបានចេញជាស្ថាពររួចហើយ។ ជាការពិតណាស់បើទោះបីជាមជ្ឈត្តវិនិច្ឆ័យបានឆ្លងកាត់ការត្រួតពិនិត្យជាច្រើនដងរួចហើយដោយមជ្ឈត្តករផង ដោយភាគីទាំងសងខាងផង រួមទាំងធ្វើសេចក្តីព្រាងទៅមជ្ឈត្តវិនិច្ឆ័យទៅអគ្គលេខាធិការ ដើម្បីត្រួតពិនិត្យពិច័យ ព្រោះតែជាការសម្រេចរួមតែងតែមានចំណុច

[116] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, លេខ នស/រកម/០៥០៦/០១០, ០៥ ឧសភា ២០០៦, មាត្រា៤៤

[117] មេធាវី ស៊ីវិន អ៊ែន អស្ទើរមីឡឺរ៍, ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅកម្ពុជា, បោះពុម្ពឆ្នាំ២០១០, ទំព័រ១៨០

ចន្លោះប្រហោងខ្វះខាតនៅត្រង់ចំណុចណាមួយជាមិនខាន ដែលតម្រូវឱ្យភាគីធ្វើការស្នើសុំការកែតម្រូវនូវចំណុចដែលហៅថា កំហុសដោយអចេតនា ដើម្បីកុំឱ្យមានការខូចខាតដល់ផលប្រយោជន៍របស់ភាគី។ ភាគីនៃការដាក់ពាក្យស្នើសុំការកែតម្រូវ ការបំភ្លឺលម្អិត ការបកស្រាយមជ្ឈត្តវិនិច្ឆ័យ និងមជ្ឈត្តវិនិច្ឆ័យបន្ថែម ត្រូវជូនដំណឹងទៅភាគីម្ខាងទៀតនៃវិវាទ អគ្គលេខាធិការដ្ឋាន និងវេទិកាមជ្ឈត្តកម្មអំពីការស្នើសុំឱ្យវេទិកាមជ្ឈត្តកម្ម ធ្វើការកែតម្រូវនូវកំហុសដែលមានក្នុងមជ្ឈត្តវិនិច្ឆ័យនោះ លើកលែងតែមានការព្រមព្រៀងពីការពន្យាអំឡុងពេលបន្ថែមផ្សេងពីនេះទៀតដោយភាគីវិវាទ។[118] ជាការពិតណាស់ មុនពេលដែលចេញនូវមជ្ឈត្តវិនិច្ឆ័យសម្រាប់ការកែតម្រូវ ការបំភ្លឺលម្អិត ការបកស្រាយមជ្ឈត្តវិនិច្ឆ័យ និងមជ្ឈត្តវិនិច្ឆ័យបន្ថែម វេទិកាមជ្ឈត្តកម្មត្រូវធ្វើការបញ្ជូនសេចក្តីព្រាងមជ្ឈត្តវិនិច្ឆ័យនោះទៅអគ្គលេខាធិការដ្ឋានសម្រាប់ការពិនិត្យពិច័យលើទម្រង់។ ក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃនៃការទទួលបានសេចក្តីព្រាងមជ្ឈត្តវិនិច្ឆ័យសម្រាប់ការកែតម្រូវ ការបំភ្លឺលម្អិត ការបកស្រាយ ឬក៏សេចក្តីព្រាងនូវមជ្ឈត្តវិនិច្ឆ័យបន្ថែម អគ្គលេខាធិការដ្ឋានអាចស្នើសុំការកែប្រែលើទម្រង់របស់មជ្ឈត្តវិនិច្ឆ័យ និងដោយមិនប៉ះពាល់ដល់សេរីភាពក្នុងការសម្រេចរបស់វេទិកាមជ្ឈត្តកម្ម អាចស្នើឱ្យវេទិកាមជ្ឈត្តកម្មយកចិត្តទុកដាក់លើចំណុចសារធាតុនានានៃមជ្ឈត្តវិនិច្ឆ័យ។[119]

សំណើសុំការកែតម្រូវ ការបំភ្លឺលម្អិត ការបកស្រាយ ឬមជ្ឈត្តវិនិច្ឆ័យបន្ថែម ដែលមានការពន្យារអំឡុងពេលបន្ថែមផ្សេងពីនេះតាមការព្រមព្រៀងរបស់ភាគីវិវាទ មុនពេលបិទនូវដំណើរការមជ្ឈត្តការត្រូវមានសេចក្តីជូនដំណឹងទៅភាគីម្ខាងទៀត ក៏ដូចជាទៅកាន់អគ្គលេខាធិការដ្ឋាន និងវេទិកាមជ្ឈត្តកម្ម ភាគីវិវាទណាមួយអាចស្នើសុំវេទិកាមជ្ឈត្តកម្មឱ្យកែតម្រូវកំហុសក្នុងការគណនា ផ្នែកការងារ លេខាធិការ ឬកំហុសក្នុងការបោះពុម្ព ឬកំហុសផ្សេងៗទៀត ដែលមានលក្ខណៈស្រដៀងនោះដែលមានក្នុងមជ្ឈត្តវិនិច្ឆ័យ។ កំហុសដែលកើតមានឡើងទាំងអស់នេះ ជាមូលហេតុនាំឱ្យភាគីណាម្ខាងសម្រេចចិត្តធ្វើការដាក់ពាក្យស្នើសុំមកកាន់វេទិកាមជ្ឈត្តកម្មដើម្បីធ្វើការកែតម្រូវមជ្ឈត្តវិនិច្ឆ័យនោះ។ ក្រៅពីនេះទៅទៀត ភាគីដាក់ពាក្យស្នើសុំក៏អាចធ្វើការស្នើសុំឱ្យវេទិកាមជ្ឈត្តកម្មធ្វើការបកស្រាយបញ្ជាក់បន្ថែម បំភ្លឺលម្អិតពីចំណុច ឬផ្នែកណាមួយនៃមជ្ឈត្តវិនិច្ឆ័យបន្ថែមផងដែរ នេះប្រសិនបើមានការព្រមព្រៀងគ្នារវាងភាគីម្ខាងទៀត។ ការពន្យារអំឡុងពេលបន្ថែមផ្សេងតាមការព្រមព្រៀងរវាងគូរភាគីមុនពេលបិទដំណើរការមជ្ឈត្តការ និងមានសេចក្តីជូនដំណឹងទៅភាគីម្ខាងទៀត ទៅកាន់អគ្គលេខាធិការដ្ឋាន និងវេទិកាមជ្ឈត្តកម្ម ភាគីវិវាទណាមួយអាចស្នើសុំវេទិកាមជ្ឈត្តកម្មឱ្យបកស្រាយ ឬបំភ្លឺលម្អិត លើចំណុចជាក់លាក់ណាមួយ ឬផ្នែកណាមួយនៃមជ្ឈត្តវិនិច្ឆ័យអំឡុងពេល៣០ (សាមសិប) ថ្ងៃបន្ទាប់ពីទទួលបានមជ្ឈត្តវិនិច្ឆ័យ។

[118] វិធានស្តីពីមជ្ឈត្តការ, ២៨ មីនា ២០២១, ប្រការ៣៨.១

[119] វិធានស្តីពីមជ្ឈត្តការ, ២៨ មីនា ២០២១, ប្រការ៥០.២

ការពន្យារពេលបន្ថែមផ្សេងតាមការព្រមព្រៀងរវាងគូភាគីវិវាទ មុនពេលបិទដំណើរការមជ្ឈត្តការក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃបន្ទាប់ពីទទួលបានមជ្ឈត្តវិនិច្ឆ័យ ភាគីវិវាទដែលបានជូនដំណឹងទៅភាគីវិវាទម្ខាងទៀតអាចស្នើសុំវេទិកាមជ្ឈត្តកម្មឱ្យចេញនូវមជ្ឈត្តវិនិច្ឆ័យបន្ថែមទៀត លើចំណុចដែលត្រូវបានបង្ហាញក្នុងដំណើរការមជ្ឈត្តការ ប៉ុន្តែមិនបានដាក់បញ្ចូលទៅក្នុងមជ្ឈត្តវិនិច្ឆ័យដែលបានទទួល។

ភាគីវិវាទម្ខាងទៀតអាចផ្តល់មតិរបស់ខ្លួនពាក់ព័ន្ធនឹងសំណើនេះ ក្នុងអំឡុងពេលសមរម្យណាមួយដែលកំណត់ដោយវេទិកាមជ្ឈត្តកម្ម។ សេចក្តីសម្រេចលើការកែតម្រូវ ការបំភ្លឺលម្អិត ការបកស្រាយ និងមជ្ឈត្តវិនិច្ឆ័យបន្ថែមនោះ គឺវាអាស្រ័យលើវេទិកាមជ្ឈត្តកម្ម ប្រសិនបើវេទិកាមជ្ឈត្តកម្ម យល់ឃើញថាសំណើណាមួយសមរម្យ វេទិកាមជ្ឈត្តកម្មត្រូវកែតម្រូវធ្វើការបំភ្លឺលម្អិត ឬផ្តល់ការបកស្រាយជាលាយលក្ខណ៍អក្សរ ឬចេញមជ្ឈត្តវិនិច្ឆ័យបន្ថែមក្នុងអំឡុងពេល៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីទទួលបានសំណើនោះ។ វេទិកាមជ្ឈត្តកម្មអាចពន្យារអំឡុងពេលដែលវេទិកាមជ្ឈត្តកម្មត្រូវតែកែតម្រូវធ្វើការបំភ្លឺលម្អិត ផ្តល់ការបកស្រាយជាលាយលក្ខណ៍អក្សរ ឬក៏ចេញនូវមជ្ឈត្តវិនិច្ឆ័យបន្ថែមបានតាមការចាំបាច់ និងដោយមានការជូនដំណឹងទៅគូភាគីវិវាទ។[120]

## ៣.២. អានុភាពនៃមជ្ឈត្តវិនិច្ឆ័យ

ទីនេះគឺសំដៅដល់ការចេញមជ្ឈត្តវិនិច្ឆ័យរួចហើយ ភាគីឈ្នះក្តីត្រូវតែដាក់ឱ្យអនុវត្តនូវមជ្ឈត្តវិនិច្ឆ័យនេះ ប្រសិនបើភាគីចាញ់ក្តី ខកខានមិនបានគោរពតាមមជ្ឈត្តវិនិច្ឆ័យនេះទេ។ វេទិកាមជ្ឈត្តកម្មគ្មានអំណាចក្នុងការអនុវត្តដោយខ្លួនឯងទេ ពោលគឺពុំមាននគរបាលផ្នែកមជ្ឈត្តការឡើយ។ អាស្រ័យហេតុនេះ ភាគីវិវាទត្រូវផ្អែកលើប្រព័ន្ធតុលាការដើម្បីអនុវត្តមជ្ឈត្តវិនិច្ឆ័យនោះ។ យោងតាមច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម មជ្ឈត្តវិនិច្ឆ័យនៅពេលដែលបានចូលជាធរមានរួច គឺមានអនុភាពដូចគ្នានឹងសាលក្រមតុលាការដែរក្នុងការដាក់ឱ្យអនុវត្ត។[121] ដើម្បីឱ្យកាន់តែច្បាស់អំពីផ្នែកនេះ ដូច្នេះខាងក្រោមនឹងបង្ហាញអំពី ៣.២.១. ការទទួលស្គាល់មជ្ឈត្តវិនិច្ឆ័យ និង ៣.២.២. ការអនុវត្តចំពោះមជ្ឈត្តវិនិច្ឆ័យ និងដាក់ឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យអន្តរជាតិ។

### ៣.២.១. ការទទួលស្គាល់មជ្ឈត្តវិនិច្ឆ័យ

នៅក្នុងករណីដែលភាគីពុំមានការប្តឹងឧបាស្រ័យទៅនឹងសេចក្តីសម្រេចមជ្ឈត្តវិនិច្ឆ័យទេ ហើយមានការទទួលស្គាល់ទៅលើមជ្ឈត្តវិនិច្ឆ័យរួចហើយ នោះមជ្ឈត្តវិនិច្ឆ័យនឹងមានអានុភាព។ តាមច្បាប់ប្រទេសភាគច្រើន និងច្បាប់អន្តរជាតិព្រមទាំងកម្ពុជាផង សេចក្តីសម្រេចមជ្ឈត្តវិនិច្ឆ័យ គឺជាសេចក្តីសម្រេចចុងក្រោយ នឹងមានអានុភាពចាប់បង្ខំ ផ្ទុយទៅវិញនោះនៅក្នុងករណីភាគីចាញ់ក្តីពុំបានអនុវត្តទៅតាមសេចក្តីសម្រេចមជ្ឈត្តវិនិច្ឆ័យទេនោះ អានុភាពនៃសេចក្តីសម្រេចមជ្ឈត្តវិនិច្ឆ័យ ក៏ពុំមានអានុភាពទៅភាគីនោះដែរ ពោលគឺមជ្ឈត្តិវិនិច្ឆ័យកន្លែង

[120] វិធានស្តីពីមជ្ឈត្តការ, ២៨ មីនា ២០២១, ប្រការ៥៣

[121] មេធាវី ស៊្ទីវិន អ៊ែន អស្ទើរមីឡឺ, ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅកម្ពុជា, បោះពុម្ពឆ្នាំ២០១០, ទំព័រ១៨០

នេះនៅមិនទាន់អានុភាពចាប់បង្ខំដល់ភាគីរូបនោះទេ ប៉ុន្តែក្នុងករណីនេះភាគីឈ្នះក្តីអាចយកសេចក្តីសម្រេចនោះទៅសុំការអនុវត្តតាមប្រព័ន្ធតុលាការបាន។

ពាក់ព័ន្ធនឹងបញ្ហានីតិវិធី ភាគីដែលស្វែងរកការទទួលស្គាល់ និងដាក់ឱ្យអនុវត្ត ត្រូវផ្តល់ដល់តុលាការនូវសំណៅដើម ឬសំណៅចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវនៃមជ្ឈត្តវិនិច្ឆ័យ និងកិច្ចព្រមព្រៀងមជ្ឈត្តការ ព្រមទាំងសំណៅបកប្រែជាភាសាខ្មែរដែលមានការបញ្ជាក់ត្រឹមត្រូវ ក្នុងករណីដែលសំណៅដើមមិនមែនសរសេរជាភាសាខ្មែរ។ ហើយក្រោយពេលដាក់ជូនត្រឹមត្រូវរួច តុលាការត្រូវទទួល និងអនុវត្តមជ្ឈត្តវិនិច្ឆ័យដែលប្រៀបដូចជាមជ្ឈត្តវិនិច្ឆ័យនោះគឺជាសាលក្រមស្ថាពរ និងអាចអនុវត្តបានដូច្នោះដែរ។[122]

ដោយឡែកមជ្ឈត្តវិនិច្ឆ័យបរទេសក៏ត្រូវបានទទួលស្គាល់ដូចគ្នាដែរ ទោះបីជាមជ្ឈត្តវិនិច្ឆ័យនោះជារបស់ប្រទេសណាក៏ដោយ ក៏ត្រូវបានគេទទួលស្គាល់និងមានការជាប់នូវកាតព្វកិច្ចដែលភាគីត្រូវតែអនុវត្តបាន។ ជាមួយគ្នានេះ នៅក្នុងករណីដែលភាគីមានការចង់ប្តឹងជំទាស់ទៅនឹងមជ្ឈត្តវិនិច្ឆ័យបរទេសនោះភាគីអាចធ្វើការប្តឹងជំទាស់ទៅបានដោយធ្វើការដាក់ស្នើសុំមកាន់សាលាឧទ្ធរណ៍ ជាលាយលក្ខ័អក្សរ ហើយការដាក់ពាក្យស្នើសុំនេះផងដែរ ហើយត្រូវស្របទៅនឹងលក្ខខណ្ឌ ដែលមានចែងនៅក្នុងមាត្រា៤៤នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។ បន្ថែមពីនេះទៅទៀតភាគីចង់ដាក់បញ្ចូលនូវមជ្ឈត្តវិនិច្ឆ័យបរទេស ចូលមកដើម្បីអនុវត្ត ភាគីត្រូវធ្វើការដាក់ពាក្យសុំដោយភ្ជាប់មកជាមួយនឹងមជ្ឈត្តវិនិច្ឆ័យច្បាប់ដើមមួយ រួមជាមួយនឹងច្បាប់ដើមនៃកិច្ចសន្យាព្រមព្រៀងផ្សះផ្សារបស់គូភាគីវិវាទផងដែរ។ នៅពេលដំណើរការមជ្ឈត្តការត្រូវបានបញ្ចប់ ដោយវេទិការមជ្ឈត្តកម្មនោះមជ្ឈត្តករនិងធ្វើការចេញនូវសេចក្តីសម្រេចមួយ ឬមជ្ឈត្តវិនិច្ឆ័យចំពោះរឿងវិវាទតាមរយៈការពិនិត្យពិចារណាលើអង្គហេតុ រួមជាមួយនឹង ការប្រជុំ ការដាក់សេចក្តីថ្លែងការណ៍ដោយគូភាគីវិវាទ ការពិនិត្យមើលលើសាក្សី និងភស្តុតាងនានាដែលភាគីបានដាក់ជូន ទើបមជ្ឈត្តករធ្វើការសម្រេចដើម្បីទទួលស្គាល់។

### ៣.២.២. ការអនុវត្តចំពោះមជ្ឈត្តវិនិច្ឆ័យ

មជ្ឈត្តវិនិច្ឆ័យនឹងក្លាយជាមជ្ឈត្តវិនិច្ឆ័យស្ថាពរ និងមានអនុភាពអនុវត្តចំពោះគូភាគីវិវាទ គិតចាប់ពីកាលបរិច្ឆេទដែលមជ្ឈត្តវិនិច្ឆ័យនោះត្រូវបានចេញ និងបោះត្រា។ គូភាគីវិវាទទទួលស្គាល់ថា ខ្លួនមិនមានសិទ្ធិក្នុងការប្តឹងជំទាស់ផ្សេងក្រៅពីស្របតាមបញ្ញត្តិច្បាប់ដែលមានអានុភាពចាប់បង្ខំ ហើយដោយមិនអាចដកហូតវិញបាន គូភាគីវិវាទធ្វើការបោះបង់សិទ្ធិក្នុងការប្តឹងជំទាស់របស់ខ្លួន ដរាបណាសិទ្ធិក្នុងការប្តឹងជំទាស់នោះអាចបោះបង់បានដោយមានសុពលភាព។[123] ដោយយោងទៅតាមមាត្រា៤២ នៃច្បាប់ស្តីមជ្ឈត្តការផ្នែកពាណិជ្ជកម្មបានចែងថា សេចក្តីសម្រេចលើការធ្វើបណ្តឹងទាស់ ការទទួលស្គាល់ និងការដាក់ឱ្យអនុវត្តនូវមជ្ឈត្តវិនិច្ឆ័យជា

[122] មេធាវី ស្ទីវិន អ៊ែន អស្ទើរមីឡឺរ៍, ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅកម្ពុជា, បោះពុម្ពឆ្នាំ២០១០, ទំព័រ១៨១

[123] វិធានស្តីពីមជ្ឈត្តការ, ២៨ មីនា ២០២១, ប្រការ៥២

សមត្ថកិច្ចរបស់សាលាឧទ្ធរណ៍នៃព្រះរាជាណាចក្រកម្ពុជា។ ស្របទៅតាមខ្លឹមសារនៃមាត្រានេះ បានបញ្ជាក់ច្បាស់ថា ការអនុវត្តមជ្ឈត្តវិនិច្ឆ័យគឺជាសមត្ថកិច្ចរបស់សាលាឧទ្ធរណ៍។ ជាការពិតណាស់ នេះជាលក្ខណៈពិសេសនៃមជ្ឈត្តវិនិច្ឆ័យ។ មជ្ឈត្តវិនិច្ឆ័យទោះជាបានធ្វើនៅប្រទេសណាក៏ដោយត្រូវបានគេទទួលស្គាល់ថាជាកាតព្វកិច្ច បន្ទាប់ពីត្រូវបានដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរទៅសាលាឧទ្ធរណ៍រួចមក ត្រូវបានអនុវត្តដោយយោងតាមបទប្បញ្ញត្តិក្នុងមាត្រា៤៤ និងមាត្រា៤៥ ។[124]

ភាគីដែលសំអាងលើមជ្ឈត្តវិនិច្ឆ័យ ឬដែលដាក់ពាក្យសុំឱ្យមានការអនុវត្តមជ្ឈត្តវិនិច្ឆ័យ ត្រូវផ្តល់ច្បាប់ដើមត្រឹមត្រូវពិតប្រាកដនៃមជ្ឈត្តវិនិច្ឆ័យ និងច្បាប់ដើមនៃកិច្ចព្រមព្រៀងផ្សះផ្សាដូចចែងក្នុងមាត្រា៧នៃច្បាប់នេះ ឬអត្ថបទថតចម្លងដែលបញ្ជាក់ថាបានចម្លងត្រឹមត្រូវតាមច្បាប់ដើម។ ប្រសិនបើមជ្ឈត្តវិនិច្ឆ័យ ឬកិច្ចព្រមព្រៀងនោះមិនបានធ្វើជាភាសាខ្មែរទេ ភាគីនោះត្រូវផ្តល់សេចក្តីបកប្រែជាភាសាខ្មែរ ដែលមានការបញ្ជាក់ត្រឹមត្រូវតាមច្បាប់ដើម។ ក្នុងចំណោមទីកន្លែងខាងក្រោម ស្ថិតនៅក្រៅប្រទេសធ្វើពាណិជ្ជកម្មរបស់ភាគីវិវាទ៖

- ទីកន្លែងធ្វើមជ្ឈត្តការ ប្រសិនបើបានកំណត់ ឬយោងក្នុងកិច្ចព្រមព្រៀងផ្សះផ្សា ទីកន្លែងដែលកាតព្វកិច្ចសំខាន់នៃទំនាក់ទំនងពាណិជ្ជកម្មបានប្រព្រឹត្តទៅ ឬទីកន្លែងដែលជិតជាងគេពាក់ព័ន្ធនឹងវិវាទ ឬភាគីវិវាទបានព្រមព្រៀងដាក់លាក់ថា រឿងនៃកិច្ចព្រមព្រៀងផ្សះផ្សាទាក់ទងនឹងប្រទេសលើសពីមួយ។
- ប្រសិនបើភាគីមួយមានទីកន្លែងប្រកបពាណិជ្ជកម្មលើសពីមួយ ទីកន្លែងដែលដែលមានទាក់ទងជិតស្និទ្ធជាងគេបំផុតនឹងកិច្ចព្រមព្រៀងផ្សះផ្សា គឺជាទីកន្លែងពាណិជ្ជកម្ម។ ប្រសិនបើភាគីមួយមិនមានទីកន្លែងប្រកបពាណិជ្ជកម្មទេ ការយោងក្នុងច្បាប់នេះគឺទីលំនៅអចិន្ត្រៃយ៍របស់ភាគីនោះ ។

ពាក់ព័ន្ធនឹងមជ្ឈត្តការអន្តរជាតិ ការអនុម័តច្បាប់ស្តីពីមជ្ឈការផ្នែកពាណិជ្ជកម្ម បានធ្វើឱ្យប្រទេសកម្ពុជាបំពេញតាមលក្ខខណ្ឌតម្រូវនៃអនុសញ្ញាក្រុងញូវយ៉ក ដែលស្តីពីការទទួលស្គាល់មជ្ឈត្តវិនិច្ឆ័យបរទេសឆ្នាំ១៩៥៨ អនុសញ្ញាក្រុងញូវយ៉កបានទាំងស្រុង។ អនុសញ្ញាក្រុងញូវយ៉ក បានផ្តល់នូវក្របខណ្ឌអន្តរជាតិដ៏ចម្បងសម្រាប់ការទទួលស្គាល់ការអនុវត្តមជ្ឈត្តវិនិច្ឆ័យបរទេស និងមជ្ឈត្តវិនិច្ឆ័យដែលមានលក្ខណៈអន្តរជាតិ។

ដូច្នេះច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មមិនត្រឹមតែចែងអំពីការអនុវត្តមជ្ឈត្តវិនិច្ឆ័យកម្ពុជាប៉ុណ្ណោះទេ ថែមទាំងចែងអំពីការអនុវត្តមជ្ឈត្តវិនិច្ឆ័យអន្តរជាតិផងដែរ។ ឧទាហរណ៍ វិវាទរវាងក្រុមហ៊ុនកូរ៉េ និងក្រុមហ៊ុនថៃត្រូវបានធ្វើមជ្ឈត្តការក្នុងក្រុងហុងកុង និងអាចអនុវត្តប្រឆាំងនឹងភាគីនីមួយៗនៅក្នុងប្រទេសកម្ពុជា ហើយប្រសិនបើ ភាគីនីមួយៗមានទ្រព្យសម្បត្តិនៅទីនេះ។ អនុសញ្ញានេះ និងរបបអនុវត្តន៍ជាអន្តរជាតិ គឺជាមូលហេតុមួយក្នុងចំណោមមូលហេតុមួយដែលក្រុមហ៊ុនអន្តរជាតិចូលចិត្តប្រើប្រាស់មជ្ឈត្តការជាង។ ក្នុងករណីមានវិវាទ

[124] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, លេខ នស/រកម/០៥០៦/០១០, ០៥ ឧសភា ២០០៦, មាត្រា៤៥

នឹងមានការធានាថាមជ្ឈត្តវិនិច្ឆ័យនឹងអាចអនុវត្តបានស្ទើរតែនៅគ្រប់ទីកន្លែងទូទាំងសកលលោក។ ដោយសារប្រទេសកម្ពុជាគឺជាផ្នែកមួយនៃប្រព័ន្ធអនុវត្តន៍នេះ ក្រុមហ៊ុនអន្តរជាតិកាន់តែមានបំណងចង់ធ្វើការវិនិយោគនៅក្នុងប្រទេសកម្ពុជាថែមទៀត។[125]

## ៣.៣. លទ្ធផលសម្រេចបានក្នុងការដោះស្រាយវិវាទពាណិជ្ជកម្មតាមយន្តការមជ្ឈត្តការ

ដោយយោងតាមស្ថិតិនៃការដោះស្រាយកន្លងមក យើងឃើញថាមានសំណុំរឿងមជ្ឈត្តការចំនួន ២៥ បានដាក់មក ម.ជ.ម. ដែលមានតម្លៃកម្មវត្ថុនៃវិវាទសរុបលើស ៧២ លានដុល្លារអាមេរិក ដោយរាប់គិតចាប់ពីឆ្នាំ ២០១៥ ដល់ខែកញ្ញា ឆ្នាំ២០២១។ មិនមែនគ្រប់សំណុំរឿងមជ្ឈត្តការដែលបានដាក់មក ម.ជ.ម. ត្រូវបានចាត់ចែងដោយ ម.ជ.ម. នោះទេ។ ក្នុងនោះមាន ០៨% មិនមានសមត្ថកិច្ច ៤% ត្រូវបានដកចេញដោយភាគីវិវាទ ២៨% ត្រូវបានចេញមជ្ឈត្តវិនិច្ឆ័យរួចរាល់ និង៦០% នៅកំពុងដំណើរការ។ ប្រភេទនៃវិវាទដែលបានដាក់មកកាន់ ម.ជ.ម. មានដូចជាជំនួញអន្តរជាតិ ០៨% សេវាធនាគារ និងហិរញ្ញវត្ថុ ២៨% សាជីវកម្ម ០៨% អចលនទ្រព្យ ៤៤% និងសំណង់ ១២%។ ក្នុងនោះដែរមានភាគីវិវាទសរុបចំនួន ៥៥ ភាគី មកពី ០៦ ដែនសមត្ថកិច្ច ដែល ៤២% ជារូបវន្តបុគ្គល ៥៦% ជានីតិបុគ្គល និង ០២% ជាស្ថាប័នរដ្ឋ។ មជ្ឈត្តការពាណិជ្ជកម្មបានក្លាយជាជម្រើសដ៏សមស្របមួយដែលគូវិវាទមានបំណងក្នុងការដោះស្រាយវិវាទរបស់ខ្លួនក្រៅប្រព័ន្ធតុលាការ ហើយយន្តការនេះនឹងកើនឡើងខ្លាំងនាពេលអនាគត។ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មបានទទួលចាត់ចែងធ្វើមជ្ឈត្តការលើសំណុំរឿងក្រោមវិធានស្តីពីមជ្ឈត្តការឆ្នាំ២០១៤ ចំនួន២៥ សំណុំរឿង ដោយបានរួមបញ្ចូលទាំងសំណុំរឿងអន្តរជាតិមានតម្លៃកម្មវត្ថុនៃវិវាទសរុបលើសពី៧២លានដុល្លារអាមេរិក។[126]

ថ្មីៗនេះ យើងឃើញថាកាលពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២ ម.ជ.ម. បានជូនដំណឹងអំពីមជ្ឈត្តករបន្ទាន់បានចេញមជ្ឈត្តវិនិច្ឆ័យលើវិធានបណ្តោះអាសន្នជាលើកដំបូងបន្ទាប់ពីវិធាននេះចូលជាធរមាន។ នៅក្នុងថ្ងៃទី ១៤ ខែមករា ឆ្នាំ២០២២ ម.ជ.ម. បានទទួលសេចក្តីជូនដំណឹងស្តីពីមជ្ឈត្តកម្ម ភ្ជាប់ជាមួយនឹងសំណើសុំវិធានបណ្តោះអាសន្នចេញដោយមជ្ឈត្តករបន្ទាន់ក្រោមវិធាន ម.ជ.ម. ។[127] សំណុំរឿងនៃសំណើនេះពាក់ព័ន្ធនឹងវិវាទក្នុងវិស័យអចលវត្ថុរវាងភាគីជាជនជាតិបរទេស និងជនជាតិខ្មែរ ដែលមជ្ឈត្តវិនិច្ឆ័យលើវិធានការបណ្តោះអាសន្ននេះត្រូវបានចេញដោយមជ្ឈត្តករបន្ទាន់ក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ។

[125] មេធាវី ស៊ឹវិន អ៊ែន អស្ទើរមីឡឺរ៍, ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅកម្ពុជា, បោះពុម្ពឆ្នាំ២០១០, ទំព័រ១៨៣

[126] ដកស្រង់ចេញពីគេហទំព័រ https://ncac.org.kh/statistics/, ចូលមើលថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២

[127] សេចក្តីប្រកាសព័ត៌មានស្តីពី សំណុំរឿងមជ្ឈត្តករបន្ទាន់ដំបូងត្រូវបានប្រព្រឹត្តទៅដោយជោគជ័យ, ថ្ងៃទី០១ កុម្ភៈ ២០២២

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឆ្លងកាត់រយៈពេលនៃសិក្សាស្រាវជ្រាវចំពោះប្រធានបទនេះ ឃើញថាការស្រាយវិវាទពាណិជ្ជកម្មអាចធ្វើឡើងតាមលក្ខណៈទម្រង់ផ្សេងៗ មានដូចជាដោះស្រាយវិវាទពាណិជ្ជកម្មតាមប្រព័ន្ធតុលាការដែលជាបែបបទនីតិវិធីមួយ និងការដោះស្រាយវិវាទពាណិជ្ជកម្មតាមក្រៅប្រព័ន្ធតុលាការមានជាច្រើនទម្រង់ដូចជាការផ្សះផ្សា ការចរចា សន្ធានកម្ម និងមជ្ឈត្តការ។ ជាក់ស្តែង ការដោះស្រាយវិវាទពាណិជ្ជកម្មតាមរយៈយន្តការមជ្ឈត្តការ គឺជាយន្តការទំនើបថ្មីមួយ ដែលទើបបានបង្កើតឡើងដើម្បីដោះស្រាយវិវាទទាក់ទងនឹងពាណិជ្ជកម្ម ដោយមានភាពរហ័ស អព្យាក្រឹត ច្បាស់លាស់ និងជាការសម្ងាត់។

ម្យ៉ាងវិញទៀត ការបង្កើតនូវមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលជាស្ថាប័នឯករាជ្យមួយស្ថិតនៅក្រោមការឧបត្ថម្ភរបស់ក្រសួងពាណិជ្ជកម្ម ក្នុងគោលបំណងដើម្បីជំរុញឱ្យមានការដោះស្រាយវិវាទពាណិជ្ជកម្មតាមរយៈការផ្សះផ្សា និងបង្កើតនូវរចនាសម្ព័ន្ធព្រមទាំងវិធានការចាំបាច់សម្រាប់ធ្វើការគ្រប់គ្រងរឿងមជ្ឈត្តការក្នុងព្រះរាជាណាចក្រកម្ពុជា នៅពេលដែលមានការព្រមព្រៀងគ្នាយ៉ាងជាក់ច្បាស់ណាមួយនៃភាគីវិវាទដាក់វិវាទទៅមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មត្រូវបានបែកចែងជារចនាសម្ព័ន្ធមួយចំនួនដូចជាមហាសន្និបាត ក្រុមប្រឹក្សាប្រតិបត្តិ អគ្គលេខាធិការដ្ឋាន សមាជិកភាព សវនកម្ម និងសាខាជាដើម ដែលជាផ្នែកយ៉ាងសំខាន់មួយនៅក្នុង ម.ជ.ម.។

ចំណែកនៅក្នុងដំណើរការមជ្ឈត្តការផ្នែកពាណិជ្ជកម្មវិញ យើងឃើញថាមុននឹងធ្វើការចាប់ផ្តើមនីតិវិធីនៃការដោះស្រាយវិវាទ ត្រូវមានការធ្វើសន្និសីទអំពីការគ្រប់គ្រងចាត់ចែងសំណុំរឿងដោយតម្រូវមានការជួបប្រជុំរវាងវេទិកាមជ្ឈត្តកម្មនិងភាគីវិវាទដើម្បីពិភាក្សាអំពីនីតិវិធីនានា និងការចំណាយតិចក្នុងការដោះស្រាយ។ បន្ទាប់ពីមានការធ្វើនូវសន្និសីទគ្រប់គ្រងចាត់ចែងសំណុំរឿងរួចរាល់ហើយ ជំហានបន្ទាប់គឺការជូនដំណឹងអំពីមជ្ឈត្តកម្មដែលត្រូវបានចាត់ទុកថាជាការចាប់ផ្តើមកាលបរិច្ឆេទនៃការដាក់សំណុំឯកសារ និងជូនដំណឹងអំពីមជ្ឈត្តកម្មពេញលេញដោយភាគីប្តឹងទាមទារ ម្យ៉ាងទៀតដើម្បីទាញយកព័ត៌មានពេញលេញគ្រប់គ្រាន់ដើម្បីអាចឱ្យភាគីឆ្លើយតប ធ្វើការឆ្លើយតបទៅនឹងការទាមទាររបស់ភាគីបណ្តឹងទាមទារតាមគ្រប់ចំណុចដែលចង់បាន។ បន្ទាប់ពីទទួលបានសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្មមក ភាគីឆ្លើយតបត្រូវដាក់បញ្ជូនសេចក្តីជូនដំណឹងអំពីការឆ្លើយតបទៅកាន់អគ្គលេខាធិការដ្ឋាន។ ចំណុចបន្ទាប់ ក៏មានការពិនិត្យទៅលើកិច្ចព្រមព្រៀងរបស់មជ្ឈត្តកម្ម ដែលជាចំណុចមុននឹងឈានចូលដល់ការបើកនូវវេទិកាមជ្ឈត្តកម្ម ដែលកិច្ចព្រមព្រៀងនេះកើតឡើងតាមរយៈខចែងនៅក្នុងកិច្ចសន្យា ដោយបានសន្យាថានៅដែលពេលមានវិវាទកើតឡើង នឹងត្រូវយកវិវាទនោះមកធ្វើការដោះស្រាយតាមរយៈយន្តការមជ្ឈត្តការពាណិជ្ជកម្មហើយវាត្រូវបានធ្វើឡើងជាលាយលក្ខណ៍អក្សរ ព្រមទាំងមានទាក់ទងនឹងសមត្ថភាពរបស់ភាគីផងដែរ។

ដើម្បីឱ្យមជ្ឈត្តការពាណិជ្ជកម្មអាចប្រព្រឹត្តទៅបានយ៉ាងរលូន ភាគីវិវាទមានសេរីភាពក្នុងការព្រមព្រៀងគ្នាដើម្បីជ្រើសរើសយកស្ថាប័នមជ្ឈត្តការពាណិជ្ជកម្ម ដែលវាអាចតាមរយៈកិច្ចសន្យា និងភាគីវិវាទអាចព្រមព្រៀងគ្នាក្នុងការជ្រើសមជ្ឈត្តករ ទីកន្លែង ភាសា វិធានគតិយុត្ត ការរៀបចំ និងការចងក្រងសំណៅឯកសារផ្សេងៗ ព្រមទាំងនីតិវិធីនៃការដោះស្រាយ។ បន្ទាប់បានកំណត់ និងជ្រើសអ្វីដែលបានរៀបរាប់មកខាងលើនេះហើយ ដំណើរការមជ្ឈត្តការតម្រូវឱ្យមានសវនាការមួយ ដែលមានភាពស្រដៀងគ្នាទៅនឹងដំណើរការនៃការជំនុំជម្រះនៅក្នុងតុលាការដែរ ត្រូវបានចែកជាច្រើនជំហានដូចជាសេចក្តីថ្លែងហេតុបើករបស់មជ្ឈត្តករ សេចក្តីថ្លែងហេតុបើករបស់ភាគីវិវាទ ការប្រើប្រាស់ភស្តុតាង ភាពចាំបាច់នៃសាក្សីអង្គហេតុ សេចក្តីថ្លែងការណ៍សក្ខីកម្មរបស់សាក្សីអង្គហេតុ ការឆ្លើយនិងឆ្លើយតប និងសេចក្តីថ្លែងការបិទ និងការចេញសេចក្តីសម្រេចរបស់មជ្ឈត្តវិនិច្ឆ័យ។

បន្ទាប់ពីបានពិនិត្យវិនិច្ឆ័យលើកម្មវត្ថុវិវាទរួចហើយ អង្គវេទិកាមជ្ឈត្តកម្មនឹងចេញនូវសេចក្តីសម្រេចអាចហៅបានថា មជ្ឈត្តវិនិច្ឆ័យ ដើម្បីអាចឱ្យភាគីវិវាទយកទៅអនុវត្ត ព្រមទាំងចងកាតព្វកិច្ចចំពោះភាគីវិវាទផងដែរ។ ប៉ុន្តែមុននឹងចេញនូវសេចក្តីសម្រេចមជ្ឈត្តវិនិច្ឆ័យជាផ្លូវការនោះ វេទិកាមជ្ឈត្តកម្មត្រូវធ្វើសេចក្តីព្រាងមួយ ហើយបញ្ជូនសេចក្តីព្រាងសេចក្តីសម្រេចមជ្ឈត្តវិនិច្ឆ័យនោះ ទៅកាន់អគ្គលេខាធិការដ្ឋាន ក្នុងគោលបំណងធ្វើការត្រួតពិនិត្យលើទម្រង់ផ្សេងៗចំពោះសេចក្តីសម្រេចមុនធ្វើការចេញមជ្ឈត្តវិនិច្ឆ័យ។ នៅក្នុងការចេញនូវមជ្ឈត្តវិនិច្ឆ័យនោះដែរ ត្រូវធ្វើឡើងជាទម្រង់លាយលក្ខណ៍អក្សរដែលបានព្រមព្រៀង បញ្ជាក់មូលហេតុ កាលបរិច្ឆេទ ទីកន្លែង និងចុះហត្ថលេខាដោយមជ្ឈត្តករទាំងអស់។ នៅពេលដែលវេទិកាមជ្ឈត្តកម្មបានចេញនូវមជ្ឈត្តវិនិច្ឆ័យរួចហើយ អគ្គលេខាធិការត្រូវបោះត្រាទៅលើមជ្ឈត្តវិនិច្ឆ័យនោះដោយមិនមានការបង្អង់ និងបញ្ជូនមជ្ឈត្តវិនិច្ឆ័យនោះទៅគ្រប់ភាគីវិវាទទាំងអស់។ សម្រាប់ករណីដែលមជ្ឈត្តវិនិច្ឆ័យស្ថាពរ នោះវាអានុភាពអនុវត្តចំពោះគូភាគី ចាប់ពីពេលដែលមជ្ឈត្តវិនិច្ឆ័យនោះត្រូវបានចេញនិងបោះត្រា។

សរុបសេចក្តីមក ការដោះស្រាយវិវាទពាណិជ្ជកម្មតាមរយៈយន្តការមជ្ឈត្តការបានផ្តល់សិទ្ធិសេរីភាពយ៉ាងពេញលេញដល់គូភាគីដើម្បីធ្វើការសម្រេចចិត្តក្នុងការជ្រើសរើសបែបបទនៃការដោះស្រាយ និងនៅពេលដែលមានការចេញមជ្ឈត្តវិនិច្ឆ័យ ប្រសិនបើក្នុងករណីឃើញថាមានកំហុស ភាគីនៃការដាក់ពាក្យស្នើសុំការកែតម្រូវ ការបំភ្លឺលម្អិត ការបកស្រាយមជ្ឈត្តវិនិច្ឆ័យ និងមជ្ឈត្តវិនិច្ឆ័យបន្ថែម ត្រូវជូនដំណឹងទៅភាគី ជូនដំណឹងទៅអគ្គលេខាធិការដ្ឋាន និងវេទិកាមជ្ឈត្តកម្មអំពីការស្នើសុំឱ្យវេទិកាមជ្ឈត្តកម្ម ធ្វើការកែតម្រូវនូវកំហុសដែលមានក្នុងមជ្ឈត្តវិនិច្ឆ័យនោះ លើកលែងតែមានការព្រមព្រៀងពីការពន្យារអំឡុងពេលផ្សេងពីនេះទៀតដោយភាគីវិវាទ។ ភាគីមានការមិនពេញចិត្តនោះ ភាគីអាចធ្វើការប្តឹងជំទាស់ទៅកាន់តុលាការឧទ្ធរណ៍ ដែលជាស្ថាប័នក្នុងការដោះស្រាយនិងចេញសេចក្តីសម្រេចចុងក្រោយ។

# អនុសាសន៍

# អនុសាសន៍

ខ្ញុំព្រះករុណាអាត្មាភាពទាំងពីរព្រះអង្គ បានធ្វើការស្រាវជ្រាវទៅលើប្រធានបទទាក់ទងនឹងការដោះស្រាយវិវាទពាណិជ្ជកម្មតាមយន្តការមជ្ឈត្តការនៅកម្ពុជា ឃើញថាពិតជាមានសារៈប្រយោជន៍ ព្រមទាំងមាននូវគុណប្រយោជន៍ជាច្រើន ប៉ុន្តែក៏បានលេចឡើងនូវចំណុចខ្វះខាតមួយចំនួនផងដែរ។ ដូច្នេះហើយ ខ្ញុំព្រះករុណាអាត្មាភាពទាំងពីរព្រះអង្គ សូមធ្វើការសំណូមពរដល់ភាគីពាក់ព័ន្ធទាំងអស់ ដូចជារាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន មន្ត្រីមានសមត្ថកិច្ច បុគ្គលឯកជន និងមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម គួរតែះ

- ខិតខំប្រឹងប្រែង និងយកចិត្តទុកដាក់បន្ថែមទៀតក្នុងការពង្រឹង ដែលធ្វើយ៉ាងណាឱ្យមានភាពរីកចម្រើន។ លើសពីនេះទៀតនោះ ធ្វើយ៉ាងណាឱ្យមានការផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីគោលគំនិតនៃការដោះស្រាយវិវាទតាមរយៈយន្តការមជ្ឈត្តការតាមរយៈរូបភាពផ្សេងៗដែលអាចធ្វើទៅបាន។
- បើក្រឡេកទៅមើលការដោះស្រាយតាមប្រព័ន្ធតុលាការ ឃើញថាតុលាការមានការរីកផ្សាយភាយទូទាំងប្រទេស ចំណែកឯសាខានៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការមិនទាន់មានការរីកដុះដាលនៅឡើយនោះទេ ដូច្នេះគួរណាតែមានការពង្រីកនូវសាខានៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការពាណិជ្ជកម្ម ទៅកាន់ទីរួមខេត្តឱ្យបានច្រើនដែលអាចធ្វើទៅបាន ព្រោះវាអាចជួយឱ្យមហាជនទទួលស្គាល់នូវមជ្ឈត្តការកាន់តែច្រើន។
- គួរតែយកចិត្តទុកដាក់ក្នុងការពង្រឹងនូវសមត្ថភាព ធនធាន និងលក្ខណៈសម្បត្តិរបស់មជ្ឈត្តករដោយមានការបណ្តុះបណ្តាល បង្កើនវគ្គសិក្សា ហ្វឹកហ្វឺន និងអប់រំបន្ថែមទៀត ដែលធ្វើឱ្យមជ្ឈត្តករទាំងប្រកបដោយសមត្ថភាព និងប្រសិទ្ធភាពខ្ពស់។
- ជាពិសេសជាងនេះ គួរតែមានការដាក់បញ្ចូលមេរៀនទាំងឡាយណាដែលទាក់ទងជាមួយនឹងការដោះស្រាយវិវាទតាមរយៈយន្តការមជ្ឈត្តការទៅក្នុងកម្មវិធីសិក្សាផ្សេងៗ ដែលអាចធ្វើឱ្យអ្នកសិក្សាទាំងឡាយទទួលបាននូវពុទ្ធិដែលទាក់ទងខាងយន្តការមួយនេះ ក៏ដូចជាការបញ្ជ្រាបទៅគ្រប់មជ្ឈដ្ឋាន និងពង្រីកនូវវិសាលភាពនៃយន្តការមួយនេះឱ្យកាន់តែមានភាពរីកសុះសាយផងដែរ។

ជាអវសាន ខ្ញុំព្រះករុណាអាត្មាភាពទាំងពីរព្រះអង្គសង្ឃឹមយ៉ាងមុតមាំថាការដោះស្រាយវិវាទពាណិជ្ជកម្មតាមរយៈយន្តការមជ្ឈត្តការនៅក្នុងប្រទេសកម្ពុជានឹងក្លាយជាយន្តការដោះស្រាយវិវាទមួយមានភាពពេញនិយមព្រមទាំងប្រកបដោយគុណភាព សមភាព អព្យាក្រឹត និងប្រសិទ្ធភាពខ្ពស់ ទាំងបច្ចុប្បន្ននិងនាពេលអនាគត។

# ឯកសារយោង

# ឯកសារយោង


## ក. ច្បាប់ និងបទដ្ឋានគតិយុត្តជាតិ

១. ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ ២០១៤

២. ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦

៣. ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

៤. ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

៥. អនុក្រឹត្យការរៀបចំនិងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៩

៦. បទបញ្ជាផ្ទៃក្នុងរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០២១

៧. វិធានស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០២១

៨. សេចក្តីប្រកាសរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២

៩. សេចក្តីប្រកាសព័ត៌មានស្តីពីសំណុំរឿងមជ្ឈត្តករបន្ទាន់ដំបូងប្រព្រឹត្តទៅដោយជោគជ័យ ឆ្នាំ២០២២

១០. ព្រឹត្តប័ត្រស្តីពីបញ្ហាអាជីវកម្ម ឆ្នាំ២០០៨

១១. អនុសញ្ញាទីក្រុងញូវយ៉ក់ស្តីពីការទទួលស្គាល់និងអនុវត្តសេចក្តីសម្រេចមជ្ឈត្តករបរទេស ឆ្នាំ១៩៥៨

## ខ. សៀវភៅផ្សេងៗ

១២. សៀវភៅដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅកម្ពុជា, មេធាវី ស៊្វីរិន អ៊ែន អស្ទើរមីឡឺរ៍ បោះពុម្ព ឆ្នាំ២០១០

១៣. សៀវភៅកម្រងវិធីសាស្ត្រគន្លឹះនីតិវិធីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, លោក ហួន សុខនីម បោះពុម្ពឆ្នាំ ២០២១

១៤. សៀវភៅ Economic history of industrialization in Cambodia, លោក ឆាយ សុខជី និងអ៊ុង លុយណា បោះពុម្ពឆ្នាំ២០១៦

១៥. សៀវភៅ Alternative Dispute Resolution: Cambodia, Mr. Steven M. Austermiller ឆ្នាំ២០១០

## គ. គេហទំព័រ

១៨. គេហទំព័រ https://ncac.org.kh/statistics/

១៩. គេហទំព័រ https://ncac.org.kh/general-secretariat/

២០. គេហទំព័រ https://ovtlaw.com/2022/02/07

២១. គេហទំព័រ http://www.preservearticles.com/201104065087/arbitrator-his-appointment-powers-and-duties.html

# ឧបសម្ព័ន្ធ

# មាតិកាឧបសម្ព័ន្ធ


ឧបសម្ព័ន្ធទី១៖ គំរូខថែង

ឧបសម្ព័ន្ធទី២៖ តារាងកម្រៃសេវារបស់ ម.ជ.ម.

ឧបសម្ព័ន្ធទី៣៖ ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦

ឧបសម្ព័ន្ធទី៤៖ ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ ២០១៤

ឧបសម្ព័ន្ធទី៥៖ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

ឧបសម្ព័ន្ធទី៦៖ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ឧបសម្ព័ន្ធទី៧៖ អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៩

## ឧបសម្ព័ន្ធទី១៖ គំរូខចែងរបស់ ម.ជ.ម.

# គំរូខចែងរបស់ ម.ជ.ម.

**ខចែងស្តីពីមជ្ឈត្តការ**

រាល់វិវាទទាំងអស់ដែលកើតចេញពី ឬដែលទាក់ទងនឹងកិច្ចសន្យានេះ រួមបញ្ចូលវិវាទទាំងឡាយដែលពាក់ព័ន្ធនឹងអត្ថិភាព សុពលភាព ការអនុវត្ត ឬការបញ្ចប់កិច្ចសន្យានេះ ត្រូវបញ្ជូនទៅដោះស្រាយជាស្ថាពរតាមរយៈមជ្ឈត្តការចាត់ចែងដោយមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា ស្របតាមវិធានស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (វិធានស្តីពីមជ្ឈត្តការ ម.ជ.ម.) ដែលមានសុពលភាពអនុវត្តនៅពេលចាប់ផ្តើមដំណើរការមជ្ឈត្តការ ហើយតាមរយៈការយោងក្នុងប្រការនេះ វិធានស្តីពីមជ្ឈត្តការ ម.ជ.ម. ត្រូវចាត់ទុកថាបានរួមបញ្ចូលជាផ្នែកមួយនៃកិច្ចសន្យានេះ។

ទីកន្លែងធ្វើមជ្ឈត្តការគឺ [រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា]។*

វេទិកាមជ្ឈត្តកម្មត្រូវមានមជ្ឈត្តករចំនួន__________**រូប។

ភាសានៃមជ្ឈត្តការគឺ ________________ ។

**ខចែងស្តីពីច្បាប់គ្រប់គ្រងកិច្ចសន្យា**

ច្បាប់ដែលត្រូវយកមកអនុវត្តលើកិច្ចសន្យានេះគឺច្បាប់នៃ________________***។

* គូភាគីវិវាទគួរបញ្ជាក់អំពីជម្រើស នៃទីកន្លែងធ្វើមជ្ឈត្តការរបស់ខ្លួន។ ប្រសិនបើគូភាគីវិវាទមានបំណងចង់ជ្រើសរើសទីកន្លែងធ្វើមជ្ឈត្តការផ្សេងពីរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា គូភាគីវិវាទត្រូវជំនួស "[រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា]" ដោយឈ្មោះទីក្រុង និងប្រទេសនៃជម្រើសរបស់ខ្លួន (ឧទាហរណ៍ "[ទីក្រុង ប្រទេស]")។

** ចំនួនមជ្ឈត្តករត្រូវកំណត់ជាចំនួនសេស។

*** បញ្ជាក់ឈ្មោះប្រទេស ឬយុត្តាធិការ។

# ឧបសម្ព័ន្ធទី២៖ តារាងកម្រៃសេវារបស់ ម.ជ.ម.

**កម្រៃសេវាវេទិកាមជ្ឈត្តកម្ម** (គិតជាដុល្លារអាមេរិក)

| តម្លៃកម្មវត្ថុនៃវិវាទ | | | | | កម្រៃសេវាវេទិកាមជ្ឈត្តកម្ម ( សម្រាប់មជ្ឈត្តករមួយរូប ) | | | | |
|---|---|---|---|---|---|---|---|---|---|
| រហូត | ៥០.០០០ | | | = | ១.០០០ | | | | |
| ចាប់ពី | ៥០.០០១ | ដល់ | ១០០.០០០ | = | ២.៧៥០ | + | ២% | នៃចំនួនដែលលើសពី | ៥០.០០០ |
| ចាប់ពី | ១០០.០០១ | ដល់ | ៥០០.០០០ | = | ៣.៧៥០ | + | ១,៧០% | នៃចំនួនដែលលើសពី | ១០០.០០០ |
| ចាប់ពី | ៥០០.០០១ | ដល់ | ១.០០០.០០០ | = | ១០.៥៥០ | + | ១,៥០% | នៃចំនួនដែលលើសពី | ៥០០.០០០ |
| ចាប់ពី | ១.០០០.០០១ | ដល់ | ៣.០០០.០០០ | = | ១៨.០៥០ | + | ០,៧៥% | នៃចំនួនដែលលើសពី | ១.០០០.០០០ |
| ចាប់ពី | ៣.០០០.០០១ | ដល់ | ៥.០០០.០០០ | = | ៣៣.០៥០ | + | ០,៥០% | នៃចំនួនដែលលើសពី | ៣.០០០.០០០ |
| ចាប់ពី | ៥.០០០.០០១ | ដល់ | ១០.០០០.០០០ | = | ៤៣.០៥០ | + | ០,៣០% | នៃចំនួនដែលលើសពី | ៥.០០០.០០០ |
| ចាប់ពី | ១០.០០០.០០១ | ដល់ | ៥០.០០០.០០០ | = | ៥៨.០៥០ | + | ០,១៥% | នៃចំនួនដែលលើសពី | ១០.០០០.០០០ |
| លើសពី | ៥០.០០០.០០០ | | | = | ១១៨.០៥០ | | ០,០៧៥% | នៃចំនួនដែលលើសពី | ៥០.០០០.០០០ |

## កម្រៃសេវារដ្ឋបាល (គិតជាដុល្លារអាមេរិក)

| តម្លៃកម្មវត្ថុនៃវិវាទ | | | | | កម្រៃសេវារដ្ឋបាល | | | | |
|---|---|---|---|---|---|---|---|---|---|
| រហូត | ៥០.០០០ | | | = | ៧៥០ | | | | |
| ចាប់ពី | ៥០.០០១ | ដល់ | ១០០.០០០ | = | ១.៥០០ | + | 0,៨០% | នៃចំនួនដែលលើសពី | ៥០.០០០ |
| ចាប់ពី | ១០០.០០១ | ដល់ | ៥០០.០០០ | = | ១.៩០០ | + | 0,៧០% | នៃចំនួនដែលលើសពី | ១០០.០០០ |
| ចាប់ពី | ៥០០.០០១ | ដល់ | ១.០០០.០០០ | = | ៤.៧០០ | + | 0,៥០ % | នៃចំនួនដែលលើសពី | ៥០០.០០០ |
| ចាប់ពី | ១.០០០.០០១ | ដល់ | ៣.០០០.០០០ | = | ៧.២០០ | + | 0,២០% | នៃចំនួនដែលលើសពី | ១.០០០.០០០ |
| ចាប់ពី | ៣.០០០.០០១ | ដល់ | ៥.០០០.០០០ | = | ១១.២០០ | + | 0,១២% | នៃចំនួនដែលលើសពី | ៣.០០០.០០០ |
| ចាប់ពី | ៥.០០០.០០១ | ដល់ | ១០.០០០.០០០ | = | ១៣.៦០០ | + | 0,0៨% | នៃចំនួនដែលលើសពី | ៥.០០០.០០០ |
| ចាប់ពី | ១០.០០០.០០១ | ដល់ | ៥០.០០០.០០០ | = | ១៧.៦០០ | + | 0,0៤% | នៃចំនួនដែលលើសពី | ១០.០០០.០០០ |
| លើសពី | ៥០.០០០.០០០ | | | = | ៣៣.៦០០ | | | | |

# ព្រះរាជក្រម

នស/រកម/០៥០៦/០១០

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្ត្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីមជ្ឈត្តការផ្តែកពាណិជ្ជកម្ម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០៦ ក្នុងសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាពុំមានពេលវេលាគ្រប់គ្រាន់ដើម្បី ពិនិត្យច្បាប់នេះឱ្យទាន់តាមកាលកំណត់របស់មាត្រា១១៣ថ្មី នៃរដ្ឋធម្មនុញ្ញ និងដែលក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញតាមសេចក្តីសម្រេចលេខ ០៧៥/០០២/២០០៦ កបធ.ធ ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៦ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងសម្រួលដល់ការដោះស្រាយជាបន្ទាន់ តាមការផ្សះផ្សានូវវិវាទពាណិជ្ជកម្មដែលកើតមានឡើងក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមការស្ម័គ្រចិត្តរបស់ភាគីវិវាទដើម្បីការពារសិទ្ធិនិងផលប្រយោជន៍នៃភាគីវិវាទទាំងនេះ និងដើម្បីលើកស្ទួយការអភិវឌ្ឍន៍សេដ្ឋកិច្ច ។

ច្បាប់នេះមិនប៉ះពាល់ដល់អានុភាពគតិយុត្តិនៃច្បាប់នានាឯទៀតរបស់ព្រះរាជាណាចក្រកម្ពុជាដែលនៅក្នុងនោះ ករណីវិវាទខ្លះផ្សះផ្សាបាន ឬ ដោះស្រាយបានតាមនីតិវិធីផ្សេងៗទៀត និងវិវាទខ្លះទៀតផ្សះផ្សាមិនបាន ។

**មាត្រា ២.-**

និយមន័យ និងវិធាននៃការបកស្រាយពាក្យដែលប្រើក្នុងច្បាប់នេះ :

ក- "មជ្ឈត្តការ" គឺជាការផ្សះផ្សាវិវាទដោយប្រើប្រាស់វេទិកាមជ្ឈត្តកម្ម ហើយអាចស្ថិតនៅក្នុង ឬ នៅក្រៅក្របខ័ណ្ឌនៃការគ្រប់គ្រងរបស់ស្ថាប័នផ្សះផ្សាអចិន្ត្រៃយ៍ ។

ខ- "វេទិកាមជ្ឈត្តកម្ម" គឺជាមជ្ឈត្តករមួយនាក់ ឬ មួយក្រុម ។

គ- "តុលាការ" គឺជាស្ថាប័ន ឬ អង្គការនៃប្រព័ន្ធតុលាការរបស់ប្រទេសមួយ ។

ឃ- "កិច្ចព្រមព្រៀងផ្សះផ្សា" ជាកិច្ចព្រមព្រៀងរវាងភាគីវិវាទក្នុងការធ្វើមជ្ឈត្តការវិវាទទាំងអស់ ឬ វិវាទបែបណាមួយដែលកើតឡើង ឬ ដែលអាចកើតឡើងរវាងភាគីវិវាទនានា ដោយគោរពតាមទំនាក់ទំនងកំណត់ដោយច្បាប់ ទោះបីជាមានកិច្ចសន្យា ឬ គ្មានក៏ដោយ ។

ង- ក្រៅពីមាត្រា ៣៦ កាលណាបទប្បញ្ញត្តិនានានៃច្បាប់នេះទុកសេរីភាពឱ្យភាគីវិវាទកំណត់ពីបញ្ហាណាមួយ សេរីភាពនេះគឺរាប់បញ្ចូលទាំងសិទ្ធិរបស់ភាគីវិវាទក្នុងការអនុញ្ញាតឱ្យមានភាគីទី ៣ រួមបញ្ចូលទាំងស្ថាប័នមួយ ដើម្បីធ្វើការសម្រេចលើបញ្ហានោះ ។

4/284

ច-ក្នុងករណីដែលបទប្បញ្ញត្តិនៃច្បាប់នេះ យោងតាមអ្វីដែលភាគីវិវាទបានព្រមព្រៀង ឬ អាចនឹងព្រមព្រៀងគ្នា ឬ យោងតាមមធ្យោបាយផ្សេងទៀតនៃកិច្ចព្រមព្រៀងរបស់ភាគីវិវាទ កិច្ចព្រមព្រៀងនោះ ។

ឆ-ក្រៅពីមាត្រា ៣៣ (១) និងមាត្រា ៤០ (១) នៃច្បាប់នេះ កាលណាបទប្បញ្ញត្តិនៃច្បាប់នេះយោងតាមការប្តឹងទាមទារ បទប្បញ្ញត្តិនោះក៏ត្រូវអនុវត្តចំពោះការប្តឹងទាមទារបកវិញដែរ ហើយនៅពេលដែលយោងតាមការដោះសាពីការប្តឹងទាមទារ ក៏ត្រូវអនុវត្តចំពោះការដោះសាពីការប្តឹងទាមទារបកវិញដែរ ។

ជ-មជ្ឈត្តការមានលក្ខណៈជា "អន្តរជាតិ" ក្នុងករណី :

ជ.១-ភាគីវិវាទ និងកិច្ចព្រមព្រៀងផ្សះផ្សាមានទីកន្លែងធ្វើពាណិជ្ជកម្មនៅក្នុងប្រទេសផ្សេងពីគ្នា ក្នុងពេលសម្រេចកិច្ចព្រមព្រៀងនោះ ឬ

ជ.២-ទីកន្លែងមួយក្នុងចំណោមទីកន្លែងខាងក្រោមនោះ ស្ថិតនៅក្រៅប្រទេសធ្វើពាណិជ្ជកម្មរបស់ភាគីវិវាទ :

-ទីកន្លែងធ្វើមជ្ឈត្តការ : ប្រសិនបើបានកំណត់ ឬ បានយោងក្នុងកិច្ចព្រមព្រៀងផ្សះផ្សា ។

-ទីកន្លែងដែលកាតព្វកិច្ចសំខាន់នៃទំនាក់ទំនងពាណិជ្ជកម្មបានប្រព្រឹត្តទៅ ឬ ទីកន្លែងជិតជាងគេនៃរឿងពាក់ព័ន្ធនឹងវិវាទ ។

ជ.៣-ភាគីវិវាទបានព្រមព្រៀងជាក់លាក់ថា រឿងនៃកិច្ចព្រមព្រៀងផ្សះផ្សាទាក់ទងទៅនឹងប្រទេសលើសពីមួយ ។

ជ.៤-តាមគោលបំណងក្នុងកថាខណ្ឌ (ជ) នេះ :

-ប្រសិនបើភាគីវិវាទមួយមានទីកន្លែងប្រកបពាណិជ្ជកម្មលើសពីមួយកន្លែង ទីកន្លែងដែលមានទាក់ទងជិតស្និទ្ធជាងគេបំផុតទៅនឹងកិច្ចព្រមព្រៀងផ្សះផ្សាគឺជាទីកន្លែងពាណិជ្ជកម្ម ។

-ប្រសិនបើភាគីវិវាទមួយមិនមានទីកន្លែងប្រកបពាណិជ្ជកម្មទេ ការយោងក្នុងច្បាប់នេះគឺទីលំនៅអចិន្ត្រៃយ៍របស់ភាគីនោះ ។

ឈ-ពាក្យថា "ពាណិជ្ជកម្ម" ត្រូវបកស្រាយឱ្យបានទូលំទូលាយ ដើម្បីគ្របដណ្តប់លើធុរកិច្ចដែលមានប្រភេទជាពាណិជ្ជកម្ម ទោះបីជាមានកិច្ចសន្យា ឬ គ្មានកិច្ច

សន្យាក៏ដោយ ។ ធុរកិច្ចដែលមានប្រភេទជាពាណិជ្ជកម្មមានជាអាទិ៍ : កិច្ចការជំនួញដើម្បីផ្គត់ផ្គង់ ឬ ការផ្លាស់ប្តូរទំនិញ ឬ សេវាផ្សេងៗ កិច្ចព្រមព្រៀងនៃការចែកចាយតំណាង ឬ ទីភ្នាក់ងារពាណិជ្ជកម្ម ការទិញ-លក់គណនីក្រុមហ៊ុន ការជួលទីតាំង ឬ សម្ភារៈវត្ថុ ការងារស្ថាបនា ការពិគ្រោះយោបល់ វិស្វកម្ម ការចេញអាជ្ញាប័ណ្ណ ការវិនិយោគទុន ការផ្តល់ហិរញ្ញវត្ថុ ការធ្វើអាជីវកម្មធនាគារ ការធានារ៉ាប់រង កិច្ចព្រមព្រៀងធ្វើអាជីវកម្ម ឬ សម្បទាន ក្រុមហ៊ុនចំរុះ និងប្រភេទផ្សេងៗទៀតនៃសហប្រតិបត្តិការឧស្សាហកម្ម ឬ ពាណិជ្ជកម្ម និងការដឹកជញ្ជូនទំនិញ ឬ អ្នកដំណើរតាមផ្លូវអាកាស ផ្លូវទឹក ផ្លូវគោក ។

**មាត្រា ៣.-**

លើកលែងតែភាគីទាំងអស់បានព្រមព្រៀងផ្សេងពីនេះ :

១-លិខិតឆ្លើយឆ្លងជាលាយលក្ខណ៍អក្សរ ត្រូវចាត់ទុកថាបានទទួល ក្នុងករណីដែលបានប្រគល់ឱ្យអ្នកទទួលដោយផ្ទាល់ដៃ ឬ ប្រគល់ដល់កន្លែងប្រកបពាណិជ្ជកម្ម ឬ ទីលំនៅអចិន្ត្រៃយ៍ ឬ អាសយដ្ឋានប្រៃសណីយ៍របស់អ្នកទទួល ។ ប្រសិនបើរកកន្លែងទាំងនោះមិនឃើញទេ ក្រោយពីការស្វះស្វែងរកយ៉ាងល្អិតល្អន់រួចមក លិខិតឆ្លើយឆ្លងជាលាយលក្ខណ៍អក្សរ ត្រូវចាត់ទុកថាបានទទួលក្នុងករណីបានផ្ញើតាមរយៈលិខិតអនុសិដ្ឋ ឬ តាមមធ្យោបាយផ្សេងៗដែលផ្តល់ហេតុផលថា ពិតជាបានខំប្រឹងប្រែងប្រគល់លិខិតទៅដល់កន្លែងប្រកបពាណិជ្ជកម្ម ឬ ទីលំនៅអចិន្ត្រៃយ៍ ឬ អាសយដ្ឋានរបស់អ្នកទទួលដែលស្គាល់ចុងក្រោយបំផុត ។

២-បទប្បញ្ញត្តិនានាក្នុងមាត្រា ៣ នៃច្បាប់នេះ មិនយកទៅអនុវត្តលើលិខិតឆ្លើយឆ្លងក្នុងពេលដំណើរការកាត់ក្តីរបស់តុលាការទេ ។

**មាត្រា ៤.-**

ត្រូវបានចាត់ទុកថាបានបោះបង់សិទ្ធិជំទាស់របស់ខ្លួន ប្រសិនបើភាគីវិវាទមួយបានដឹងថាភាគីវិវាទផ្សេងទៀត អាចប្រព្រឹត្តខុសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ឬ ពុំគោរពតាមការតម្រូវរបស់កិច្ចព្រមព្រៀងផ្សះផ្សា ប៉ុន្តែភាគីវិវាទនោះនៅតែបន្តដំណើរការមជ្ឈត្តការដោយមិនបានជំទាស់ទៅនឹងការមិនគោរពនោះ ហើយក្នុងករណីដែលមានចែងពីរយៈពេលកំណត់សម្រាប់ការជំទាស់ ភាគីវិវាទនោះពុំបានធ្វើការពន្យារពេលជាចាំបាច់ ។

**មាត្រា ៥.-**

នៅក្នុងបទប្បញ្ញត្តិនៃច្បាប់នេះ តុលាការធ្វើអន្តរាគមន៍បានតែក្នុងករណីទាំងឡាយណា ដែលច្បាប់នេះបានចែង ។

**មាត្រា ៦.-**

មុខងារផ្សេងៗដែលមានចែងក្នុងមាត្រា ១៩ កថាខណ្ឌទី ៣, ៤ និង ៥ មាត្រា ២១ កថាខណ្ឌទី ៣ មាត្រា ២២ មាត្រា ២៤ កថាខណ្ឌទី ៣ នៃច្បាប់នេះ ត្រូវបំពេញដោយ តុលាការ ( តុលាការពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាការកំពូល ) ឬ មជ្ឈមណ្ឌល ជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ។

## ជំពូកទី ២
## កិច្ចព្រមព្រៀងផ្សះផ្សា

**មាត្រា ៧.-**

កិច្ចព្រមព្រៀងផ្សះផ្សារួមមានខចែងស្តីពីមជ្ឈត្តការដែលបានចែងនៅក្នុងកិច្ចសន្យា ឬ ក្នុងកិច្ចព្រមព្រៀងដោយឡែក ។

កិច្ចព្រមព្រៀងផ្សះផ្សាត្រូវសរសេរជាលាយលក្ខណ៍អក្សរ ។ ដែលហៅថាកិច្ចព្រមព្រៀង ជាលាយលក្ខណ៍អក្សរ គឺជាកិច្ចព្រមព្រៀងដែលស្ថិតនៅក្នុងឯកសារចុះហត្ថលេខាដោយ ភាគីវិវាទ ឬ ដែលស្ថិតនៅក្នុងការផ្ញើរលិខិតស្នាម ឬ មធ្យោបាយទូរគមនាគមន៍តាមប្រព័ន្ធ អេឡិចត្រូនិច ដែលផ្តល់កំណត់ត្រាបញ្ជាក់ពីការព្រមព្រៀងគ្នា ឬ ដែលស្ថិតនៅក្នុងការប្តូរ គ្នាទៅវិញទៅមកនូវពាក្យទាមទារ ឬ ពាក្យដោះសាដែលក្នុងនោះ ភាគីវិវាទមួយបានទាម ទារ ហើយមិនត្រូវបានបដិសេធដោយភាគីវិវាទម្ខាងទៀត ។ សេចក្តីយោងក្នុងកិច្ចសន្យា និង ឯកសារមួយដែលមានប្រការស្តីពីមជ្ឈត្តការអាចក្លាយជាកិច្ចព្រមព្រៀងផ្សះផ្សាបាន លុះត្រាតែកិច្ចសន្យានោះសរសេរជាលាយលក្ខណ៍អក្សរ ហើយសេចក្តីយោងនោះគឺជាប្រការ ដែលក្លាយជាផ្នែកមួយនៃកិច្ចសន្យា ។

មាត្រា ៨.-

នៅពេលដោះស្រាយបណ្តឹងវិវាទ តុលាការដែលទទួលដោះស្រាយវិវាទដែលជាកម្មវត្ថុកិច្ចព្រមព្រៀងផ្សះផ្សា ត្រូវបញ្ជូនភាគីវិវាទទៅធ្វើមជ្ឈត្តការ ប្រសិនបើមានសំណើពីភាគីវិវាទមួយ វៀរលែងតែតុលាការនោះរកឃើញថាកិច្ចព្រមព្រៀងផ្សះផ្សានោះត្រូវចាត់ទុកជាមោឃៈ ឬ មិនអាចអនុវត្តបាន ។

ទោះបីជាមានបណ្តឹងទាមទារទៅតុលាការដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះក៏ដោយ ក៏ដំណើរការរបស់វេទិកាមជ្ឈត្តកម្មអាចចាប់ផ្តើម ឬ បន្តដំណើរការបានតទៅទៀត ហើយតុលាការត្រូវបង្វែរសមត្ថកិច្ចជូនទៅវេទិកាមជ្ឈត្តកម្មវិញ ដោយរង់ចាំការសម្រេចរបស់វេទិកាមជ្ឈត្តកម្ម ។

មាត្រា ៩.-

នៅមុនពេល ឬ ក្នុងពេលកំពុងដំណើរការមជ្ឈត្តការ ការធ្វើសំណូមពររបស់ភាគីវិវាទមួយទៅតុលាការឱ្យផ្តល់វិធានការបណ្តោះអាសន្ន ដើម្បីការពារ និងការផ្តល់នូវវិធានការទាំងនោះដោយតុលាការពុំមានវិសមិតភាពជាមួយកិច្ចព្រមព្រៀងផ្សះផ្សាឡើយ ។

## ជំពូកទី ៣

## មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

មាត្រា ១០.-

ត្រូវបានបង្កើតមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការមួយឯករាជ្យ នៅក្រោមការឧបត្ថម្ភរបស់ក្រសួងពាណិជ្ជកម្ម ។ គោលបំណងនៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការគឺ :

១-ជម្រុញការដោះស្រាយវិវាទពាណិជ្ជកម្ម តាមរយៈការផ្សះផ្សានៅក្នុងព្រះរាជាណាចក្រកម្ពុជា

២-បង្កើតរចនាសម្ព័ន្ធ និងវិធានចាំបាច់សម្រាប់គ្រប់គ្រងរឿងមជ្ឈត្តការនៅក្នុងព្រះរាជាណាចក្រកម្ពុជានៅពេលដែលកិច្ចព្រមព្រៀងជាក់ច្បាស់មួយនៃភាគីវិវាទ ដាក់វិវាទទៅមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ

៣-ធានាឱ្យមជ្ឈត្តការនៅក្នុងព្រះរាជាណាចក្រកម្ពុជាមានគុណភាពខ្ពស់ ។ គោល

9/28/k

បំណងនេះរួមបញ្ចូលការកំណត់ស្តង់ដាសម្រាប់លក្ខណៈសម្បត្តិរបស់មជ្ឈត្តករ ។

**មាត្រា ១១.-**

រូបវន្តបុគ្គលមានសញ្ជាតិខ្មែរ ឬ បរទេសដែលជាមជ្ឈត្តករត្រូវចុះបញ្ជីនៅមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ ។ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការមានភារកិច្ចកំណត់ពីលក្ខណៈសម្បត្តិរបស់មជ្ឈត្តករ ហើយត្រូវធ្វើសេចក្តីប្រកាសជាសាធារណៈនូវបញ្ជីឈ្មោះមជ្ឈត្តករជារៀងរាល់ឆ្នាំ ។ បញ្ជីនេះមិនមានលក្ខណៈដាច់ណាត់ទេ ភាគីវិវាទអាចជ្រើសរើសមជ្ឈត្តករក្រៅពីបញ្ជីក៏បាន ។

**មាត្រា ១២.-**

អាចសុំចូលជាសមាជិកមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការបាន រូបវន្តបុគ្គល និងនីតិបុគ្គលដូចខាងក្រោម :

-រូបវន្តបុគ្គលជាមជ្ឈត្តករដែលបានចុះឈ្មោះក្នុងបញ្ជីរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ

-សភាពាណិជ្ជកម្ម

-គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

-រាល់សមាគមដែលប្រមូលផ្តុំពាណិជ្ជករ ឧស្សាហករ អាជីវករ និង សេវាករ ។

សំណើសុំចូលជាសមាជិកមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ ត្រូវបានពិនិត្យដោយក្រុមប្រឹក្សាប្រតិបត្តិនៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការដែលមានចំនួនមិនលើសពីប្រាំពីរ (៧) នាក់ ។ សមាជិកក្រុមប្រឹក្សាប្រតិបត្តិមានអាណត្តិរយៈពេលបី (៣) ឆ្នាំ ហើយអាចឈរឈ្មោះបន្តមួយអាណត្តិទៀតបាន ។

**មាត្រា ១៣.-**

សភាពាណិជ្ជកម្មអាចរៀបចំមជ្ឈមណ្ឌលមជ្ឈត្តកម្មមួយនៅភ្នំពេញ ។ រាល់សមាគមដែលប្រមូលផ្តុំពាណិជ្ជករ ឧស្សាហករ អាជីវករ និងសេវាករ អាចបង្កើតមជ្ឈមណ្ឌលមជ្ឈត្តកម្មរបស់ខ្លួនដោយឡែកសម្រាប់ដោះស្រាយវិវាទរវាងសមាជិក និងរវាងសមាជិកជាមួយអ្នកដទៃ ។

9/28

**មាត្រា ១៤.-**

មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ ត្រូវគ្រប់គ្រងដោយ :

-មហាសន្និបាត

-ក្រុមប្រឹក្សាប្រតិបត្តិ ។

ភារកិច្ចសំខាន់ៗរបស់មហាសន្និបាតមាន :

-ប្រជុំមួយដង ឬ ពីរដងក្នុងមួយឆ្នាំ តាមការអញ្ជើញរបស់ប្រធានមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ ឬ តាមសំណើរបស់សមាជិកភាគច្រើននៃក្រុមប្រឹក្សាប្រតិបត្តិ ។

-ជ្រើសតាំងក្រុមប្រឹក្សាប្រតិបត្តិ

-ពិនិត្យរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាប្រតិបត្តិ

-សម្រេចលើស្ថានភាពហិរញ្ញវត្ថុរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ

-កំណត់សោហ៊ុយ ដែលជាតម្លៃនៃការធ្វើមជ្ឈត្តការ

-ពិនិត្យសម្រេចលើរាល់សំណើកែប្រែលិខិតបទដ្ឋានដែលទាក់ទងដល់ដំណើរការមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ និងដំណើរការមជ្ឈត្តការ ។

-បំពេញភារកិច្ចផ្សេងទៀត ដែលកំណត់ដោយអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ ។

**មាត្រា ១៥.-**

មហាសន្និបាតរួមប្រជុំដោយសមាជិកជារូបវន្តបុគ្គល និងតំណាងមួយរូបរបស់សមាជិកជានីតិបុគ្គលនីមួយៗ ។

**មាត្រា ១៦.-**

សមាសភាពក្រុមប្រឹក្សាប្រតិបត្តិដែលគ្រប់គ្រងមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការត្រូវបានបោះឆ្នោតជ្រើសតាំងក្នុងចំណោមសមាជិកដោយមហាសន្និបាត ។ ប្រធានក្រុមប្រឹក្សាប្រតិបត្តិ គឺជាប្រធានរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ ។

10/28

**មាត្រា ១៧.–**

ការរៀបចំ និងការប្រព្រឹត្តិទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៤
## សមាសភាពនៃវេទិកាមជ្ឈត្តកម្ម

**មាត្រា ១៨.–**

ភាគីវិវាទមានសិទ្ធិកំណត់ចំនួនមជ្ឈត្តករនៃវេទិកាមជ្ឈត្តកម្ម ។ មជ្ឈត្តករត្រូវមានចំនួនសេស ។

បើគ្មានការកំណត់ពីភាគីវិវាទទេ មជ្ឈត្តករត្រូវមានចំនួនបី (៣) នាក់ ។

**មាត្រា ១៩.–**

ការជ្រើសតាំងមជ្ឈត្តករត្រូវអនុវត្តតាមបែបបទដូចខាងក្រោម :

១-មិនត្រូវបដិសេធជនណាម្នាក់មិនឱ្យធ្វើមជ្ឈត្តករ ដោយសារមូលហេតុនៃសញ្ជាតិរបស់គេឡើយ លើកលែងតែភាគីវិវាទ បានព្រមព្រៀងផ្សេងពីនេះ ។

២-ភាគីវិវាទអាចព្រមព្រៀងលើនីតិវិធីនៃការតែងតាំងមជ្ឈត្តករមួយ (១) នាក់ ឬ ច្រើននាក់ យោងតាមបទប្បញ្ញត្តិក្នុងកថាខណ្ឌទី ៤ និងកថាខណ្ឌទី ៥ នៃមាត្រានេះ ។

៣-ករណីមិនបានព្រមព្រៀងពីនីតិវិធីនេះ :

ក-ក្នុងការធ្វើមជ្ឈត្តការដែលមានមជ្ឈត្តករបី (៣) នាក់ ភាគីវិវាទនីមួយៗត្រូវជ្រើសតាំងមជ្ឈត្តករមួយ (១) នាក់ ហើយមជ្ឈត្តករទាំងពីរនាក់នេះ ត្រូវជ្រើសតាំងមជ្ឈត្តករទីបី ។ ប្រសិនបើភាគីវិវាទណាមួយពុំបានជ្រើសតាំងមជ្ឈត្តករក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ ក្រោយពេលទទួលសំណើជ្រើសតាំងពីភាគីវិវាទម្ខាងទៀត ឬ ប្រសិនបើមជ្ឈត្តករទាំងពីរ (២) នាក់ ពុំបានព្រមព្រៀងលើការតែងតាំងមជ្ឈត្តករទីបីក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ ក្រោយពីត្រូវបានគេជ្រើសតាំងរួចមក តុលាការ ( តុលាការពាណិជ្ជ-កម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាការកំពូល ) ឬ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជ-

កម្ម ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ ត្រូវជ្រើសតាំងមជ្ឈត្តករទី ៣ តាមការស្នើសុំនៃភាគីវិវាទណាមួយ ។

ខ-ក្នុងការធ្វើមជ្ឈត្តការដែលមានមជ្ឈត្តករតែមួយនាក់ ប្រសិនបើភាគីវិវាទមិនអាចព្រមព្រៀងលើការជ្រើសតាំងមជ្ឈត្តករទេនោះ តុលាការ (តុលាការ ពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាការកំពូល) ឬ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះត្រូវជ្រើសតាំងមជ្ឈត្តករតាមសំណូមពររបស់ភាគីវិវាទណាមួយ ។

៤-តាមនីតិវិធីជ្រើសតាំងមជ្ឈត្តករ ដែលបានព្រមព្រៀងដោយភាគីវិវាទភាគីវិវាទណាក៏ដោយ អាចធ្វើសំណូមពរទៅតុលាការ ( តុលាការពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាការកំពូល ) ឬ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះឱ្យចាត់វិធានការចាំបាច់ ក្នុងករណីណាមួយដូចខាងក្រោម :

ក-ភាគីវិវាទមួយមិនបានប្រតិបត្តិតាមការតម្រូវក្នុងនីតិវិធី ឬ

ខ-ភាគីវិវាទ ឬ មជ្ឈត្តករពីរ (២) នាក់ មិនអាចឈានដល់ការព្រមព្រៀងដូចដែលគេរំពឹងទុកតាមនីតិវិធីនេះ ឬ

គ-ភាគីទីបី ដោយរាប់បញ្ចូលទាំងស្ថាប័នមួយផង មិនបានអនុវត្តតួនាទីណាមួយដូចដែលបានប្រគល់ឱ្យក្នុងនីតិវិធីនោះ ។ មាត្រានេះ មិនត្រូវបានយកមកអនុវត្តទេ ប្រសិនបើការព្រមព្រៀងស្តីពីនីតិវិធីជ្រើសតាំងមជ្ឈត្តករមានចែងពីវិធីផ្សេងទៀតសម្រាប់ធានាដល់ការជ្រើសតាំងនោះ ។

៥-ការជ្រើសតាំងរបស់តុលាការ ( តុលាការពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាការកំពូល ) ឬ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ លើបញ្ហាណាមួយតាមកថាខណ្ឌទី ៣ ឬ កថាខណ្ឌទី ៤ នៃមាត្រានេះ គឺជាការសម្រេចដែលមិនអាចតវ៉ាបានឡើយ ។ នៅក្នុងការជ្រើសតាំងមជ្ឈត្តករម្នាក់ តុលាការ ( តុលាការពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាការកំពូល ) ឬ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ ត្រូវពិចារណាពីលក្ខណៈសម្បត្តិរបស់មជ្ឈត្តករដែលបានចែងក្នុងកិច្ចព្រមព្រៀងរបស់ភាគីវិវាទ ដើម្បីធានាដល់ការជ្រើសតាំងមជ្ឈត្តករដែលឯករាជ្យ និងមិនលម្អៀង ។ ក្នុងករណីមានមជ្ឈត្តករតែមួយនាក់

12/28W

ឬ មានមជ្ឈត្តករទីបី នៅក្នុងការធ្វើមជ្ឈត្តការដែលមានលក្ខណៈអន្តរជាតិ តុលាការ ( តុលាការពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាការកំពូល ) ឬ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ ត្រូវពិនិត្យលទ្ធភាពជ្រើសតាំងមជ្ឈត្តករដែលមានសញ្ជាតិផ្សេងពីសញ្ជាតិរបស់ភាគីវិវាទ ដូចមានចែងក្នុងចំណុច ១ នៃមាត្រា ១៩ នៃច្បាប់នេះ ។

**មាត្រា ២០.-**

បុគ្គលម្នាក់ដែលត្រូវគេជ្រើសតាំងជាមជ្ឈត្តករ ត្រូវបង្ហាញពីលក្ខណៈពិសេសដែលអាចបង្កឱ្យមានការសង្ស័យពីភាពមិនលម្អៀង ឬ ពីភាពឯករាជ្យរបស់ខ្លួន ចាប់ពីពេលដែលត្រូវគេជ្រើសតាំងមក រហូតដល់ពេលបញ្ចប់ដំណើរការមជ្ឈត្តការ ។ មជ្ឈត្តករត្រូវបង្ហាញពីលក្ខណៈពិសេសទាំងនោះឱ្យភាគីវិវាទបានដឹង ដោយគ្មានពន្យារពេល លើកលែងតែភាគីវិវាទបានដឹងពីលក្ខណៈសម្បត្តិរបស់មជ្ឈត្តករនោះរួចហើយ ។

មជ្ឈត្តករម្នាក់អាចត្រូវជំទាស់តែក្នុងករណីដែលកើតមានការសង្ស័យពីលក្ខណៈពិសេសដែលប៉ះពាល់ដល់ភាពមិនលម្អៀង ឬ ភាពឯករាជ្យរបស់ខ្លួន ឬ នៅពេលដែលខ្លួនមិនមានលក្ខណៈសម្បត្តិដូចដែលភាគីវិវាទបានព្រមព្រៀង ។ ភាគីវិវាទមួយអាចជំទាស់នឹងមជ្ឈត្តករដែលខ្លួនបានជ្រើសតាំង ឬ បានចូលរួមជ្រើសតាំងតែក្នុងករណីដែលមូលហេតុនៃការជំទាស់នោះត្រូវបានដឹងក្រោយពេលជ្រើសតាំងរួចប៉ុណ្ណោះ ។

**មាត្រា ២១.-**

ភាគីវិវាទដែលមានបំណងជំទាស់ទៅនឹងមជ្ឈត្តករ ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម:

១-ភាគីវិវាទ អាចព្រមព្រៀងលើនីតិវិធីនៃការជំទាស់នឹងមជ្ឈត្តករដោយអនុលោមតាមបទប្បញ្ញត្តិនៃកថាខណ្ឌទី ៣ ក្នុងមាត្រានេះ ។

២-ក្នុងករណីគ្មានការព្រមព្រៀងលើនីតិវិធីនៃការជំទាស់នេះ ភាគីវិវាទមួយដែលមានបំណងជំទាស់នឹងមជ្ឈត្តករ ត្រូវធ្វើលិខិតតវ៉ាបញ្ជាក់មូលហេតុពីការជំទាស់នោះជាលាយលក្ខណ៍អក្សរទៅកាន់វេទិកាមជ្ឈត្តកម្ម ក្នុងរយៈពេលដប់ប្រាំ (១៥) ថ្ងៃ ក្រោយពេលបង្កើតវេទិកាមជ្ឈត្តកម្ម ឬ ក្រោយពេលបានដឹងពីលក្ខណៈពិសេស ដូចចែងក្នុងមាត្រា ២០ នៃកថាខណ្ឌទី ២ ។ វេទិកាមជ្ឈត្តកម្មត្រូវសម្រេចលើការជំទាស់ លើកលែងតែមជ្ឈត្តករដែល

13/28 h/

គេជំទាស់នោះ ដកខ្លួនចេញពីមុខតំណែង ឬ លើកលែងតែភាគីវិវាទមួយទៀតបានឯកភាពនឹងការជំទាស់នោះ ។

៣-ប្រសិនបើការជំទាស់ដែលត្រូវធ្វើតាមនីតិវិធីដែលព្រមព្រៀងដោយភាគីវិវាទ ឬ តាមនីតិវិធីក្នុងកថាខណ្ឌទី ២ នៃមាត្រានេះពុំបានសម្រេចទេនោះ ភាគីជំទាស់អាចស្នើសុំឱ្យតុលាការ ( តុលាការពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាការកំពូល ) ឬ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះធ្វើការសម្រេចចុងក្រោយលើការជំទាស់ ក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងបដិសេធការជំទាស់ ។ ក្នុងពេលរង់ចាំការសម្រេចរបស់តុលាការលើសំណើជំទាស់នេះ វេទិកាមជ្ឈត្តកម្មក្នុងនោះមានទាំងមជ្ឈត្តករដែលត្រូវគេជំទាស់ផងអាចបន្តដំណើរការមជ្ឈត្តការ ហើយអាចធ្វើសេចក្តីសម្រេចបាន ។

**មាត្រា ២២.-**

ប្រសិនបើមជ្ឈត្តករម្នាក់ពុំអាចបំពេញមុខងាររបស់ខ្លួនបានដោយមូលហេតុខាងច្បាប់ ឬ មូលហេតុជាក់ស្តែងណាមួយ ឬ មូលហេតុដទៃទៀតក្នុងរយៈពេលមួយសមស្របនោះ អាណត្តិរបស់មជ្ឈត្តករនោះត្រូវបានបញ្ចប់ដោយមជ្ឈត្តករនោះដកខ្លួនចេញពីមុខតំណែង ឬ ដោយភាគីវិវាទឯកភាពបញ្ចប់អាណត្តិនោះ ។ ផ្ទុយពីនេះ បើនៅតែមានភាពខ្វែងគ្នាស្តីពីមូលហេតុណាមួយ ក្នុងចំណោមមូលហេតុទាំងនេះ ភាគីណាក៏ដោយអាចស្នើសុំឱ្យតុលាការ (តុលាការពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាកាកំពូល) ឬ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះធ្វើការសម្រេចចុងក្រោយពីការបញ្ចប់អាណត្តិនោះ ។

តាមមាត្រានេះ ឬ មាត្រា ២១ កថាខណ្ឌទី ២ នៃច្បាប់នេះ ប្រសិនបើមជ្ឈត្តករម្នាក់ដកខ្លួនចេញពីមុខតំណែង ឬ ប្រសិនបើភាគីមួយឯកភាពចំពោះការបញ្ចប់អាណត្តិរបស់មជ្ឈត្តករនោះ ហេតុការណ៍នេះមិនបណ្តាលឱ្យមានការទទួលយកជាការបាននូវមូលហេតុណាមួយដែលចែងក្នុងមាត្រានេះ ឬ មាត្រា ២០ កថាខណ្ឌទី ២ នៃច្បាប់នេះឡើយ ។

14/28

**មាត្រា ២៣.-**

ក្នុងករណីដែលអាណត្តិរបស់មជ្ឈត្តករម្នាក់ត្រូវបញ្ចប់តាមបញ្ញត្តិនៃមាត្រា ២១ ឬ មាត្រា ២២ នៃច្បាប់នេះ មជ្ឈត្តករជំនួសនឹងត្រូវជ្រើសតាំងស្របតាម វិធាននៃមាត្រា ១៩ នៃច្បាប់នេះ ។

## ជំពូកទី ៥
## សមត្ថកិច្ចរបស់វេទិកាមជ្ឈត្តកម្ម

**មាត្រា ២៤.-**

សមត្ថកិច្ចរបស់វេទិកាមជ្ឈត្តកម្មត្រូវកំណត់ដូចខាងក្រោម ៖

១-វេទិកាមជ្ឈត្តកម្មអាចសម្រេចទៅតាមសមត្ថកិច្ចរបស់ខ្លួន ក្នុងនោះមានការជំទាស់នានាដែលទាក់ទងនឹងអត្ថិភាព ឬ សុពលភាពនៃកិច្ចព្រមព្រៀងផ្សះផ្សា ។ សម្រាប់គោលដៅនេះ ខចែងស្តីពីការផ្សះផ្សាដែលបង្កើតបានជាផ្នែកមួយនៃកិច្ចសន្យា ត្រូវចាត់ទុកថាជាកិច្ចព្រមព្រៀងដោយឡែក ដែលមិនទាក់ទិនទៅនឹងល័ក្ខខ័ណ្ឌដទៃទៀតក្នុងកិច្ចសន្យាឡើយ ។ ការសម្រេចរបស់វេទិកាមជ្ឈត្តកម្ម ដែលចាត់ទុកកិច្ចសន្យាថាមោឃៈ និងអសារឥតការមិននាំអោយខចែងស្តីពីការផ្សះផ្សានោះបាត់សុពលភាពឡើយ ។

២-ទឡ្ហីករណ៍ដែលបញ្ជាក់ថា វេទិកាមជ្ឈត្តកម្មពុំមានអំណាចធ្វើមជ្ឈត្តការនោះ ត្រូវបង្ហាញឱ្យឃើញមុនការដាក់ជូនពាក្យដោះសា ។ មិនត្រូវហាមឃាត់ភាគីវិវាទមួយមិនឱ្យលើកឡើងពីទឡ្ហីករណ៍បែបនេះ ដោយសារតែភាគីនោះបានតែងតាំង ឬ បានចូលរួមតែងតាំងមជ្ឈត្តករឡើយ ។ ទឡ្ហីករណ៍ដែលបញ្ជាក់ថា ក្របខ័ណ្ឌជំលោះដែលមានកើតហួសពីក្របខ័ណ្ឌនៃសមត្ថកិច្ចរបស់វេទិកាមជ្ឈត្តកម្មត្រូវបង្ហាញភ្លាមៗនៅពេលដែលបញ្ហាហួសក្របខ័ណ្ឌសមត្ថកិច្ចនេះ ត្រូវបានគេលើកឡើងក្នុងពេលធ្វើមជ្ឈត្តការ ។ ក្នុងចំណោមករណីទាំងពីរ វេទិកាមជ្ឈត្តកម្មអាចទទួលយកទឡ្ហីករណ៍ ដែលលើកឡើងក្រោយរយៈពេលកំណត់ ប្រសិនបើពិចារណាឃើញថា ការយឺតយ៉ាវនេះមានភាពត្រឹមត្រូវ ។

៣-វេទិកាមជ្ឈត្តកម្មអាចធ្វើសេចក្តីសម្រេចលើទឡ្ហីករណ៍ដូចចែងក្នុងកថាខណ្ឌ

ទី ២ នៃមាត្រានេះ ដោយចាត់ទុកថាជាបញ្ហាដំបូង ឬ ថាជាការសម្រេចតាមជាក់ស្តែង ។ ប្រសិនបើវេទិកាមជ្ឈត្តកម្មចាត់ទុកថាជាបញ្ហាដំបូងដែលខ្លួនមានអំណាចសម្រេចនោះ ភាគីណាក៏ដោយ ក៏អាចធ្វើសំណើទៅតុលាការ ( តុលាការពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាការកំពូល ) ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ ឱ្យសម្រេចចុងក្រោយលើបញ្ហានេះក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ ក្រោយពីបានទទួលសេចក្តីជូនដំណឹងពីការសម្រេចនោះរបស់វេទិកា ។ ការសម្រេចរបស់តុលាការក្នុងរឿងនេះគឺជាការសម្រេចដែលមិនអាចតវ៉ាបាន ។ ក្នុងពេលរង់ចាំការសម្រេចពីតុលាការនោះ វេទិកាមជ្ឈត្តកម្មអាចបន្តដំណើរការមជ្ឈត្តការ និងអាចធ្វើមជ្ឈត្តវិនិច្ឆ័យបាន ។

**មាត្រា ២៥.-**

តាមការស្នើសុំរបស់ភាគីវិវាទមួយ វេទិកាមជ្ឈត្តកម្មអាចបង្គាប់ឱ្យភាគីណាមួយចាត់វិធានការបណ្តោះអាសន្នទៅតាមការចាំបាច់ទាក់ទិននឹងកម្មវត្ថុវិវាទ វៀរលែងតែភាគីវិវាទបានព្រមព្រៀងគ្នាផ្សេងពីនេះ ។ វេទិកាមជ្ឈត្តកម្មអាចតម្រូវឱ្យភាគីវិវាទណាមួយបង់ប្រាក់ធានាសមស្របសម្រាប់វិធានការនេះ ។

## ជំពូកទី ៦

## ដំណើរការនៃនីតិវិធីមជ្ឈត្តការ

**មាត្រា ២៦.-**

ភាគីវិវាទត្រូវបានទទួលការយកចិត្តទុកដាក់ស្មើៗគ្នា និងត្រូវបានផ្តល់ឱកាសពេញលេញ ដើម្បីបង្ហាញពីរឿងរ៉ាវរបស់ខ្លួនរួមទាំងសិទ្ធិតែងតាំងជនណាម្នាក់ឱ្យធ្វើជាតំណាងរបស់ខ្លួនបាន ។

**មាត្រា ២៧.-**

ភាគីវិវាទអាចព្រមព្រៀង ឬ មិនព្រមព្រៀងលើនីតិវិធីដែលវេទិកាមជ្ឈត្តកម្ម ត្រូវអនុវត្តដើម្បីចាត់ចែងដំណើរការមជ្ឈត្តការ ។

16/284

ក្នុងករណីគ្មានការព្រមព្រៀងពីនីតិវិធីនេះទេ វេទិកាមជ្ឈត្តកម្មអាចចាត់ចែងការធ្វើមជ្ឈត្តការទៅតាមបែបបទណាដែលវេទិកាយល់ឃើញថាសមស្រប ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។ អំណាចដែលត្រូវបានប្រគល់ឱ្យទៅវេទិកាមជ្ឈត្តកម្មរួមមានអំណាចក្នុងការកំណត់ពីភាពយកជាការបាននៃភស្តុតាងណាមួយ ។

**មាត្រា ២៨.-**

ភាគីវិវាទអាចព្រមព្រៀងពីទីកន្លែងមជ្ឈត្តការ ។ ក្នុងករណីមិនបានព្រមព្រៀងពីទីកន្លែងទេ វេទិកាមជ្ឈត្តកម្មត្រូវកំណត់ទីតាំងដោយគិតគូរពីលក្ខណៈពិសេសនៃវិវាទ ក្នុងនោះត្រូវមានការឯកភាពពីភាគីវិវាទផង ។

ថ្វីបើមានបទប្បញ្ញត្តិក្នុងវាក្យខ័ណ្ឌទី ១ នៃមាត្រានេះក៏ដោយ ក៏វេទិកាមជ្ឈត្តកម្មអាចប្រជុំនៅកន្លែងណាមួយដែលសមស្របក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ ក្នុងបំណងពិគ្រោះយោបល់ក្នុងចំណោមសមាជិករបស់វេទិកា ស្តាប់សាក្សី ស្តាប់អ្នកជំនាញការ ស្តាប់ភាគីវិវាទ ឬ ធ្វើអធិការកិច្ចលើសម្ភារៈ កម្មសិទ្ធិ ឬ ឯកសារដទៃទៀត ។

**មាត្រា ២៩.-**

ដំណើរការមជ្ឈត្តការដែលទាក់ទងនឹងវិវាទណាមួយ ចាប់ផ្តើមឡើងនៅថ្ងៃនៃកាលបរិច្ឆេទ ដែលភាគីឆ្លើយតបបានទទួលសំណើសុំឱ្យធ្វើមជ្ឈត្តការ វៀរលែងតែភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ ។

**មាត្រា ៣០.-**

ភាគីវិវាទអាចព្រមព្រៀងលើភាសាណាមួយ ឬ លើសពីមួយ ដែលត្រូវប្រើប្រាស់ក្នុងដំណើរការធ្វើមជ្ឈត្តការ ។ ក្នុងករណីគ្មានការឯកភាពលើភាសាទេ វេទិកាមជ្ឈត្តកម្មត្រូវកំណត់ភាសាណាមួយ ឬ លើសពីមួយសម្រាប់ប្រើប្រាស់ក្នុងដំណើរការមជ្ឈត្តការ ។

វេទិកាមជ្ឈត្តកម្មអាចបង្គាប់ឱ្យមានការបកប្រែភ្ជាប់ជាមួយនឹងឯកសារ ភស្តុតាង ដោយប្រើប្រាស់ភាសាណាមួយ ឬ លើសពីមួយ ដែលបានឯកភាពដោយភាគីវិវាទ ឬ ដែលបានកំណត់ដោយវេទិកាមជ្ឈត្តកម្ម ។

17/288

**មាត្រា ៣១.-**

នៅក្នុងរយៈពេលដែលឯកភាពដោយភាគីវិវាទ ឬ កំណត់ដោយវេទិកាមជ្ឈត្តកម្ម អ្នកប្តឹងទាមទារត្រូវបញ្ជាក់ពីអង្គហេតុ ដើម្បីគាំទ្រការទាមទាររបស់ខ្លួនព្រមទាំងបញ្ជាក់ពីចំណុចជាក់លាក់នៃបញ្ហា និងសំណងការខូចខាតដែលត្រូវទាមទារ ហើយភាគីឆ្លើយតបត្រូវឆ្លើយបញ្ជាក់ពីការដោះសាលើចំណុចទាំងនេះ វៀរលែងតែភាគីវិវាទបានព្រមព្រៀងថា ក្នុងបណ្តឹងទាមទារ ឬ ការដោះសា ត្រូវបញ្ជាក់ផ្សេងពីនេះ ។ ភាគីវិវាទអាចភ្ជាប់ឯកសារទាំងអស់ដែលយល់ថាទាក់ទងនឹងពាក្យបណ្តឹងទាមទារ ឬ ពាក្យដោះសា ឬ អាចបន្ថែមការយោងលើឯកសារ ឬ ភស្តុតាងដទៃទៀត ដែលភាគីទាំងនោះត្រូវដាក់ជូនវេទិកាមជ្ឈត្តកម្ម ។

វៀរលែងតែភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ ភាគីវិវាទមួយអាចសុំកែសម្រួល ឬ បំពេញបន្ថែមលើពាក្យបណ្តឹងទាមទារ ឬ ពាក្យដោះសារបស់ខ្លួនបាន ក្នុងពេលកំពុងដំណើរការធ្វើមជ្ឈត្តការ លើកលែងតែវេទិកាមជ្ឈត្តកម្មយល់ថា ការសុំពន្យារពេលដើម្បីកែសម្រួលនេះពុំមានលក្ខណៈសមស្រប ។

**មាត្រា ៣២.-**

លើកលែងតែភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ វេទិកាមជ្ឈត្តកម្មត្រូវសម្រេចថា តើត្រូវធ្វើសវនាការដោយផ្ទាល់មាត់ដើម្បីបង្ហាញពីភស្តុតាង ឬ ទឡ្ហីករណ៍ផ្ទាល់មាត់ ឬ ក៏ត្រូវដំណើរការមជ្ឈត្តការដោយផ្អែកលើមូលដ្ឋាននៃឯកសារ ឬ លិខិតស្នាមដទៃទៀត ។ ក៏ប៉ុន្តែ បើមានសំណើពីភាគីវិវាទមួយ វេទិកាមជ្ឈត្តកម្មត្រូវរៀបចំសវនាការបែបនេះ ក្នុងដំណាក់កាលសមស្របណាមួយនៃមជ្ឈត្តការ វៀរលែងតែភាគីវិវាទបានឯកភាពថា មិនត្រូវធ្វើសវនាការ ។

ត្រូវផ្តល់ដំណឹងឱ្យបានគ្រប់គ្រាន់ជាមុនដល់ភាគីវិវាទស្តីពីសវនាការ ឬ ក៏ការប្រជុំណាមួយរបស់វេទិកាមជ្ឈត្តកម្ម ដែលមានគោលបំណងធ្វើអធិការកិច្ចលើសម្ភារៈ ទំនិញ ទ្រព្យសម្បត្តិ និងឯកសារដទៃទៀត ។

រាល់សេចក្តីថ្លែង ឯកសារ ឬ ព័ត៌មានដទៃទៀត ដែលភាគីវិវាទមួយផ្តល់ជូនវេទិកាមជ្ឈត្តកម្ម ក៏ត្រូវបញ្ជូនទៅឱ្យភាគីវិវាទម្ខាងទៀតដែរ ។ របាយការណ៍របស់អ្នកជំនាញការ ឬ

ឯកសារភស្តុតាងណាមួយ ដែលវេទិកាមជ្ឈត្តកម្មអាចយកជាសំអាង ដើម្បីធ្វើការសម្រេច ក៏ត្រូវបញ្ជូនជាដំណឹងឱ្យភាគីវិវាទដែរ ។

**មាត្រា ៣៣.-**

វៀរលែងតែភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ ហើយបើគ្មានការបង្ហាញមូលហេតុគ្រប់គ្រាន់ :

១-វេទិកាមជ្ឈត្តកម្មត្រូវបញ្ឈប់ដំណើរការមជ្ឈត្តការ ក្នុងករណីដែលអ្នកប្តឹងពុំមានបញ្ជាក់លើពាក្យបណ្តឹងទាមទាររបស់ខ្លួនតាមមាត្រា ៣១ នៃ កថាខណ្ឌទី ១ នៃច្បាប់នេះ ។

២-បើភាគីឆ្លើយតបពុំអាចផ្តល់សេចក្តីដោះសាររបស់ខ្លួនដូចចែងក្នុងមាត្រា ៣១ នៃកថាខណ្ឌទី ១ នៃច្បាប់នេះ វេទិកាមជ្ឈត្តកម្មត្រូវបន្តដំណើរការមជ្ឈត្តការដោយពុំចាត់ទុកការខកខាននេះថា ជាការទទួលស្គាល់ពាក្យចោទប្រកាន់របស់ភាគីប្តឹងទាមទារឡើយ ។

៣-បើភាគីវិវាទណាមួយពុំបានបង្ហាញមុខនៅសវនាការ ឬ ពុំបានផ្តល់ឯកសារភស្តុតាង វេទិកាមជ្ឈត្តកម្មអាចបន្តដំណើរការ ហើយធ្វើសេចក្តីសម្រេចដោយផ្អែកលើភស្តុតាងដែលមាននៅចំពោះមុខ ។

**មាត្រា ៣៤.-**

វៀរលែងតែភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ វេទិកាមជ្ឈត្តកម្មអាច :

១-តែងតាំងអ្នកជំនាញការម្នាក់ ឬ ច្រើននាក់ ដើម្បីរាយការណ៍ឱ្យខ្លួនស្តីពីបញ្ហាជាក់លាក់នានា ដែលកំណត់ដោយវេទិកាមជ្ឈត្តកម្ម ។

២-តម្រូវឱ្យភាគីវិវាទមួយផ្តល់ព័ត៌មាន ឬ ឯកសារ ឬ អនុញ្ញាតឱ្យអ្នកជំនាញការពិនិត្យលើឯកសារ សម្ភារៈដែលសមស្របផ្សេងៗដែលទាក់ទងដល់ការធ្វើអធិការកិច្ចរបស់អ្នកជំនាញការ ។

វៀរលែងតែភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ ប្រសិនបើមានភាគីវិវាទមួយស្នើសុំ ឬ វេទិកាមជ្ឈត្តកម្មយល់ថាចាំបាច់ អ្នកជំនាញការបន្ទាប់ពីបានបង្ហាញរបាយការណ៍ផ្ទាល់មាត់ ឬ លាយលក្ខណ៍អក្សររួចហើយ ត្រូវចូលរួមក្នុងសវនាការដែលក្នុងឱកាសនោះ ភាគីវិវាទអាចលើកសំណួរ និងអញ្ជើញជំនាញការផ្សេងទៀត ក្នុងនាមជាសាក្សី ដើម្បីបញ្ជាក់ពីចំណុចជាក់លាក់នៃជម្លោះ ។

4

7/258

មាត្រា ៣៥.–

វេទិកាមជ្ឈត្តកម្ម ឬ ភាគីវិវាទមួយដោយបានការឯកភាពពីវេទិកាមជ្ឈត្តកម្ម អាចស្នើសុំជំនួយពីតុលាការ (តុលាការពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាការកំពូល) ក្នុងការត្រួតពិនិត្យភស្តុតាង ។ តុលាការ (តុលាការពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬតុលាការកំពូល) អាចអនុវត្តតាមសំណើនេះនៅក្នុងវង្វង់សមត្ថកិច្ចរបស់ខ្លួន និងដោយអនុលោមតាមវិធានស្តីពីការត្រួតពិនិត្យភស្តុតាង ។

## ជំពូកទី ៧
## ការធ្វើមជ្ឈត្តវិនិច្ឆ័យរបស់វេទិកាមជ្ឈត្តកម្ម និងការបញ្ចប់ដំណើរការមជ្ឈត្តការ

មាត្រា ៣៦.–

ក្នុងការធ្វើមជ្ឈត្តវិនិច្ឆ័យវេទិកាមជ្ឈត្តកម្មត្រូវ :

១-សម្រេចពីវិវាទមួយទៅតាមវិធាននៃច្បាប់ ដែលជ្រើសរើសដោយភាគីវិវាទ និងដែលអនុវត្តបានចំពោះកម្មវត្ថុនៃវិវាទនេះ ។ ការកំណត់យកច្បាប់ ឬ ប្រព័ន្ធច្បាប់នៃប្រទេសណាមួយដែលត្រូវយកទៅបកស្រាយ គឺមិនត្រូវបកស្រាយដោយសំអាងលើភាពផ្ទុយគ្នានៃច្បាប់ ឬវិធាននៃច្បាប់នោះឡើយ វៀរលែងតែមានការបញ្ជាក់ផ្សេងពីនេះ ។

២-ប្រើប្រាស់ច្បាប់ណាដែលយល់ថាអាចអនុវត្តបាន ក្នុងករណីដែលភាគីវិវាទមិនបានធ្វើការកំណត់លើប្រព័ន្ធច្បាប់ទេនោះ ។

៣-ធ្វើមជ្ឈត្តវិនិច្ឆ័យស្របតាមសមធម៌ ឬ តាមការស្រុះស្រួលតែក្នុងករណីដែលភាគីវិវាទអនុញ្ញាតច្បាស់លាស់ឱ្យធ្វើដូច្នោះ ។

៤-ធ្វើមជ្ឈត្តវិនិច្ឆ័យឱ្យស្របតាមល័ក្ខខ័ណ្ឌនៃកិច្ចសន្យា និងត្រូវយកចិត្តទុកដាក់ផងដែរដល់ទម្លាប់ផ្នែកពាណិជ្ជកម្ម ដែលអនុវត្តបានចំពោះមុខជំនួញនោះ ។

20/28

**មាត្រា ៣៧.-**

ក្នុងដំណើរការមជ្ឈត្តការដែលមានមជ្ឈត្តករលើសពីមួយនាក់ មជ្ឈត្តវិនិច្ឆ័យរបស់វេទិកាមជ្ឈត្តកម្ម ត្រូវធ្វើឡើងតាមមតិភាគច្រើនដោយប្រៀបនៃមជ្ឈត្តករ ដែលជាសមាជិកនៃវេទិកាមជ្ឈត្តកម្ម ។

**មាត្រា ៣៨.-**

មុនពេលចាប់ផ្តើមដំណើរការមជ្ឈត្តការផ្លូវការ វេទិកាមជ្ឈត្តកម្មត្រូវពិភាក្សាជាមួយភាគីវិវាទ ដើម្បីស្វែងរកលទ្ធភាពនៃការដោះស្រាយវិវាទដោយស្ម័គ្រចិត្តរបស់ភាគី :

១-ប្រសិនបើភាគីវិវាទព្រមដោះស្រាយវិវាទដោយស្ម័គ្រចិត្ត វេទិកាមជ្ឈត្តកម្មត្រូវជួយភាគីវិវាទទៅតាមបែបបទដែលសមស្រប ។

២-ប្រសិនបើភាគីវិវាទបានស្រុះស្រួលគ្នាមុនពេលចាប់ផ្តើម ឬ ក្នុងពេលកំពុងធ្វើមជ្ឈត្តការជាផ្លូវការ វេទិកាមជ្ឈត្តកម្មត្រូវបញ្ចប់ដំណើរការ ។ ប្រសិនបើមានការស្នើសុំពីភាគីវិវាទ វេទិកាមជ្ឈត្តកម្មអាចកត់ត្រាទុកការដោះស្រាយនោះ ក្នុងមជ្ឈត្តវិនិច្ឆ័យរបស់វេទិកាមជ្ឈត្តកម្ម ។

៣-មជ្ឈត្តវិនិច្ឆ័យដែលផ្អែកលើការស្រុះស្រួល ត្រូវធ្វើឡើងតាមបទប្បញ្ញត្តិក្នុងមាត្រា ៣៩ នៃច្បាប់នេះ ហើយត្រូវបញ្ជាក់ថាជាមជ្ឈត្តវិនិច្ឆ័យរបស់វេទិកាមជ្ឈត្តកម្ម ។ មជ្ឈត្តវិនិច្ឆ័យនេះមានលក្ខណៈ និង ឥទ្ធិពលដូចមជ្ឈត្តវិនិច្ឆ័យដទៃទៀតដែលវេទិកាមជ្ឈត្តកម្មធ្វើដោយផ្អែកលើភាពជាក់ស្តែងនៃវិវាទដែរ ។

**មាត្រា ៣៩.-**

មជ្ឈត្តវិនិច្ឆ័យត្រូវមានទម្រង់ទ្រាយ និងខ្លឹមសារដូចខាងក្រោម :

១-មជ្ឈត្តវិនិច្ឆ័យរបស់វេទិកាមជ្ឈត្តកម្មត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយត្រូវចុះហត្ថលេខាដោយមជ្ឈត្តករ ។ ក្នុងដំណើរការមជ្ឈត្តការដែលមានមជ្ឈត្តករលើសពីមួយនាក់ ហត្ថលេខារបស់សមាជិកភាគច្រើនក្នុងវេទិកាមជ្ឈត្តកម្មត្រូវចាត់ទុកថាគ្រប់គ្រាន់ ល្គឹកណាមានការបញ្ជាក់ពីមូលហេតុដែលមជ្ឈត្តករដទៃទៀតមិនបានចុះហត្ថលេខា ។

២-មជ្ឈត្តវិនិច្ឆ័យត្រូវបញ្ជាក់ពីមូលហេតុនានាដែលបានយកមកធ្វើជាគោលបង្អែក វៀរលែងតែភាគីវិវាទបានព្រមព្រៀងគ្នាថាមិនចាំបាច់បញ្ជាក់ពីមូលហេតុទេ ឬ វៀរលែងតែ

21/28

មជ្ឈត្តវិនិច្ឆ័យដែលផ្អែកលើការស្រុះស្រួលរបស់ភាគី ដូចមានចែងក្នុងមាត្រា ៣៨ នៃច្បាប់នេះ ។

៣-មជ្ឈត្តវិនិច្ឆ័យត្រូវបញ្ជាក់ពីសោហ៊ុយចំណាយក្នុងការធ្វើមជ្ឈត្តការ ដែលភាគីវិវាទមានចំណែកត្រូវចេញ ក្នុងនោះមានប្រាក់កម្រៃសម្រាប់មជ្ឈត្តករនិងការចំណាយផ្សេងៗ ដែលបានបម្រុងទុកជាមុន ដោយអនុលោមតាមបែបបទដែលព្រមព្រៀងដោយភាគីវិវាទ ឬ អនុលោមតាមការយល់សមស្របរបស់មជ្ឈត្តករ ប្រសិនបើគ្មានការព្រមព្រៀងដោយភាគីទេ ។ មជ្ឈត្តវិនិច្ឆ័យអាចចែងផងដែរពីសោហ៊ុយចំណាយសមស្របសម្រាប់ការពិគ្រោះច្បាប់ ដែលត្រូវសងទៅឱ្យភាគីឈ្នះ ប្រសិនបើភាគីវិវាទបានព្រមព្រៀងដូច្នោះ ឬ មជ្ឈត្តករយល់ថាសមស្រប ។

៤-មជ្ឈត្តវិនិច្ឆ័យត្រូវចែងពីកាលបរិច្ឆេទ និងទីកន្លែងផ្សះផ្សាដូចកំណត់ក្នុងមាត្រា ២៨ កថាខណ្ឌទី ១ នៃច្បាប់នេះ ។ ត្រូវចាត់ទុកទីកន្លែងធ្វើមជ្ឈត្តការជាទីកន្លែងធ្វើមជ្ឈត្ត-វិនិច្ឆ័យ ។

៥-បន្ទាប់ពីធ្វើមជ្ឈត្តវិនិច្ឆ័យរួចហើយ អត្ថបទចម្លងនៃមជ្ឈត្តវិនិច្ឆ័យនោះ ដែលចុះហត្ថលេខាដោយមជ្ឈត្តករតាមបែបបទក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ត្រូវបញ្ជូនទៅឱ្យភាគីវិវាទនីមួយៗ ។

**មាត្រា ៤០.-**

ដំណើរការមជ្ឈត្តការត្រូវបញ្ចប់ដោយធ្វើមជ្ឈត្តវិនិច្ឆ័យជាស្ថាពរ ឬ ដោយដីកាបង្គាប់របស់វេទិកាមជ្ឈត្តកម្មស្របតាមកថាខណ្ឌទី ២ នៃមាត្រានេះ ។

វេទិកាមជ្ឈត្តកម្មចេញដីកាបង្គាប់ដើម្បីបញ្ចប់ដំណើរការមជ្ឈត្តការ នៅក្នុងករណីដែល :

១-ភាគីប្តឹងទាមទារដកពាក្យទាមទាររបស់ខ្លួន វៀរលែងតែភាគីឆ្លើយតបធ្វើការជំទាស់នឹងការដកពាក្យនោះ ហើយវេទិកាមជ្ឈត្តកម្មទទួលស្គាល់ពីអត្ថប្រយោជន៍ស្របច្បាប់របស់ភាគីឆ្លើយតបក្នុងការទទួលដំណោះស្រាយវិវាទជាស្ថាពរ ។

២-ភាគីវិវាទឯកភាពឱ្យបញ្ចប់ដំណើរការមជ្ឈត្តការ ។

៣-វេទិកាមជ្ឈត្តកម្មរកឃើញមូលហេតុផ្សេងទៀត ដែលបញ្ជាក់ពីភាពមិនចាំបាច់សម្រាប់បន្តដំណើរការ ឬ ការធ្វើមជ្ឈត្តការនោះពុំអាចបន្តទៅទៀតកើត ។

អាណត្តិរបស់វេទិកាមជ្ឈត្តកម្មបញ្ចប់ជាមួយនឹងការបញ្ចប់ដំណើរការមជ្ឈត្តការតាមបទប្បញ្ញត្តិនៃមាត្រា ៤១ និងមាត្រា ៤២ កថាខណ្ឌទី ៤ នៃច្បាប់នេះ ។

**មាត្រា ៤១.-**

ការកែតម្រូវនិងការបកស្រាយមជ្ឈត្តវិនិច្ឆ័យត្រូវគោរពតាមល័ក្ខខ័ណ្ឌដូចខាងក្រោម :

១-ក្នុងកំឡុងពេលសាមសិប (៣០) ថ្ងៃ យ៉ាងយូរបន្ទាប់ពីទទួលមជ្ឈត្តវិនិច្ឆ័យ វៀរលែងតែភាគីវិវាទបានព្រមព្រៀងលើរយៈពេលបន្តទៀត :

ក-ភាគីវិវាទមួយដែលបានជូនដំណឹងដល់ភាគីវិវាទម្ខាងទៀតអាចស្នើសុំឱ្យវេទិកាមជ្ឈត្តកម្មកែតម្រូវកំហុសផ្នែកគណនា កំហុសផ្នែកការងារលេខាធិការ និងកំហុសនៃការបោះពុម្ព ឬ កំហុសដទៃទៀត ដែលមានលក្ខណៈស្រដៀងគ្នា ។

ខ-ភាគីវិវាទមួយដែលបានជូនដំណឹងដល់ភាគីវិវាទម្ខាងទៀត អាចស្នើសុំឱ្យវេទិកាមជ្ឈត្តកម្មផ្តល់ការបកស្រាយ ឬ ការបំភ្លឺលម្អិតពីចំណុច ឬ ផ្នែកណាមួយនៃមជ្ឈត្តវិនិច្ឆ័យ ប្រសិនបើភាគីវិវាទបានព្រមព្រៀងដូច្នេះ ។ ប្រសិនបើយល់ថាសំណើនោះសមស្របវេទិកាមជ្ឈត្តកម្មត្រូវបកស្រាយ ឬ បំភ្លឺលម្អិតក្នុងរយៈពេលយ៉ាងយូរសាមសិប (៣០) ថ្ងៃ បន្ទាប់ពីទទួលសំណើ ។ ការបកស្រាយ ឬ ការបំភ្លឺលម្អិតនោះ ត្រូវបញ្ចូលជាផ្នែកមួយនៃមជ្ឈត្តវិនិច្ឆ័យ ។

២-ក្នុងរយៈពេលសាមសិប (៣០) ថ្ងៃយ៉ាងយូរ ក្រោយកាលបរិច្ឆេទចេញមជ្ឈត្តវិនិច្ឆ័យរបស់វេទិកាមជ្ឈត្តកម្មអាចកែតម្រូវកំហុសដូចដែលចែងក្នុងកថាខណ្ឌទី ១ក នៃមាត្រានេះ ទៅតាមគំនិតផ្តួចផ្តើមរបស់ខ្លួនផ្ទាល់ ។

៣-វៀរលែងតែភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ ក្នុងរយៈពេលយ៉ាងយូរសាមសិប (៣០) ថ្ងៃ ក្រោយពីទទួលបានមជ្ឈត្តវិនិច្ឆ័យ ភាគីវិវាទមួយដែលបានជូនដំណឹងដល់ភាគីវិវាទម្ខាងទៀត អាចស្នើសុំឱ្យវេទិកាមជ្ឈត្តការធ្វើមជ្ឈត្តវិនិច្ឆ័យបន្ថែម ដូចជាដោយសារការទាមទារនានា ដែលលើកឡើងក្នុងដំណើរការមជ្ឈត្តការនោះ មិនបានដាក់ចូលទៅក្នុងមជ្ឈត្តវិនិច្ឆ័យ ។ ប្រសិនបើយល់ឃើញថាសំណើនោះសមស្របវេទិកាមជ្ឈត្តកម្ម ត្រូវធ្វើមជ្ឈត្តវិនិច្ឆ័យបន្ថែមក្នុងរយៈពេលយ៉ាងយូរសាមសិប (៣០) ថ្ងៃ ។

23/28

៤-ប្រសិនបើចាំបាច់ និងដោយបានជូនដំណឹងដល់ភាគីវិវាទ វេទិកាមជ្ឈត្តកម្ម អាចពន្យារយៈពេលដែលកំណត់សម្រាប់ការកែតម្រូវការបកស្រាយ ការបំភ្លឺលម្អិត ឬ ការធ្វើមជ្ឈត្តវិនិច្ឆ័យបន្ថែមតាមកថាខណ្ឌទី ១ និងកថាខណ្ឌទី ៣ នៃមាត្រានេះ ។

៥-បទប្បញ្ញត្តិនានានៃមាត្រា ៣៩ នៃច្បាប់នេះ ត្រូវយកទៅអនុវត្តសម្រាប់កែតម្រូវការបកស្រាយ ឬ ការបំភ្លឺលម្អិតលើមជ្ឈត្តវិនិច្ឆ័យ ឬ ការចេញមជ្ឈត្តវិនិច្ឆ័យបន្ថែម ។

## ជំពូកទី ៨
## ការប្តឹងជំទាស់ ការទទួលស្គាល់
## និង ការដាក់ឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យ

### ផ្នែកទី១
### ស្ថាប័នមានសមត្ថកិច្ចក្នុងការប្តឹងជំទាស់
### ការទទួលស្គាល់ និងការដាក់ឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យ

**មាត្រា ៤២.-**

សេចក្តីសម្រេចលើការប្តឹងជំទាស់ ការទទួលស្គាល់ និងការដាក់ឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យ ជាសមត្ថកិច្ចរបស់សាលាឧទ្ធរណ៍នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤៣.-**

តុលាការកំពូលជាសាលាជំនុំជម្រះក្តីចុងក្រោយ ដែលមានសមត្ថកិច្ចជំនុំជម្រះបណ្តឹងជំទាស់របស់ភាគីវិវាទ ដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ក្នុងរយៈពេលដប់ប្រាំថ្ងៃ (១៥) ថ្ងៃ ។

### ផ្នែកទី ២
### បណ្តឹងជំទាស់ទៅនឹងមជ្ឈត្តវិនិច្ឆ័យ

**មាត្រា ៤៤.-**

ភាគីវិវាទអាចប្តឹងជំទាស់ទៅនឹងមជ្ឈត្តវិនិច្ឆ័យតាមទម្រង់ទ្រាយជាបណ្តឹងបដិសេធ និងតាមបែបបទដូចខាងក្រោម :

ᔑ

24/28 ℛ

១-បណ្តឹងបដិសេធទៅនឹងមជ្ឈត្តវិនិច្ឆ័យតាមផ្លូវតុលាការ អាចធ្វើទៅបានលុះត្រាតែស្របតាមល័ក្ខខ័ណ្ឌ ដូចមានចែងក្នុងវាក្យខ័ណ្ឌទី ២ និងវាក្យខ័ណ្ឌទី ៣ នៃមាត្រានេះ ។

២-សាលាឧទ្ធរណ៍ និង តុលាការកំពូលអាចបដិសេធមជ្ឈត្តវិនិច្ឆ័យរបស់មជ្ឈត្តករ បានក្នុងករណី :

ក-ភាគីដែលដាក់ពាក្យសុំបដិសេធបានផ្តល់ភស្តុតាងគ្រប់គ្រាន់ថា :

ក.១-ភាគីមួយនៃកិច្ចព្រមព្រៀងផ្សះផ្សាដូចមានយោងក្នុងមាត្រា ៧ នៃច្បាប់នេះ បានបាត់បង់សិទ្ធិមួយចំនួនខាងផ្លូវច្បាប់ ឬ កិច្ចព្រមព្រៀងផ្សះផ្សានោះ ពុំអាចយកជាការបាន បើយោងតាមច្បាប់ដែលភាគីវិវាទបានសំអាង ឬ កិច្ចព្រមព្រៀងផ្សះផ្សាពុំបានគោរពតាមបញ្ញត្តិណាមួយនៃច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

ក.២-ភាគីដែលដាក់ពាក្យសុំបដិសេធនោះ មិនបានទទួលដំណឹងត្រឹមត្រូវពីការតែងតាំងមជ្ឈត្តករ ឬ ពីដំណើរការមជ្ឈត្តការ ឬ ភាគីនេះពុំអាចបង្ហាញពីអង្គហេតុរបស់ខ្លួនបានដោយប្រសិទ្ធភាព ។

ក.៣-មជ្ឈត្តវិនិច្ឆ័យដែលទាក់ទិននឹងវិវាទនោះពុំឆ្លើយតប ឬ ពុំគោរពល័ក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀងផ្សះផ្សា ។ ប្រសិនបើបញ្ហាដែលដាក់ឱ្យធ្វើមជ្ឈត្តការនោះ អាចផ្តាច់ចេញពីបញ្ហាដែលមិនបានដាក់ឱ្យធ្វើមជ្ឈត្តការ ការបដិសេធអាចធ្វើទៅបានតែត្រង់ផ្នែកមួយនៃមជ្ឈត្តវិនិច្ឆ័យ លើបញ្ហាដែលបានដាក់ឱ្យធ្វើមជ្ឈត្តការពីមុនប៉ុណ្ណោះ ។

ក.៤-ការបង្កើតវេទិកាមជ្ឈត្តកម្ម ឬ ដំណើរការមជ្ឈត្តការ ពុំស្របនឹងកិច្ចព្រមព្រៀងរបស់ភាគីវិវាទ ក្នុងករណីដែលកិច្ចព្រមព្រៀងនោះស្របតាមបទបញ្ញត្តិនៃច្បាប់នេះ ។ ក្នុងករណីដែលគ្មានកិច្ចព្រមព្រៀងផ្សះផ្សាទេ ការបង្កើតវេទិកាមជ្ឈត្តកម្ម ឬ ដំណើរការមជ្ឈត្តការខាងលើមិនសមស្របតាមច្បាប់នេះ ។

ខ-សាលាឧទ្ធរណ៍ និង តុលាការកំពូលរកឃើញថា :

ខ.១- កម្មវត្ថុនៃវិវាទនោះ ពុំអាចដោះស្រាយបានតាមរយៈការធ្វើមជ្ឈត្តការឡើយ បើយោងទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

ខ.២-មជ្ឈត្តវិនិច្ឆ័យនោះផ្ទុយនឹងនយោបាយសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ។

25/2ក

៣-ការដាក់ពាក្យសុំបដិសេធមិនអាចធ្វើបានឡើយ បើរយៈពេលបានកន្លងផុតសាមសិប (៣០) ថ្ងៃ គិតពីថ្ងៃដែលភាគីសុំបដិសេធនោះទទួលបានមជ្ឈត្តវិនិច្ឆ័យ ឬ ប្រសិនបើសំណើនោះធ្វើឡើងតាមមាត្រា ៤១ នៃច្បាប់នេះ រយៈពេលសាមសិប (៣០) ថ្ងៃ គិតពីកាលបរិច្ឆេទដែលវេទិកាមជ្ឈត្តកម្មបានដោះស្រាយលើសំណើនោះ ។

៤-នៅពេលទទួលដំណឹងបដិសេធមជ្ឈត្តវិនិច្ឆ័យ បើមានលក្ខណៈសមស្របហើយមានសំណើពីភាគីមួយ សាលាឧទ្ធរណ៍ និង តុលាការកំពូលអាចផ្អាកដំណើរការបដិសេធនេះ នៅក្នុងរយៈពេលមួយដែលកំណត់ដោយសាលាឧទ្ធរណ៍ និង តុលាការកំពូល ដើម្បីផ្តល់ឱកាសដល់វេទិកាមជ្ឈត្តកម្មធ្វើដំណើរការមជ្ឈត្តការឡើងវិញ ឬ ចាត់វិធានការមួយតាមការយល់ឃើញរបស់វេទិកាថា អាចនឹងលុបបំបាត់មូលហេតុនៃការសុំបដិសេធនោះបាន ។

## ជំពូកទី ៣

## ការទទួលស្គាល់ និងការដាក់ឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យ

### មាត្រា ៤៥.-

មជ្ឈត្តវិនិច្ឆ័យ ទោះជាបានធ្វើនៅប្រទេសណាក៏ដោយត្រូវបានគេទទួលស្គាល់ថាជាកាតព្វកិច្ច ហើយបន្ទាប់ពីបានដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរទៅសាលាឧទ្ធរណ៍រួចមក ត្រូវបានអនុវត្តដោយយោងតាមបទប្បញ្ញត្តិក្នុងមាត្រានេះ និងមាត្រា ៤៤ ។

ភាគីដែលសំអាងលើមជ្ឈត្តវិនិច្ឆ័យ ឬ ដែលដាក់ពាក្យសុំឱ្យមានការអនុវត្តមជ្ឈត្តវិនិច្ឆ័យ ត្រូវផ្តល់ច្បាប់ដើមត្រឹមត្រូវពិតប្រាកដនៃមជ្ឈត្តវិនិច្ឆ័យ និងច្បាប់ដើមនៃកិច្ចព្រមព្រៀងផ្សះផ្សាដូចចែងក្នុងមាត្រា ៧ នៃច្បាប់នេះ ឬ អត្ថបទថតចម្លងដែលបញ្ជាក់ថាបានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។ ប្រសិនបើមជ្ឈត្តវិនិច្ឆ័យ ឬ កិច្ចព្រមព្រៀងនោះមិនបានធ្វើជាភាសាខ្មែរទេ ភាគីនោះត្រូវផ្តល់សេចក្តីបកប្រែជាភាសាខ្មែរ ដែលមានការបញ្ជាក់ត្រឹមត្រូវតាមច្បាប់ដើម ។

### មាត្រា ៤៦.-

ទោះបីជាមជ្ឈត្តវិនិច្ឆ័យធ្វើនៅប្រទេសណាក៏ដោយ ការជំទាស់ទៅនឹងការទទួលស្គាល់ ឬ ជំទាស់ទៅនឹងការដាក់ឱ្យអនុវត្តនូវមជ្ឈត្តវិនិច្ឆ័យ អាចធ្វើបានតែក្នុងករណី :

26/28A/

១-អនុវត្តន៍តាមសំណើរបស់ភាគីជំទាស់ទៅនឹងមជ្ឈត្តវិនិច្ឆ័យ ដោយភាគីនោះផ្តល់ភស្តុតាងដល់សាលាឧទ្ធរណ៍ថា :

ក-ភាគីមួយនៃកិច្ចព្រមព្រៀងផ្សះផ្សាដូចបានយោងក្នុងមាត្រា ៧ បានបាត់បង់សិទ្ធិមួយចំនួនខាងផ្លូវច្បាប់ ឬ កិច្ចព្រមព្រៀងនោះពុំអាចយកជាការបាន បើយោងតាមច្បាប់ដែលភាគីវិវាទបានសំអាង ឬ កិច្ចព្រមព្រៀងផ្សះផ្សាពុំបានគោរពតាមការកំណត់ណាមួយនៃច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ឬ

ខ-ភាគីដែលជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យនោះ ពុំទទួលបានព័ត៌មានត្រឹមត្រូវពីការតែងតាំងមជ្ឈត្តករ ឬ ពីដំណើរការមជ្ឈត្តការពុំអាចបង្ហាញពីករណីរបស់ខ្លួនបានដោយប្រសិទ្ធភាព ឬ

គ-មជ្ឈត្តវិនិច្ឆ័យដែលទាក់ទងនឹងវិវាទនោះពុំឆ្លើយតប ឬ ពុំគោរពល័ក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀងផ្សះផ្សា ឬ ក៏បញ្ហាដែលបានសម្រេចនោះហួសពីក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងផ្សះផ្សា ។ ប្រសិនបើការសម្រេចលើបញ្ហាដែលបានដាក់ជូនឱ្យផ្សះផ្សា អាចផ្តាច់ចេញពីបញ្ហាដែលពុំបានដាក់ឱ្យផ្សះផ្សានោះ ផ្នែកមួយនៃមជ្ឈត្តវិនិច្ឆ័យលើបញ្ហាដែលបានដាក់ជូនអាចត្រូវគេទទួលស្គាល់ និងដាក់អោយអនុវត្ត ឬ

ឃ-ការបង្កើតវេទិកាមជ្ឈត្តកម្ម ឬ ដំណើរការមជ្ឈត្តការពុំសមស្របជាមួយនឹងកិច្ចព្រមព្រៀងរបស់ភាគីវិវាទ ឬ ប្រសិនបើគ្មានកិច្ចព្រមព្រៀងផ្សះផ្សានោះទេ ការបង្កើតវេទិកាមជ្ឈត្តកម្ម ឬ ដំណើរការមជ្ឈត្តការ គឺពុំសមស្របទៅនឹងច្បាប់នៃប្រទេសដែលការផ្សះផ្សាបានប្រព្រឹត្តទៅ ឬ

ង-មជ្ឈត្តវិនិច្ឆ័យនោះពុំទាន់បានក្លាយទៅជាកាតព្វកិច្ចនៅឡើយសម្រាប់ភាគីវិវាទ បើយោងតាមច្បាប់នៃប្រទេសដែលធ្វើសេចក្តីសម្រេចនោះ ឬ ម្យ៉ាងទៀតមជ្ឈត្តវិនិច្ឆ័យត្រូវបានបដិសេធ ឬ ព្យួរទុក ដោយតុលាការនៃប្រទេសដែលធ្វើមជ្ឈត្តវិនិច្ឆ័យ ឬ

២-ប្រសិនបើសាលាឧទ្ធរណ៍រកឃើញថា :

ក-កម្មវត្ថុនៃវិវាទនោះ ពុំអាចដោះស្រាយបានតាមការធ្វើមជ្ឈត្តការឡើយ បើយោងតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ឬ

ខ-ការទទួលស្គាល់មជ្ឈត្តវិនិច្ឆ័យនោះ អាចផ្ទុយនឹងនយោបាយសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ។

បើមានការសុំឱ្យសាលាឧទ្ធរណ៍បដិសេធ ឬ ព្យួរទុកមជ្ឈត្តវិនិច្ឆ័យ ដូចមានចែងក្នុងកថាខណ្ឌទី ១ (ង) នៃមាត្រានេះ ហើយប្រសិនបើសាលាឧទ្ធរណ៍យល់ថាត្រឹមត្រូវ សាលាឧទ្ធរណ៍ដែលភាគីវិវាទស្នើសុំការទទួលស្គាល់ ឬ ការអនុវត្តមជ្ឈត្តវិនិច្ឆ័យនោះ អាចបញ្ឈប់ការសម្រេចរបស់ខ្លួន ហើយអាចបញ្ជាឱ្យភាគីវិវាទម្ខាងទៀតផ្តល់ការធានាសមស្របទៅតាមសំណូមពររបស់ភាគីដែលសុំឱ្យមានការទទួលស្គាល់ ឬ ការអនុវត្តមជ្ឈត្តវិនិច្ឆ័យ ។

## ជំពូកទី ៩

## អវសានប្បញ្ញត្តិ

**មាត្រា ៤៧.-**

បទប្បញ្ញត្តិទាំងឡាយណាក្នុងវិស័យមជ្ឈត្តការពាណិជ្ជកម្មដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ៥ ខែឧសភា ឆ្នាំ ២០០៦

នស/រកម.០៥០៦/០១៨ **ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ហត្ថលេខា**

**ចម ប្រសិទ្ធ**

លេខៈ ៧០៩ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញថ្ងៃទី ១៥ ខែឧសភា ឆ្នាំ២០០៦

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាងី តាត់

5/25/4

# ច្បាប់

# ស្ដីពី

# ការរៀបចំអង្គការតុលាការ

ROYAUME DU CAMBODGE
LE MINISTÈRE DU PALAIS ROYAL

រដ្ឋសភា

ចូល លេខ [illegible]
ថ្ងៃទី [illegible] ឆ្នាំ២០១[illegible] ម៉ោង [illegible]
បញ្ជូនទៅ [illegible]

# ព្រះរាជក្រម

នស/រកម/០៧១៤/០១៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីការរៀបចំអង្គការតុលាការ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៤ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៤ នាសម័យប្រជុំលើកទី៥ នីតិកាលទី៣ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របតាមនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ១៤៥/០០៣/២០១៤ កបធ.ច ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅៈ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ឡាយណាដែលពុំមានបទប្បញ្ញត្តិណាមួយ ប្រគល់សមត្ថកិច្ចទៅឲ្យតុលាការជំនាញផ្សេងទៀត ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណី ។

តុលាការរដ្ឋប្បវេណីនៃសាលាដំបូងជំនុំជម្រះរឿងក្តីរដ្ឋប្បវេណីដោយមានចៅក្រមទោល ឬដោយមានក្រុមប្រឹក្សាជំនុំជម្រះ ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណី ។

## មាត្រា ២២.-

តុលាការពាណិជ្ជកម្មនៃសាលាដំបូង មានសមត្ថកិច្ចជំនុំជម្រះរឿងក្តីពាណិជ្ជកម្ម ដោយរួមទាំងរឿងក្តីក្ស័យធនក្នុងរឿងពាណិជ្ជកម្ម ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីពាណិជ្ជកម្ម ។

## មាត្រា ២៣.-

តុលាការពាណិជ្ជកម្មជំនុំជម្រះដោយមានចៅក្រម ០៣ (បី) រូប និងអមដោយទីប្រឹក្សា ០២ (ពីរ) រូប ជាពាណិជ្ជករ ឬអ្នកដែលមានចំណេះដឹងផ្នែកច្បាប់ពាណិជ្ជកម្មក្នុងករណីរឿងក្តីពាណិជ្ជកម្មដែលកម្មវត្ថុបណ្តឹងមានតម្លៃចាប់ពី ១.០០០.០០០.០០០ (មួយពាន់លាន) រៀល ឡើងទៅ ។

តុលាការពាណិជ្ជកម្មជំនុំជម្រះដោយមានចៅក្រម ០១ (មួយ) រូប និងអមដោយទីប្រឹក្សា ០២ (ពីរ) រូប ជាពាណិជ្ជករ ឬអ្នកដែលមានចំណេះដឹងផ្នែកច្បាប់ពាណិជ្ជកម្មក្នុងករណីរឿងក្តីពាណិជ្ជកម្មដែលកម្មវត្ថុបណ្តឹងមានតម្លៃចាប់ពី ១០០.០០០.០០០ (មួយរយលាន) រៀល ដល់ក្រោម ១.០០០.០០០.០០០ (មួយពាន់លាន) រៀល ។

តុលាការពាណិជ្ជកម្មជំនុំជម្រះដោយចៅក្រម ០១ (មួយ) រូប ដោយមិនចាំបាច់មានការចូលរួមពីទីប្រឹក្សាពាណិជ្ជកម្មឡើយក្នុងករណីរឿងក្តីពាណិជ្ជកម្ម ដែលកម្មវត្ថុបណ្តឹងមានតម្លៃក្រោម ១០០.០០០.០០០ (មួយរយលាន) រៀល ។

សាលក្រមរបស់តុលាការពាណិជ្ជកម្មត្រូវសម្រេចដោយចៅក្រម ០១ (មួយ) រូប ឬ ០៣ (បី) រូប យោងទៅតាមកថាខណ្ឌទី ១ និងទី ២ ខាងលើនេះ ក្រោយពីបានពិគ្រោះយោបល់ជាមួយទីប្រឹក្សាពាណិជ្ជកម្ម ។

ទីប្រឹក្សាពាណិជ្ជកម្មមិនបំពេញមុខងាររបស់ខ្លួនជាអចិន្ត្រៃយ៍ នៅក្នុងតុលាការពាណិជ្ជកម្មនៃសាលាដំបូងឡើយ ។ ទីប្រឹក្សាពាណិជ្ជកម្មត្រូវចូលមកបំពេញមុខងាររបស់ខ្លួននៅសាលាដំបូងតាមការអញ្ជើញរបស់ប្រធានតុលាការពាណិជ្ជកម្មនៃសាលាដំបូង ។

## មាត្រា ២៤.-

របៀបនៃការជ្រើសតាំង និងការបំពេញភារកិច្ចរបស់ទីប្រឹក្សាពាណិជ្ជកម្ម ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

## ជំពូកទី ៨
## អវសានប្បញ្ញត្តិ

**មាត្រា ៩១.-**

បទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ សំរាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាលចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ និងច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជាដែលប្រកាសឲ្យប្រើដោយក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ព្រមទាំងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ហើយត្រូវជំនួសដោយច្បាប់នេះ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៤

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/រកម/០៧១៤/០១៦

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**ហត្ថលេខា**

**អង្គ វង្សវឌ្ឍានា**

លេខៈ ៩០៣ ស.ណ

**សំណៅដើមមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុយ សុខា**

# ព្រះរាជក្រម

នស/រកម/០៧០៦/០២១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមនីតិវិធីរដ្ឋប្បវេណី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានកែប្រែអ្វីឡើយ កាលពីថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០០៦នាសម័យប្រជុំពេញអង្គលើកទី១នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ង-កាលណាចៅក្រមបានធ្វើជាសាក្សី ឬ ធ្វើជាអ្នកជំនាញក្នុងរឿងក្តី ។

ច-កាលណាចៅក្រមជាអ្នកតំណាង ឬ ធ្លាប់ជាអ្នកតំណាង ឬ ជាអ្នកជំនួយឱ្យភាគីចំពោះរឿងក្តី ។

ឆ-កាលណាចៅក្រមបានចូលរួមក្នុងការសម្រេចសេចក្តីមជ្ឈត្តករចំពោះរឿងក្តី ឬ បានចូលរួមក្នុងការសម្រេចសេចក្តីនៅក្នុងការជំនុំជម្រះលើកទី ១ ដែលបានឧបាស្រ័យ ឬ ការជំនុំជម្រះនៃបណ្តឹងឧទ្ធរណ៍ដែលបានឧបាស្រ័យ ឬ បង្ហាញមតិយោបល់ណែនាំផ្នែកច្បាប់ ចំពោះរឿងក្តី ។

២-ក្នុងករណីដូចមានមូលហេតុនៃការដកហូត ដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការត្រូវសម្រេចសេចក្តីអំពីការដកហូតនោះ តាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ។

**មាត្រា ២៨.–** បណ្តឹងជិតចិត្តចៅក្រម

១-ក្នុងករណីដែលមានកាលៈទេសៈដែលបណ្តាលឱ្យមានការលំអៀងក្នុងការជម្រះក្តី ចំពោះចៅក្រមណាម្នាក់ នោះភាគីអាចប្តឹងជិតចិត្តចៅក្រមនោះបាន ។

២-ក្នុងករណីដែលភាគីបានឆ្លើយទាញហេតុផលចំពោះមុខចៅក្រម ឬ បានធ្វើសេចក្តីដោះសានៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលចំពោះមុខចៅក្រមរួចហើយ នោះភាគីមិនអាចប្តឹងជិតចិត្តចៅក្រមនោះបានឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលភាគីនោះមិនបានដឹងអំពីមូលហេតុដែលអាចប្តឹងជិតចិត្ត ឬ ករណីដែលមូលហេតុនៃបណ្តឹងជិតចិត្តបានកើតឡើងនៅពេលក្រោយ ។

**មាត្រា ២៩.–** ការដកខ្លួនរបស់ចៅក្រម

ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ២៧ (ការដកហូតចៅក្រមពីសមត្ថកិច្ចជំនុំជម្រះ) ឬ កថាខណ្ឌទី ១ នៃមាត្រា ២៨ (បណ្តឹងជិតចិត្តចៅក្រម) នៃក្រមនេះ ចៅក្រមអាចដកខ្លួនបាន ដោយទទួលការអនុញ្ញាតពីប្រធានតុលាការដែលខ្លួនស្ថិតនៅក្រោម ។

**មាត្រា ៣០.–** ការសម្រេចសេចក្តីអំពីពាក្យសុំដកហូត ឬ បណ្តឹងជិតចិត្ត

១-ចំពោះការដកហូតចៅក្រម ឬ បណ្តឹងជិតចិត្តចំពោះចៅក្រម ក្រុមប្រឹក្សាជំនុំជម្រះ

## គន្ថីទី ៩

## អវសានប្បញ្ញត្តិ

### ជំពូកតែមួយ

### អវសានប្បញ្ញត្តិ

**មាត្រា ៥៨៧.-** ការអនុវត្តក្រមនេះ

ក្រោយពីចូលជាធរមាន ក្រមនេះត្រូវផ្សព្វផ្សាយរយៈពេល ១ ( មួយ ) ឆ្នាំ ទើបអនុវត្ត ។

**មាត្រា ៥៨៨.-** ការធ្វើឱ្យនិរាករណ៍នូវច្បាប់ផ្សេង ជាអាទិ៍

១-ច្បាប់ដែលបានកំណត់ដូចខាងក្រោមនេះ ត្រូវបាត់បង់អានុភាព ចាប់ពីថ្ងៃដែលក្រមនេះត្រូវបានអនុវត្ត :

ក-ច្បាប់ស្តីអំពីវិធីអនុវត្តសាលក្រមរដ្ឋប្បវេណីដែលត្រូវបានប្រកាសឱ្យប្រើដោយក្រឹត្យលេខ ៥១ ក្រ ចុះថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ១៩៩២ ។

ខ-ច្បាប់ស្តីពីប្រាក់ប្រដាប់ក្តី ដែលត្រូវបានប្រកាសឱ្យប្រើដោយក្រឹត្យលេខ ០៧ ក្រ ចុះថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

២-បញ្ញត្តិនៃច្បាប់ផ្សេងទៀត ដែលមានអានុភាពនៅពេលក្រមនេះត្រូវបានអនុវត្ត ហើយផ្ទុយនឹងបញ្ញត្តិនៃក្រមនេះ ត្រូវចាត់ទុកថា គ្មានអានុភាព ត្រឹមទំហំដែលផ្ទុយនឹងក្រមនេះ ចាប់ពីថ្ងៃដែលក្រមនេះត្រូវបានអនុវត្ត ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ៦ ខែ កក្កដា ឆ្នាំ ២០០៦

នស/រកម.០៧០៦.៣១០ **ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**ហត្ថលេខា**

**អង្គ វង្សវឌ្ឍានា**

លេខ : ៤៨៣ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ.ថ្ងៃទី ១០ ខែកក្កដាឆ្នាំ២០០៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឃុន ឌឺនកេន**

# ព្រះរាជក្រម

នស/រកម/១២០៧/០៣០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**

**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**

**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមរដ្ឋប្បវេណី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្រប តាមទម្រង់ និងគតិនៃក្រមនេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៤ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ខាត ដោយអ្នកដែលបានទទួលរងនូវការរំលោភផលប្រយោជន៍ទាក់ទងនឹងលក្ខណបុគ្គល នោះ ដោយយោងទៅតាមបញ្ញត្តិស្តីពីអំពើអនីត្យានុកូលបានឡើយ ។

## ផ្នែកទី ៣
## សមត្ថភាពខាងឆន្ទៈ

**មាត្រា ១៤.–** ការខ្វះសមត្ថភាពខាងឆន្ទៈ

សកម្មភាពដែលភាគីបានធ្វើនៅក្នុងស្ថានភាពដែលខ្លួនមិនអាចយល់ដឹង និងវិនិច្ឆ័យបាន អំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន អាចលុបចោលបាន ។

**មាត្រា ១៥.–** និយមន័យនៃសកម្មភាព

ពាក្យ “សកម្មភាព” ដែលត្រូវបានប្រើនៅក្នុងផ្នែកទី ៣ (សមត្ថភាពខាងឆន្ទៈ) ផ្នែកទី ៤ (សមត្ថភាពក្នុងការធ្វើសកម្មភាព) និង ផ្នែកទី ៦ (ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់បុគ្គលដែលអវត្តមាន និង ការប្រកាសអំពីការបាត់ខ្លួន) នៃជំពូកទី ១ នេះ សំដៅទៅលើកិច្ចសន្យា និង សកម្មភាពឯកតោភាគី ។

## ផ្នែកទី ៤
## សមត្ថភាពក្នុងការធ្វើសកម្មភាព

**មាត្រា ១៦.–** អត្ថន័យនៃជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព

ជនដែលត្រូវបានកម្រិតសមត្ថភាព សំដៅទៅលើអនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ និង ជននៅក្រោមហិតូបត្ថម្ភ ។

### កថាភាគទី ១
### អនីតិជន

**មាត្រា ១៧.–** អត្ថន័យនៃអនីតិជន

អនីតិជន សំដៅទៅលើជនដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ។

## គន្ថីទី ៩

## អវសានប្បញ្ញត្តិ

### ជំពូកទោល

### អវសានប្បញ្ញត្តិ

**មាត្រា ១៣០៥.– កាលបរិច្ឆេទនៃការអនុវត្ត ជាអាទិ៍**

១-ក្រមនេះ ត្រូវអនុវត្ត ចាប់តាំងពីថ្ងៃដែលកំណត់ផ្សេងដោយច្បាប់ ។

២-ចំពោះវិធានការអន្តរកាលដែលទាក់ទងនឹងការអនុវត្តក្រមនេះ និងចំណុចចាំបាច់ផ្សេងទៀតដែលទាក់ទងនឹងការអនុវត្តក្រមនេះ ត្រូវកំណត់ផ្សេងដោយច្បាប់ ។

រាជធានីភ្នំពេញថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧

ក្នុងព្រះបរមនាម និងតាមព្រះរាជបន្ទូលបង្គាប់

**ប្រមុខរដ្ឋស្តីទី**

ពរល.០៧១២.៦២២ **ហត្ថលេខា និងព្រះរាជលញ្ចករ**

**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ហត្ថលេខា**

**អង្គ វង្សវឌ្ឍនា**

លេខ:៥៧៤ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ២០០៧

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**យុន ជិនគេន**

២០

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៦៤ អនក្រ.បក

4334
14 08 9

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

ថតចម្លង

នាយកដ្ឋាន.រដ្ឋបាល.

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១០ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែសីហា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៩

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះកំណត់ពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ។

មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលសរសេរកាត់ថា **ម.ជ.ម.** ជាអង្គភាពមិនស្វែងរកប្រាក់ចំណេញ និងមានទីស្នាក់ការនៅរាជធានីភ្នំពេញ ។

## ជំពូកទី២

## តួនាទីនិងភារកិច្ច

**មាត្រា២.-**

**ម.ជ.ម.** មានតួនាទីនិងភារកិច្ចដូចខាងក្រោម ÷

- ជំរុញវិស័យមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ផ្តល់ការបណ្តុះបណ្តាលនិងហ្វឹកហ្វឺនបុគ្គលដែលកំពុងអនុវត្តនិងបុគ្គលដែលមានបំណងអនុវត្តវិជ្ជាជីវៈ ជាមជ្ឈត្តករ ដើម្បីធានាឱ្យមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាមានគុណភាពខ្ពស់
- កំណត់ពីលក្ខណសម្បត្តិនៃបុគ្គល ដែលមានបំណងចូលជាសមាជិក **ម.ជ.ម.**
- ផ្តល់សេវាដោះស្រាយវិវាទផ្នែកពាណិជ្ជកម្មក្រៅប្រព័ន្ធតុលាការ
- រៀបចំសន្និសីទថ្នាក់ជាតិនិងអន្តរជាតិ ក្នុងគោលដៅជំរុញវិស័យមជ្ឈត្តការផ្នែកពាណិជ្ជកម្ម
- រៀបចំ ចូលរួមសិក្ខាសាលានិងវគ្គសិក្សា លើប្រធានបទទាក់ទងនឹងមជ្ឈត្តការផ្នែកពាណិជ្ជកម្ម
- ប្រមូល បោះពុម្ព និងផ្សព្វផ្សាយព័ត៌មាន អត្ថបទនិពន្ធ សៀវភៅនិងឯកសារ សោតទស្សន៍ឬប្រហ្វូណូក្រាម ដែលទាក់ទងនឹងមជ្ឈត្តការផ្នែកពាណិជ្ជកម្ម
- គ្រប់គ្រងនិងចាត់ចែងទ្រព្យសម្បត្តិ **ម.ជ.ម.**
- រៀបចំបណ្ណាល័យនិងបន្ទប់ផ្សេងៗ សម្រាប់បម្រើសេវាទាក់ទងនឹងមជ្ឈត្តការផ្នែកពាណិជ្ជកម្ម
- ចុះកិច្ចព្រមព្រៀងនានាដែលចាំបាច់ក្នុងការបំពេញមុខងាររបស់ខ្លួន
- បំពេញភារកិច្ចផ្សេងៗទៀតតាមការកំណត់របស់មហាសន្និបាត **ម.ជ.ម.** ។

## ជំពូកទី៣

## រចនាសម្ព័ន្ធ

## ផ្នែកទី១

## មហាសន្និបាត

**មាត្រា៣.–**

សិទ្ធិអំណាចកំពូលរបស់ **ម.ជ.ម.** គឺមហាសន្និបាត។

មហាសន្និបាតប្រចាំឆ្នាំត្រូវធ្វើឡើងតាមកាលបរិច្ឆេទ ដែលកំណត់ដោយក្រុមប្រឹក្សាប្រតិបត្តិ។ ក្នុងករណីចាំបាច់ ប្រធានក្រុមប្រឹក្សាប្រតិបត្តិ ឬសមាជិកភាគច្រើននៃក្រុមប្រឹក្សាប្រតិបត្តិ អាចស្នើសុំបើកមហាសន្និបាតវិសាមញ្ញបានដោយមានភ្ជាប់មកជាមួយ នូវរបៀបវារៈក្នុងរយៈពេលយ៉ាងតិច១៥ (ដប់ប្រាំ)ថ្ងៃ មុនថ្ងៃប្រជុំ។ មហាសន្និបាតវិសាមញ្ញនេះត្រូវពិចារណាតែបញ្ហាណាដែលមិនបានលើកឡើង ឬដោះស្រាយនៅក្នុងមហាសន្និបាតប្រចាំឆ្នាំ ដែលបានធ្វើឡើងរួចហើយតែប៉ុណ្ណោះ។

**មាត្រា៤.–**

មហាសន្និបាតប្រចាំឆ្នាំពិនិត្យនិងអនុម័តលើបញ្ហាជាអាទិ៍÷

- របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនិងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាប្រតិបត្តិ
- គម្រោងថវិកាប្រចាំឆ្នាំរបស់ **ម.ជ.ម.**
- ការបោះឆ្នោតជ្រើសតាំងនិងដកហូតសមាជិកក្រុមប្រឹក្សាប្រតិបត្តិ
- បទបញ្ជាផ្ទៃក្នុងនិងវិធាន ដែលទាក់ទងនឹងការដោះស្រាយវិវាទផ្នែកពាណិជ្ជកម្ម
- ការកែប្រែនូវបទប្បញ្ញត្តិនានា ដែលទាក់ទងដល់ដំណើរការរបស់ **ម.ជ.ម.**
- បែបបទហិរញ្ញវត្ថុនិងរដ្ឋបាល សម្រាប់ការគ្រប់គ្រងដំណើរការរបស់ **ម.ជ.ម.**
- នីតិវិធីសម្រាប់ការចុះបញ្ជីមជ្ឈត្តករ
- លក្ខណសម្បត្តិបន្ថែមសម្រាប់ឱ្យធ្វើជាមជ្ឈត្តករនៅ **ម.ជ.ម.**
- ក្រមសីលធម៌សម្រាប់មជ្ឈត្តករ។

**មាត្រា៥.–**

ការជូនដំណឹងពីមហាសន្និបាតប្រចាំឆ្នាំ ត្រូវធ្វើឡើងយ៉ាងតិច ៣០ (សាមសិប)ថ្ងៃ មុនថ្ងៃប្រជុំ។ លិខិតជូនដំណឹងនេះត្រូវបញ្ជាក់ពីកាលបរិច្ឆេទ ទីកន្លែងប្រជុំ និងរបៀបវារៈ។

**មាត្រា៦._**

មហាសន្និបាតអាចប្រព្រឹត្តទៅបានលុះត្រាតែមានវត្តមាន២/៣ (ពីរភាគបី) នៃសមាជិកទាំងអស់គិតទាំងសមាជិកផ្ទេរសិទ្ធិ ហើយបញ្ហានានាដែលលើកមកពិភាក្សា ត្រូវសម្រេចដោយសំឡេងភាគច្រើនដាច់ខាត។

ក្នុងករណីមិនមានកូរ៉ុមដើម្បីដំណើរការមហាសន្និបាត កិច្ចប្រជុំនេះត្រូវពន្យាររយៈពេលចំនួន១៤ (ដប់បួន) ថ្ងៃ ហើយកូរ៉ុមសម្រាប់កិច្ចប្រជុំលើកទីពីរនេះគឺ ១/២ (មួយភាគពីរ) នៃសមាជិកទាំងអស់ គិតទាំងសមាជិកផ្ទេរសិទ្ធិ។

ក្នុងករណីដែលកិច្ចប្រជុំលើកទីពីរពុំមានកូរ៉ុម មហាសន្និបាតនេះត្រូវពន្យាររយៈពេលចំនួន១៤ (ដប់បួន) ថ្ងៃទៀត ហើយប្រសិនបើនៅតែគ្មានកូរ៉ុមនៅក្នុងកិច្ចប្រជុំនេះទៀត ចំនួនអ្នកចូលរួមក្នុងកិច្ចប្រជុំដែលត្រូវពន្យាពេលជាលើកទីពីរ នោះត្រូវចាត់ទុកថាជាកូរ៉ុមដើម្បីចាប់ផ្តើមមហាសន្និបាត។

ការបោះឆ្នោតតាមរយៈសិទ្ធិប្រទានត្រូវបានអនុញ្ញាតប៉ុន្តែសមាជិកម្នាក់អាចទទួលបានសិទ្ធិប្រទានតែមួយប៉ុណ្ណោះ។ សិទ្ធិប្រទានត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយត្រូវចុះក្នុងកំណត់ហេតុប្រជុំ។

**មាត្រា៧._**

មហាសន្និបាតវិសាមញ្ញ ត្រូវបានកោះប្រជុំដោយប្រធានក្រុមប្រឹក្សាប្រតិបត្តិ និងតាមពេលកំណត់ដោយក្រុមប្រឹក្សាប្រតិបត្តិ។

ប្រសិនបើប្រធានក្រុមប្រឹក្សាប្រតិបត្តិ មិនបានកោះប្រជុំមហាសន្និបាតវិសាមញ្ញ ក្នុងរយៈពេល៣ (បី) ខែ បន្ទាប់ពីបានទទួលសំណើជាលាយលក្ខណ៍អក្សរទេនោះ សមាជិកដែលស្នើសុំឱ្យមានមហាសន្និបាតវិសាមញ្ញ អាចបើកមហាសន្និបាតវិសាមញ្ញតាមរយៈការជូនដំណឹងទៅសមាជិកទាំងអស់ ក្នុងរយៈពេល៣០ (សាមសិប) ថ្ងៃជាមុន ដោយរៀបរាប់អំពីបញ្ហាដែលត្រូវពិភាក្សា ហើយត្រូវបិទផ្សាយរបៀបវារៈរបស់ខ្លួន នៅលើក្តារព័ត៌មានក្នុងបរិវេណ **ម.ជ.ម.**។

## ផ្នែកទី២
## ក្រុមប្រឹក្សាប្រតិបត្តិ

**មាត្រា៨._**

**ម.ជ.ម.** គ្រប់គ្រងដោយក្រុមប្រឹក្សាប្រតិបត្តិ ដែលត្រូវជួបប្រជុំរៀងរាល់ខែ។ ក្រុមប្រឹក្សាប្រតិបត្តិត្រូវមានសមាជិកមិនលើសពី ៧ (ប្រាំពីរ) រូបឡើយ។

សមាសភាពក្រុមប្រឹក្សាប្រតិបត្តិរួមមាន ÷

- ប្រធានមួយរូប
- អនុប្រធានមួយរូប

- ហេរញ្ញិកមួយរូប
- សមាជិកមួយចំនួន។

**មាត្រា៩.-**

ក្រុមប្រឹក្សាប្រតិបត្តិគ្រប់គ្រងនិងសម្រេចការងារប្រចាំថ្ងៃ។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាប្រតិបត្តិមានអានុភាពអនុវត្ត លើកលែងតែសេចក្តីសម្រេចនោះ ត្រូវបានបដិសេធដោយមហាសន្និបាត។

**មាត្រា១០.-**

ក្រុមប្រឹក្សាប្រតិបត្តិបំពេញតួនាទីផ្សេងៗទៀតមានជាអាទិ៍ ÷

- ជ្រើសរើសបុគ្គលិកឱ្យបម្រើការងារជាអគ្គលេខាធិការរបស់ **ម.ជ.ម.**
- កំណត់ចំនួនបុគ្គលិក និយោជិត លក្ខខណ្ឌការងារ ប្រាក់បៀវត្ស កម្រៃសេវា ឬលក្ខខណ្ឌដទៃទៀត
- បញ្ឈប់ការងារនិងដាក់វិន័យលើបុគ្គលិក ដោយផ្អែកតាមកិច្ចសន្យាការងារ។

**មាត្រា១១.-**

ក្រុមប្រឹក្សាប្រតិបត្តិត្រូវធ្វើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ គម្រោងថវិកាប្រចាំឆ្នាំ និងរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ **ម.ជ.ម.** ជូនមហាសន្និបាតប្រចាំឆ្នាំ។

**មាត្រា១២.-**

សមាជិករបស់ក្រុមប្រឹក្សាប្រតិបត្តិ ត្រូវបានបោះឆ្នោតជ្រើសតាំងនៅក្នុងមហាសន្និបាតនៃ **ម.ជ.ម.**។

សមាជិកក្រុមប្រឹក្សាប្រតិបត្តិមានអាណត្តិ ៣ (បី)ឆ្នាំ ហើយសមាជិកទាំងអស់អាចធ្វើជាសមាជិកនៃក្រុមប្រឹក្សាប្រតិបត្តិមិនលើសពី ២(ពីរ) អាណត្តិឡើយ។ សមាជិកក្រុមប្រឹក្សាប្រតិបត្តិទាំងអស់អាចត្រូវបានបោះឆ្នោតសម្រាប់ ២ (ពីរ) អាណត្តិជាប់គ្នា លើកលែងតែមុខតំណែងជាហេរញ្ញិកដែលមិនអាចត្រូវបានជ្រើសរើស ២(ពីរ) អាណត្តិជាប់គ្នា។

**មាត្រា១៣.-**

ប្រធាន អនុប្រធាន និងហេរញ្ញិក ត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោតដោយឡែកពីគ្នាក្នុងចំណោមសមាជិកក្រុមប្រឹក្សាប្រតិបត្តិដោយក្រុមប្រឹក្សាប្រតិបត្តិ។

**មាត្រា១៤.-**

ប្រធានក្រុមប្រឹក្សាប្រតិបត្តិត្រូវបានបោះឆ្នោតជ្រើសរើសនៅក្នុងកិច្ចប្រជុំលើកដំបូងរបស់ខ្លួន។ ការបោះឆ្នោតជ្រើសរើសប្រធានត្រូវធ្វើជា ២ (ពីរ)ជុំ ប្រសិនបើជុំទី១ គ្មានបេក្ខជនណាទទួលសំឡេងគាំទ្រភាគច្រើនដាច់ខាតទេ។ ការបោះឆ្នោតនៃជុំទីពីរ គឺយកតែបេក្ខជនពីររូបដែលមានសំឡេងឆ្នោតច្រើនជាងគេ នៃជុំទីមួយប្រជែងឈ្មោះមកឱ្យឈរឈ្មោះ។

ដោយឡែកអនុប្រធាននិងហេរញ្ញិក ត្រូវបោះឆ្នោតជ្រើសរើសដោយយកតាមសំឡេងភាគច្រើនធម្មតា ក្នុងករណីមានសំឡេងស្មើគ្នា ត្រូវយកអ្នកមានអាយុច្រើនជាងគេ។

សមាជិកភាគច្រើននៃក្រុមប្រឹក្សាប្រតិបត្តិ ត្រូវមានសញ្ជាតិខ្មែរ។ ដោយឡែក ប្រធាន និង ហេរញ្ញិក ត្រូវមានសញ្ជាតិខ្មែរ។

ប្រធានរបស់ក្រុមប្រឹក្សាប្រតិបត្តិ គឺជាប្រធានរបស់ **ម.ជ.ម.**។

អនុប្រធាន ត្រូវជួយការងាររបស់ប្រធាន ហើយជំនួសប្រធាននៅពេលដែលប្រធានអវត្តមាន។

ហេរញ្ញិក ត្រូវគ្រប់គ្រងមូលនិធិ ប្រមូលចំណូលនិងចាត់ចែងចំណាយក្នុងនាម **ម.ជ.ម.** ហើយត្រូវមានគណនីចរន្ត និងត្រូវទទួលខុសត្រូវពីភាពត្រឹមត្រូវនៃគណនីទាំងនោះ។

សមាជិករបស់ក្រុមប្រឹក្សាប្រតិបត្តិ ត្រូវជួយការងារ **ម.ជ.ម.**និងបំពេញភារកិច្ច ដែលក្រុមប្រឹក្សាប្រតិបត្តិប្រគល់ជូន។

**មាត្រា១៥.-**

ក្នុងករណីតំណែងប្រធាន អនុប្រធាន ឬហេរញ្ញិក របស់ក្រុមប្រឹក្សាប្រតិបត្តិនៃ **ម.ជ.ម.** នៅទំនេរដោយសារការលាលែងពីមុខតំណែង ក្រុមប្រឹក្សាប្រតិបត្តិត្រូវបោះឆ្នោតជ្រើសរើសសមាជិករបស់ខ្លួនម្នាក់ទៀតឱ្យចូលកាន់មុខតំណែងដែលនៅទំនេរនោះនៅក្នុងកិច្ចប្រជុំបន្ទាប់ ឬនៅឯកិច្ចប្រជុំណាមួយដ៏ខ្លី បន្ទាប់ពីការលាលែងនោះ។

**មាត្រា១៦.-**

សមាជិកគ្រប់រូបរបស់ **ម.ជ.ម.** ទោះរូបវន្តបុគ្គលក្តី អ្នកតំណាងផ្ទេរសិទ្ធិដែលទទួលបានការចាត់តាំងពីសភាពាណិជ្ជកម្មរាជធានី ខេត្តនៃព្រះរាជាណាចក្រកម្ពុជា សភាមុខរបរនិងមីក្រូសហគ្រាស គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងសមាគមដែលប្រមូលផ្តុំពាណិជ្ជករ ឧស្សាហករ អាជីវករ និងសេវាករក្តី មានសិទ្ធិឈរឈ្មោះឱ្យមហាសន្និបាតបោះឆ្នោតជាសមាជិកក្រុមប្រឹក្សាប្រតិបត្តិ លុះត្រាតែបានចុះឈ្មោះ ជាមជ្ឈត្តករក្នុងបញ្ជីនៃ **ម.ជ.ម.**។

**មាត្រា១៧.-**

ក្នុងរយៈពេល៦០ (ហុកសិប) ថ្ងៃ មុនកាលបរិច្ឆេទដែលត្រូវបានកំណត់ សម្រាប់មហាសន្និបាតប្រចាំឆ្នាំ ក្រុមប្រឹក្សាប្រតិបត្តិត្រូវធ្វើការកំណត់ និងផ្សព្វផ្សាយនូវ÷

- កាលបរិច្ឆេទនៃការជ្រើសរើសបេក្ខជន
- កាលបរិច្ឆេទបោះឆ្នោត ដែលមិនត្រូវតិចជាង៣ (បី) សប្តាហ៍ បន្ទាប់ពីកាលបរិច្ឆេទនៃការជ្រើសរើសបេក្ខជន
- ទីកន្លែងដែលមានភាពងាយស្រួលក្នុងបរិវេណ **ម.ជ.ម.** ឬកន្លែងផ្សេងទៀតសម្រាប់រៀបចំការបោះឆ្នោតជាសម្ងាត់។

**មាត្រា១៨.-**

ការបោះឆ្នោតជ្រើសរើសសមាជិកទាំងអស់ ឬសមាជិកណាម្នាក់របស់ក្រុមប្រឹក្សាប្រតិបត្តិ ត្រូវធ្វើឡើងតាមរយៈការបោះឆ្នោតជាសម្ងាត់ ដោយសមាជិកមួយរូបមានសំឡេងឆ្នោតមួយសំឡេង ក្នុងមហាសន្និបាតប្រចាំឆ្នាំ ឬមហាសន្និបាតវិសាមញ្ញ ដោយអនុលោមតាមវិធានកំណត់ដោយមហាសន្និបាត។

ក្រុមប្រឹក្សាប្រតិបត្តិថ្មីដែលទើបកើតឡើងក្រោយពីមានការបោះឆ្នោតត្រូវចូលកាន់មុខតំណែងនៅក្រោយពេលមហាសន្និបាតប្រចាំឆ្នាំ។

**មាត្រា១៩.-**

មជ្ឈត្តករដែលឈរឈ្មោះបោះឆ្នោត ជាសមាជិកក្រុមប្រឹក្សាប្រតិបត្តិ ត្រូវមានលក្ខខណ្ឌដូចខាងក្រោម ÷

- សមាជិក **ម.ជ.ម.** ពីររូបអាចស្នើតែងតាំងសមាជិក **ម.ជ.ម.** បានតែម្នាក់ប៉ុណ្ណោះធ្វើជាបេក្ខជន
- សំណើតែងតាំងបេក្ខជនត្រូវមានការយល់ព្រមពីសាមីខ្លួនផ្ទាល់
- សំណើតែងតាំងត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងមានចុះហត្ថលេខា។

**មាត្រា២០.-**

បើសិនបេក្ខជនឈរឈ្មោះមានចំនួនតិចជាង ឬស្មើនឹងតំណែងដែលត្រូវបោះឆ្នោតរើស សម្រាប់ធ្វើជាសមាជិកក្រុមប្រឹក្សាប្រតិបត្តិ ការជ្រើសរើសត្រូវពន្យាររយៈពេល១៥(ដប់ប្រាំ)ថ្ងៃទៀត។ ក្រោយរយៈពេលពន្យារ ១៥ (ដប់ប្រាំ) ថ្ងៃ ប្រសិនបើបេក្ខជននៅតែមានចំនួនតិចជាង ឬស្មើនឹងតំណែងដែលត្រូវបោះឆ្នោតជ្រើសរើស បេក្ខជនទាំងនោះត្រូវចាត់ទុកថាជាប់ឆ្នោតដោយស្វ័យប្រវត្តិ។ ក្នុងករណីដែលបេក្ខជនឈរឈ្មោះមិនគ្រប់ចំនួន មហាសន្និបាតអាចតែងតាំងបេក្ខជនបន្ថែមតាមនីតិវិធីដដែល។ ក្នុងករណីដែលបេក្ខជនមានចំនួនលើសពីចំនួនតំណែង ដែលត្រូវជ្រើសរើស មហាសន្និបាតត្រូវធ្វើការបោះឆ្នោត។

**មាត្រា២១.-**

សមាជិកក្រុមប្រឹក្សាប្រតិបត្តិត្រូវបាត់បង់មុខតំណែងក្នុងករណីដូចខាងក្រោម ÷

- ក្លាយជាអសមត្ថជនផ្នែករូបរាងកាយ និងសតិស្មារតី មិនអាចបំពេញមុខងាររបស់ខ្លួនបាន
- ត្រូវបានផ្តន្ទាទោសពីបទល្មើសមជ្ឈិម ឬឧក្រិដ្ឋណាមួយ
- អវត្តមានពីកិច្ចប្រជុំ ៣ (បី)ដង ជាប់ៗគ្នាដោយគ្មានមូលហេតុ
- ត្រូវបានវិនិច្ឆ័យថា ក្ស័យធនដោយតុលាការ
- សុំលាលែងជាលាយលក្ខណ៍អក្សរពីក្រុមប្រឹក្សាប្រតិបត្តិ
- លែងជាសមាជិករបស់ **ម.ជ.ម.**
- លែងជាតំណាងចាត់តាំងរបស់អង្គការសមាជិក

- ទទួលមរណភាព។

**មាត្រា២២.-**

ក្រៅពីការប្រជុំប្រចាំខែ ប្រធានក្រុមប្រឹក្សាប្រតិបត្តិ អាចកោះប្រជុំក្រុមប្រឹក្សាប្រតិបត្តិពេលណាក៏បាន ដោយជូនដំណឹងទៅកាន់សមាជិកក្រុមប្រឹក្សាប្រតិបត្តិ រយៈពេល ៧ (ប្រាំពីរ) ថ្ងៃជាមុន។ យ៉ាងហោចណាស់ត្រូវមានសមាជិក ២/៣ (ពីរភាគបី) វត្តមាន ដើម្បីឱ្យដំណើរការប្រជុំមានសុពលភាព។

បញ្ហានានាដែលត្រូវបានលើកឡើងមកពិភាក្សា នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាប្រតិបត្តិ ត្រូវសម្រេចដោយសំឡេងភាគច្រើន ហើយក្នុងករណីមានសំឡេងស្មើគ្នា សំឡេងប្រធានមានឧត្តមានុភាព។

**មាត្រា២៣.-**

ក្នុងករណីមានសមាជិកក្រុមប្រឹក្សាប្រតិបត្តិបាត់បង់សមាជិកភាពរបស់ខ្លួន ប្រធាន **ម.ជ.ម.** ត្រូវកោះប្រជុំសន្និបាតវិសាមញ្ញ ដើម្បីធ្វើការជ្រើសរើសសមាជិកបង្គ្រប់។ អាណត្តិរបស់សមាជិកជំនួសនេះជាអាណត្តិរបស់សមាជិក ដែលបានបាត់បង់សមាជិកភាព។

**មាត្រា២៤.-**

ក្រុមប្រឹក្សាប្រតិបត្តិ អាចបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការនានា ដែលមានសមាសភាពសមាជិកក្រុមប្រឹក្សាប្រតិបត្តិមួយរូប ឬច្រើនរូបដឹកនាំការងារ។ ការរៀបចំគណៈកម្មាធិការ ឬអនុគណៈកម្មាធិការនានាត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់ **ម.ជ.ម.**។

## ផ្នែកទី៣

## អគ្គលេខាធិការដ្ឋាន

**មាត្រា២៥.-**

អគ្គលេខាធិការដ្ឋាននៃ **ម.ជ.ម.** ត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូប អមដោយអគ្គលេខាធិការរងមួយចំនួនជាជំនួយការ ដែលត្រូវជ្រើសរើសដោយក្រុមប្រឹក្សាប្រតិបត្តិ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃ **ម.ជ.ម.** ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុង។

**មាត្រា២៦.-**

អគ្គលេខាធិការដ្ឋាននៃ **ម.ជ.ម.** មានតួនាទីជាសេនាធិការឱ្យក្រុមប្រឹក្សាប្រតិបត្តិ និងមានភារកិច្ចដូចខាងក្រោម ÷

- គ្រប់គ្រងលើការងារនិងសកម្មភាពប្រចាំថ្ងៃរបស់ **ម.ជ.ម.**
- អនុវត្តគោលនយោបាយដែលក្រុមប្រឹក្សាប្រតិបត្តិដាក់ចេញ
- រៀបចំកិច្ចប្រជុំរបស់ក្រុមប្រឹក្សាប្រតិបត្តិ មហាសន្និបាត និងកិច្ចប្រជុំផ្សេងទៀត

- រក្សាឯកសារ
- ប្រមូលព័ត៌មានដែលពាក់ព័ន្ធនិងសកម្មភាពមជ្ឈត្តការផ្នែកពាណិជ្ជកម្មដែលអាចមានប្រយោជន៍ដល់សមាជិករបស់ **ម.ជ.ម.**
- ផ្តួចផ្តើមគំនិតលើកិច្ចការថ្មីៗ និងរៀបចំសកម្មភាព និងគម្រោងនានាដែលជួយទ្រទ្រង់តួនាទីរបស់ **ម.ជ.ម.**
- ផ្តល់សេវាផ្នែកលេខាធិការដល់សមាជិក ដោយយកកម្រៃសេវាស្របតាមលក្ខខណ្ឌ ដែលអនុម័តដោយក្រុមប្រឹក្សាប្រតិបត្តិ
- ទ្រទ្រង់ផ្នែកបោះពុម្ពនានារបស់ **ម.ជ.ម.** រួមទាំងកាន់កាប់គេហទំព័ររបស់ **ម.ជ.ម.**
- រៀបចំការបណ្តុះបណ្តាល
- បំពេញភារកិច្ចផ្សេងៗដែលក្រុមប្រឹក្សាប្រតិបត្តិប្រគល់ជូន។

**មាត្រា២៧.-**

**ម.ជ.ម.** មានសិទ្ធិប្រើត្រាដោយឡែករបស់ខ្លួន។

## ផ្នែកទី៤

## សមាជិកនៃ ម.ជ.ម.

**មាត្រា២៨.-**

បុគ្គលទាំងឡាយដែលចង់ក្លាយជាសមាជិកនៃ **ម.ជ.ម.** ត្រូវចុះបញ្ជីជាមជ្ឈត្តករនៅ **ម.ជ.ម.**។

រាល់ពាក្យសុំចុះឈ្មោះទាំងអស់ ត្រូវដាក់ជូនទៅក្រុមប្រឹក្សាប្រតិបត្តិរបស់ **ម.ជ.ម.** ព្រមទាំងភ្ជាប់មកជាមួយនូវឯកសារផ្សេងៗ តាមការតម្រូវរបស់ក្រុមប្រឹក្សាប្រតិបត្តិ និងបង់ភាគទានតាមការកំណត់របស់ **ម.ជ.ម.**។

**មាត្រា២៩.-**

រូបវន្តបុគ្គលដែលមានសញ្ជាតិខ្មែរ ឬបរទេស អាចដាក់ពាក្យសុំធ្វើជាមជ្ឈត្តករជាមួយ **ម.ជ.ម.** បាន បើសិនជារូបវន្តបុគ្គលនោះ មានលក្ខណសម្បត្តិដូចខាងក្រោម ÷

- មានអាយុចាប់ពី ៣០ ( សាមសិប ) ឆ្នាំឡើង
- មានសញ្ញាបត្របរិញ្ញាបត្រជំនាញណាមួយ ក្រោយពីបានបញ្ចប់ការសិក្សានៅតាមសកលវិទ្យាល័យក្នុងព្រះរាជាណាចក្រកម្ពុជា ឬនៅបរទេស និង
- បានឆ្លងកាត់វគ្គបណ្តុះបណ្តាលផ្នែកមជ្ឈត្តការផ្នែកពាណិជ្ជកម្មជាមួយ **ម.ជ.ម.** ឬវគ្គបណ្តុះបណ្តាលជាមួយ...

- មជ្ឈមណ្ឌលនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មអន្តរជាតិនានា ដែលទទួលស្គាល់ដោយ **ម.ជ.ម.** ។

ប្រសិនបើពុំមានលក្ខណសម្បត្តិដូចខាងលើទេ រូបវន្តបុគ្គលដែលមានសញ្ជាតិខ្មែរ ឬបរទេសនោះត្រូវជាបុគ្គលដែលធ្លាប់ធ្វើជា÷

- សមាជិកនៃស្ថាប័នវិជ្ជាជីវៈផ្នែកមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលទទួលស្គាល់ដោយ **ម.ជ.ម.** ឬ
- មជ្ឈត្តករ ឬអ្នកតំណាងក្នុងដំណើរការមជ្ឈត្តការផ្នែកពាណិជ្ជកម្មចាប់ពី៣ (បី) ដង ឡើងទៅ ឬបានសរសេរសេចក្តីបង្គាប់មជ្ឈត្តការផ្នែកពាណិជ្ជកម្ម ចំនួនយ៉ាងតិច៣ (បី) ក្នុងពេលដែលបុគ្គលនោះធ្វើជាមជ្ឈត្តករ ។

ទោះបីដូចមានចែងខាងលើក៏ដោយ និងក្រោយពីមានការយល់ព្រមពីមហាសន្និបាត ក្រុមប្រឹក្សាប្រតិបត្តិអាចកំណត់នូវលក្ខណវិនិច្ឆ័យបន្ថែមផ្សេងទៀត ដែលខ្លួនគិតថា សមស្រប និងមានប្រយោជន៍ដល់ **ម.ជ.ម.** ។

**មាត្រា៣០.–**

មជ្ឈត្តករ÷

- មិនត្រូវស្ថិតនៅក្នុងឋានានុក្រមជាមន្ត្រីនៃស្ថាប័ននីតិប្រតិបត្តិ ស្ថាប័ននីតិប្បញ្ញត្តិ និងតុលាការ
- មិនធ្លាប់ត្រូវបានផ្តន្ទាទោសពីបទមជ្ឈិម ឬឧក្រិដ្ឋណាមួយ ។

**មាត្រា៣១.–**

**ម.ជ.ម.** ត្រូវរៀបចំបញ្ជីឈ្មោះសមាជិករបស់ខ្លួន ដែលមានចុះព័ត៌មានដូចខាងក្រោម÷

- ឈ្មោះនិងអាសយដ្ឋាន
- កាលបរិច្ឆេទនៃការចុះបញ្ជី
- លក្ខណសម្បត្តិនិង
- ព័ត៌មានចាំបាច់ដទៃទៀត ដែលកំណត់ដោយក្រុមប្រឹក្សាប្រតិបត្តិ ។

**មាត្រា៣២.–**

ក្រុមប្រឹក្សាប្រតិបត្តិត្រូវបដិសេធការចុះបញ្ជីឱ្យបេក្ខជនណាមួយ ដែលពុំមានលក្ខណសម្បត្តិគ្រប់គ្រាន់ តាមមាត្រា២៩ និង៣០ នៃអនុក្រឹត្យនេះ ។

**មាត្រា៣៣.–**

វិញ្ញាបនបត្រចុះបញ្ជី ត្រូវសុំបន្តជារៀងរាល់ឆ្នាំតាមរយៈការបង់ភាគទានប្រចាំឆ្នាំ ។

រៀងរាល់ឆ្នាំ **ម.ជ.ម.** ត្រូវប្រកាសជាសាធារណៈ នូវឈ្មោះរបស់មជ្ឈត្តករដែលបានចុះបញ្ជី ។

សមាជិក **ម.ជ.ម.** ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ នូវរាល់ការផ្លាស់ប្តូរអាសយដ្ឋានវិជ្ជាជីវៈ ឬ អាសយដ្ឋានផ្ទាល់ខ្លួន ក្នុងរយៈពេល ១ (មួយ) ខែ គិតចាប់ពីថ្ងៃផ្លាស់ប្តូរនោះ។

**មាត្រា៣៤.-**

សភាពាណិជ្ជកម្មរាជធានី ខេត្ត នៃព្រះរាជាណាចក្រកម្ពុជា សភាមុខរបរនិងមីក្រូសហគ្រាស គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា និងសមាគមដែលប្រមូលផ្តុំពាណិជ្ជករ ឧស្សាហករ អាជីវករ និងសេវាករ អាចតែងតាំងបុគ្គលមួយរូបធ្វើជាតំណាង និងបោះឆ្នោតក្នុងមហាសន្និបាតនានារបស់ **ម.ជ.ម.**។ ក្នុងករណីលាលែង ឬឈប់ធ្វើការជាមួយអង្គការដែលខ្លួនជាតំណាង បុគ្គលរូបនោះលែងមានសិទ្ធិជាអ្នកតំណាងរបស់អង្គការសមាជិកនោះដោយស្វ័យប្រវត្តិ។ ក្រុមប្រឹក្សាប្រតិបត្តិមានសិទ្ធិបដិសេធអ្នកតំណាង ដែលតែងតាំងដោយអង្គការសមាជិកណាមួយ ប្រសិនបើពុំមានលក្ខណសម្បត្តិគ្រប់គ្រាន់។

**មាត្រា៣៥.-**

សមាជិក **ម.ជ.ម.** ត្រូវបាត់បង់សមាជិកភាពរបស់ខ្លួន ក្នុងករណីណាមួយដូចខាងក្រោមនេះ ÷

- មិនបានបន្តចុះបញ្ជីជាមជ្ឈត្តករជាមួយ **ម.ជ.ម.** តាមការកំណត់
- ក្លាយជាអសមត្ថជនផ្នែករូបរាងកាយនិងសតិស្មារតី ដែលមិនអាចបំពេញមុខងាររបស់ខ្លួនបាន
- ត្រូវបានវិនិច្ឆ័យថា ក្ស័យធន ឬត្រូវដាក់ឱ្យជម្រះបញ្ជី
- សុំលាលែងជាលាយលក្ខណ៍អក្សរទៅកាន់ **ម.ជ.ម.**
- ត្រូវបានផ្តន្ទាទោសពីបទមជ្ឈិម ឬឧក្រិដ្ឋ
- បានរំលោភលើក្រមសីលធម៌របស់មជ្ឈត្តករនិងបទបញ្ជាផ្ទៃក្នុង
- ទទួលមរណភាព
- ខកខានមិនបានបង់ភាគទានតាមការកំណត់

ការបាត់បង់សមាជិកភាពនេះត្រូវសម្រេចដោយក្រុមប្រឹក្សាប្រតិបត្តិ។

**មាត្រា៣៦.-**

ការដកហូតសមាជិកភាពរបស់សមាជិកណាម្នាក់ អាចធ្វើទៅបាន លុះត្រាតែសមាជិកនោះ ត្រូវបានផ្តល់ឱកាសដើម្បីធ្វើការដោះសារជាលាយលក្ខណ៍អក្សរតែមិនបានដោះសារតាមពេលវេលាកំណត់។ ក្នុងករណីដែលក្រុមប្រឹក្សាប្រតិបត្តិសម្រេចដកហូតសមាជិកភាពពី **ម.ជ.ម.** ក្រុមប្រឹក្សាត្រូវផ្តល់ហេតុផលជាលាយលក្ខណ៍អក្សរ។ ក្នុងករណីដែលសាមីខ្លួនមិនសុខចិត្តនឹងសេចក្តីសម្រេចនេះ សមាជិកនោះមានសិទ្ធិប្តឹងទៅសាលាឧទ្ធរណ៍

**មាត្រា៣៧._**

សមាជិក **ម.ជ.ម.** ត្រូវទទួលក្នុងរយៈពេល ២ (ពីរ) ឆ្នាំម្តងយ៉ាងតិចនូវការបណ្តុះបណ្តាលបន្ត ដែលរៀបចំដោយ **ម.ជ.ម.** ឬរៀបចំដោយស្ថាប័នជាតិ និងអន្តរជាតិដែលទទួលស្គាល់ដោយ **ម.ជ.ម.** ។

នៅក្នុងការចុះបញ្ជីបន្តជាមជ្ឈត្តករនៅ **ម.ជ.ម.** ក្រុមប្រឹក្សាប្រតិបត្តិអាចបដិសេធការចុះបញ្ជីរបស់សមាជិកណាម្នាក់បាន ក្នុងករណីដែលសមាជិកនោះខកខានមិនបានធ្វើការបណ្តុះបណ្តាលវិជ្ជាជីវៈបន្ត។

**មាត្រា៣៨._**

នៅក្នុងកាលៈទេសៈពិសេសដែលកំណត់ដោយក្រុមប្រឹក្សាប្រតិបត្តិ ក្រុមប្រឹក្សាប្រតិបត្តិ អាចចុះបញ្ជីបន្តសម្រាប់មជ្ឈត្តករណាម្នាក់បាន ទោះបីមជ្ឈត្តករនោះខកខានមិនបានបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងមាត្រា ៣៧ ខាងលើ។

## ផ្នែកទី៥

## សវនកម្ម

**មាត្រា៣៩._**

ក្រុមហ៊ុនសវនកម្មដែលទទួលបានការអនុម័តយល់ព្រមពីមហាសន្និបាត ត្រូវបានជ្រើសតាំងជាសវនកររបស់ **ម.ជ.ម.** សម្រាប់រយៈពេល ១ (មួយ) ឆ្នាំ ហើយអាចត្រូវបានជ្រើសតាំងសារជាថ្មីទៀតបាន។

**មាត្រា៤០._**

សវនករមានតួនាទីនិងភារកិច្ច ដូចខាងក្រោម ÷

- ធ្វើសវនកម្មប្រចាំឆ្នាំ និងបង្ហាញរបាយការណ៍សវនកម្មរបស់ខ្លួន ក្នុងមហាសន្និបាតប្រចាំឆ្នាំ
- ធ្វើសវនកម្មតាមការស្នើសុំរបស់ប្រធាន **ម.ជ.ម.** សម្រាប់រយៈពេលណាមួយក៏បាន និងនៅគ្រប់ពេលវេលានៅក្នុងអំឡុងពេលនៃកិច្ចសន្យា ហើយត្រូវធ្វើរបាយការណ៍ជូនក្រុមប្រឹក្សាប្រតិបត្តិ។

សមាជិកនិងបុគ្គលិកគ្រប់រូបរបស់ **ម.ជ.ម.** មានកាតព្វកិច្ចផ្តល់ព័ត៌មាន និងសេចក្តីពន្យល់នានាដែលតម្រូវដោយសវនករ។

## ផ្នែកទី៦

## សាខារបស់ម.ជ.ម.

**មាត្រា៤១._**

**ម.ជ.ម.** អាចបង្កើតសាខារបស់ខ្លួនបាននៅតាមខេត្តនានា នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ [illegible]រៀបចំ និងការប្រព្រឹត្តទៅរបស់សាខានីមួយៗត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ **ម.ជ.ម.** ។

## ជំពូកទី៤

## ប្រភពធនធាន

**មាត្រា៤២.-**

ប្រភពធនធានរបស់ **ម.ជ.ម.** បានមកពី ÷

- ភាគទានរបស់សមាជិក
- អំណោយនិងវិភាគទានពីប្រភពផ្សេងៗ
- កម្រៃសេវាផ្នែករដ្ឋបាលរបស់ **ម.ជ.ម.** ។

**មាត្រា៤៣.-**

សមាជិកត្រូវបង់ភាគទានប្រចាំឆ្នាំ តាមការកំណត់របស់មហាសន្និបាតដែលស្នើដោយក្រុមប្រឹក្សាប្រតិបត្តិ ។

ភាគទានប្រចាំឆ្នាំត្រូវបង់ជាមុន ក្នុងអំលុងខែទីមួយរៀងរាល់ឆ្នាំ។ ប្រសិនបើសមាជិកណាម្នាក់ មានភាពយឺតយ៉ាវក្នុងការបង់ភាគទានប្រចាំឆ្នាំ ឬវិភាគទានដទៃទៀត ហើយហេរញ្ញិកត្រូវក្រើនរំលឹកជាបន្ទាន់ដល់សមាជិកនោះ ។

ប្រសិនបើសមាជិកណាម្នាក់ មានការយឺតយ៉ាវក្នុងការបង់ភាគទានប្រចាំឆ្នាំ លើសពី ៣ (បី)ខែ ចាប់ពីខែទីពីរ សមាជិកនោះត្រូវបាត់បង់សមាជិកភាពរបស់ខ្លួន ដោយស្វ័យប្រវត្តិ ។

រាល់មូលនិធិបន្ថែមនានាដែលតម្រូវដោយ **ម.ជ.ម.** សម្រាប់គោលបំណងពិសេសណាមួយអាចប្រមូលពីបណ្តាសមាជិកបាន លុះត្រាតែមានសំឡេងយល់ព្រមពីមហាសន្និបាតរបស់សមាជិកលើសពី៥០ (ហាសិប) ភាគរយ នៃសមាជិកដែលមានវត្តមានក្នុងមហាសន្និបាត ។

**មាត្រា៤៤.-**

បុគ្គលិករបស់ **ម.ជ.ម.** និងសមាជិករបស់ក្រុមប្រឹក្សាប្រតិបត្តិ ទទួលបានការធានារ៉ាប់រងពី **ម.ជ.ម.** ចំពោះរាល់ការបង់ថ្លៃចំណាយ និងការខាតបង់នានាក្នុងការបំពេញដំត្រឹមត្រូវនូវភារកិច្ចរបស់ខ្លួន ។

## ជំពូកទី៥

## ការជ្រើសរើសមជ្ឈត្តករដំបូង

**មាត្រា៤៥.-**

ក្រសួងពាណិជ្ជកម្មត្រូវបង្កើតគណៈកម្មការរៀបចំ និងជ្រើសរើសមជ្ឈត្តករដំបូងមួយ ដែលមានសមាជិកមិនលើសពី ១២ (ដប់ពីរ)រូប ។

គណៈកម្មការនេះត្រូវដឹកនាំដោយតំណាងក្រសួងពាណិជ្ជកម្ម ដោយមានការចូលរួមពីតំណាងក្រសួង ស្ថាប័ន ដូចខាងក្រោម ÷

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងយុត្តិធម៌
- សហព័ន្ធនិយោជក
- សភាពាណិជ្ជកម្មកម្ពុជា
- គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- សភាពាណិជ្ជកម្មអន្តរជាតិនៃកម្ពុជា
- សមាគមរោងចក្រកាត់ដេរកម្ពុជា
- សភាមុខរបរនិងមីក្រូសហគ្រាស
- បុគ្គលដទៃទៀតដែលក្រសួងពាណិជ្ជកម្ម និងក្រសួងយុត្តិធម៌យល់ថា សមស្រប ។

**មាត្រា៤៦.-**

ក្រសួងពាណិជ្ជកម្មត្រូវចេញប្រកាសតែងតាំងសមាសភាពគណៈកម្មការរៀបចំនិងជ្រើសរើសមជ្ឈត្តករដំបូង ។ សមាជិកម្នាក់ៗត្រូវចូលរួមដោយផ្ទាល់ ក្នុងរាល់ការប្រជុំរបស់គណៈកម្មការតាមការអញ្ជើញរបស់ប្រធាន ។

**មាត្រា៤៧.-**

គណៈកម្មការរៀបចំ និងជ្រើសរើសនោះត្រូវរៀបចំធ្វើការជ្រើសរើសចេញពីពាក្យស្នើសុំរបស់បេក្ខជនដំបូង ដែលមានចំនួនមិនលើសពី ៦០ (ហុកសិប)រូប ដើម្បីឱ្យចុះឈ្មោះជាមជ្ឈត្តករដំបូងនៃ **ម.ជ.ម.** ។

**មាត្រា៤៨.-**

សេចក្តីជូនដំណឹងផ្សេងៗរបស់គណៈកម្មការត្រូវធ្វើឡើងតាមរយៈបណ្តាញសារព័ត៌មាន និងផ្ញើជូន អង្គការ ក្រសួង ស្ថាប័នទាំងអស់ និងបុគ្គលពាក់ពន្ធ័នានាដោយផ្ទាល់ ។

**មាត្រា៤៩.-**

អ្នកដាក់ពាក្យទាំងអស់ត្រូវផ្តល់ព័ត៌មានលម្អិតផ្ទាល់ខ្លួន និងព័ត៌មានអំពីលក្ខណសម្បត្តិរបស់ខ្លួនដូចបានកំណត់នៅក្នុងអនុក្រឹត្យនេះ និងតាមការកំណត់របស់គណៈកម្មការរៀបចំ និងជ្រើសរើសមជ្ឈត្តករដំបូង ។

គណៈកម្មការត្រូវធ្វើការប្រជុំតាមការចាំបាច់ ដើម្បីធ្វើការពិនិត្យលើពាក្យសុំ និងកំណត់ពីបេក្ខជន ដែលត្រូវជ្រើសរើសមិនតិចជាង ៥០ (ហាសិប)រូប ។

**មាត្រា៥០.-**

ការប្រជុំរបស់គណៈកម្មការអាចប្រព្រឹត្តទៅបាន លុះត្រាតែមានកូរ៉ុមលើសពី ៥០ (ហាសិប) ភាគរយ នៃចំនួនសមាជិក។ សេចក្តីសម្រេចរបស់គណៈកម្មការរៀបចំ និងជ្រើសរើសត្រូវធ្វើឡើងដោយសំឡេងភាគច្រើន នៃសមាជិកដែលមានវត្តមាន និងបោះឆ្នោតនៅក្នុងកិច្ចប្រជុំ។ ក្នុងករណីសំឡេងស្មើគ្នា សំឡេងខាងប្រធានមានឧត្តមានុភាព។

**មាត្រា៥១.-**

ឈ្មោះរបស់បុគ្គលដែលត្រូវបានជ្រើសរើសជាសមាជិកដំបូង ត្រូវបិទផ្សាយក្នុងរយៈពេល១៤ (ដប់បួន)ថ្ងៃ បន្ទាប់ពីថ្ងៃសម្រេចចុងក្រោយ ហើយបុគ្គលដែលជាប់ឈ្មោះទាំងនោះត្រូវឆ្លងកាត់វគ្គបណ្តុះបណ្តាលមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលរៀបចំដោយក្រសួងពាណិជ្ជកម្ម។

**មាត្រា៥២.-**

បុគ្គលដែលត្រូវបានជ្រើសរើសដំបូង មិនតិចជាង៥០ (ហាសិប) រូប ត្រូវដាក់ពាក្យសុំធ្វើជាមជ្ឈត្តករនៅ **ម.ជ.ម.** ក្រោយពីបានបញ្ចប់វគ្គបណ្តុះបណ្តាលមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។

**មាត្រា៥៣.-**

ក្រសួងពាណិជ្ជកម្មត្រូវទទួលខុសត្រូវ ក្នុងការរៀបចំបង្កើតការិយាល័យចុះបញ្ជីមជ្ឈត្តករជាលើកដំបូង និងត្រូវគ្រប់គ្រងការិយាល័យនេះរហូតដល់ពេលដែល **ម.ជ.ម.** ដំណើរការងារដំបូងរបស់ខ្លួន ហើយមានការបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សាប្រតិបត្តិ។

## ជំពូកទី៦

## អន្តរប្បញ្ញត្តិ

**មាត្រា៥៤.-**

ក្រោយពីសមាជិក **ម.ជ.ម.** ត្រូវបានជ្រើសរើសនិងក្រុមប្រឹក្សាប្រតិបត្តិ ត្រូវបានបោះឆ្នោតរួចមក ក្រសួងពាណិជ្ជកម្មត្រូវសហការជាមួយ **ម.ជ.ម.** ក្នុងការផ្ទេរបញ្ជីឈ្មោះមជ្ឈត្តករទៅឱ្យអ្នកកាន់បញ្ជីរបស់ **ម.ជ.ម.** រួមទាំងមូលនិធិ និងទ្រព្យនានា ដែលជាកម្មសិទ្ធិ ឬក្លាយជាកម្មសិទ្ធិរបស់ **ម.ជ.ម.**។

ភារកិច្ចគណៈកម្មការត្រូវបញ្ចប់ នៅពេលក្រុមប្រឹក្សាប្រតិបត្តិ **ម.ជ.ម.** ចូលកាន់ការងារ។

# ជំពូកទី៧

# អវសានប្បញ្ញត្តិ

**មាត្រា៥៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៥៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែសីហា ឆ្នាំ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ